# <u>មាតិកា</u>


១-ព្រឹត្តការណ៍ព័ត៌មានក្នុងប្រទេស ............................................ ២

២-ទំនាក់ទំនងកម្ពុជា  និងបណ្តាប្រទេសអាស៊ាន ................................ ២០

៣-កម្ពុជា  និងបណ្តាប្រទេសអឺរ៉ុប ............................................ ២៨

៤-ទំនាក់ទំនងកម្ពុជា  និងប្រទេសចិន ........................................ ៤៣

៥-ទំនាក់ទំនងកម្ពុជា  និងប្រទេសកូរ៉េ ....................................... ៤៨

៦-ទំនាក់ទំនងកម្ពុជា  និងប្រទេសជប៉ុន ...................................... ៥៦

៧-ទំនាក់ទំនងកម្ពុជា  និងសហរដ្ឋអាមេរិក ................................... ៦៦

៨-ទំនាក់ទំនងកម្ពុជា  និងប្រទេសអូស្ត្រាលី-ណូវែលហ្ស៊ីឡង់ ....................... ៧៧

៩-ទំនាក់ទំនងកម្ពុជា  និងបណ្តាប្រទេសផ្សេងៗ ................................ ៨១

១០-កម្ពុជា  និងអង្គការអន្តរជាតិ ........................................... ៨៥

# ១-ព្រឹត្តការណ៍ព័ត៌មានក្នុងប្រទេស

## ម៉ៃក្រូសូហ្វផ្តល់មូលនិធិដល់សាលាក្តីខ្មែរក្រហម

ខណៈពេលដែលទឹកប្រាក់សំរាប់ដំណើរការតុលាការខ្មែរក្រហមនៅខ្វះចំនួន៨លានដុល្លារទៀតនោះ ក្រុមហ៊ុនម៉ៃក្រូសូហ្វ（Microsoft ）បានសំរេចផ្តល់មូលនិធិរបស់ខ្លួនចំនួន១00.000ដុល្លារអាមេរិក ដើម្បីគាំទ្រដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម។

លោក ភីធ័រ ហ្វូស័រ មន្ត្រីទំនាក់ទំនងនៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា បាននិយាយប្រាប់ទីភ្នាក់ងារព័ត៌មានមួយថា ទឹកប្រាក់ទាំងអស់នេះត្រូវបានផ្តល់ដោយក្រុមហ៊ុនម៉ៃក្រូសូហ្វនៅក្នុងប្រទេសសាំងហ្គាពួរ។

ថវិកាសរុបសំរាប់ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះមានចំនួនសរុប ៥៦ លានដុល្លារ ប៉ុន្តែវានៅខ្វះប្រហែល ៨ លានដុល្លារសំរាប់បង្គ្រប់ភាគច្រើនគឺខាងរាជរដ្ឋាភិបាលកម្ពុជា។

*កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី១៥ ខែមករា ឆ្នាំ២00៧ ។*

## វិស័យទេសចរណ៍ផ្តល់ចំណូលជាង១000លានដុល្លារនៅក្នុងឆ្នាំ២00៦

យោងតាមសេចក្តីរាយការណ៍របស់ក្រសួងទេសចរណ៍បានអោយដឹងថា នៅក្នុងឆ្នាំ២00៦ វិស័យទេសចរណ៍បានផ្តល់ប្រាក់ចំណូលដោយផ្ទាល់ចំនួន ១.0៤៩ លានដុល្លារ និងផ្តល់ការងារជូនប្រជាពលរដ្ឋប្រមាណ ២៥0 000 នាក់។ នៅឆ្នាំ ២00៥ កម្ពុជាទទួលបានចំណូលដែលផ្តល់ពីវិស័យទេសចរណ៍ចំនួន ៨៣២ លានដុល្លារ និងផ្តល់ការងារជូនប្រជាពលរដ្ឋប្រមាណ ២00 000 នាក់។

របាយការណ៍និយាយថា ការសិក្សាជាបឋមបានបង្ហាញថា ការចំណាយរបស់ភ្ញៀវទេសចរណ៍ជាមធ្យមក្នុងម្នាក់ប្រមាណ ៦១៧ ដុល្លារអាមេរិក។ ការចំណាយទាំងនោះ មានដូចជា សេវាដឹកជញ្ជូនក្នុងស្រុក ការស្នាក់នៅហូបចុក វត្ថុអនុស្សាវរីយ៍ និងសេវាផ្សេងៗក្នុងរយៈពេលស្នាក់នៅមធ្យម ៦.៥ ថ្ងៃ ដោយមិនគិតបញ្ចូលការចំណាយទៅលើការធ្វើដំណើរតាមយន្តហោះពីក្រៅមកកម្ពុជាឡើយ។ *កាសែតកម្ពុជាថ្មី ចេញផ្សាយថ្ងៃទី0៨ ខែកុម្ភៈ ឆ្នាំ២00៧។*

## រដ្ឋាភិបាលត្រូវការថវិកា២២0៥លានដុល្លារសំរាប់វិនិយោគសាធារណៈ៣ឆ្នាំ

រដ្ឋាភិបាលគ្រោងចំណាយទៅលើកម្មវិធីវិនិយោគសាធារណៈឆ្នាំ ២00៧-២00៩ ក្នុងទឹកប្រាក់សរុបប្រមាណជាង២២0៥លានដុល្លារអាមេរិក ហើយកិច្ចប្រជុំពេញគណៈរដ្ឋមន្ត្រីក៏បានឯកភាពនិងអនុម័តទៅលើសេចក្តីព្រាងកម្មវិធីនេះកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២00៧។

កម្មវិធីវិនិយោគសាធារណៈឆ្នាំ ២00៧-២00៩ នឹងចំណាយលើផ្នែកហិរញ្ញវត្ថុសរុបសំរាប់រយៈពេល៣ឆ្នាំ គឺ២២0៥លានដុល្លារអាមេរិក។ ក្នុងនោះសំរាប់ឆ្នាំ២00៧មានចំនួន៦៩៥លានដុល្លារ សំរាប់ឆ្នាំ២00៨ចំនួន៧៤0លាន

ដុល្លារ និងឆ្នាំ២០០៩ចំនួន៧៧០លានដុល្លារ ហើយក្នុងនោះបរិមាណទុនដែលបានសន្យាដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍មានចំនួន ១១៤៣ លានដុល្លារ និងត្រូវការទុនបន្ថែមទៀតចំនួន១០៦១លានដុល្លារ ។

កម្មវិធីវិនិយោគសាធារណៈនេះបានបញ្ចូលរាល់គំរោងដែលចុះកិច្ចសន្យារួចហើយ ទៅជាគំរោងកំពុងដំណើរការទាំងអស់ដែលក្នុងនោះគំរោងកំពុងដំណើរការនិងបញ្ចប់មានចំនួន៣៣១គំរោង និងគំរោងកំពុងចរចាមានអាទិភាពខ្ពស់មានចំនួន២៧៤គំរោង ។ សរុបទាំងអស់មានចំនួន៦០៥គំរោង ។ *រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៧ ។*

## រក្សាកំណើនសេដ្ឋកិច្ច គឺត្រូវបន្តរក្សាលំនឹងតុល្យភាពជញ្ជីងពាណិជ្ជកម្ម

មន្ត្រីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្មបានអោយដឹងកាលពីពេលថ្មីៗនេះថា នៅដើមឆ្នាំ២០០៧នេះស្ថានភាពនាំចេញ និងនាំចូលនៅកម្ពុជាកំពុងតែមានលក្ខណៈល្អប្រសើរប្រហាក់ប្រហែលគ្នា ។ នៅឆ្នាំ២០០៦ ការនាំចេញផលិតផលផ្សេងៗពីប្រទេសកម្ពុជាសរុបចំនួន ៣.៦១២ លានដុល្លារអាមេរិក កើនឡើង៤៨ភាគរយ( តាមតួរលេខគយ) ក្នុងនោះការនាំចេញផលិតផលវាយនភ័ណ្ឌនិងសំលៀកបំពាក់ និងទំនិញផ្សេងៗទៀតក្រោមកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធGSPនិងMFNបានកើនឡើង១៦ភាគរយ គឺពី២.២២៩លានដុល្លារអាមេរិកនៅឆ្នាំ២០០៥ ទៅ២.៥៨៤លានដុល្លារអាមេរិកនៅឆ្នាំ២០០៦ ។

ផលិតផលនាំចូលសរុបនៅឆ្នាំ២០០៦មានចំនួន៣.០១៥លានដុល្លារ កើនឡើង២១ភាគរយធៀបនឹងឆ្នាំ២០០៥ ដែលនាំចូលមានចំនួន២.៤៨៤លានដុល្លារអាមេរិក ។ ក្រសួងពាណិជ្ជកម្ម និងក្រសួងនានាដែលពាក់ព័ន្ធដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចបានខិតខំទាក់ទាញវិនិយោគទុនបរទេសអោយចូលមកវិនិយោគលើវិស័យកាត់ដេរបន្ថែមទៀត និងវិនិយោគលើវិស័យផ្សេងៗទៀត ដូចជារោងចក្រផលិតកង់ និងរោងចក្រមួយចំនួនទៀតដែលប្រើប្រាស់វត្ថុធាតុដើមជាទំនិញកសិផលនៅក្នុងស្រុក ។ ព្រោះថាបើមានអ្នកវិនិយោគមកវិនិយោគផលិតនៅក្នុងស្រុក គឺការជំរុញនូវកំណើនបរិមាណទំនិញនាំចេញពីកម្ពុជា ។

តាមតួលេខនាំចេញនាំចូលនៅឆ្នាំ២០០៦ បានបង្ហាញអោយឃើញថា ប្រទេសកម្ពុជាមានសមត្ថភាពរក្សានូវលំនឹងនិងតុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់ខ្លួនបានដោយជោគជ័យដែលប្រទេសក្រីក្រកំរនិងធ្វើបានណាស់ ចំពោះការនាំចេញលើសការនាំចូលរហូតដល់ ៣.៦ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗដូចនេះ ។ កម្ពុជាបានធ្វើការនាំចេញច្រើនជាងការនាំចូលចំនួន៣ឆ្នាំជាប់ៗគ្នារួចមកហើយ ។

ការនាំចេញសំខាន់បំផុតរបស់កម្ពុជា គឺពឹងផ្អែកលើសំលៀកបំពាក់ និងស្បែកជើង ដែលមានចំនួន ២.២២៨ ពាន់លានដុល្លារនៅក្នុងឆ្នាំ២០០៦នេះ ។ នៅដំណាច់ឆ្នាំ២០០៦ ប្រទេសកម្ពុជាមានរោងចក្រកាត់ដេរកំពុងដំណើរការចំនួន ៣០៧ និងមានកម្មករប្រមាណ ៣៥៨.000 នាក់ដែលទទួលប្រាក់បៀវត្សរ៍ ២៥.៩ លានដុល្លារអាមេរិកក្នុងមួយខែ ។

ទាក់ទិននឹងការសំរួលពាណិជ្ជកម្មមន្ត្រីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្មបានអោយដឹងថា ដើម្បីទាក់ទាញអ្នកវិនិយោគទុនបន្ថែមទៀត និងធានាបាននូវសមត្ថភាព លទ្ធភាពប្រកួតប្រជែងជាមួយប្រទេសជិតខាងនោះ ក្រសួងស្ថាប័នជំនាញបានធ្វើការសំរួលពាណិជ្ជកម្មតាមវិធានការផ្សេងៗ ដូចជាការកាត់បន្ថយបែបបទរដ្ឋបាលនិងការចំណាយក្រៅផ្លូវការ កាត់បន្ថយរយៈពេលត្រួតពិនិត្យទំនិញ ជាពិសេសការងារត្រួតពិនិត្យតាមប៉ុស្តិ៍កាំកុងត្រូលអាចសំរេចបាននៅនឹងកន្លែង ការបន្ត

ជំរុញនូវការកាត់បន្ថយរយៈពេលផ្តល់អាជ្ញាប័ណ្ណ（EL） មកនៅតិចជាង១១ម៉ោងនិង៤៥នាទីនៃម៉ោងធ្វើការកាត់បន្ថយចំណាយក្នុងការចុះបញ្ជីក្រុមហ៊ុនមកនៅត្រឹមតែ ២៦០.០០០ រៀល។ កាត់បន្ថយប្រាក់ដើមទុនតម្កល់ពេលចុះបញ្ជីពី៥០០០ដុល្លារមកនៅត្រឹមតែ១០០០ដុល្លារ និងកាត់បន្ថយការចុះបញ្ជីពីតិចជាង១០ថ្ងៃកន្លះ បង្កើតស្នាក់ការត្រួតពិនិត្យរួមគ្នារវាងទីចាត់ការគយនិងរដ្ឋាករនិងកាំកុងត្រូលដើម្បីផ្តល់ភាពងាយស្រួលជូនអ្នកវិនិយោគ និងបង្កើនល្បឿនត្រួតពិនិត្យអោយបានឆាប់បំផុត។

ប្រទេសកម្ពុជាអាចនឹងបង្កើនការនាំចេញបានកាន់តែច្រើនទៀត តាមរយៈនៃការបង្កើតការវិនិយោគផ្នែកឯកជនវិនិយោគផលិតផលសំរាប់នាំចេញយ៉ាងច្រើនស្របទៅតាមតំរូវការទីផ្សារអន្តរជាតិ។

*កម្ពុជាថ្មី ចេញផ្សាយថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៧។*

## ដៃគូរអភិវឌ្ឍន៏ចំនួន ១៤ ផ្តល់មូលនិធិ ៦០ លានដុល្លារដល់កម្មវិធីកាត់បន្ថយភាពក្រីក្រ

មូលនិធិរួមគ្នាមួយ បានផ្តល់ដោយដៃគូរអភិវឌ្ឍន៏ផ្សេងៗគ្នា ចំនួន៦០លានដុល្លារអាមេរិក។ យោងតាមសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មាធិការជាតិដឹកនាំកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការក្រសួងមហាផ្ទៃ បានអោយដឹងថា មូលនិធិនេះនឹងប្រើប្រាស់រយៈពេល៤ឆ្នាំកន្លះ ចាប់ពីខែសីហាឆ្នាំ២០០៦ ដល់ខែធ្នូឆ្នាំ២០១០ ដែលគ្របដណ្តប់លើឃុំចំនួន៧០៧ឃុំ ភាគច្រើនឃុំមានមូលដ្ឋាននៅក្រៅតំបន់ផលិតកម្មស្រូវសំខាន់ៗ។

លោក សក់ សេដ្ឋា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បានមានប្រសាសន៏ថា ទឹកប្រាក់ចំនួន៦០លានដុល្លារអាមេរិកនេះ ផ្តល់ដោយដៃគូរអភិវឌ្ឍន៏នានាចំនួន ១៤ ក្នុងនោះអង្គការ Danida និងអង្គការ DFID បានផ្តល់ចំនួន២០លានដុល្លារអាមេរិក ជូនដល់រាជរដ្ឋាភិបាលកម្ពុជាសំរាប់អនុវត្តគំរោងគ្រប់គ្រងធនធានធម្មជាតិ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលជាផ្នែកមួយនៃកម្មវិធីគាំទ្រអភិបាលកិច្ចរដ្ឋបាលមូលដ្ឋានតាមរយៈកម្មវិធីវិមជ្ឈការក្រសួងមហាផ្ទៃ។ លោកបន្តថា ចំនែកជំនួយប្រមាណ៤០លានដុល្លារទៀត គឺដៃគូរអភិវឌ្ឍន៏នានានឹងផ្តល់ទៅដៃគូររបស់រដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលនានា។ *កាសែតរស្មីកម្ពុជា ចេញផ្សាយ ថ្ងៃទី១៦ខែមីនាឆ្នាំ២០០៧ ។*

## សម្តេច ហ៊ុន សែន : IMF WB និងADB
## ពុំគប្បីផ្តល់យោបល់អោយកម្ពុជាកាប់ឈើដើម្បីចំណូលជាតិទៀតទេ

លោកស្រី ម៉ូនិក បាប៉ុយ នាយិកាប្រតិបត្តិមូលនិធិបរិស្ថានពិភពលោក បានចូលជួបពិភាក្សាជាមួយសម្តេច ហ៊ុន សែន កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៧។

លោកស្រីបានសុំការពន្យល់ពីសម្តេចពាក់ព័ន្ធដល់កាប់ព្រៃឈើនៅកម្ពុជា បញ្ហាការពារព្រៃឈើនិងបរិស្ថាននៅអាងទន្លេមេគង្គនិងអាងទន្លេសាបរបស់កម្ពុជា។ លោកស្រីមានប្រសាសន៏ថា ការស្វែងយល់នេះគឺដើម្បីមានគោលបំណងជួយដល់ប្រទេសកម្ពុជាលើវិស័យបរិស្ថាន។ លោកស្រីបន្តថា អង្គការ GEF（Globle Environment Fund）ជាអង្គការ

មួយមានការទទួលស្គាល់ពីពិភពលោក។ អង្គការមានសមាជិកចំនួន១៧៧ប្រទេស និងទទួលបានជំនួយពីប្រទេសចំនួន ៤២ដែលជាសមាជិក ដែលមានទឹកប្រាក់៣.២០០លានដុល្លារសំរាប់អង្គការនេះ។

អ្នកនាំពាក្យជំនួបនេះបានបញ្ជាក់ថា ជាការឆ្លើយតបសម្ដេចបានបញ្ជាក់ថា ប្រទេសកម្ពុជាតាំងពីអាណត្តិទី២មក ត្រូវហាមប្រាមមិនអោយមានការកាប់ឈើទៀតឡើយ។ សម្ដេចបានលើកឡើងថា សម្ដេចបានជំរាបទៅ IMF WB ADB ថា ពុំគប្បីណាផ្ដល់អនុសាសន៍អោយកម្ពុជាបន្តធ្វើការកាប់ព្រៃឈើដើម្បីយកជាចំណូលជាតិនោះទេ។

ពាក់ព័ន្ធនិងអាងទន្លេមេគង្គ សម្ដេចបង្ហាញកង្វល់ថា អាងទន្លេមេគង្គមានការផ្លាស់ប្ដូរយ៉ាងច្រើនដោយសារ ធម្មជាតិក្នុងរយៈពេល៤០ឆ្នាំកន្លងមកនេះ ដូចជាការគោករាក់ដោយសារការហូរច្រោះដីពីផ្នែកខាងលើ។ ហើយបញ្ហានេះ កម្ពុជាកំពុងតែសិក្សាដើម្បីបូមស្តារអាងទន្លេមេគង្គនេះឡើងវិញ។ ពាក់ព័ន្ធអាងទន្លេសាបរាជរដ្ឋាភិបាលក៏បានយកចិត្តទុក ដាក់ការពារនូវបរិស្ថានក្នុងតំបន់អាងដោយហាមមិនអោយមានការកាប់បំផ្លាញព្រៃលិចទឹកដែលជាជំរកត្រីពង ការពារ ជំរកសត្វស្លាបជាដើម។

លោកស្រីម៉ូនិក ក៏បានលើកឡើងផងដែរថា នៅពេលខាងមុខឆាប់ៗនេះនឹងមានកិច្ចប្រជុំមួយនៅអាល្លឺម៉ង់ ដែល កិច្ចប្រជុំនោះនឹងឈានទៅដល់ការផ្ដល់ថវិកាដល់ប្រទេសដែលថែរក្សាបរិស្ថានបានល្អផងដែរ។
*កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧។*

## លោក ស ខេង : ADB ទទួលស្គាល់ការសង់ប៉ុស្តិ៍ឃុំ-សង្កាត់ ប្រកបដោយតម្លាភាព

លោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងកាលពីថ្ងៃទី២៣ ខែមេសាថា ធនាគារ ADB ដែលជាអ្នកផ្ដល់កម្ចីសំរាប់សង់ប៉ុស្តិ៍រដ្ឋបាលឃុំទូទាំងប្រទេសបានវាយតំលៃថា ការកសាងនេះមានតម្លាភាព និងរបៀប រៀបរយ។ លោកបញ្ជាក់ថា ADBបានផ្ដល់ប្រាក់កម្ចីចំនួនប្រមាណ១០លានដុល្លារអាមេរិក សំរាប់កម្ពុជាយកទៅសង់ប៉ុស្តិ៍ រដ្ឋបាលឃុំនៅទូទាំងប្រទេសសំរាប់ជំហានទី១។ ប្រាក់កម្ចីនេះក្រសួងមហាផ្ទៃបានសំរេចធ្វើការសាងសង់ប៉ុស្តិ៍នគរបាល ចំនួន៥០២ឃុំនៅក្នុងខេត្តចំនួន២០។

នៅជំហានទី១នេះក្រៅពី ADB ផ្ដល់ប្រាក់កម្ចី១០លានដុល្លារដល់កម្ពុជា ក៏នៅមានប្រទេសមួយចំនួនទៀតបាន ផ្ដល់កម្ចី ដូចជាប្រទេសស៊ុយអ៊ែត៣.៥៤លានដុល្លារ ប្រទេសហុល្លង់២.៤០លានដុល្លារ ព្រមទាំងមានថវិកាបដិភាគរបស់ រាជរដ្ឋាភិបាលមួយចំនួនផងដែរ។ *រស្មីកម្ពុជា ថ្ងៃពុធ ទី២៥ ខែមេសា ឆ្នាំ២០០៧ ទំព័រក៣។*

## យន្តហោះមួយគ្រឿងធ្លាក់ : មនុស្ស២២នាក់ដែលស្ថិតនៅក្នុងយន្តហោះបានស្លាប់បាត់បង់ជីវិត

យន្តហោះប្រភេទ AN២៤ ផលិតនៅរុស្ស៊ីបានធ្លាក់ និងបានសំលាប់មនុស្សទាំងអស់ដែលជិះនៅក្នុងយន្តហោះ។ យន្តហោះនោះបានធ្វើដំណើរចេញពីខេត្តសៀមរាបទៅកាន់ក្រុងព្រះសីហនុ ហើយបានធ្លាក់នៅចំងាយប្រមាណ៩គីឡូម៉ែត្រ ខាងកើតសង្កាត់តានៃ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ។ យន្តហោះនេះ បានបែកជាកំណាត់ៗ ហើយអ្នកនៅលើយន្តហោះ

ទាំង២២នាក់បានស្លាប់ទាំងអស់ ដោយគៀបជាប់នឹងយន្តហោះ ហើយមានសាកសពតែម្នាក់ប៉ុណ្ណោះដែលខ្ទាតចេញក្រៅ។ យន្តហោះនេះត្រូវបានគេរកឃើញនៅវេលាម៉ោង៧និង៣០នាទីព្រឹក ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ បន្ទាប់ពីយន្តហោះនេះបានធ្លាក់តាំងពីថ្ងៃទី២៥ ខែមិថុនាមកម្លេះ។ មូលហេតុសំខាន់ដែលអូសបន្លាយការរកឃើញនេះ ដោយសារបញ្ហាអាកាសធាតុដែលមានអ័ព្ទធ្លាក់ច្រើននិងមានភ្លៀងរំខាន។

ក្នុងប្រតិបត្តិការនេះ ឃើញមានការចុះអន្តរាគមន៍ដោយផ្ទាល់ពីសម្តេច ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់កងទ័ពកម្ពុជាព្រមទាំងមានការចូលរួមពីសំណាក់តំណាងទូតដែលមានជនជាតិស្ថិតនៅលើយន្តហោះនោះផងដែរ។

មធ្យោបាយដែលប្រើនៅក្នុងប្រតិបត្តិការនោះរួមមាន កំលាំងយោធា និងអង្គរក្សសម្តេច ហ៊ុន សែន ជាង ១000 នាក់ ឧទ្ធម្ភាគចក្រ៤គ្រឿង និងមានជំនួយពីផ្កាយរណបរបស់អាមេរិក និងកំលាំងអាជ្ញាធរដែនដីដែលពាក់ព័ន្ធ និងប្រជាពលរដ្ឋមូលដ្ឋានផងដែរ។

ជនរងគ្រោះក្នុងឧបទ្ទភាគច្រើនជាជនជាតិកូរ៉េខាងត្បូង ដែលចំនួនរហូតដល់១៣នាក់នៃចំនួនសរុប២២នាក់ ក្រៅពីនោះមានជនជាតិឆេក រុស្ស៊ីនិងអាកាសយានិកជាតិខ្មែរ។ *រស្មីកម្ពុជា ថ្ងៃអង្គារ ទី២៦ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក៣។*

## ប្រទេសកម្ពុជាទទួលចំណាត់ថ្នាក់បេប្លូក( B +) បេ២( B2) ក្នុងចំណាត់ថ្នាក់លើកទី១

រដ្ឋាភិបាលកម្ពុជាបានស្វាគមន៍ចំពោះប្រទេសកម្ពុជាដែលបានទទួលចំណាត់ថ្នាក់បេបូកពីទីភ្នាក់ងារ Standard & Poor's និងចំណាត់ថ្នាក់បេ២ពីទីភ្នាក់ងារ Moody's ដែលចំណាត់ថ្នាក់នេះបានបង្ហាញថា ជាទូទៅនៅក្នុងប្រទេសកម្ពុជាគឺមានស្ថិរភាពគ្រប់ផ្នែក។

នៅក្នុងសន្និសីទសារព័ត៌មានមួយកាលពីថ្ងៃទី២១ខែឧសភាឆ្នាំ២០០៧នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបង្ហាញថាការវាយតំលៃនេះ គឺជាព្រឹត្តការណ៍ដ៏សំខាន់មួយក្នុងការធ្វើអោយប្រសើរឡើងទំនុកចិត្តរបស់អ្នកវិនិយោគនៅក្នុងប្រទេសកម្ពុជានិងបង្ហាញពីឆន្ទៈរបស់ប្រទេសកម្ពុជាដើម្បីធ្វើអោយសាធារណៈជនដឹងពីការរីកចំរើននៃហិរញ្ញវត្ថុ។
*កាសែតរស្មីកម្ពុជា ថ្ងៃពុធ ទី២៣ ខែឧសភា ឆ្នាំ២០០៧ ទំព័រក៤។*

## កម្ពុជា : មីយ៉ានម៉ានឹងសំរេចបានជាស្ថាពរនូវរបបប្រជាធិបតេយ្យ

លោក ហោ ណាំហុង បានថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីថ្ងៃទី២៣ខែឧសភាឆ្នាំ២០០៧ បន្ទាប់ពីដំណើរនិវត្តន៍ពីប្រទេសភូមារបស់គណៈប្រតិភូជាន់ខ្ពស់កម្ពុជាដែលដឹកនាំដោយសម្តេច ហ៊ុន សែន ថា ដំណើរទស្សនៈកិច្ចនេះមានគោលដៅសំខាន់ពីរ ទី១-គឺពង្រឹងកិច្ចសហប្រតិបត្តិការនឹងមិត្តភាពជាមួយសហភាពមីយ៉ាន់ម៉ា និងទី២-គឺស្វែងយល់អំពីសភាពការណ៍របស់សហភាពមីយ៉ាន់ម៉ា។

ក្នុងដំណើរទស្សនកិច្ចនេះ សម្តេច ហ៊ុន សែន បានជួបពិភាក្សាជាមួយឧត្តមសេនីយ៍ ធេន សេន នាយករដ្ឋមន្ត្រីស្តីទីសហភាពមីយ៉ាន់ម៉ា និងឧត្តមសេនីយ៍ ថាន់ស្វេ ដែលជាប្រធានក្រុមប្រឹក្សាសន្តិភាពនិង អភិវឌ្ឍន៍នៃសហភាពមីយ៉ាន់ម៉ា។

ក្នុងជំនួយពិភាក្សារវាងភាគីទាំងពីរ បានសំរេចអោយមានការហោះហើរត្រង់ពីតំបន់ទេសចរណ៏របស់មីយ៉ាន់ម៉ា បាហ្គានម៉ងដាឡេ មកកាន់ខេត្តទេសចរណ៏សៀមរាបរបស់កម្ពុជា ។

ភាគីមីយ៉ាន់ម៉ាក៏បានធ្វើការឧទ្ទេសនាមប្រាប់ភាគីកម្ពុជា អំពីភាពជឿនលឿននៃការអនុវត្តន៏ផែនទី ចង្អុលផ្លូវ៧ ចំណុចដែលសំដៅទៅរកប្រជាធិបតេយ្យភាវូនីយកម្មនៅមីយ៉ាន់ម៉ា ។

ពាក់ព័ន្ធនឹងបញ្ហាអ្នកស្រី អ៊ុង សានស៊ូជី ភាគីទាំងពីរពុំបានលើកយកមកពិភាក្សាគ្នានោះទេ ។ តែភាគីមីយ៉ាន់ម៉ា បានស្នើសុំការយោគយល់ថា មីយ៉ាន់ម៉ាមានជនជាតិរហូតដល់ជាង១០០ខុស១គ្នា និងមានកំលាំងប្រដាប់អាវុធប្រឆាំងរដ្ឋាភិបាល១៨ក្រុម ប៉ុន្តែបានចុះចូល១៧ក្រុមនៅសល់តែ១ក្រុមប៉ុណ្ណោះ ដូច្នេះការធ្វើរបស់មីយ៉ាន់ម៉ាគឺដើម្បីអោយមានការឯកភាពនិងទទួលយកបានពីគ្រប់ជនជាតិទាំងអស់ ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី២៤ ខែឧសភា ឆ្នាំ២០០៧ ទំព័រក៧ ។*

## សម្តេច ជា ស៊ីម ចូលរួមជាអធិបតីក្នុងសន្និសីទអន្តរជាតិរំលឹកខួបប្រវត្តិសាស្ត្រ លើកទី៥០នៃសហគមន៏អឺរ៉ុប និងខួបលើកទី៤០នៃសមាគមន៏ប្រជាជាតិអាស៊ីអាគ្នេយ៏

សន្និសីទនេះប្រារព្ធធ្វើកាលពីថ្ងៃទី៣០ខែឧសភាឆ្នាំ២០០៧ ក្រោមអធិបតីភាពរបស់សម្តេចប្រមុខរដ្ឋស្តីទី ជា ស៊ីម ។ ក្នុងពិធីនេះសម្តេចបានលើកឡើងថា ទំនាក់ទំនងរវាងកម្ពុជា-សហគមន៏អឺរ៉ុប ក៏ដូចជាទំនាក់ទំនងកម្ពុជា-អាស៊ាន នឹងកាន់តែត្រូវបានពង្រឹងពង្រីកឡើងថែមទៀតក្នុងភាពជាដៃគូរយ៉ាងរឹងមាំនិងមានប្រសិទ្ធិភាព ។

សម្តេចបញ្ជាក់ថា សកលភាវូនីយកម្ម និងសមាហរណកម្មតំបន់ គឺជាចរន្តមិនអាចចៀសបាននៅក្នុងបរិយាកាសដែលពិភពលោក ក៏ដូចជាតំបន់មួយចំនួនក៏កំពុងមានការវិវឌ្ឍន៏ឆាប់រហ័ស ទន្ទឹមនឹងការរីកចំរើនខាងវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី៣១ ខែឧសភា ឆ្នាំ២០០៧ ទំព័រក២ ។*

## កម្ពុជារៀបចំតាំងពិព័រណ៏ផលិតផលស្ត្រីអាស៊ាន ដើម្បីស្វែងរកថវិកាជួយដល់ជនរងគ្រោះដោយធម្មជាតិ

ប្រសាសន៏នេះ ត្រូវបានលើកឡើងដោយលោក ហោ ណាំហុង ក្នុងឱកាសដែលលោកបានទទួលជួបជាមួយលោកស្រី Ten Yee Woan ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅកម្ពុជា កាលពីថ្ងៃទី១៨ខែកក្កដា ឆ្នាំ២០០៧ ។

ក្នុងឱកាសជំនួយពិភាក្សាគ្នានោះ ភាគីទាំងពីរបានផ្តោតលើកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។ លោក ហោ ណាំហុង បានថ្លែងអំណរគុណចំពោះប្រទេសសិង្ហបុរី ដែលបានជួយដល់កម្ពុជា ក្នុងនោះរួមមាន : សិង្ហបុរីបានបណ្តុះបណ្តាលធនធានមនុស្សកម្ពុជាបានចំនួន ៨៧២នាក់ និងបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្ពុជា-សិង្ហបុរីនៅភ្នំពេញ ដើម្បីបណ្តុះបណ្តាលរយះពេលខ្លីដល់មន្ត្រីកម្ពុជាចំនួន ២.៨១៩ នាក់ គិតចាប់ពីឆ្នាំ២០០២ដល់ឆ្នាំ២០០៦ ។ សិង្ហបុរីក៏បានផ្តល់អំណោយ Computer (ប្រើរួចហើយ)ចំនួន១០០គ្រឿងដល់ក្រសួងពាណិជ្ជកម្មកាលពីឆ្នាំ២០០២ ហើយនៅឆ្នាំ២០០៣ បានផ្តល់នូវម៉ាស៊ីន Scanner ចំនួន២គ្រឿងមានតំលៃសរុប ១២៧.០០០ ដុល្លារអាមេរិក សំរាប់ត្រួតពិនិត្យជំងឺ SARS អ្នកដំណើរនៅព្រលានយន្តហោះភ្នំពេញ ។

ទាក់ទងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-សិង្ហបុរី ភាគីទាំងពីរបានចុះហត្ថលេខាជាមួយគ្នារួចហើយលើអនុស្សរណៈស្តីពីសេវាកម្មផ្លូវអាកាសកាលពីខែវិច្ឆិកាឆ្នាំ១៩៩៦ ហើយក៏បានផ្លាស់ប្តូរកំណត់ទូត លិខិតឆ្លងដែនផ្លូវការ និងលិខិតឆ្លងដែនធម្មតាសំរាប់ការស្នាក់នៅតិចជាង៣០ថ្ងៃ ដែលចាប់អនុវត្តពីថ្ងៃទី០១ខែមករាឆ្នាំ២០០៦។

ប្រទេសសិង្ហបុរីបានដាក់ទំនាក់ទំនងការទូតជាមួយប្រទេសកម្ពុជានៅថ្ងៃទី១០ខែសីហាឆ្នាំ១៩៦៥ ហើយនៅឆ្នាំ ១៩៧៥ ទំនាក់ទំនងនេះត្រូវបានកាត់ផ្តាច់ទាំងស្រុងក្នុងរបបខ្មែរក្រហម។ លុះមកដល់ថ្ងៃទី១៨ខែសីហាឆ្នាំ១៩៩២ ទំនាក់ទំនងការទូតនេះត្រូវបានផ្សារភ្ជាប់ឡើងវិញ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ទី២១ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៣។*

## នាំទូតប្រទេសធំៗទៅពិនិត្យមើលប្រាសាទព្រះវិហារ

គណៈប្រតិភូចំរុះមួយក្រុម រួមមានឯកអគ្គរដ្ឋទូតអាមេរិក តំណាងស្ថានទូតកាណាដា តំណាងស្ថានទូតជប៉ុន និងតំណាងក្រសួងពាក់ព័ន្ធដឹកនាំដោយលោក វ៉ា គឹមហុង ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា បានចុះទៅពិនិត្យមើលស្ថានភាពជាក់ស្តែងរបស់ប្រាសាទព្រះវិហារ កាលពីថ្ងៃទី២៤ខែកក្កដាកន្លងទៅ ក្រោយពីមានការបដិសេធពីប្រទេសថៃក្នុងការដាក់ប្រាសាទនេះទៅជាបេតិកភណ្ឌពិភពលោកនោះ។

លោក ចូសេហ្វ មូសូមេលី ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា បានមានប្រសាសន៍ថា ក្រោយពីទស្សនកិច្ច ឃើញថា ប្រាសាទព្រះវិហារនេះពិតជាអស្ចារ្យ ទាំងការសាងសង់និងសោភ័ណភាព ព្រមទាំងអាកាសធាតុជុំវិញមានអំណោយផលច្រើនគួរអោយគយគន់។

លោកឯកអគ្គរដ្ឋទូតបានបន្តថា យើងតាំងចិត្តថានឹងអនុវត្តតាមការស្នើសុំរបស់កម្ពុជាទៅលើបញ្ហាគ្រប់គ្រងនិងអភិរក្សប្រាសាទព្រះវិហារ ហើយយើងសង្ឃឹមថាកម្ពុជានឹងធ្វើកិច្ចការទាំងអស់នេះដើម្បីជំរុញអោយដំណើរការគ្រប់គ្រងប្រាសាទបានល្អ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ ទី២៦ ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៣។*

## - លោក សុខ អាន ជួបទូតអាល្លឺម៉ង់ ពិភាក្សាលើបញ្ហាខ្សែក្រវាត់បៃតងនៅសៀមរាប និង តំណាងទូតកាណាដា និងតំណាង ធនាគារពិភពលោក ជួបថ្នាក់ដឹកនាំ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ( NCDM )

## - ពិធីបំពាក់មេដាយជូនមន្ត្រីស្ថានទូតបារាំង និងអាល្លឺម៉ង់ ដែលមានស្នាដៃក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន

ជំនួបនេះប្រព្រឹត្តទៅផ្សេងគ្នា ហើយការពិភាក្សាផ្តោតទៅលើបញ្ហាកិច្ចសហប្រតិបត្តិការ និងពង្រីកទំនាក់ទំនងបន្ថែមរវាងកម្ពុជានិងដៃគូទាំងនោះ។

លោក សុខ អាន បានទទួលជួបលោក Puus Fisher ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា ដោយផ្តោតការពិភាក្សាលើគំរោងអភិវឌ្ឍន៍ខ្សែក្រវាត់បៃតង(Green Bell) នៅជុំវិញខេត្តសៀមរាប។ គំរោងខ្សែក្រវាត់បៃតងនេះ

ផ្តោតលើជំនួយអាល្លឺម៉ង់សំរាប់ជួយប្រជាពលរដ្ឋនៅខេត្តសៀមរាប ក្នុងការដាំបន្លែដើម្បីលក់ទៅអោយសណ្ឋាគារទំនើបៗក្នុងខេត្ត និងអាចជាផ្នែកមួយក្នុងនាំចេញទៅលក់នៅក្រៅប្រទេសក៏ដូចជាទីផ្សារក្នុងស្រុក។

ដោយឡែកជំនួបរវាងទូតកាណាដានិងតំណាង WB ជាមួយថ្នាក់ដឹកនាំ NCDM វិញ ធ្វើឡើងនៅថ្ងៃទី១១ ខែកក្កដា រវាងលោក ញឹម វ៉ាន់ដា និងលោកស្រីទូតកាណាដា DONICA PETIE ឯកអគ្គរដ្ឋដែលត្រូវបញ្ចប់អាណត្តិ។ លោក ញឹម វ៉ាន់ដា បានថ្លែងអំណរគុណដល់កាណាដា ដែលកន្លងមកបានជួយដល់កម្ពុជាលើការបណ្តុះបណ្តាលធនធានមនុស្ស ការងារកំចាត់គ្រាប់មីន ការងារសិទ្ធិមនុស្ស និងការងារគ្រោះមហន្តរាយ។

នៅរសៀលថ្ងៃដដែលលោក ញឹម វ៉ាន់ដា បានជួបជាមួយលោក ALAN PIAZZA មន្ត្រីជំនាញការសេដ្ឋកិច្ចជាន់ខ្ពស់របស់ធនាគារពិភពលោកពីការប្រើប្រាស់មូលនិធិលើការងារអនុវត្តន៍ទប់ស្កាត់ជំងឺផ្តាសាយបក្សីនៅកម្ពុជា។

រីឯពិធីបំពាក់មេដាយវិញបានធ្វើឡើងនៅក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោក តេង សាវង្ស នៅថ្ងៃទី១២ ខែកក្កដា ។ មេដាយនេះបានផ្តល់ជូនមន្ត្រីអនុព័ន្ធសន្តិសុខផ្ទៃក្នុងប្រចាំនៅស្ថានទូតបារាំងប្រចាំកម្ពុជាចំនួន២រូប និងអ្នកជំនាញការអាល្លឺម៉ង់ប្រចាំនៅអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនចំនួន១រូប។

មេដាយសហមេត្រី ថ្នាក់មហាសេនា បំពាក់ជូនលោក Eric GUILLET និងមេដាយសហមេត្រីថ្នាក់អស្សឫទ្ធិបំពាក់ជូនលោក Jean Luc Labbe អនុព័ន្ធសន្តិសុខផ្ទៃក្នុងបារាំង។ ចំនែកលោក Martin Lutterjohann អ្នកជំនាញការអាលឺម៉ង់ ត្រូវបានបំពាក់មេដាមាសស្ថាបនាជាតិ ព្រោះតែលោកបានខិតខំស្វែងរកថវិកាចំនួន ២៦.៨០០ ដុល្លារអាមេរិកដើម្បីទិញសំភារៈបំពាក់សាលប្រជុំរបស់អាជ្ញាធរជាតិគ្រឿងញៀន។
*រស្មីកម្ពុជា ថ្ងៃសុក្រ ទី១៣ខែកក្កដាឆ្នាំ២០០៧ ទំព័រក២។*

## ព្រះមហាក្សត្រ យាងជាអធិបតីក្នុងពិធីសម្ពោធអគាររដ្ឋសភាថ្មី

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានយាងជាអធិបតីក្នុងពិធីសម្ពោធអគាររដ្ឋសភាថ្មី កាលពីព្រឹកថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៧។

ក្នុងព្រះរាជសន្ទរកថា ថ្លែងក្នុងពិធីបើកនោះ ព្រះមហាក្សត្របានកត់សំគាល់ថា វិមានរដ្ឋសភាថ្មីដែលបានសម្ពោធនៅថ្ងៃនេះ គឺជាសមិទ្ធផលជាសក្ខីភាពនៃការប្តេជ្ញាចិត្តប្រកបដោយគតិបណ្ឌិតរបស់កម្ពុជាក្នុងការពង្រឹងស្ថាប័ននីតិបញ្ញត្តិ និងនីតិរដ្ឋ តាមទស្សនវិស័យនៃនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។

អមដំណើរព្រះវត្តមានរបស់ព្រះមហាក្សត្រក្នុងពិធីនោះ រួមមាន សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា សម្តេច ហេង សំរិន ប្រធានរដ្ឋសភា សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ចំនែកមន្ត្រីទូតក៏មានការចូលរួមច្រើនកុះករផងដែរ។

អគាររដ្ឋសភាថ្មីនេះសង់ឡើងតាមរចនាបថខ្មែរ និងមានតុបតែងលំអតាមក្បាច់បុរាណនៅផ្ទាំងប្រាសាទរបស់ខ្មែរជាច្រើន។ វិមានរដ្ឋសភាថ្មីនេះត្រូវបានសាងសង់អស់ទឹកប្រាក់ប្រមាណជាង២៦លានដុល្លារ និងពិធីសម្ពោធនេះត្រូវបានចំណាយអស់ប្រមាណ ៨០ ម៉ឺនដុល្លារទៀត។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ច័ន្ទទី០៨-០៩ ខែកក្កដា ឆ្នាំ២០០៧ ទំព័រក២។*

## រដ្ឋមន្ត្រីការបរទេសកម្ពុជា -វៀតណាម
## ចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំលើកទី៩   នៃគណៈកម្មការចំរុះទ្វេរភាគី

លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង និងលោក Pham Gia Khiem ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម បានចុះហត្ថលេខាកាលពីរសៀលថ្ងៃទី២១ ខែសីហា នៅក្រសួងការបរទេសកម្ពុជា លើកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការចំរុះលើកទី៩ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជារវាងកម្ពុជា-វៀតណាម។

ថ្លែងនៅក្នុងពិធីនោះ លោក ហោ ណាំហុង បានលើកឡើងថា កិច្ចប្រជុំនេះសំរេចបានលទ្ធផលច្រើន ក្នុងនោះភាគីវៀតណាមនឹងផ្តល់អាហារូបករណ៍ដល់មន្ត្រី និសិត្សកម្ពុជាទៅសិក្សានៅប្រទេសវៀតណាមនៅក្នុងឆ្នាំ២០០៧-២០០៨នេះចំនួន ៤៥០ នាក់ក្នុងរយៈពេលខ្លី និង១០០នាក់ក្នុងរយៈពេលវែង។

ភាគីវៀតណាម បានសាងសង់អគារមួយនៅខេត្តមណ្ឌលគិរីសំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអន្តេវាសិកដ្ឋាន។ ជាមួយនេះកម្ពុជាបានស្នើតភ្ជាប់ព្រែកជីកវិញតេរបស់វៀតណាមមកកាន់តំបន់ភ្នំដិនខេត្តតាកែវរបស់កម្ពុជា ហើយភាគីវៀតណាមសន្យានឹងធ្វើការសិក្សាលើបញ្ហានេះ ដើម្បីសំរួលដល់ដឹកជញ្ជូនទំនិញពីខេត្តតាកែវទៅវៀតណាមតាមរយៈព្រែកជីកវិញតេនេះផងដែរ។

ជាមួយនេះកិច្ចពិភាក្សារបស់គណៈកម្មការចំរុះរវាងភាគីទាំងពីរក៏បានយល់ព្រមលើបញ្ហាជាច្រើនទៀត ដូចជាបញ្ហាថាមពលអគ្គិសនី រ៉ែ ប្រេង ឧស្ម័ន វិស័យកសិកម្ម សុខាភិបាល និងចំនុចជាច្រើនទៀត។

*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី២៣ ខែសីហា ឆ្នាំ២០០៧ ទំព័រក១។*

## សម្តេច ហ៊ុន សែន រំពឹងថា ប្រទេសជប៉ុន និងអាល្លឺម៉ង់ នឹងបន្តឧបត្ថម្ភដល់កម្ពុជា

សម្តេចបានលើកឡើងបែបនេះ ក្នុងខណៈពេលដែលសម្តេចបានទទួលជួបដោយឡែកជាមួយលោក TAKEBE TSUTOMU សមាជិកសភានៃប្រទេសជប៉ុន និងលោក FRANK MARCUS MANN ដែលទើបត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសអាល្លឺម៉ង់ប្រចាំនៅប្រទេសកម្ពុជា កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៧។

*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី១៩-២០ ខែសីហា ឆ្នាំ២០០៧ ទំព័រក២។*

## គំរោងវិនិយោគសហគ្រិនកម្ពុជាចំនួន៤ បានទទួលប្រាក់ចំនួន ១.៦៣៣ លានដុល្លារអាមេរិក

ទឹកប្រាក់ចំនួន១.៦៣៣លានដុល្លារអាមេរិក ក្នុងគំរោងវិនិយោគទុនសហគ្រិនកម្ពុជាចំនួន៤ ត្រូវបានចុះហត្ថលេខាទទួលក្នុងពិធីសារនៃការចុះអនុស្សរណៈវិនិយោគទុនជាមួយសមាគមសហគ្រិនចិនពិភពលោក។

យោងតាមរបាយការណ៍បេសកម្មចូលរួមវេទិកាសមាគមសហគ្រិនចិនពិភពលោកលើកទី២ បានអោយដឹងថា :

**អនុស្សរណៈទី១ –** គឺអនុស្សរណៈស្តីពីការទទួលយកគំរោងអភិវឌ្ឍន៍តំបន់អភិវឌ្ឍន៍ពិសេសមួយកន្លែងនៅកម្ពុជា ដែលមានទឹកប្រាក់សរុបប្រមាណ ១.០០០ លានដុល្លារអាមេរិក សំរាប់រយៈពេលអនុវត្តពី៥ទៅ១០ឆ្នាំ ដែលចុះហត្ថលេខាដោយលោក កេត ហាចកណ្ណា៉ ប្រធានគំរោងរបស់ភាគីហត្ថលេខីកម្ពុជា ។

**អនុស្សរណៈទី២ –** គំរោងអភិវឌ្ឍន៍និងវិនិយោគទុនសាងសង់តំបន់លំនៅដ្ឋានថ្មីមួយនៅទីក្រុងភ្នំពេញរបស់ក្រុមហ៊ុន ៧ NG ដែលមានទឹកប្រាក់សរុបប្រមាណ ១៥០ លានដុល្លារ និងគំរោងវិនិយោគទុនលើវិស័យកសិកម្ម សុវត្ថិភាពពាណិជ្ជកម្មប្រកបដោយសុវត្ថិភាព ដែលមានទឹកប្រាក់សរុប ១ លានដុល្លារ របស់ក្រុមហ៊ុន SAC ចុះហត្ថលេខាដោយលោក ស្រី ចាន់ថន ប្រធានគំរោងហត្ថលេខីភាគីកម្ពុជា ។

**អនុស្សរណៈទី៣ –** គំរោងអភិវឌ្ឍន៍ និងវិនិយោគទុនលើវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជារបស់អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ដែលមានទឹកប្រាក់ប្រមាន ៨២ លានដុល្លារ ចុះហត្ថលេខាដោយលោក ម៉ែន សាវ៉ន្ត ភាគីខាងហត្ថលេខីកម្ពុជា ។

**អនុស្សរណៈទី៤ –** គំរោងអភិវឌ្ឍន៍ និងវិនិយោគលើតំបន់ឧស្សាហកម្មពិសេស និងតំបន់សេដ្ឋកិច្ចពិសេសរបស់កម្ពុជា ដែលមានទឹកប្រាក់សរុបប្រមាណ ៤០០ លានដុល្លារ ដែលចុះហត្ថលេខាដោយលោក ទុំប៉ែន វិរៈវិទូ ប្រធានគំរោង BPUDC ដែលជាហត្ថលេខីកម្ពុជា ។

ពិធីចុះហត្ថលេខាលើអនុស្សរណៈនេះធ្វើឡើងក្នុងវេទិកាសមាគមសហគ្រិនចិនពិភពលោកលើកទី២ នៅទីក្រុងហុងកុង កាលពីថ្ងៃទី១០ ដល់ ១១ ខែសីហា ឆ្នាំ២០០៧ ។

*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី១៩-២០ ខែសីហា ឆ្នាំ២០០៧ ទំព័រក៤ ។*

## ទទួលស្គាល់សម្តេច ហ៊ុន សែន ជាអ្នកការទូតជំចំណាន

សមាគមអ្នកមានសញ្ញាប័ត្រជាអ្នកការទូតអាជីពដែលមានទីស្នាក់ការនៅទីក្រុងឡុងដ៏ ប្រទេសអង់គ្លេសបានទទួលស្គាល់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាជាអ្នកការទូត ដែលភាសាអង់គ្លេសហៅថា Charterd Diplomat ។ ការផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់នេះដោយសារសម្តេចមានស្នាដៃក្នុងវិស័យការទូត និងការកសាងសន្តិភាព ។ ការផ្តល់ជូននូវគោរមងារនេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ។

*រស្មីកម្ពុជា ថ្ងៃសុក្រ ទី១៧ ខែសីហា ឆ្នាំ២០០៧ ទំព័រក២ ។*

## សម្តេច ហ៊ុន សែន : ត្រូវប្រើស្រ្តេយការអាស៊ានដើម្បីដោះស្រាយបញ្ហាមីយ៉ាន់ម៉ា

សម្តេចបានស្នើបែបនេះជាលើកដំបូង ក្នុងប្រតិកម្មជាការឆ្លើយតបទៅនឹងការបង្រ្កាបទៅលើបាតុករពីសំណាក់រដ្ឋាភិបាលភូមា ដែលបណ្តាអោយមានមនុស្សស្លាប់បាត់បង់ជីវិត ដែលបាតុកម្មនោះមានការចូលរួមពីព្រះសង្ឃផងដែរ ។

សម្តេចលើកឡើងកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧ តបតាមការចោទសួររបស់អ្នកកាសែតពីការរំលោភសិទ្ធិមនុស្សនៅភូមា ដោយសម្តេចមានប្រសាសន៍ថា ៖ លោកនាយករដ្ឋមន្ត្រីសិង្ហបុរីនិងជាប្រធានអាស៊ាន បាននិយាយកាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៧ ថា លោកនឹងធ្វើលិខិតមួយទៅកាន់លោក ថាន់ ស្វេ ប្រមុខជាន់ខ្ពស់បំផុតរបស់ភូមា ដោយស្នើអោយមានការបញ្ឈប់នូវការប្រើប្រាស់កំលាំង និងធ្វើការដោះលែងព្រះសង្ឃ និងអ្នកទោសនយោបាយរាប់ទាំងអ្នកស្រី អ៊ុង សានស៊ូជី ផងដែរ ។

សម្តេចបានលើកឡើងថា បញ្ហាភូមាគួរតែដោះស្រាយដោយប្រើរូបមន្តស្រ្តយការអាស៊ានតែម្តងទៅ ព្រោះរឿងនៅពេលនេះធ្ងន់ធ្ងរ ព្រោះមានការចូលរួមដោយព្រះសង្ឃ ។ សម្តេចបញ្ជាក់ថា រូបមន្តស្រ្តយការអាស៊ាន គឺអតីតប្រធានអាស៊ាន ប្រធានអាស៊ានបច្ចុប្បន្ន និងអនាគតប្រធានអាស៊ាន ត្រូវចូលរួមដោះស្រាយបញ្ហាភូមាអោយបានជោគជ័យនៅក្នុងក្របខ័ណ្ឌអាស៊ានគ្នាឯង ។ ប៉ុន្តែទោះយ៉ាងណា សម្តេចបានស្នើអោយភូមាមានការអត់ធ្មត់ជាអតិបរមា ដោយកុំប្រើកំលាំងបង្ក្រាបទៅលើបាតុករ ហើយខិតខំបន្តដំណើរការបង្រួបបង្រួមជាតិ និងដោះស្រាយបញ្ហានានាឈានទៅរកប្រជាធិបតេយ្យភាវូបនីយកម្ម សន្តិភាព ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅភូមា ។

*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ៍ ទី០៤ ខែតុលា ឆ្នាំ២០០៧ ទំព័រក២ ។*

## ត្រឹមខែកញ្ញា២០០៧ ៖ តួរលេខវិនិយោគមានចំនួន ១.៨១២ លានដុល្លារ

លោក ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអនុប្រធាន CDC បានអោយដឹងកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ ថា គិតមកដល់ពេលនេះតួលេខវិនយោគសរុបដែលបានចុះបញ្ជីនៅ CDC បានកើនឡើងដល់ចំនួន ១០.០០០ លានដុល្លារអាមេរិក ក្នុងនោះមានវិនិយោគបរទេសចំនួន ៩.៤១៧ លានដុល្លារអាមេរិក ។

គេសង្កេតឃើញថា វិស័យឧស្សាហកម្មនិងកម្មន្តសាលមានចំនួន ១.៨៤៨ លានដុល្លារ វិស័យទេសចរណ៍មានចំនួន ២.៦៨៩ លានដុល្លារ និងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងសេវាកម្មមានចំនួន ៤.៣៨០ លានដុល្លារអាមេរិក ។

លោករដ្ឋមន្ត្រីបានបន្ថែមថា សំរាប់ឆ្នាំ២០០៧ គិតត្រឹមខែកញ្ញាឆ្នាំ២០០៧ តួលេខវិនិយោគដែលបានចុះបញ្ជីនៅ CDC មានចំនួន ១.៨១២ លានដុល្លារអាមេរិក ក្នុងនោះវិនិយោគបរទេសមានចំនួន ៨៦១លានដុល្លារអាមេរិក ។ ការវិនិយោគវិស័យកសិកម្មនិងកសិឧស្សាហកម្មមានចំនួន៥៦លានដុល្លារ វិស័យឧស្សាហកម្មនិងកម្មន្តសាលមានចំនួន២៤៩ លានដុល្លារអាមេរិក វិស័យទេសចរណ៍មានចំនួន៩៣៤លានដុល្លារអាមេរិក និងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងសេវាកម្មមានចំនួន៥៧២លានដុល្លារ ។ ប៉ុន្តែយ៉ាងណាតួលេខនេះបើធៀបនឹងប្រទេសជិតខាងនៅទាបជាងគេឆ្ងាយ ។

*រស្មីកម្ពុជា ថ្ងៃសុក្រ ទី១៩ ខែតុលា ឆ្នាំ២០០៧ ទំព័រក៥ ។*

## តំណាងអាមេរិកប្រចាំ UNESCO មកទស្សនាប្រាសាទព្រះវិហារ

លោកស្រី Louise V. Oliver តំណាងអចិន្ត្រៃយ៍របស់សហរដ្ឋអាមេរិកប្រចាំនៅអង្គការយូណេស្កូ បានអញ្ជើញមកដល់ប្រទេសកម្ពុជា នឹងបានជួបពិភាក្សាការងារជាមួយលោក ឡុង វិសាលោ រដ្ឋលេខាធិការក្រសួងការបរទេសសហប្រតិបត្តិការនិងអន្តរជាតិ កាលពីថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០០៧។

គោលបំណងនៃដំណើរទស្សនកិច្ចរបស់លោកស្រី Oliver មកកាន់កម្ពុជាគឺ : អញ្ជើញទៅទស្សនាប្រាសាទបុរាណខ្មែរមួយចំនួននៅក្នុងខេត្តសៀមរាប ដូចជាប្រាសាទអង្គរវត្ត ហើយនៅសប្តាហ៍ក្រោយលោកស្រី ដែលអមដំណើរដោយលោក សុខ អាន នឹងអញ្ជើញទៅទស្សនាប្រាសាទព្រះវិហារ។

លោកស្រី Oliver ជាអ្នកតស៊ូមតិដើម្បីកម្ពុជា ជាមួយគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដើម្បីបញ្ចូលប្រាសាទព្រះវិហារខ្មែរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ លោកស្រីជាអ្នកតាក់តែងសេចក្តីសំរេចចិត្តរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកដែលដាក់ថា **ឯកភាពអោយកម្ពុជាចុះឈ្មោះប្រាសាទព្រះវិហារនៅក្នុងបញ្ជីបេតិកភណ្ឌជាគោលការណ៍** នៅប្រទេសនូវែលហ្សេឡង់ ហើយការបញ្ចូលជាផ្លូវការនឹងធ្វើនៅប្រទេសកាណាដា នៅខែ កក្កដា ឆ្នាំ ២០០៨ ខាងមុខនេះ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី២៤ ខែវិច្ឆកា ឆ្នាំ២០០៧ ទំព័រ២*។

## ថវិកាឆ្នាំ២០០៨ : ចំណាយកើន២០ភាគរយធៀបឆ្នាំ២០០៧

យោងតាមសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០០៨ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងដាក់ឆ្លងសភាជាតិនៅថ្ងៃទី២៩ខែវិច្ឆិកា បានបង្ហាញអោយឃើញថា ថវិកាជាតិឆ្នាំ២០០៨ រដ្ឋាភិបាលមានផែនការប្រមូលចំណូលអោយបានប្រមាណ ១.៤៤០ លានដុល្លារអាមេរិក និងចំណាយវិញប្រមាណ ១.៤៥៦ លានដុល្លារ គឺចំណាយច្រើនជាងឆ្នាំ២០០៧ប្រមាណ ២១ ភាគរយជាង។ ដើម្បីអោយសមតុល្យរវាងចំណូលចំណាយថវិកាឆ្នាំ២០០៨នេះ គេនឹងប្រើប្រាស់បញ្ញើរបស់រដ្ឋនៅធនាគារជាតិកម្ពុជាចំនួន ៦៥.០៦៧ លានរៀល ឬប្រមាណ ១៦ លានដុល្លារ។

ក្នុងចំណោមប្រាក់ចំណូលក្នុងស្រុក រដ្ឋាភិបាលមានផែនការប្រមូលចំណូលពន្ធគយអោយបាន ៥០៨ លានដុល្លារ (លើសឆ្នាំ២០០៧ចំនួន ១២.៥ ភាគរយ) និងចំណូលពីពន្ធដារចំនួន២៧៥លានដុល្លារ (ច្រើនជាងឆ្នាំ២០០៧ប្រមាណ ១៣ភាគរយ)។ ទន្ទឹមនេះគេគ្រោងប្រមូលចំណូលមិនមែនសារពើពន្ធអោយបានប្រមាណ១៤.៥លានដុល្លារដែរ។

យោងតាមសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០០៨ បានបង្ហាញអោយឃើញទៀតថា លើការចំណាយវិស័យរដ្ឋបាលទូទៅទទួលបានចំណែកសំរាប់យកទៅចំណាយប្រមាណ១២២លានដុល្លារកើនជាងឆ្នាំ២០០៧ ប្រមាណ ២០.៨ភាគរយ។ វិស័យការពារជាតិនិងសន្តិសុខបានទទួលចំណែក១៣៤លានដុល្លារ កើន៧.៦ភាគរយធៀបឆ្នាំ២០០៧។ វិស័យសង្គមកិច្ចទទួលបានចំណែក៣២៦លានដុល្លារ កើន១៨ភាគរយ។ សំរាប់ក្រសួងសុខាភិបាលទទួលបានចំណែក ១០២.២លានដុល្លារ កើន២០ភាគរយ។ ក្រសួងអប់រំទទួលចំណែកប្រមាណ១៩៥លានដុល្លារ កើនប្រមាណ១៤ភាគរយធៀបនឹងឆ្នាំ២០០៧។

ក្រសួងកសិកម្មទទួលបានចំណែក១៦.៥លានដុល្លា កើន១១.៤ភាគរយ។ ក្រសួងអភិវឌ្ឍន៍ជនបទទទួលបានចំណែក ១២ លានដុល្លារ និងក្រសួងធនធានទឹកបានចំណែក ០.៦ លានដុល្លារ។

*រស្មីកម្ពុជា សុក្រ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ១១។*

## ប្រជាជនកម្ពុជាដែលមានចំណេះដឹងនិងមានប្រាក់ អាចមានសំណាងទៅរស់នៅសហរដ្ឋអាមេរិក

លោកស្រី Anne Simon ប្រធានផ្នែកកុងស៊ុលរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា បាននិយាយកាលពីថ្ងៃទី៣០ ខែតុលាថា កាលពីឆ្នាំទៅមានប្រជាពលរដ្ឋកម្ពុជាប្រមាណ ១៧៧ នាក់ បានជាប់ឆ្នោតផ្សងសំណាងទៅរស់នៅសហរដ្ឋអាមេរិក ប៉ុន្តែក្នុងនោះ មានតែ ១៣៥ នាក់ប៉ុណ្ណោះ ដែលទទួលបានទិដ្ឋការ។

លោកស្រីបានបញ្ជាក់ពីលក្ខខ័ណ្ឌក្នុងការចូលរួមក្នុងការផ្សងសំណាងនេះថា ពួកគេត្រូវមានសញ្ញាប័ត្រទុតិយភូមិ ឬសញ្ញាប័ត្រជំនាញណាមួយ ដែលមានរយៈពេល២ឆ្នាំ។ ចំណែកការសំភាសន៍សុំទិដ្ឋាការនោះ ពួកគេត្រូវចំណាយថវិកាចំនួន ៧៥៥ ដុល្លារ ហើយបើទោះបីជាពួកគេមិនបានជាប់ក្តី ក៏ថវិកានេះមិនអាចទទួលយកមកវិញបានឡើយ។

លោកស្រីបញ្ជាក់បន្ថែមទៀតថា អ្នកដែលជាប់ឆ្នោតហើយ ត្រូវចំណាយសោហ៊ុយដោយខ្លួនឯង រាប់ទាំងសំបុត្រយន្តហោះ ហើយក៏ត្រូវមានអ្នកធានាច្បាស់លាស់ដែរ។

មានប្រជាពលរដ្ឋកម្ពុជាប្រមាណ ១២០០ នាក់ហើយ ដែលបានជាប់ឆ្នោតនិងទៅរស់នៅដោយស្របច្បាប់នៅប្រទេសអាមេរិក ហើយស្ថានភាពរស់នៅក៏បានប្រសើរ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ ទី០១ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ៨។*

## កម្ពុជានិងភ្ជាប់ផ្លូវដែកទៅថៃនៅពេលដែលទទួលបានមូលនិធិពីធនាគារ ADB

លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន បានអះអាងថា កម្ពុជានឹងភ្ជាប់ផ្លូវដែកជាមួយប្រទេសថៃនៅក្នុងពេលឆាប់ៗ បន្ទាប់ពីទទួលបានមូលនិធិចំនួន ៨០ លានដុល្លារពី ADB ហើយនិងអង្គការនៃបណ្តាប្រទេសនាំចេញប្រេងកាត។

លោកបានអះអាងនៅប្រទេសសឹង្ហបុរី នៅក្នុងខណៈដែលលោកទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីក្រសួងដឹកជញ្ជូនអាស៊ានថា ក្រៅពីកសាងកំណាត់ផ្លូវដែលមិនទាន់តភ្ជាប់ កម្ពុជាក៏នឹងប្រើប្រាស់ទឹកប្រាក់ចំនួន៨០លានដុល្លារនោះ សំរាប់កែលំអប្រព័ន្ធផ្លូវដែកផ្នែកផ្សេងទៀតផងដែរ។

កម្ពុជានៅមានផ្លូវដែកចំនួនពីរខ្សែ ដោយមួយខ្សែចេញពីភ្នំពេញទៅកាន់ទីក្រុងព្រះសីហនុ និងមួយខ្សែទៀតចេញដំណើរពីភ្នំពេញទៅកាន់ស៊ីសូផុន ខេត្តបន្ទាយមានជ័យ។ ប៉ុន្តែផ្លូវដែកទាំងពីរខ្សែនេះមានសភាពទ្រុឌទ្រោមទៅហើយ។

បើតាមសំណើដែលធ្វើឡើងដោយបណ្តាប្រទេសសមាជិកអាស៊ាន កាលពីឆ្នាំ១៩៩៥ សមាជិកអាស៊ានទាំងអស់ត្រូវធ្វើការតភ្ជាប់ផ្លូវដែកមួយដែលមានចំងាយ ៥.៥០០ គីឡូម៉ែត្រ ដោយភ្ជាប់ប្រទេសសិង្ហបុរីទៅកាន់ទីក្រុងគុនមិញ

ប្រទេសចិន។ ប៉ុន្តែកម្ពុជានៅខ្វះផ្លូវដែកចំនួនពីរខ្សែ គឺពីស៊ីសូផុនទៅប៉ោយប៉ែត និងមួយខ្សែទៀតពីភ្នំពេញទៅកាន់ឡុកនិញ ព្រំដែនកម្ពុជា-វៀតណាម។

ផ្លូវដែកដែលភ្ជាប់ពីភ្នំពេញទៅកាន់ព្រំដែនវៀតណាមនេះ គឺមានចំងាយ២៥៧គីឡូម៉ែត្រ។ លោក ស៊ុន ចាន់ថុល បាននិយាយថា ផ្លូវដែកមួយខ្សែនេះនឹងត្រូវសាងសង់អស់ទឹកប្រាក់ប្រមាណជា៥០០លានដុល្លារ ហើយនៅពេលនេះប្រទេសកម្ពុជាកំពុងស្វះស្វែងរកជំនួយ។ *រស្មីកម្ពុជា អាទិត្យ-ចន្ទ ទី០៤-០៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រក៤។*

## សម្តេច ហ៊ុន សែន បន្ទោសលោកខាងលិច
## ចំពោះការដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើភូមា ចំណែកឡាវប្រឆាំងនឹងការដាក់ទណ្ឌកម្មនេះ

យោងតាមសេចក្តីរាយការណ៍របស់ទីភ្នាក់ងារព័ត៌មានរ៉យទ័រកាលពីថ្ងៃទី១៨ខែវិច្ឆិកាកន្លងទៅនេះបានអោយដឹងថា សម្តេច ហ៊ុន សែន និងនាយករដ្ឋមន្ត្រីឡាវ បានធ្វើការជំទាស់នឹងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចរបស់លោកខាងលិចទៅលើប្រទេសភូមា បន្ទាប់ពីអាជ្ញាធរប្រទេសនេះ បានធ្វើការបង្ក្រាបទៅលើបាតុកម្មដើម្បីលទ្ធិប្រជាធិបតេយ្យកាលពីខែកញ្ញាកន្លងទៅនេះ។

សម្តេច ហ៊ុន សែន បានលើកឡើងថា ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចគឺមិនល្អឡើយ។ បណ្តាមេដឹកនាំលោកខាងលិចនឹងមិនធ្វើអោយមេដឹកនាំភូមាស្លាប់នោះទេ ប៉ុន្តែវាបណ្តាអោយប្រជាជនប្រទេសនេះ នឹងជួបនូវមហន្តរាយដ៏ធំ។

ចំនែកលោក Bouasone Bouphavanh នាយករដ្ឋមន្ត្រីឡាវបានមានប្រសាសន៍ថា យើងមិនព្រមទទួលការដាក់ទណ្ឌកម្ម ឬការរាំងខ្ទប់សេដ្ឋកិច្ចប្រឆាំងនឹងប្រទេសភូមាឡើយ។

ការដាក់ទណ្ឌកម្មរបស់បណ្តាប្រទេសលោកខាងលិច ជាពិសេសសហរដ្ឋអាមេរិក បានកើតមានឡើងកាលពីខែតុលា នៅក្រោយពេលរបបដឹកនាំប្រទេសនេះបានបង្ក្រាបបាតុកម្មប្រជាធិបតេយ្យមួយ ដែលដឹកនាំដោយព្រះសង្ឃ ហើយបានសំលាប់ជីវិតមនុស្សអស់ចំនួន១៥នាក់។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រក២។*

## លោក ហោ ណាំហុង ស្នើប្រទេសសមាជិក CLMV រៀបចំគំរោងអភិវឌ្ឍន៍អោយបានសំរេច

លោក ហោ ណាំហុង បានស្នើបែបនេះកាលពីថ្ងៃទី១៨ ខែធ្នូឆ្នាំ២០០៧ ក្នុងឱកាសដែលលោកទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូឧត្តមមន្ត្រីរបស់ប្រទេសសមាជិក CLMV ក្នុងនោះមានលោក Sisouvong Sayakane មកពីប្រទេសឡាវ លោក Phae Thann Oo មកពីប្រទេសភូមា លោក Pham Hoang Mai មកពីវៀតណាម។

លោក ហោ ណាំហុង បានលើកឡើងនៅក្នុងជំនួបនោះថា ប្រទេសនិមួយៗនៃសសមាជិក CLMV ត្រូវជំរុញធ្វើយ៉ាងណារៀបចំគំរោងអភិវឌ្ឍន៍អោយបានសំរេចដើម្បីកសាងប្រទេសនិមួយៗរបស់ខ្លួនសំដៅឈានទៅធ្វើសមាហរណកម្មរួមគ្នាក្នុងតំបន់អាស៊ាននៅឆ្នាំ ២០១៥ ខាងមុខនេះ។

គណៈប្រតិភូខាងលើមកចូលរួមកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីនៃបណ្តាប្រទេសសមាជិក CLMV នៅទីក្រុងភ្នំពេញ។

ក្នុងឱកាសនោះដែរ លោក ហោ ណាំហុង បានបញ្ជាក់ផងដែរថា សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន បានកំនត់ថា នៅឆ្នាំ២០១៥ បណ្តាប្រទេសសមាជិកអាស៊ាននឹងធ្វើសមាហរណកម្មរួមគ្នា។ ដូច្នេះបើសិនជាឆ្នាំ ២០១៥នេះ យើងធ្វើសមាហរណកម្មអាស៊ានមិនបានទេ គឺការអភិវឌ្ឍន៍នោះគ្មានន័យអ្វីទាំងអស់។ ហេតុនេះស្នើបណ្តា ប្រទេសសមាជិក CLMV លើកឡើងនៅក្នុងរាល់វេទិកានានា ដូចជាកិច្ចប្រជុំ GMS កិច្ចប្រជុំ ACMECS និងកិច្ចប្រជុំ CLMV ដើម្បីអភិវឌ្ឍន៍អោយបានលឿនឆាប់រហ័ស។

ឥឡូវនេះប្រទេសជប៉ុនមានកញ្ចប់ជំនួយប្រមាណ២១លានដុល្លារអាមេរិក។ ដូចនេះ កិច្ចប្រជុំនៅភ្នំពេញនាពេល នេះ គឺជាការត្រៀមរៀបចំនូវគោលការណ៍នានាដើម្បីលើកឡើងក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ការបរទេសនៃប្រទេសសមាជិក CLMV ជាមួយរដ្ឋមន្ត្រីការបរទេសជប៉ុននៅទីក្រុងតូក្យូ នៅថ្ងៃទី១៦-១៧ ខែមករា ឆ្នាំ២០០៨ខាងមុខ។

*រស្មីកម្ពុជា ថ្ងៃពុធទី១៩ខែធ្នូឆ្នាំ២០០៧ ទំព័រក២។*

## ការបង្កើតសហគមន៍អាស៊ីខាងកើត : បញ្ញវ័ន្តវ័យក្មេង១៦ប្រទេសចូលរួមពិភាក្សានៅជប៉ុន

បញ្ញវ័ន្តវ័យក្មេងមកពីប្រទេស១៦នៅក្នុងតំបន់អាស៊ីខាងកើត បានពិភាក្សាគ្នានៅទីក្រុងតូក្យូដើម្បីជំនះភាពចំរុះ នៃវប្បធម៌និងសាសនានៅក្នុងតំបន់ ហើយឆ្ពោះទៅរកការបង្កើតអោយបានជាសហគមន៍អាស៊ី ខាងកើតមួយដែលរស់នៅ យ៉ាងល្អកល្អើននិងសន្តិភាពដោយមានការអភិវឌ្ឍន៍រួមគ្នា រយះពេល៣ថ្ងៃ ពីថ្ងៃទី១៤ដល់ថ្ងៃទី១៧ខែធ្នូឆ្នាំ២០០៧។

នៅក្នុងអំឡុងពេលនៃការពិភាក្សាក្នុងវេទិកាអន្តរជាតិ ក្រោមប្រធានបទ **សហគមន៍អាស៊ីខាងកើត : ការ សម្លឹងមើលហួសពីចំរុះភាពផ្នែកវប្បធម៌** ពួកគេបានធ្វើការពិភាក្សាយ៉ាងល្អិតល្អន់ ដើម្បីអោយស្គាល់វប្បធម៌ និងសាសនា គ្នាទៅវិញទៅមក ហើយពិនិត្យមើលរកចំនុចខុសគ្នាដើម្បីផ្តល់ការគោរពនិងទទួលស្គាល់ ភាពខុសគ្នានោះ។

នៅក្នុងតំបន់អាស៊ីខាងកើតនេះ មានសាសនាខុសៗគ្នាចំនួន៤ធំៗ គឺសាសនាព្រះពុទ្ធ(កម្ពុជា ឡាវ ថៃ ភូមា វៀតណាម ចិន កូរ៉េខាងត្បូង ជប៉ុន សិង្ហបុរី) អ៊ិស្លាម(ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប្រ៊ុយណេ) សាសនាគ្រិស្ត (ហ្វីលីពីន អូស្ត្រាលី ញូហ្សេឡែន) និងសាសនាហិណ្ឌូដែលគ្របដណ្តប់នៅឥណ្ឌា។ ម្យ៉ាងទៀតនៅតំបន់នេះ ក៏មានកាន់និន្នាការខុសគ្នាដែរ ដោយក្នុងនោះមានរបបប្រជាធិបតេយ្យ របបសង្គមនិយម របបគ្រប់គ្រងដោយយោធា និងរបបរាជានិយម។

ដំណើរការនៃការបង្កើតអោយមានសហគមន៍អាស៊ីខាងកើត គឺជាដំណើរដ៏លំបាកមួយដោយសារមិនទាន់យល់ ពីគ្នាអោយអស់នៅឡើយទាំងផ្នែកវប្បធម៌ សាសនា និងសង្គម ដែលមានចំនុចខុសគ្នាខ្លះនៅក្នុងតំបន់។

*រស្មីកម្ពុជា ថ្ងៃពុធទី១៩ខែធ្នូឆ្នាំ២០០៧ ទំព័រក៣។*

## កម្ពុជាគាំទ្របេសកម្មអង្គការសហប្រជាជាតិក្នុងការដោះស្រាយបញ្ហានៅមីយ៉ាន់ម៉ា

ខណៈជួបពិភាក្សាការងារជាមួយលោក Ibrahim Gambari បេសកជនពិសេសរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ នៅរសៀលថ្ងៃទី២៩ខែវិច្ឆិកានេះ លោក ហោ ណាំហុង បានបញ្ជាក់ពីជំហររបស់កម្ពុជាដូចបាន

លើកឡើងខាងលើ និងអបអរសាទរចំពោះជំហានទៅមុខរបស់មីយ៉ាន់ម៉ាក្នុងការដោះស្រាយបញ្ហាររវាងរដ្ឋាភិបាលមីយ៉ាន់ម៉ាជាមួយនឹងក្រុមប្រឆាំងរបស់លោកស្រី អ៊ុង សានស៊ូជី។

ប្រភពនៃជំនួបនេះបានអោយដឹងថា លោក Ibrahim បានផ្តល់នូវព័ត៌មាននូវរបាយការណ៍ខ្លីៗអំពីដំណើរទស្សនកិច្ចរបស់គាត់៤ដងរួមមកហើយនៅប្រទេសមីយ៉ាន់ម៉ា គឺ២ដងនៅឆ្នាំ២០០៦និង២ដងទៀតនៅឆ្នាំ២០០៧។

ភាគីជំនួបទាំងពីរបង្ហាញនូវភាពសុទិដ្ឋិនិយមចំពោះការវិវត្តសភាពការណ៍នៅមីយ៉ាន់ម៉ា ជាពិសេសតាមរយៈជំនួបពីរដងរវាងរដ្ឋមន្ត្រីក្រសួងការងារនៃរដ្ឋាភិបាលមីយ៉ាន់ម៉ាជាមួយលោកស្រី អ៊ុង សានស៊ូជី។ ភាគីទាំងពីរក៏បានឯកភាពគ្នាថា យើងមិនត្រូវនិយាយអំពីការដាក់ទណ្ឌកម្មទេ។

លោក Ibrahim មានគំរោងនិងទៅទស្សនកិច្ចនៅមីយ៉ាន់ម៉ាម្តងក្នុងអំឡុងឆ្នាំ២០០៧នេះ បន្ទាប់ពីលោកបានធ្វើដំណើរទៅទីនោះ២ដងរួចមកហើយក្នុង២០០៧នេះ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ទី០១ ខែធ្នូឆ្នាំ២០០៧ ទំព័រក២។*

## កម្ពុជា -ថៃបានចុះកិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ទិដ្ឋាការ ACMECS តែមួយ

លោក ហោ ណាំហុង និងលោក Nitya Pubulsonggram រដ្ឋមន្ត្រីក្រសួងការបរទេសថៃបានចុះហត្ថលេខាកាលពីថ្ងៃទី១៧ខែធ្នូ នៅលើកិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ទិដ្ឋាការ ACMECS តែមួយបន្ទាប់ ពីភាគីទាំងពីរបានជួបពិភាក្សាជាមួយគ្នាអស់រយៈពេលប្រមាណជាងមួយម៉ោងនៅទីស្តីការក្រសួងការបរទេសការបរទេស។

លោក ហោ ណាំហុង បានមានប្រសាសន៍ក្រោយការពិភាក្សានិងចុះហត្ថលេខាថា ការចុះហត្ថលេខានេះដើម្បីជំរុញទេសចរណ៍អោយបានកាន់តែច្រើនថែមទៀតរវាងប្រទេសកម្ពុជា-ថៃហើយរំពឹងថាទិដ្ឋាការ ACMECS គឺឈានទៅអនុវត្តសំរាប់៥ប្រទេស ប៉ុន្តែដោយសារតឡូវនេះប្រទេសកម្ពុជានិងប្រទេសថៃបានឯកភាពមុនគេទើបយើងចុះហត្ថលេខារវាងប្រទេសទាំងពីរសិន។ យើងសង្ឃឹមថាប្រទេសចំនួន៣ទៀត ដែលជាសមាជិកអង្គការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាយុទ្ធសាស្ត្រអាយេយ៉ាវ៉ាឌី ចៅប្រាយ៉ា មេគង្គ (ACMECS) នេះរួមមានប្រទេសឡាវ មីយ៉ាន់ម៉ា និងប្រទេសវៀតណាម ទៅអនាគតនឹងធ្វើយ៉ាងម៉េចអោយទៅជាប្រទេស៥ដែលមានទិសដៅតែមួយសំរាប់ភ្ញៀវទេសចរណ៍ ដោយប្រើប្រាស់ទិដ្ឋការ ACMECS តែមួយ។

លោក ហោ ណាំហុង បញ្ជាក់ថា ទិដ្ឋាការ ACMECS តែមួយនេះមានន័យថា បើអ្នកទេសចរណ៍ម្នាក់ទៅយកទិដ្ឋាការនៅប្រទេសថៃ គេអាចមកប្រទេសកម្ពុជាយើងដោយមិនបាច់យកទិដ្ឋាការនៅប្រទេសកម្ពុជាយើងទេ ផ្ទុយមកវិញករណីនេះអាចអនុវត្តន៏សំរាប់ករណីយកទិដ្ឋាការនៅកម្ពុជាវិញផងដែរ។ រីឯបញ្ហាលុយកាក់យើងទូទាត់គ្នាតាមក្រោយ។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី១៨ ខែធ្នូឆ្នាំ២០០៧ ទំព័រក២។*

## **លោក Ong Keng Yong ទទួលបានមេដាយកិត្តិយសពីកម្ពុជា**

លោក **Ong Keng Yong** អគ្គលេខាធិការអាស៊ានត្រូវបានបំពាក់មេដាយសហមេត្រីថ្នាក់ធិបឌិន នៃព្រះរាជាណាចក្រកម្ពុជា ដោយលោក ហោ ណាំហុង កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ នៅក្រសួងការបរទេស ដើម្បីឆ្លើយតបចំពោះការកដឹកនាំប្រកបដោយជោគជ័យ និងការចូលរួមវិភាគក្នុងសមាគមអាស៊ាន ក៏ដូចជាការបញ្ចប់អាណត្តិរយៈពេល៥ឆ្នាំរបស់លោកនៅលេខាធិការដ្ឋានអាស៊ាន។

លោក Ong Keng Yong បានសំដែងនូវចំណាប់អារម្មណ៍ថា បច្ចុប្បន្ននេះប្រមុខរដ្ឋប្រមុខរដ្ឋាភិបាលអាស៊ានទាំងអស់មានភាពសកម្មណាស់ហើយភារកិច្ចអាស៊ានទៅអនាគត នឹងត្រូវធ្វើពង្រាងផែនការគោលចំនួនពីរទៀតដែលទាក់ទងទៅនឹងការបង្កើតគណៈកម្មការសន្តិសុខអាស៊ាន។

នៅថ្ងៃដដែល ក្រោយពីបំពាក់មេដាយរួចមក លោក Ong Keng Yong បានត្រូវអនុញ្ញអោយចូលជួបសំដែងការគួរសមជាមួយសម្តេច ហ៊ុន សែន ផងដែរ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី១៥ខែធ្នូឆ្នាំ២០០៧ ទំព័រក២។*

## **កំណែទំរង់ច្បាប់នៅកម្ពុជាកំពុងស្ថិតនៅក្នុងវិថីមួយដ៏ត្រឹមត្រូវ**

លោក Joseph A. Mussomeli ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា បានមានប្រសាសន៍បែបនេះ ក្នុងឱកាសដែលលោកអញ្ជើញចូលរួមបើកសម្ពោធមជ្ឈមណ្ឌលអាមេរិកាំងមួយមានឈ្មោះថា : អាមេរិកាំង ខនណ័រ ខេមបូឌា (American Corner Cambodia) កាលពីថ្ងៃទី១២ខែធ្នូ។

លោកបានបន្ថែមទៀតថា កិច្ចការកំណែទំរង់ច្បាប់ជាដំណើរការវែងឆ្ងាយទៅមុខទៀត ប៉ុន្តែដំណើរការកំណែទំរង់ច្បាប់នេះកំពុងតែស្ថិតនៅក្នុងវិថីដ៏ត្រឹមត្រូវ។ *រស្មីកម្ពុជាថ្ងៃសៅរ៍ទី១៥ខែធ្នូឆ្នាំ២០០៧ ទំព័រក២។*

## **ព្រះមហាក្សត្រយាងសម្ពោធអគារស្នាក់ការកាកបាទក្រហមកម្ពុជា**

អគារដ៏ស្កឹមស្កៃនៃស្នាក់ការកណ្តាលថ្មីកាកបាទក្រហមកម្ពុជា ដែលដំណើរការសាងសង់អស់រយៈពេល១៧ខែ ចំណាយទឹកប្រាក់ជាង៣លានដុល្លារអាមេរិក ត្រូវបានប្រារព្ធព្រះរាជពិធីបើកសម្ពោធដាក់អោយប្រើប្រាស់កាលពីថ្ងៃទី១៥ខែធ្នូឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ពិធីនេះក៏មានការអញ្ជើញចូលរួមផងដែរពីសំណាក់សម្តេច ហ៊ុន សែន លោក ជំទាវ ប៊ុន រ៉ានីហ៊ុន សែន លោក Tadaterukonoe អនុប្រធានសហព័ន្ធអន្តរជាតិ ទទួលបន្ទុកកិច្ចការអាស៊ីប៉ាស៊ីហ្វិក រួមជាមួយប្រតិភូនៃសមាគមជាតិជាបងប្អូននិងដៃគូរសហប្រតិបត្តិការជាច្រើនរូបទៀត។

អគារទីស្នាក់ការកណ្តាលថ្មីនេះ ស្ថិតនៅដីឡូត៍លេខ១៦អា ផ្លូវលេខ៦៥២ តំបន់អូរបែកមក្អមក្នុងសង្កាត់ ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ *រស្មីកម្ពុជាថ្ងៃអាទិត្យ-ចន្ទទី១៦-១៧ខែធ្នូឆ្នាំ២០០៧ទំព័រក២។*

## កម្ពុជាទទួលការហោះហើរត្រង់ពីអឺរ៉ុបជាលើកដំបូង

ការហោះត្រង់នេះ បានធ្វើឡើងពីក្រុងស្តុកខូល ប្រទេសស៊ុយអ៊ែត និងឈប់សំចតចាក់សាំងនៅ ប្រទេសអារ៉ាប់ប៊ី អេមីរ៉ាត មុននឹងបន្តដំណើរមកកាន់ទីក្រុងភ្នំពេញ។ ដំណើរនេះរៀបចំដោយក្រុមហ៊ុនទេសចរណ៍ធំបំផុតរបស់ស៊ុយអ៊ែត ឈ្មោះ TUI NORDIC សហការជាមួយក្រុមហ៊ុនទេសចរណ៍កម្ពុជាឈ្មោះ DESTINATION ASIA ។

នេះជាការចុះចតលើដំបូងរបស់យន្តហោះដឹកអ្នកទេសចរណ៍មកពីសហគមន៍អឺរ៉ុបមកកម្ពុជា។ ការហោះហើរលើកដំបូងនេះនាំមកនៅភ្ញៀវប្រមាណ២១៥នាក់ ដែលក្នុងនោះភាគច្រើនគឺជាជនជាតិស៊ុយអ៊ែត និងមួយចំនួនទៀតជាដាណឺម៉ាក។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទទី០៩-១០ ខែធ្នូឆ្នាំ២០០៧ ទំព័រក៣ ។*

## រយៈពេល១៥ឆ្នាំ មន្ទីរពេទ្យគន្ធបុប្ផាចំណាយអស់២៥០លានដុល្លារ

មានប្រសាសន៍នៅក្នុងពិធីបើកសម្ពោធមន្ទីរពេទ្យគន្ធបុប្ផាទី៥ លោកសាស្រ្តាចារ្យ Beat Richner នាយកមន្ទីរពេទ្យគន្ធបុប្ផា បានមានប្រសាសន៍ថា មួយឆ្នាំៗមន្ទីរពេទ្យនេះគ្រប់សាខាទាំងអស់បានចំណាយ ចំនួន២៤លានដុល្លារលើការត្រួតពិនិត្យព្យាបាលកុមារក្នុងប្រទេសកម្ពុជា។

ពិធីបើកសម្ពោធមន្ទីរពេទ្យដែលសាងសង់អស់ទឹកប្រាក់ប្រមាណ៩លានដុល្លារនេះ មានការយាងចូលរួមពីព្រះករុណាសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រកម្ពុជា និងសម្តេច ហ៊ុន សែន។
*រស្មីកម្ពុជា ថ្ងៃសៅរ៍ទី២៩ខែធ្នូឆ្នាំ២០០៧ ទំព័រក២ ។*

## ២.ទំនាក់ទំនងកម្ពុជា និងបណ្ដាប្រទេសអាស៊ាន

### សម្ដេច ហ៊ុន សែន ត្រឡប់ពីចូលរួមកិច្ចប្រជុំកំពូលអាស៊ាននៅទីក្រុងសេប៊ូ

ប្រតិភូជាន់ខ្ពស់កម្ពុជា ដែលដឹកនាំដោយសម្ដេច ហ៊ុន សែន បានវិលត្រឡប់ពីកិច្ចប្រជុំកំពូលអាស៊ាន នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០៧ ។

លោក ហោ ណាំហុង ដែលអមដំណើរសម្ដេច ហ៊ុន សែន ទៅចូលរួមកិច្ចប្រជុំនេះបានថ្លែងថា ឯកសារដែលប្រមុខរដ្ឋាភិបាលប្រទេសអាស៊ានបានចុះហត្ថលេខា បានសង្កត់ធ្ងន់ទៅលើសេចក្ដីថ្លែងការណ៍ពីគំរោងធម្មនុញ្ញរបស់អាស៊ាន ដែលជាបញ្ហាដ៏សំខាន់មួយសំរាប់កំណត់នូវការឈានទៅមុខរបស់សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ។

សេចក្ដីថ្លែងការណ៍ទី២ ស្ដីពីបញ្ហាពលករចល័តរបស់អាស៊ានដែលចេញទៅធ្វើការពីប្រទេសមួយទៅប្រទេសមួយនៅក្នុងអាស៊ាន ។ សេចក្ដីថ្លែងការណ៍ទី៣ ស្ដីពីសហគមន៍អាស៊ានប្រឆាំងនឹងភេរវកម្ម ។

ចំណែកឯកសារ២ដែលរដ្ឋមន្ត្រីការបរទេសអាស៊ានបានចុះហត្ថលេខានោះគឺអនុញ្ញាតអោយប្រទេសបារាំងចូលក្នុងសន្ធិសញ្ញាមិត្តភាពសហប្រតិបត្តិការអាស៊ាន( ជាឯកសារមូលដ្ឋានរបស់អាស៊ានក្នុងការទំនាក់ទំនងរវាងអាស៊ាននិងប្រទេសក្នុងតំបន់ដើម្បីរក្សាសន្តិភាព សន្តិសុខនិងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក) ហើយសហគមន៍អឺរ៉ុបដែលមានប្រទេសជាសមាជិកចំនួន២៧នោះបានសំរេចថានឹងចូលរួមក្នុងសន្ធិសញ្ញាមិត្តភាពសហប្រតិបត្តិការអាស៊ាន ។

លោក ហោ ណាំហុង ក៏បានថ្លែងអោយដឹងផងដែរថា ប្រទេសចិនបានសន្យាអោយប្រទេសកម្ពុជាខ្ចី ១០០ លានដុល្លារអាមេរិកសំរាប់កសាងផ្លូវលេខ ១០ ពីបាត់ដំបងទៅប៉ៃលិន កសាងស្ពានតាខ្មៅ និងផ្លូវជាតិសំខាន់ៗមួយចំនួនទៀត ។

ជាមួយនេះ ជប៉ុនបានត្រៀមលុយចំនួន៥០លានដុល្លារជួយពង្រឹងទំនាក់ទំនងជប៉ុន-អាស៊ាន ដែលក្នុងនោះជប៉ុនត្រៀមលុយ៤០លានដុល្លារសំរាប់ជួយដល់ប្រទេសកម្ពុជា ឡាវ វៀតណាម និងមីយ៉ាន់ម៉ា ហើយក្នុងនោះ ២០ លានដុល្លារសំរាប់អភិវឌ្ឍន៏ត្រីកោណ កម្ពុជា ឡាវ វៀតណាម ដែលជាតំបន់ក្រខ្សត់ ។ ជប៉ុនបានសន្យាថា ផ្ដល់ជំនួយផ្លូវការបន្ថែមដល់កម្ពុជា ឡាវ វៀតណាម ក្នុង៣ឆ្នាំខាងមុខទៀត ។

នៅក្នុងកិច្ចប្រជុំនោះ ប្រទេសកូរ៉េខាងត្បូង បានសន្យាផ្ដល់ ១០ លានដុល្លារអាមេរិក ពីឆ្នាំ២០០៧ ដល់២០១០ សំរាប់អាស៊ាន ។

លោក ហោ ណាំហុង បានបន្តថា ក្រៅពីកិច្ចប្រជុំកំពូលខាងលើ ក៏នៅមានកិច្ចប្រជុំកំពូលជាច្រើនទៀត ដូចជាកិច្ចប្រជុំកំពូលកម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ។ នៅក្នុងកិច្ចប្រជុំនោះ បានឯកភាពគ្នាធ្វើផែនការសកម្មភាពថ្មីឡើងវិញដែលមានវិស័យ៤ គឺទេសចរណ៍និងដឹកជញ្ជូន កសិ-ឧស្សាហកម្ម ថាមពល វិនិយោគពាណិជ្ជកម្ម វិទ្យាសាស្ត្រព័ត៌មាន និងអភិវឌ្ឍន៏ធនធានមនុស្ស ។ ហើយកម្ពុជាត្រូវបានធ្វើជាប្រធានផ្នែកទេសចរណ៍ ។ *កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៧ ។*

## ប្រទេសអាស៊ានទាំង១០ចុះអនុស្សរណៈលើការតភ្ជាប់បណ្តាញអគ្គសនី

រដ្ឋមន្រ្តីថាមពលនៃបណ្តាប្រទេសអាស៊ានទាំង១០ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការតភ្ជាប់បណ្តាញហេដ្ឋារចនាសម្ព័ន្ធអគ្គសនីទៅវិញទៅមកក្នុងតំបន់អាស៊ាន។

ការចុះហត្ថលេខាលើអនុស្សរណៈនេះ បានធ្វើឡើងនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្រ្តីថាមពលអាស៊ានលើកទី២៥ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២០ ដល់២៣ខែសីហា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរី។

ការជំរុញការប្រើប្រាស់អគ្គសនីក្នុងតំបន់អាស៊ានអោយមានប្រសិទ្ធភាព សុវត្ថិភាព និងចីរភាពនោះ រដ្ឋមន្រ្តីថាមពលនៃបណ្តាប្រទេសអាស៊ានទាំង១០ ក៏បានឯកភាពគ្នាលើការបង្កើតអនុបណ្តាញមួយដែលប្រទេសមួយចំនួនក្នុងអាស៊ានមានគំរោងផលិតថាមពលអគ្គសនីដោយប្រើប្រាស់ថាមពលនុយក្លេអ៊ែរ។ ប៉ុន្តែយ៉ាងណាក៏ដោយ កិច្ចប្រជុំនោះក៏កំពុងតែមានការព្រួយបារម្ភអំពីគ្រោះមហន្តរាយនាពេលអនាគតដោយសារការប្រើប្រាស់ថាមពលនុយក្លេអ៊ែរនេះផងដែរ។

*រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី២៥ ខែសីហា ឆ្នាំ២០០៧ ទំព័រក៣។*

## សម្តេច ហ៊ុន សែន វិលត្រឡប់ពីប្រជុំកំពូលអាស៊ាន

សម្តេច ហ៊ុន សែន ព្រមទាំងគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣នៅប្រទេសសិង្ហបុរី បានធ្វើមាតុភូមិនិវត្តន៍មកដល់ប្រទេសវិញនៅថ្ងៃទី២២ ខែវិច្ឆកា ឆ្នាំ២០០៧ (អញ្ជើញទៅកាលពីថ្ងៃទី១៧ ខែវិច្ឆកា)។

លោក ហោ ណាំហុង ដែលអមដំណើរសម្តេច ហ៊ុន សែន ទៅចូលរួមនោះ បានថ្លែងថា បញ្ហាសំខាន់ក្នុងកិច្ចប្រជុំនោះរួមមាន : កំណត់យកឆ្នាំ២០១៥ ដើម្បីបង្កើតសហគមន៍អាស៊ានសំខាន់មួយ។ ហើយការបង្កើតសហគមន៍ អាស៊ាននោះ វាមានសសរទ្រូងចំនួន៣ : ទី១- សហគមន៍នយោបាយនិងសន្តិសុខរបស់អាស៊ាន ទី២-សហគមន៍សេដ្ឋកិច្ចអាស៊ាន និងទី៣- សហគមន៍វប្បធម៌និងសង្គមរបស់អាស៊ាន។

លោកបញ្ជាក់ថា ដើម្បីបង្កើតសហគមន៍អាស៊ាននេះបានតាមកាលកំណត់ ចាំបាច់ធ្វើសមាហរណកម្មអាស៊ានអោយបាន។ មានន័យថា ធ្វើយ៉ាងណាកុំអោយគម្លាតខាងការអភិវឌ្ឍន៍សេដ្ឋកិច្ច រវាងប្រទេសអាស៊ានថ្មី និងអាស៊ានចាស់មានគំម្លាតគ្នាឆ្ងាយពេក។ លោក ហោ ណាំហុង បានបន្ថែមទៀតថា នៅក្នុងបញ្ហានេះមានប្រទេសមួយចំនួនបានសំរេចផ្តល់ការឧបត្ថម្ភសំរាប់ការធ្វើសមាហរណកម្មអាស៊ាននេះ ដូចជាសិង្ហបុរីបានផ្តល់៣០លានដុល្លារសំរាប់ឆ្នាំ២០០៩-២០១១។ សហភាពអឺរ៉ុបបានសំរេចផ្តល់៣០លានអឺរ៉ូ និងកូរ៉េបានផ្តល់ចំនួន ៥ លានដុល្លារផងដែរ។

ដោយឡែកបញ្ហាដែលត្រូវយកចិត្តទុកដាក់ក្នុងនោះផងដែរ គឺការដែលអាស៊ានបានអនុម័តលើធម្មនុញ្ញអាស៊ានដែលជាលើកទី១របស់ប្រជាជាតិអាស៊ីអាគ្នេយ៍ ព្រោះធម្មនុញ្ញអាស៊ាននេះបានបង្កើតអោយមាននីតបុគ្គលរបស់អាស៊ាន

សំរាប់ការទាក់ទងនឹងអង្គការនានានៅលើឆាកអន្តរជាតិ។ បញ្ហាមួយទៀតនោះ គឺអាស៊ានបានបង្កើតនូវស្ថាប័នសិទ្ធិមនុស្ស មួយនៅក្នុងអាស៊ាន។

កិច្ចប្រជុំនេះ ក៏បានសំដែងនូវភាពសុទិដ្ឋិនិយមផងដែរពីបញ្ហាប្រទេសភូមា ដែលបានបង្ហាញនូវចេតនាដោះស្រាយ បញ្ហាចំរូងចំរាស់ផ្ទៃក្នុងរបស់ខ្លួន។

បញ្ហាមួយទៀត គឺបញ្ហាបរិស្ថាន ក៏ត្រូវបានលើកយកមកពិភាក្សាគ្នាផងដែរ ជាពិសេសបញ្ហាកើនកំដៅផែនដី។ ជាមួយនេះប្រទេសមួយចំនួនជាដៃគូរអាស៊ានដូចជា ឥណ្ឌាបានសំរេចផ្តល់នូវថវិកាចំនួន៥លានដុល្លារសំរាប់បង្កើតមូលនិធិ អាស៊ាន-ឥណ្ឌា ដែលហៅថាមូលនិធិបៃតង។ ប្រទេសជប៉ុនផ្តល់ ២.០០០ លានដុល្លារសំរាប់ការពារបរិស្ថានសំរាប់ទប់ ស្កាត់ការបំពុលបរិយាកាស ហើយសហគមន៍អឺរ៉ុបក៏បានប្រកាសថា ជួយ៩០លានអឺរ៉ូ សំរាប់ការពារបរិស្ថាន ដែលក្នុងនោះ ៣០លានអឺរ៉ូសំរាបអាស៊ាន។

កិច្ចប្រជុំក៏បានលើកឡើងពីការបង្កើតតំបន់សេដ្ឋកិច្ចសេរីជាមួយឥណ្ឌា និងអឺរ៉ុបផងដែរ។ ក៏ប៉ុន្តែសហគមន៍អឺរ៉ុប បានលើកឡើងអំពីការចាប់ផ្តើមជាមួយប្រទេសអាស៊ាន៧ លើកលែងតែកម្ពុជា ឡាវ វៀតណាម តែអាស៊ានបានប្រកាន់ ជំហរថា ត្រូវធ្វើក្នុងតំបន់ជារួមតែម្តង គឺអាស៊ានទាំង១០។

ជាមួយនេះ ក៏មានការលើកឡើងនូវបញ្ហាផ្សេងៗទៀត ដូច វិទ្យាសាស្ត្រពតិមាន និងមានការប្រជុំរវាងកម្ពុជា វៀតណាម ឡាវ និងជប៉ុន។

ជាលទ្ធផលក្នុងកិច្ចប្រជុំនេះ មានការចុះហត្ថលេខារវាងមេដឹកនាំអាស៊ាន និងបណ្តាមេដឹកនាំប្រទេសជាដៃគូរ អាស៊ានផ្សេងៗទៀត រួមមាន :

**១- កិច្ចប្រជុំកំពូលអាស៊ានលើកទី១៣**

- សេចក្តីថ្លែងការណ៍ស្តីពីផែនការគោលសហគមន៍សេដ្ឋកិច្ចអាស៊ាន
- សេចក្តីថ្លែងការណ៍ស្តពីនិរន្តរភាពបរិស្ថាន
- សេចក្តីថ្លែងការណ៍អាស៊ានស្តីពីសម័យប្រជុំលើកទី១៣នៃសន្និសីទភាគីអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជា ជាតិអំពីការប្រែប្រួលអាកាសធាតុ និងសន្និសីទលើកទី៣ របស់ភាគីនៃកិច្ចប្រជុំភាគីពិធីសារទីក្រុងក្យូតូ
- ធម្មនុញ្ញអាស៊ាន
- អនុម័តសេចក្តីថ្លែងការណ៍សិង្ហបុរីស្តីពីធម្មនុញ្ញអាស៊ាន

**២- កិច្ចប្រជុំជាមួយដៃគូរ អាស៊ានបូក៣ លើកទី១១**

- សេចក្តីប្រកាសរួមលើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការអាស៊ីបូព៌ា
- ផែនការងារកិច្ចសហប្រតិបត្តិការអាស៊ានបូក៣(២០០៧-២០១៧)

**៣- កិច្ចប្រជុំអាស៊ី-បូព៌ាលើកទី៣**

- ចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ ទីក្រុងសិង្ហបុរី ស្តីពីការប្រែប្រួលអាកាសធាតុ ថាមពលនិងបរិស្ថាន

**៤- កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍៣០ឆ្នាំ នៃទំនាក់ទំនងអាស៊ាន-អឺរ៉ុប**

- អនុម័តសេចក្តីប្រកាសរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍៣០ឆ្នាំនៃទំនាក់ទំនងអាស៊ាន-សហភាពអឺរ៉ុប ។

- ផែនការសកម្មភាពអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងនូរ៉ុមបឺក ក្នុងការលើកកំពស់ភាពជាដៃគូរអាស៊ាន-អឺរ៉ុប ។

**៥- ឯកសារបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេស**

- អនុស្សរណៈស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ាន-កូរ៉េ

**៦- ឯកសារដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ច**

- ពិធីសារអនុវត្តន៍កញ្ចប់នៃការសន្យាទី៦ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានផ្នែកសេវាកម្ម

- កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានសំរាប់ការទទួលស្គាល់គ្នាទៅវិញទៅមក ស្តីពីការស្រាវជ្រាវ

- កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមករបស់អាស៊ានស្តីពីសេវាកម្មស្ថាបត្យកម្ម

- កិច្ចព្រមព្រៀងពាណិជ្ជកម្មផ្នែកសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងកូរ៉េ

**៧- ឯកសារបានចុះហត្ថលេខាដោយអគ្គលេខាធិការអាស៊ានជាមួយភាគីចិន**

- អនុស្សរណៈរវាងអាស៊ាន-ចិន ស្តីពីយន្តការពង្រីកកិច្ចសហប្រតិបត្តិការអនាម័យភូតគាមអនាម័យ ។

*រស្មីកម្ពុជា ថ្ងៃសុក្រ ទី២៣ ខែវិច្ឆកា ឆ្នាំ ២០០៧ ទំព័រ២ ។*

## លោក ហោ ណាំហុង ទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី៨នៅប្រទេសអាល្លឺម៉ង់

លោក ហោ ណាំហុង បានអ្នកសារព័ត៌មានកាលពីថ្ងៃទី២៦ខែឧសភា មុនការអញ្ជើញទៅថា កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៨ដល់២៩ខែឧសភាឆ្នាំ២០០៧ នៅទីក្រុង Hamburg ប្រទេសអាល្លឺម៉ង់ ។

ដំណើរទៅកាន់ប្រទេសអាល្លឺម៉ង់នេះ តបតាមការអញ្ជើញរបស់លោក Frank Walter Steinmeier ប្រធានក្រុមប្រឹក្សាសហគមន៍អឺរ៉ុបនិងជារដ្ឋមន្ត្រីការបរទេសអាល្លឺម៉ង់ ។

លោកបានបញ្ជាក់អោយដឹងទៀតថា កិច្ចប្រជុំអាស៊ី-អឺរ៉ុប លើកទី៨ផ្តោតទៅលើបញ្ហាអន្តរជាតិជាច្រើន ដូចជាបញ្ហាអ៊ីរ៉ាក់ អ៊ីរ៉ង់ អាហ្វហ្កានីស្ថាន បញ្ហាផ្លាស់ប្តូរអាកាសធាតុ ។

បន្ទាប់ពីចូលរួមកិច្ចប្រជុំនេះ លោក ហោ ណាំហុង និងអញ្ជើញទៅកាន់ប្រ៊ុចសែលនៃប្រទេសបែលហ្ស៊ិក ដើម្បីធ្វើទស្សនកិច្ចនិងចូលរួមកិច្ចប្រជុំគណៈកម្មការចំរុះទ្វេភាគីកម្ពុជា-បែលហ្ស៊ិកពីថ្ងៃទី៣០ ដល់ថ្ងៃទី៣១ខែឧសភា ឆ្នាំ២០០៧ ។

*រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី២៩ខែឧសភាឆ្នាំ២០០៧ ទំព័រ២ ។*

## ប្រធានរដ្ឋវៀតណាមទស្សនកិច្ចនៅកម្ពុជា

លោក ង្វៀន មិញត្រៀត ប្រធានរដ្ឋវៀតណាម នឹងដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា រយៈពេល៣ថ្ងៃ ពីថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧ខាងមុខនេះ។

ទស្សនកិច្ចរបស់ប្រធានរដ្ឋវៀតណាមនេះ គឺជាការឆ្លើយតបតាមការអញ្ជើញរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រកម្ពុជា។

ប្រភពនៃដំណើរទស្សនកិច្ចនេះបានបញ្ជាក់អោយដឹងថាលោក ង្វៀន មិញត្រៀត នឹងចូលបង្គំគាល់ព្រះមហាក្សត្រកម្ពុជា អនុញ្ញាតអោយមានការសម្តែងការគួរសម ជាមួយសម្តេច ជា ស៊ីម សម្តេច ហេង សំរិន និងសម្តេច ហ៊ុន សែន។
*កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៧។*

## វៀតណាមថា ពាណិជ្ជកម្មជាមួយកម្ពុជាកើនឡើងដល់ ២.៤៥ ពាន់លានដុល្លារនៅឆ្នាំ២០១០

នាយកដ្ឋាននាំចេញនាំចូលនៃក្រសួងពាណិជ្ជកម្មវៀតណាមបានអះអាងថា ទំនាក់ទំនងពាណិជ្ជកម្មជាមួយកម្ពុជានឹងកើនឡើងរហូតដល់ទៅ ២.៤៥ ពាន់លានដុល្លារនៅក្នុងឆ្នាំ២០១០។ ចំណែកមន្ត្រីកម្ពុជាបានអះអាងអំពីការខិតខំពង្រីងការនាំចេញផលិតផលរបស់ខ្លួន។

យោងតាមទិន្នន័យដែលដកស្រង់ដោយទីភ្នាក់ងារព័ត៌មានវៀតណាម កាលពីថ្ងៃទី២៦ ខែកុម្ភៈ កន្លងទៅនេះបានអោយដឹងថា នៅក្នុងរយៈពេល៣ឆ្នាំខាងមុខនេះ ទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា និងវៀតណាម នឹងកើនឡើងរហូតដល់ ២៧ ភាគរយ ហើយមានតំលៃ ២.៤៥ ពាន់លានដុល្លារ នៅក្នុងនោះ ១.៩ ពាន់លានដុល្លារ គឺកម្ពុជានាំចូលទំនិញវៀតណាម ចំណែកកម្ពុជានាំចេញទៅវៀតណាមវិញនោះ គឺមាន ៥៤៥ លានដុល្លារ។

របាយការណ៍ក្រសួងពាណិជ្ជកម្មវៀតណាមអោយដឹងថា រហូតមកដល់ពេលនេះផលិតផលវៀតណាមនាំចូលមកក្នុងទីផ្សារនៅក្នុងប្រទេសកម្ពុជាមានច្រើនប្រភេទដូចជាប្រេងឥន្ធនៈ គ្រឿងហូបចុក ផលិតផលប្លាស្ទិក ដែក ជី សម្ភារៈគ្រឿងម៉ាស៊ីន និងគ្រឿងសំអាង។ ចំនែកទំនិញកម្ពុជាចូលទៅវៀតណាមវិញរួមមានផលិតផលចំបង គឺ កៅស៊ូ និងឈើ។

វៀតណាមជាប្រទេសទី៤ ដែលនាំចូលទំនិញមកកម្ពុជា បន្ទាប់ពីប្រទេសថៃ ប្រទេសចិន និងហុងកុង។
*កាសែត រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧។*

## ប្រធានរដ្ឋសភាវៀតណាមបញ្ចប់ទស្សនកិច្ចផ្លូវការនៅកម្ពុជា

គណប្រតិភូជាន់ខ្ពស់របស់រដ្ឋសភាវៀតណាមបានបញ្ចប់ដំណើរទស្សនកិច្ចជាផ្លូវការ បន្ទាប់ពីប្រតិភូដែលមានសមាជិកចំនួន ៤៤ រូប បានមកបំពេញទស្សនកិច្ចនៅកម្ពុជា ពីថ្ងៃទី២៥ ដល់ ២៨ ខែមេសា ឆ្នាំ២០០៧។

ក្នុងពេលទស្សនកិច្ចនៅកម្ពុជា លោក Nguyen Phu Trong ប្រធានរដ្ឋសភាវៀតណាម បានជួបសវនការជាមួយសម្តេច ជា ស៊ីម នឹងសម្តេច ហេង សំរិន ប៉ុន្តែប្រតិភូនេះមិនបានជួបជាមួយសម្តេច ហ៊ុន សែនទេ។

ប្រភពព័ត៌មានរដ្ឋសភាបានអោយដឹងថា នៅព្រឹកថ្ងៃទី២៦ ខែមេសា លោក Nguyen Phu Trong និងសម្តេច ហេង សំរិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការទ្វេភាគីរវាងស្ថាប័ននីតិបញ្ញត្តិកម្ពុជា-វៀតណាម។

កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានោះ គឺឯកភាពអោយមានការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់រដ្ឋសភានៃប្រទេសទាំងពីរអោយបានទៀតទាត់ ក៏ដូចជាគណៈកម្មការជំនាញទាំង៩ និងការពង្រឹងការងាររបស់អគ្គលេខាធិការដ្ឋានរដ្ឋសភានៃប្រទេសទាំងពីរផងដែរ។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី២៩ ខែមេសា ឆ្នាំ២០០៧ ទំព័រ២។*

## ឆ្នាំ២០០៧ វៀតណាមអាចនឹងទទួលបានវិនិយោគទុនពីបរទេស១០ពាន់លានដុល្លារ

ពួកអ្នកវិនិយោគទុនបរទេសធំៗមួយចំនួន កំពុងតែនាំគ្នាសំរុកចូលទៅរកស៊ីនៅប្រទេសវៀតណាម ដែលនៅក្នុងឆ្នាំ២០០៧នេះ អាចមានទឹកប្រាក់កើនឡើងរហូតដល់ជាង១០ពាន់លានដុល្លារ។

លោក Nguyen Chien Thang ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំកម្ពុជាបានបញ្ជាក់នៅថ្ងៃទី២៤ខែសីហាថា នៅឆ្នាំ២០០៦កន្លងទៅ វិនិយោគទុនបរទេសនៅប្រទេសវៀតណាមគឺមានចំនួន១០ពាន់លានដុល្លារ។ ប៉ុន្តែក្នុងរយៈពេល៦ខែដើមឆ្នាំ២០០៧នេះ ទុនវិនិយោគបរទេសនៅវៀតណាម គឺមានជាង៥ពាន់លានដុល្លារហើយ។

លោកឯកអគ្គរដ្ឋទូតបានបញ្ជាក់ថា ផ្អែកតាមតួរលេខដើមឆ្នាំ យើងអាចប៉ាន់ស្មានថា ឆ្នាំ២០០៧នេះវិនិយោគទុនបរទេសអាចមានចំនួនកើនពី១២ដល់១៣ពាន់លានដុល្លារ។ ជាមួយនេះលោកក៏បានលើកបង្ហាញពីមូលហេតុសំខាន់ក្នុងការធ្វើអោយមានកំណើននេះផងដែរ នោះគឺមកពីកត្តាសំខាន់៣យ៉ាង រួមមាន : ទី១- ប្រទេសវៀតណាមសព្វថ្ងៃ កំពុងតែធ្វើខ្លួនអោយប្រែក្លាយទៅជាទីផ្សារមួយសំរាប់អូសទាញអ្នកវិនិយោគទុនបរទេស។ ទី២- វៀតណាមបានបង្ហាញពីលទ្ធភាពក្នុងការដោះស្រាយនូវរាល់បញ្ហាដែលជាប់ពាក់ព័ន្ធជាមួយនឹងអ្នកវិនិយោគអោយមានលទ្ធផលជាក់ស្តែង។ ទី៣- ការពារនិងធានាបរិយាកាសសំរាប់អ្នកដែលចូលមកវិនិយោគទុន និងធ្វើអោយមានស្ថិរភាពតំលៃលើទីផ្សារប្រទេសវៀតណាម។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី២៦-២៧ ខែសីហា ឆ្នាំ២០០៧ ទំព័រ៨។*

## ប្រធានាធិបតីឡាវ ពិភាក្សាបញ្ហាព្រំដែនជាមួយមេដឹកនាំកម្ពុជា

ប្រធានាធិបតីឡាវដែលបំពេញទស្សនកិច្ចនៅកម្ពុជា បានពិភាក្សាអំពីបញ្ហាព្រំដែនជាមួយសម្តេច ហ៊ុន សែន។ ភាគីឡាវបាននិយាយថា ព្រំដែនកម្ពុជា-ឡាវ បានបោះបង្គោលរួចបានជាង៨០ភាគរយ ចំណែកសម្តេច ហ៊ុន សែន បានស្នើអោយប្រើប្រាស់ផែនទីខ្នាត១លើ១០០ពាន់ ដោះស្រាយព្រំដែននៃប្រទេសជិតខាងអាស៊ីអាគ្នេយ៍ទាំងពីរ។

ក្នុងពេលបំពេញទស្សនកិច្ចនៅកម្ពុជា លោក Choummaly Sayasone ប្រធានាធិបតីឡាវបានជួបជាមួយសម្តេច ជា ស៊ីម សម្តេច ហេង សំរិន សម្តេច ហ៊ុន សែន និងចូលបង្គំគាល់សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

កិច្ចការសំខាន់ក្នុងអំឡុងទស្សនកិច្ចនេះ រួមមាន : ការដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ ដោយការយោគយល់ សន្តិវិធី និងជាមិត្តភាពក្នុងនាមជាអ្នកភូមិផងរបងជាប់គ្នា និងការតភ្ជាប់បណ្តាញផ្លូវជាតិនៃប្រទេសទាំងពីរ។ ជាមួយនេះលោកប្រធានរដ្ឋឡាវក៏បានជួបសំណេះសំណាលជាមួយសហគមន៍ឡាវនៅកម្ពុជា និងទស្សនាប្រាសាទអង្គរវត្ត។
*រស្មីកម្ពុជា ថ្ងៃពុធ ទី០៨ ខែសីហា ឆ្នាំ២០០៧ ទំព័រក២។*

## កម្ពុជា-ឡាវ ឯកភាពលើបញ្ហាជាច្រើនក្នុងកិច្ចប្រជុំគណៈកម្មាធិការចំរុះ

ប្រភពព័ត៌មានពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានអោយដឹងនៅថ្ងៃទី១១សីហា ឆ្នាំ២០០៧ នេះថា កិច្ចប្រជុំគណៈកម្មាធិការនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវលើកទី១០ ដែលប្រព្រឹត្តទៅនៅក្រុងទីក្រុងព្រះសីហនុ កាលពីថ្ងៃទី០៩-១០ ខែសីហា បានព្រមព្រៀងគ្នាចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំ ដែលក្នុងនោះភាគីទាំងពីរបានឯកភាពគ្នាលើបញ្ហាជាច្រើនវិស័យ។

កិច្ចប្រជុំនេះដឹកនាំដោយលោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង និងលោកឧបនាយករដ្ឋមន្ត្រី Thongloun Sisoulith រដ្ឋមន្ត្រីការបរទេសឡាវ។

ប្រភពខាងលើបានបញ្ជាក់ថា កិច្ចប្រជុំនេះបានសំរេច និងឯកភាពគ្នាលើបញ្ហាមួយចំនួនដូចជា : បញ្ហាព្រំដែន រៀបចំប៉ុស្តិ៍ត្រួតពិនិត្យច្រកព្រំដែន បញ្ហាឆ្លងកាត់ព្រំដែន ជំរុញវិស័យទេសចរណ៍ ពាណិជ្ជកម្ម កសិកម្ម ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ការជួញដូរអនុផលកសិកម្ម ធនធានធម្មជាតិ និងសត្វព្រៃគ្រប់ប្រភេទ។
*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី១២-១៣ ខែសីហា ឆ្នាំ២០០៧ ទំព័រក២។*

## នាយករដ្ឋមន្ត្រីភូមាបញ្ចប់ដំណើរទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា

លោកឧត្តមសេនីយ៍ ថេន សេន នាយករដ្ឋមន្ត្រីភូមា បានបញ្ចប់ទស្សនកិច្ចផ្លូវការនៅរាជធានីភ្នំពេញ នាល្ងាចថ្ងៃទី១ ខែធ្នូឆ្នាំ២០០៧។

ឧត្តមសេនីយ៍ ថេន សេន បានអញ្ជើញមកដល់ប្រទេសកម្ពុជា កាលពីព្រឹកថ្ងៃទី៣០ខែវិច្ឆកា ឆ្នាំ២០០៧។ ក្នុងការស្នាក់នៅព្រះរាជាណាចក្រកម្ពុជា លោកបានអញ្ជើញសម្តែងការគួរសមជាមួយសម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី សម្តេច ហេង សំរិន និងជួបប្រជុំទ្វេភាគីជាមួយសម្តេច ហ៊ុន សែន។

ក្នុងជំនួបប្រជុំទ្វេភាគី គឺផ្តោតសំខាន់ទៅលើការធ្វើកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម វិស័យទេសចរណ៍ និងពាណិជ្ជកម្ម។ ភូមាចង់អោយមានការហោះនាំភ្ញៀវទេសចរណ៍ពីក្រុងសៀមរាបរបស់កម្ពុជា ទៅកាន់ទីក្រុងបាហ្គានរបស់ភូមា។ ភាគីភូមាបានបង្ហាញបំណងចង់ជួយកម្ពុជាលើវិស័យកសិកម្ម លើការដាំ ដំណាំ និងឬស្សី។ ជាមួយនេះលោក ថេន សេន ក៏បានស្នើសុំកម្ពុជាជួយជំរុញវិស័យពាណិជ្ជកម្មបន្ថែមទៀត ព្រោះបច្ចុប្បន្នប្រទេសទាំងពីរមានការផ្លាស់ប្តូរ

ពាណិជ្ជកម្មត្រឹមតែ២០០ពាន់ដុល្លារប៉ុណ្ណោះ។ លោក ថេន សេន ក៏ស្នើសុំរដ្ឋាភិបាលកម្ពុជាជួយជំរុញអ្នកវិនិយោគទៅរកស៊ីនៅប្រទេសភូមា ព្រោះភូមាមានសក្តានុពលច្រើន ដែលអាចធ្វើការវិនិយោគបាន។

ជាមួយនេះកម្ពុជាបង្ហាញជំហរក្នុងការគាំទ្រចំពោះចំណាត់ការដែលភូមាបានធ្វើចំពោះ លោកស្រី អ៊ុង សានស៊ូជី ដោយចាត់អោយមានការចរចាទៅទៀតដើម្បីផលប្រយោជន៍រួមរបស់ប្រទេសភូមា និងការស្វះស្វែងក្នុងការសាកល្បងធ្វើអន្តរជាតិតូបនីយកម្មលើបញ្ហាភូមានិងប្រឆាំងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងភូមា។

លោក ថេន សេន បានចាកចេញពីទីក្រុងភ្នំពេញ ក្រោមការជូនដំណើរពីសម្តេច ហ៊ុន សែន អមដោយកងកិត្តិយស កាលពីល្ងាចថ្ងៃទី០១ខែធ្នូ ដោយឆ្ពោះទៅខេត្តសៀមរាប ហើយលោកបានស្នាក់នៅ ទីនោះមួយថ្ងៃដើម្បីទស្សនាប្រាសាទអង្គរវត្ត។ លោក ថេន សេន និងចាកចេញពីប្រទេសកម្ពុជានៅល្ងាច ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៧ ដោយធ្វើដំណើរនិវត្តន៍ទៅប្រទេសភូមាវិញ។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី០២-០៣ ខែធ្នូ ឆ្នាំ២០០៧ ទំព័រក២។*

## ៣-កម្ពុជា និងបណ្តាប្រទេសអឺរ៉ុប

### ទិវាសហភាពអឺរ៉ុប ថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៥០-២០០៧

**១- សហភាពអឺរ៉ុប : ដៃគូ និងអ្នកគាំទ្រស្នូលមួយសំរាប់អាស៊ាន**

សហភាពអឺរ៉ុបកំពុងផ្តល់ការគាំទ្រដល់ចលនារបស់អាស៊ាន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការប្រចាំតំបន់នៅអាស៊ីអាគ្នេយ៍ រួមទាំងការសំរេចចិត្តដើម្បីបង្កើតធម្មនុញ្ញអាស៊ានមួយដែលជារដ្ឋធម្មនុញ្ញសំរាប់សមាគមន៍អាស៊ាននិងមហិច្ឆតាដើម្បីបង្កើតទីផ្សាររួមមួយនៅឆ្នាំ២០១៥។ ចាប់តាំងពីឆ្នាំ២០០០មក គណៈកម្មការសហគមន៍អឺរ៉ុបបានសន្យាផ្តល់ជំនួយ ៨០លានអឺរ៉ូដល់កម្មវិធីសហប្រតិបត្តិការប្រចាំតំបន់អាស៊ីអាគ្នេយ៍។ គណៈកម្មការសហគមន៍អឺរ៉ុបកំពុងប្រឹងប្រែងធ្វើការជំរុញអោយក្រុមប្រឹក្សាសហភាពអឺរ៉ុបធ្វើការចរចារបង្កើតអោយមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយអាស៊ានដើម្បីបង្កើតពាណិជ្ជកម្មទ្វេភាគីជាមួយតំបន់នេះ។

**២- សហភាពអឺរ៉ុប : ដៃគូដ៏សំខាន់មួយសំរាប់កម្ពុជា**

សហភាពអឺរ៉ុបជាដៃគូមួយក្នុងចំណោមដៃគូធំជាងគេរបស់ប្រទេសកម្ពុជា បើគិតពីជំនួយឥតសំណងសំរាប់ការអភិវឌ្ឍន៍ ក៏ដូចជាដៃគូមួយក្នុងចំណោមដៃគូពាណិជ្ជកម្មសំខាន់បំផុតរបស់ប្រទេសកម្ពុជាផងដែរ។ ជំនួយរបស់សហភាពអឺរ៉ុបគាំទ្រដល់គ្រប់វិស័យជាយុទ្ធសាស្ត្រ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិរបស់អភិបាលកិច្ចសិទ្ធិមនុស្ស និងការបោសសំអាតមីន។ នៅក្នុងឆ្នាំ២០០៧ ទឹកប្រាក់ ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់សហភាពអឺរ៉ុបដែលបានផ្ទេរមកអោយប្រទេសកម្ពុជាមានប្រមាណ១៤៤លានអឺរ៉ូ ឬច្រើនជាង១៩០លានដុល្លារអាមេរិក។

ដើម្បីរួមវិភាគទានចំពោះការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា កម្មវិធីចង្អុលបង្ហាញសំរាប់ ឆ្នាំ២០០៧-២០១០ របស់គណៈកម្មការសហគមន៍អឺរ៉ុប (EC Multi-Annual Indicative Programme-MIP) ត្រូវបានធ្វើអោយស្របគ្នាទាំងស្រុងជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិ(NSDP) នៃរាជរដ្ឋាភិបាលកម្ពុជា។ ដោយមានទឹកប្រាក់បំរុងទុក៧៧លានអឺរ៉ូ កម្មវិធី MIP និងផ្តោតលើសកម្មភាពជាគន្លឹះចំនួនពីរ (ការគាំទ្រដល់NSDP និងការគាំទ្រដល់ការអប់រំជាមូលដ្ឋាន) បន្ថែមលើសកម្មភាពស្នូលទាំងពីរនេះ គណៈកម្មាការសហគមន៍អឺរ៉ុបនៅមានការគាំទ្រទៅលើសកម្មភាពផ្សេងៗ ទៀតរួមមានជំនួយទាក់ទងនឹងពាណិជ្ជកម្មនិងកិច្ចសហប្រតិបត្តិការ និងការចរចារវាងគណៈកម្មាការសហគមន៍អឺរ៉ុប ដើម្បីបង្កើនប្រសិទ្ធិភាពជំនួយដែលបានអនុម័តនៅក្នុងខែធ្នូឆ្នាំ២០០៧ បានគូសបញ្ជាក់ពីគោលការណ៍នានាដើម្បីបង្កើនសុខុដុមនីយកម្មក្នុងចំណោមដៃគូរអភិវឌ្ឍន៍របស់សហភាព អឺរ៉ុបនៅក្នុងប្រទេសកម្ពុជា។

*រស្មីកម្ពុជា ថ្ងៃពុធ ទី០៩ ខែឧសភា ឆ្នាំ២០០៧ ទំព័រ៨។*

**សហគមន៍អឺរ៉ុបនិងកម្ពុជាព្រមព្រៀងលើកម្មវិធីសហប្រតិបត្តិការដែលមានទឹកប្រាក់៧៧លានអឺរ៉ូ**

អនុស្សរណៈនៃការយោគយល់មួយស្តីពីកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍បានត្រូវចុះហត្ថលេខា កាលពីថ្ងៃទី២៩ ខែមិថុនានេះ ដោយលោក អ៊ុច បូរិទ្ធ រដ្ឋមន្ត្រីស្តីទីក្រសួងការបរទេស និងលោក Winston MC COlgan ភារៈធារីនៃប្រតិភូគណៈកម្មការសហគមន៍អឺរ៉ុបប្រចាំកម្ពុជា។

នៅក្នុងអនុស្សរណៈនេះ គណៈកម្មការសហគមន៍អឺរ៉ុបបានសន្យាផ្តល់ទឹកប្រាក់ចំនួន៧៧លានអឺរ៉ូនៅក្នុងកម្មវិធីផ្តល់មូលនិធិសហប្រតិបត្តិការទ្វេរភាគីសំរាប់កម្ពុជាពីឆ្នាំ ២០០៧-២០១០។

លោក អ៊ុច បូរិទ្ធ បានមានប្រសាសន៍ថា កម្មវិធីសូចនាករចំរុះប្រចាំឆ្នាំ ២០០៧-២០១០ ដែលមានទឹកប្រាក់ចំនួន ៧៧លានអឺរ៉ូនេះផ្តោតទៅលើ : ទី១-ឧបត្ថម្ភគំរោងអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិឆ្នាំ២០០៦-២០១០។ ទី២- វិស័យអប់រំ។ ទី៣- ជំនួយដែលទាក់ទងផ្នែកពាណិជ្ជកម្ម និងទី៤- ការឧបត្ថម្ភដល់កិច្ចសហប្រតិបត្តិការរវាង គណៈកម្មការសហគមន៍អឺរ៉ុបនិងកម្ពុជា និងឧបត្ថម្ភដល់កិច្ចសន្ទនាដែលទាក់ទងផ្នែកអភិបាលកិច្ចនិងសិទ្ធិមនុស្ស។

គណៈកម្មការសហគមន៍អឺរ៉ុប បានអះអាងបន្តដើរតួនាទីសកម្មខ្លួនក្នុងវិស័យអប់រំ ដោយ៤០ភាគរយនៃមូលនិធិសរុបនេះ( ប្រហែល៣០,៨លានអឺរ៉ូឬប្រមាណ៤១លានដុល្លារអាមេរិក) ផ្តល់សំរាប់ការគាំទ្រដល់ក្រសួងអប់រំអោយសំរេចគោលដៅរបស់ខ្លួនក្នុងការផ្តល់ការអប់រំជាមូលដ្ឋាន។ ថវិកា៣៥ភាគរយ( ប្រហែល២៧លានអឺរ៉ូឬប្រមាណ៣៦លានដុល្លារអាមេរិក) នឹងត្រូវផ្តល់គាំទ្រថវិកាទូទៅសំរាប់រដ្ឋាភិបាលក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ(NSDP)។ មូលនិធិនៅសល់ចំនួន២៥ភាគរយនឹងត្រូវផ្តល់សំរាប់សកម្មភាពថ្មីៗនៅក្នុងវិស័យជំនួយ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម អភិបាលកិច្ច និងសិទ្ធិមនុស្ស។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ ច័ន្ទ ទី០១-០២ ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៤។*

## សហភាពអឺរ៉ុបផ្តល់ទឹកប្រាក់ចំនួន១០លានដុល្លារ សំរាប់ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅកម្ពុជា

គណៈកម្មការសហគមន៍អឺរ៉ុបដែលជាស្ថាប័នប្រតិបត្តិរបស់សហភាពអឺរ៉ុបនឹងផ្តល់ទឹកប្រាក់ប្រមាណ ៧,៤ លានអឺរ៉ូ ( ប្រមាណ១០លានដុល្លារអាមេរិក) ដើម្បីជួយដល់កម្ពុជាក្នុងការរៀបចំតាក់តែងគោលនយោបាយពាណិជ្ជកម្មរបស់ខ្លួន ដើម្បីពង្រីកការអភិវឌ្ឍន៍សេដ្ឋកិច្ច អោយមានការរីកចំរើន និងជួយដល់ការកាត់បន្ថយភាពក្រីក្រអោយបានច្រើនជាអតិបរមាផងដែរ។

តាមសេចក្តីប្រកាស កាលពីថ្ងៃទី០៦ ខែកក្កដា បាននិយាយថា គំរោងរយៈពេល៤ឆ្នាំដែលមានឈ្មោះថា : **កម្មវិធីគាំទ្ររបស់គណៈកម្មការសហគមន៍អឺរ៉ុបដល់ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅកម្ពុជា** នឹងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តនូវគោលនយោបាយពាណិជ្ជកម្មកាន់តែសព្វមុខនិងស៊ីសង្វាក់គ្នាដើម្បីរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាពនិងទូលំទូលាយ និងដើម្បីឈានទៅដល់ការសំរេចទិសដៅដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ(NSDP)របស់ខ្លួន។

គំរោងនេះរួមមាន២សមាសភាគ ដែលមានទិសដៅដើម្បីពង្រឹងនូវរចនាសម្ព័ន្ធពាក់ព័ន្ធនៃស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ដែលរួមមានក្រសួងពាណិជ្ជកម្ម និងនាយកដ្ឋានពន្ធដា។

ទឹកប្រាក់សរុបសំរាប់ការអនុវត្តន៏គំរោងនេះមានប្រមាណជា ៨,៣លានអឺរ៉ូ ដែលក្នុងនោះគណៈកម្មការសហគមន៏អឺរ៉ុបនឹងផ្តល់ថវិកាចំនួន ៧,៤ លានអឺរ៉ូ ហើយស្ថាប័នផ្តល់ជំនួយផ្សេងៗទៀតនឹងផ្តល់ ថវិកាប្រមាណជា ៩០០.០០០ អឺរ៉ូ ។
*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី០៨-០៩ ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៤ ។*

## កម្ពុជា-សហគមន៏អឺរ៉ុប ពិភាក្សាគ្នាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទ្វេភាគី និងអាស៊ាន-អឺរ៉ុប

លោក ហោ ណាំហុង បានទទួលជួបកាលពីរសៀលថ្ងៃទី១៧ខែកញ្ញនេះ ជាមួយលោកឯកអគ្គរដ្ឋទូត Fridrech Humberger ប្រធានគណៈប្រតិភូនៃគណៈកម្មការសហគមន៏អឺរ៉ុប ដើម្បីពិភាក្សាលើការងារមួយចំនួនផ្តោតលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌកម្ពុជា-សហគមន៏អឺរ៉ុប និងរវាងអាស៊ាន-សហគមន៏អឺរ៉ុប ។

លោក កៅ គឹមហួន រដ្ឋលេខាធិការក្រសួងការបរទេសបានអោយដឹងថា ទាក់ទងនឹងកិច្ចសហប្រតិបត្តិការរវាងអាស៊ាន-សហគមន៏អឺរ៉ុប មាន២ចំណុច គឺទី១- ការត្រៀមប្រជុំកំពូលអាស៊ាន-សហគមន៏អឺរ៉ុប នៅប្រទេសសិង្ហបុរីនាចុងខែវិច្ឆកាខាងមុខនេះ និងទី២- ជុំវិញរឿងធម្មនុញ្ញអាស៊ានដែលកំពុងមានការចរចាក្នុងចំណោមប្រទេសអាស៊ានទាំង១០ ។

ឆ្នាំនេះជាខួបលើកទី៣០នៃទំនាក់ទំនងរវាងអាស៊ាននិងសហគមន៏អឺរ៉ុប ដូច្នេះហើយបានជាគេត្រៀមរៀបចំកិច្ចប្រជុំកំពូលអនុស្សាវរីយ៏រវាងអាស៊ាន-សហគមន៏អឺរ៉ុប ។

ចំពោះកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-សហគមន៏អឺរ៉ុប ភាគីសហគមន៏អឺរ៉ុបចង់អោយមានការចុះហត្ថលេខាលើវិសោធនកម្មកិច្ចព្រមព្រៀងហិរញ្ញប្បទាន ហើយនៅពេលណាកម្ពុជាយើងចុះហត្ថលេខារួចហើយវានឹងផ្តលភាពងាយស្រួលដល់គណៈកម្មការសហគមន៏អឺរ៉ុបក្នុងការផ្តល់ជំនួយមកដល់ប្រទេសកម្ពុជាខាងកម្មវិធីអភិវឌ្ឍន៏ជនបទនៅបណ្តាខេត្តពាយព្យនៃប្រទេសកម្ពុជា ដូចជាខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ។ បន្ថែមពីលើនេះទៀត សហគមន៏អឺរ៉ុបក៏ស្នើអោយកម្ពុជាយើងធ្វើកិច្ចព្រមព្រៀងលើផ្នែកគយ ហើយលោក ហោ ណាំហុង ក៏យល់ព្រមលើបញ្ហានេះ ។
*រស្មីកម្ពុជា ថ្ងៃពុធ ទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៣ ។*

## ASEM ជ្រើសរើសកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាក្រៅផ្លូវការលើកទី៨ស្តីពីសិទ្ធិមនុស្ស

សិក្ខាសាលាដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះរៀបចំនេះ ក្រោមប្រធានបទ សេរីភាពក្នុងការបញ្ចេញមតិ ដែលសិក្ខាសាលានេះនឹងប្រព្រឹត្តទៅរយៈពេល៣ថ្ងៃ( ថ្ងៃទី២៦ដល់២៨ខែកញ្ញា ឆ្នាំ២០០៧) នៅខេត្តសៀមរាប ។ សម្តេច ហ៊ុន សែន នឹងអញ្ជើញជាអធិបតីក្នុងពិធីបើសិក្ខាសាលានេះ ។

នេះជាព្រឹត្តការណ៏នយោបាយថ្មីមួយទៀតសំរាប់កម្ពុជា ដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាអន្តរជាតិមួយដែលមានប្រទេសចំនួន៤៣ចូលរួម ដែលក្នុងនោះមាន ប្រទេសអឺរ៉ុបចំនួន២៧ប្រទេស និងមកពីអាស៊ី១៦ប្រទេស ព្រមទាំងអ្នកសង្កេតការណ៏មកពីគណៈកម្មការអឺរ៉ុបនិងលេខាធិការដ្ឋានអាស៊ានមួយចំនួនទៀត ដែលមានចំនួនមនុស្សប្រមាណចំនួន១២០នាក់ ។

សិក្ខាសាលាក្រោមប្រធានបទ សេរីភាពក្នុងការបញ្ចេញមតិ និងពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់និងនយោបាយស្តីពីសេរីភាពក្នុងការបញ្ចេញមតិ និងបែបបទតួនាទីទំនាក់ទំនងរវាងរដ្ឋនិងសង្គម កំពុងតែត្រូវបានបន្តពិភាក្សារវាងអាស៊ីន-អឺរ៉ុបនិងកំណត់អំពីនិន្នាការផលលំបាក និងកាលានុវត្តភាព ហើយឈរលើមូលដ្ឋានទាំងនេះ បង្កើតនូវផែនការទិសដៅអនាគត សំរាប់អនុវត្តសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងតំបន់អាស៊ី-អឺរ៉ុប ក៏ដូចជាពិភពលោកទាំងមូលជាពិសេសចំពោះការអភិវឌ្ឍន៍ដ៏លឿននៃបច្ចេកវិជ្ជាទូរគមនាគមន៍និងព័ត៌មាននិងរៀបចំគោលនយោបាយ តាមរយៈកិច្ចពិភាក្សារវាងអាស៊ី-អឺរ៉ុបនិងកិច្ចប្រជុំអាស៊ី-អឺរ៉ុប(ASEM)។ សិក្ខាសាលា ASEM បែបនេះ បានចាប់ផ្តើមធ្វើឡើងតាំងពីឆ្នាំ១៩៩៧មក ក្រោមការលើកឡើងរបស់ប្រទេសស៊ុយអែតនិងប្រទេសបារាំង នាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ី-អឺរ៉ុបនៅប្រទេសសិង្ហបុរី។

លើកទី១នៃកិច្ចប្រជុំនេះធ្វើឡើងនៅប្រទេសស៊ុយអែតនៅខែធ្នូឆ្នាំ១៩៩៧ ក្រោមប្រធានបទ ការទទួលបានយុត្តិធម៌ចំណុចពិសេសរបស់ជាតិ និងតំបន់ក្នុងការគ្រប់គ្រងផ្នែកយុត្តិធម៌ និងការលើកកំពស់គ្រប់គ្រងផ្នែកយុត្តិធម៌។ ហើយលើកទី៧ ធ្វើនៅប្រទេសហុងគ្រីនៅក្នុងខែកុម្ភៈឆ្នាំ២០០៦ ក្រោមប្រធានបទ សិទ្ធិមនុស្សនិងជនជាតិភាគតិច ភាសានិងសាសនានៃជនជាតិភាគតិច។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី២៣-២៤ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រ២។*

## សហភាពអឺរ៉ុបផ្តល់ជំនួយឥតសំណងគាំទ្រកម្មវិធីអភិវឌ្ឍន៍កម្ពុជា

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការផ្តល់ជំនួយឥតសំណង ដែលមានទឹកប្រាក់ចំនួន២៣.១លានអឺរ៉ូ ឬប្រមាណជា ៣៣.៣ លានដុល្លារអាមេរិកនេះ បានធ្វើកាលពីថ្ងៃទី២៨ខែវិច្ឆកាឆ្នាំ២០០៧ រវាងលោក គាត ឈន់ និងលោក Ragael Dochao Moreno ភារធារីនៃប្រតិភូគណៈកម្មការសហគមន៍អឺរ៉ុប។

ជំនួយឥតសំណងនេះ ដើម្បីគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ថ្នាក់ជាតិរបស់រដ្ឋាភិបាលជាកម្មវិធីដែលមានដៃគូរអភិវឌ្ឍន៍ច្រើន។ ជំនួយនេះនឹងប្រើសំរាប់ពង្រឹងសមត្ថភាពមន្ត្រីរាជរដ្ឋាភិបាល ហើយកាលពីពេលថ្មីៗនេះ ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានលើកម្មវិធីនេះជាហិរញ្ញប្បទានឥតសំណងចំនួន១៥លានដុល្លារអាមេរិក ហើយប្រទេសជប៉ុនបានជួយ ១000 លាយយ៉េនផងដែរ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ ទី២៩ ខែវិច្ឆកា ឆ្នាំ២០០៧ ទំព័រ៤។*

## គំរោងខ្សែក្រវ៉ាត់បៃតងរបស់អាល្លឺម៉ង់មានទឹកប្រាក់១២លានអឺរ៉ូ

អង្គការGTZរបស់រដ្ឋាភិបាលអាល្លឺម៉ង់ បានសំរេចចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគំរោងខ្សែក្រវ៉ាត់បៃតងនៅខេត្តសៀមរាបដែលមានទឹកប្រាក់ប្រមាណ១២លានអឺរ៉ូ (ប្រហែល១៧លានដុល្លារ) សំរាប់រយៈពេល៣ឆ្នាំ។

ពិធីចុះហត្ថលេខានេះធ្វើឡើងកាលពីថ្ងៃទី៧ខែធ្នូ ដែលចុះហត្ថលេខាដោយលោក ស៊ុំ មានិត ទីប្រឹក្សារដ្ឋាភិបាល និងលោក Juergen Sehilling ប្រធានអង្គការ GTZ ប្រចាំនៅប្រទេសកម្ពុជា និងក្រោមអធិបតីភាពរបស់លោក សុខ អាន និងលោកឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា។

លោក សុខ អាន បានចាត់ទុកគំរោងការនេះវាមានសារៈសំខាន់ណាស់ ព្រោះវាមានលក្ខណៈជាការកាត់បន្ថយភាពក្រីក្រផងនិងផ្សារភ្ជាប់ទៅការរីកចំរើន ដោយមិនគិតតែការរីកចំរើនផ្នែកសេដ្ឋកិច្ចមួយមុខនោះទេ តែបានគិតទៅដល់ការជំរុញធ្វើអោយជីវភាពរបស់ប្រជាជននៅជុំវិញខេត្តសៀមរាបអាចកសាងជីវភាពឈានឡើង តាមរយៈការដាំដុះបន្លែ បង្ការ ផ្លែឈើ ចិញ្ចឹមសត្វ ហើយដែលបញ្ហានេះរដ្ឋត្រូវមានផែនការច្បាស់លាស់ជួយបង្កលក្ខណៈអោយផលិតផលរបស់ពួកគាត់ត្រូវបានលក់នៅលើទីផ្សារ ឬសណ្ឋាគារធំៗក្នុងខេត្ត ឬលក់ដោយផ្ទាល់ទៅកាន់ភ្ញៀវទេសចរណ៍តែម្តង។
*រស្មីកម្ពុជា ថ្ងៃសៅរ៍ទី០៨ខែធ្នូឆ្នាំ២០០៧ ទំព័រក៣។*

## អាល្លឺម៉ង់ផ្តល់ជំនួយជាង ១ លានដុល្លារសំរាប់ដោះមីន

រដ្ឋាភិបាលអាល្លឺម៉ង់បានសំរេចផ្តល់ជំនួយដល់កម្ពុជាលើគំរោងគាំទ្រដល់កិច្ចសហប្រតិបត្តិការបោសសំអាតមីននៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យក្នុងទឹកប្រាក់ប្រមាណ ១.៥ លានដុល្លារអាមេរិក សំរាប់ឆ្នាំ២០០៧។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់និងទទួលជំនួយរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាល្លឺម៉ង់បានប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ រវាងលោក សុខ អាន និងលោក PIUS FISHER ឯកអគ្គរដ្ឋទូតអាល្លឺម៉ងប្រចាំនៅកម្ពុជា។

ទឹកប្រាក់ជាង១.៥លានដុល្លារ របស់រដ្ឋាភិបាលអាល្លឺម៉ង់នឹងត្រូវផ្តល់ជូនដល់អង្គភាពប្រតិបត្តិការដោះមីនទី៦នៅក្នុងខេត្តសៀមរាប និងខេត្តឧត្តរមានជ័យសំរាប់ឆ្នាំ២០០៧។

លោក សុខ អាន បានមានប្រសាសន៍ថា ចាប់ពីឆ្នាំ១៩៩២ មកដល់ឆ្នាំ ២០០៦ ក្រុមប្រតិបត្តិការដោះមីនរបស់ CMAC បានទទួលគ្រោះថ្នាក់រហូតដល់ស្លាប់ចំនួន៣នាក់និងរបួស៨៦នាក់។ ក៏ប៉ុន្តែនៅក្នុងឆ្នាំ២០០៧នេះមានគ្រោះថ្នាក់គួរអោយរន្ធត់និងសោកស្តាយជាទីបំផុតដែលអ្នកស្ម័គ្រចិត្តដោះមីនចំនួន៧នាក់បានបាត់បង់ជីវិតក្នុងពេលប្រតិបត្តិការដោះមីននៅក្នុងខេត្តបាត់ដំបងក្នុងពេលតែមួយ។

លោក សុខ អាន បានបន្ថែមទៀតថា គោលដៅរបស់កម្ពុជា គឺនៅឆ្នាំ២០១២ អោយអស់អ្នករងគ្រោះដោយមីន និងគ្រាប់មិនទាន់ផ្ទុះ និងនៅឆ្នាំ២០២០ធ្វើយ៉ាងណាអោយផលប៉ះពាល់ដែលកើតចេញពីមីនធ្លាក់ដល់កំរិតសូន្យ។

ដោយឡែកឆ្នាំ២០០៦នេះ អ្នករងរបួសដោយសារមីនមានចំនួនជាង៤៤០នាក់ ដែលប៉ុន្មានឆ្នាំមុននេះមានរហូតដល់៨០០នាក់ក្នុងមួយឆ្នាំ។ ជាមួយនេះលោកក៏បញ្ជាក់ផងដែរថា តាំងពីឆ្នាំ១៩៩៦មក រដ្ឋាភិបាលអាល្លឺម៉ង់បានផ្តល់ជំនួយសំរាប់វិស័យដោះមីននៅកម្ពុជាសរុបជិត៩លានដុល្លារ ដែលក្នុងនោះ៧.៤លានដុល្លារផ្តល់ជាទ្វេរភាគី និង១.៥លានដុល្លារតាមរយៈអង្គការ UNDP។ *កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧។*

## អាល្លឺម៉ង់ផ្តល់ជំនួយ៨លានដុល្លារសំរាប់បណ្តាញអគ្គិសនីនៅកំពត

ពិធីប្រគល់និងទទួលជំនួយនេះ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៧ រវាងលោក អូន ពន្ធមុនីរ័ត្ន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក Christran Richter នាយកតំបន់នៃធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

តាមសេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអោយដឹងថា កិច្ចព្រមព្រៀងផ្តល់ជំនួយសំរាប់អគ្គសនីជនបទនេះ គឺជាប្រាក់ជំនួយឥតសំណងរបស់រដ្ឋាភិបាលនៃសហព័ន្ធអាល្លឺម៉ង់ចំពោះប្រទេសកម្ពុជា ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាល្លឺម៉ង់-កម្ពុជា ឆ្នាំ២០០៥។

ប្រភពដដែលបានអោយដឹងថា នេះគឺជាជំហានទី២ហើយដែលសហព័ន្ធអាល្លឺម៉ងបានផ្តល់ជំនួយសំរាប់គំរោងអគ្គសនីភាវូនីយកម្មជនបទនៅខេត្តតាកែវ និងកំពត ដែលជំហានទី១ អាល្លឺម៉ងបានផ្តល់រួចហើយ តាមកិច្ចព្រមព្រៀងចុះហត្ថលេខាកាលពីថ្ងៃទី៩ខែកញ្ញាឆ្នាំ២០០៥។

ប្រាក់ជំនួយទាំងពីរលើកនេះ ផ្តល់អោយអគ្គសនីកម្ពុជាខ្ចីបន្តយកទៅសំរាប់អនុវត្តន៏គំរោងការអគ្គសនីជនបទ។
*រស្មីកម្ពុជា ថ្ងៃសុក្រ ទី២២ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក៤។*

## អាល្លឺម៉ង់ផ្តល់ជំនួយ១៤.៥លានអឺរ៉ូសំរាប់អនុវត្តគំរោងអភិវឌ្ឍន៍មួយចំនួន

ការផ្តល់ជំនួយលើកនេះ ជាផ្នែកមួយនៃការអនុវត្តន៏កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ អាល្លឺម៉ង-កម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេសឆ្នាំ២០០៥។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រគល់និងទទួលជំនួយនេះ បានធ្វើកាលពីថ្ងៃទី១៤ ខែមិថុនា រវាងលោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេសកម្ពុជា និងលោក Puis Fisher ឯកអគ្គរដ្ឋទូតអាល្លឺម៉ងប្រចាំកម្ពុជា។

កិច្ចព្រមព្រៀងផ្តល់ជំនួយ១៤.៥លានអឺរ៉ូនេះ គឺសំរាប់យកទៅអនុវត្តគំរោងមួយចំនួនដូចជា :

ទី១- គាំទ្រកំណែទម្រង់ការគ្រប់គ្រងដីធ្លី។ ទី២- កម្មវិធីអភិវឌ្ឍន៍ជនបទជំហានទី២ នៅតំបន់បឹងទន្លេសាប ទី៣- ការកំណត់គោលដៅ កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។ ទី៤- កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ជនបទ។ ទី៥- គាំទ្រកំណែទំរង់វិស័យសុខាភិបាល។ ទី៦- គាំទ្រសកម្មភាពយេនឌ័រ និងសិទ្ធិរបស់ស្ត្រី។ ទី៧- មូលនិធិសំរាប់ការសិក្សានិងជំនាញការ។ គំរោងទាំងនេះនឹងត្រូវអនុវត្តរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។
*រស្មីកម្ពុជា ថ្ងៃសុក្រ ទី១៤ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក៤។*

## លោក ហោ ណាំហុង ជួបសន្ទនាការងារជាមួយទូតអាល្លឺម៉ង់ រំលឹកជំនួយ និងពង្រីកកិច្ចសហប្រតិបត្តិការ

ជំនួបសន្ទនានេះ បានធ្វើឡើងកាលពីថ្ងៃទី១៤ខែសីហាឆ្នាំ២០០៧ នៅទីស្តីការក្រសួងការបរទេស រវាងលោក ហោ ណាំហុង និងលោក Frank Marcus MANN ដែលទើបត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ថ្មីប្រចាំកម្ពុជា។

ប្រភពនៃជំនួបនោះបានអោយដឹងថា ប្រទេសកម្ពុជានិងអាល្លឺម៉ង់បានភ្ជាប់ទំនាក់ទំនងការទូតឡើងវិញនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩២។ ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៣ កម្ពុជាបានទទួលជំនួយអភិវឌ្ឍន៍ពីភាគីអាល្លឺម៉ងសរុបចំនួន ១១៩.៩២២.000 ដុល្លារ ដើម្បីផ្គត់ផ្គង់ក្នុងវិស័យមួយចំនួនដូចជា ហេដ្ឋារចនាសម្ព័ន្ធជនបទ ការជំរុញអោយមានសហគ្រាសធុនតូច និងមធ្យម ផ្គត់ផ្គង់បណ្តាញអគ្គសនីពីខេត្តតាកែវទៅខេត្តកំពត ការគ្រប់គ្រងដីធ្លី សមភាពយេនឌ័រ និងការជំរុញនូវការគោរពសិទ្ធិស្ត្រី ការបណ្តុះបណ្តាលផែនការ សុខភាពបុគ្គលនិងគ្រួសារ កម្មវិធីអភិវឌ្ឍន៍ជនបទ វិមជ្ឈការ កំណែទំរង់សេដ្ឋកិច្ចទីផ្សារ និងការកំណត់ពិសេសដើម្បីជំរុញផ្នែកពាណិជ្ជកម្ម។

នៅក្នុងឆ្នាំ២០០៤ អាល្លឺម៉ង់បានផ្តល់ជំនួយមនុស្សធម៌ក្នុងការបោសសំអាតមីននៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ មានទឹកប្រាក់ចំនួន ៨៣៥.០០០ ដុល្លារអាមេរិក ។

នៅក្នុងឆ្នាំ២០០៥ អាល្លឺម៉ង់បានព្រមព្រៀង តាមរយៈធនាគារ គធី ផ្តល់ហិរញ្ញប្បទានសំរាប់កម្មវិធីកែលំអផ្លូវលេខ ៤ ដែលមានទឹកប្រាក់ចំនួន ៧.៦ លានអឺរ៉ូ។ ដោយឡែកក្នុងសន្និសីទអង្គការសហប្រជាជាតិនៅទីក្រុងញ៉ូយកអាល្លឺម៉ង់បានប្រកាសសន្យាផ្តល់ប្រាក់ចំនួន ២.៩ លានដុល្លារអាមេរិកសំរាប់សាលាក្តីខ្មែរក្រហម។

ប្រទេសអាល្លឺម៉ង់បានផ្តល់ថវិកាគាំទ្រការអនុវត្តន៍គំរោង **ការជំរុញវិស័យឯកជន** ដែលមានទឹកប្រាក់ចំនួន ៤.៤៨៩.០០០ អឺរ៉ូសំរាប់ឆ្នាំសារពើពន្ធ២០០៥ ដល់២០០៧ និងគំរោង **ការគាំទ្រវិជ្ជាការ និងវិសហមជ្ឈការ** ដែលមានទឹកប្រាក់ចំនួន ២.៤០០.០០០ អឺរ៉ូ សំរាប់ឆ្នាំសារពើពន្ធ២០០៥ដល់២០០៨។

ឆ្នាំ២០០៦ អាល្លឺម៉ង់បានផ្តល់ទឹកប្រាក់១៣លានអឺរ៉ូ សំរាប់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ដោយផ្តោតទៅលើការបណ្តុះបណ្តាលសុខភាព និងការអភិវឌ្ឍន៏ជនបទ។ ដោយឡែកនៅក្នុងកិច្ចពិគ្រោះយោបលនៅទីក្រុងភ្នំពេញ អាល្លឺម៉ង់បានសន្យាផ្តល់ជំនួយដល់កម្ពុជាចំនួន ២៨.១៩០.០០០ ដុល្លារអាមេរិក។

នៅឆ្នាំ២០០៧ ធនាគារអភិវឌ្ឍន៏អាល្លឺម៉ង់បានព្រមព្រៀងផ្តល់ហិរញ្ញប្បទានសំរាប់ការបញ្ជូនថាមពលអគ្គិសនីជនបទនៅភាគខាងត្បូងកម្ពុជា ដែលមានទឹកប្រាក់៦លានអឺរ៉ូ។ ទាក់ទងនឹងបច្ចេកទេស អាល្លឺម៉ង់បានផ្តល់ប្រាក់ចំនួន ១៤.៥ លានអឺរ៉ូ ដោយផ្តោតទៅលើវិស័យកំណែទំរង់សេដ្ឋកិច្ច និងអភិវឌ្ឍន៏ប្រព័ន្ធទីផ្សារ ការបណ្តុះបណ្តាលសុខភាព លទ្ធិប្រជាធិបតេយ្យ សង្គមស៊ីវិល រដ្ឋបាលសាធារណៈ និងអភិបាលកិច្ចល្អ មូលនិធិការសិក្សាជំនាញ គំរោងសហប្រតិបត្តិការបច្ចេកទេសថ្មី ឧបត្ថម្ភដល់ការទំរង់ការរៀបចំដីធ្លី ការកំណត់គោលដៅនិងផ្តល់អត្តសញ្ញាណផ្ទះសំបែងដែលងាយរងគ្រោះ។ ក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជាលើកទី១នៅទីក្រុងភ្នំពេញ អាល្លឺម៉ង់ក៏បានសន្យាផ្តល់ជំនួយដល់កម្ពុជាពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ ដែលមានទឹកប្រាក់សរុបចំនួន ៦០.០៧៣.៦៧៥ ដុល្លារអាមេរិក។

ក្រៅពីជំនួយដែលបានផ្តល់ដល់កម្ពុជារួចមកហើយ អាល្លឺម៉ង់មានបំណងពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជាបន្តទៅទៀត ជាក់ស្តែងតាមរយៈការតែងតាំងលោក Frank Marcus MANN នាពេលនេះ។

*រស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ ទី១៦ ខែសីហា ឆ្នាំ២០០៧ ទំព័រក២ ។*

## នីកូឡាសសាកូហ្ស៊ីឈ្នះតំណែងប្រធានាធិបតីបារាំង

លោក នីកូឡាស សាកូហ្ស៊ី ជនអភិរក្សដែលនិយាយចំៗគ្មានការសំរបសំរួលហើយគាំទ្រអាមេរិកត្រូវបានជ្រើសតាំងជាប្រធានាធិបតីនៃប្រទេសបារាំងនៅក្នុងការបោះឆ្នោតកាលពីថ្ងៃទី០៦ខែឧសភា ជាមួយនឹងអាណត្តិមួយដើម្បីបង្កើតទិសដៅថ្មីមួយសំរាប់ប្រទេសមួយដែលមានភាពអសកម្មខាងសេដ្ឋកិច្ច ដើម្បីពុះពារធ្វើសមាហរណកម្មជនអន្តោប្រវេសន៍ និងកុមារមកក្នុងសង្គមបារាំង។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី០៨ ខែឧសភា ឆ្នាំ ២០០៧ ទំព័រក១ ។*

## បារាំងដំឡើងជំនួយដល់កម្ពុជា១២០លានអឺរ៉ូសំរាប់រយៈពេល៥ឆ្នាំ

ប្រទេសបារាំងបានអះអាងថា នឹងដំឡើងជំនួយដល់កម្ពុជាចំនួន១២០លានអឺរ៉ូសំរាប់រយៈពេល៥ឆ្នាំ។ នៅក្នុងជំនួបជាមួយសម្តេច ហ៊ុន សែន កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ លោកស្រី Brigitte Geradin រដ្ឋមន្ត្រីប្រតិភូសហប្រតិបត្តិការអភិវឌ្ឍន៏និងហ្វ្រង់កូហ្វូនីនៃប្រទេសបារាំង បានជំរាបសម្តេច ហ៊ុន សែន ថា ដំណើរទស្សនកិច្ចរបស់លោកស្រីមកកម្ពុជាពេលនេះ ដើម្បីពិនិត្យមើលការអនុវត្តន៏ជាក់ស្តែងនៃកិច្ចព្រមព្រៀងភាពជាដៃគូរនៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-បារាំង។

លោកស្រីបានជំរាបសម្តេច ហ៊ុន សែន ថា លោកស្រីបានជួបពិភាក្សាការងារជាមួយលោក ហោ ណាំហុង រួចហើយ ដែលការពិភាក្សានោះទទួលបានលទ្ធផលយ៉ាងប្រសើរ ហើយក៏បានចុះហត្ថលេខាធ្វើវិសោធនកម្មលើឯកសារក្របខ័ណ្ឌភាពជាដៃគូរ និងកិចសហប្រតិបត្តិការរវាងកម្ពុជា-បារាំង ដោយដំឡើងថវិកាជំនួយរហូតដល់១២០លានអឺរ៉ូសំរាប់រយៈពេល៥ឆ្នាំ។

សម្តេចបានអរគុណចំពោះការដំឡើងនេះ ហើយចាត់ទុកថាជំនួយទាំងអស់នោះពិតជាមានសារសំខាន់ណាស់ព្រោះវាបានជួយដល់ផ្នែកកសិកម្ម ជួយដល់ការកសាងប្រព័ន្ធច្បាប់ និងតុលាការ ជួយដល់វិស័យអប់រំនៅកម្ពុជា ជួយដល់វិស័យសុខាភិបាល ហើយជាពិសេសបារាំងបានជួយដល់ការបណ្តុះបណ្តាលចៅក្រម និងសាលាភូមិន្ទរដ្ឋបាល។ ជាមួយនេះសម្តេចបានស្នើអោយបារាំងជួយដល់កម្ពុជាលើការពង្រីកវិសាលភាពនៃការដាំដំណាំកៅស៊ូដើម្បីមានទំហំធំជាមុន។ សម្តេចក៏ស្នើអោយបារាំងពិនិត្យលទ្ធភាពបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៏កសិកម្មជាគំរូរបស់ប្រទេសបារាំងមួយនៅកម្ពុជា។

គួររំលឹកថា ក្រោយពីពិធីចុះហត្ថលេខាកិច្ចសន្យាបន្ថែមទៅនឹងឯកសារក្របខ័ណ្ឌនៃភាពជាដៃគូរបារាំង-កម្ពុជាមកលោកស្រីបានអះអាងថា ប្រទេសបារាំងគ្រោងនឹងផ្តល់ជំនួយដែលមានទឹកប្រាក់សរុបរហូតដល់ទៅ១២០លានអឺរ៉ូសំរាប់ការអភិវឌ្ឍន៏ប្រទេសកម្ពុជានៅចន្លោះឆ្នាំ២០០៦-២០១០ ដែលកិច្ចព្រមព្រៀងនេះនឹងពង្រីកទំនាក់ទំនងជាឯកសិទ្ធីរវាងប្រទេសបារាំងនិងកម្ពុជា ហើយធ្វើអោយបារាំងស្ថិតនៅក្នុងចំណោមប្រទេសផ្តល់ជំនួយទ្វេភាគីសំខាន់ៗនៅកម្ពុជា។ *កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧។*

## ព្រឹទ្ធសភាបារាំងជួបលោក គាត ឈន់

មន្ត្រីនាំពាក្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអោយដឹងថា លោក គាត ឈន់ បានជួបធ្វើសវនការជាមួយលោកមីសែលហ្សារ៉ាហ្វេ នៅថ្ងៃទី២៦ខែមីនាឆ្នាំ២០០៧ ដោយផ្តោតការពិភាក្សាទៅលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ព្រមទាំងគំរោងផ្សេងៗទៀតដែលកំពុងប្រើប្រាស់ហិរញ្ញប្បទានពីប្រទេសបារាំង។

មន្ត្រីនាំពាក្យបានអោយដឹងផងដែរថា ស្ថិតក្រោមកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុទ្វេភាគីកម្ពុជា-បារាំងចាប់តាំងពីឆ្នាំ២០០១ដល់ឆ្នាំ២០០៥ បារាំងបានផ្តល់ជំនួយជាអំណោយដល់ប្រទេសកម្ពុជាប្រមាណ១១២លានអឺរ៉ូ ឬជាមធ្យមប្រមាណ២២លានអឺរ៉ូក្នុងមួយឆ្នាំ។ កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុឆ្នាំ២០០៦-២០១០ជំនួយបារាំងមាន៥៤ លានអឺរ៉ូ។

ទោះបីជាយ៉ាងណាក្តី បើគិតពីឆ្នាំ១៩៩៣-២០០៦ ជំនួយបារាំងសំរាប់កម្ពុជា ដែលបានជួយមកកម្ពុជាតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៏បារាំង AFD មានចំនួនសរុបជាង១០០លានអឺរ៉ូ ដោយបានគាំទ្រដល់គំរោងអភិវឌ្ឍន៏ចំនួន៤០គំរោងផ្តោតសំខាន់លើផ្នែកកសិកម្ម ចម្ការកៅស៊ូ ហេដ្ឋារចនាសម្ព័ន្ធ និងមីក្រូហិរញ្ញវត្ថុ។

*កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៧ ។*

## លោកទេសរដ្ឋមន្ត្រី គាត ឈន់ ជួបទូតបារាំង

មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអោយដឹងថា លោក ហ្វង់ ហ្វ្រង់ស្វ័រ ដេម៉ាហ្សៀរ ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា បានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយលោក គាត ឈន់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។

ភាគីទាំងពីរបានពិភាក្សាទៅលើកិច្ចសហប្រតិបត្តិការទាំងវិស័យឯកជន និងវិស័យសាធារណៈ ។ ការពិភាក្សាគ្នាបានផ្តោតសំខាន់ផងដែរទៅលើការរិះរកគន្លឹះសំខាន់ៗដើម្បីជំរុញនិងទាក់ទាញវិនិយោគិនបារាំងមកប្រទេសកម្ពុជា ។

ចាប់ពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០០៧ ប្រទេសបារាំងបានផ្តល់ហិរញ្ញប្បទានដល់ប្រទេសកម្ពុជាប្រមាណ៨៧លានអឺរ៉ូសំរាប់ការជួយអភិវឌ្ឍន៍លើវិស័យជាច្រើន ។ *រស្មីកម្ពុជា ថ្ងៃពុធ ទី២៥ ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៦ ។*

## បារាំងបន្ថែមជំនួយសំរាប់ជួយដំណាំកៅស៊ូ និងកសិកម្មចំរុះ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសអោយដឹងថា ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង AFD បានសំរេចផ្តល់ជំនួយមានទឹកប្រាក់ចំនួន ៨៤០.000 អឺរ៉ូដល់រដ្ឋាភិបាលកម្ពុជា ជាប្រយោជន៍សំរាប់ការផ្តល់អោយខ្ចីបន្តដល់ប្រជារាស្ត្រដាំដំណាំកៅស៊ូជាលក្ខណៈគ្រួសារ និងការរៀបចំគំរោងថ្មីនៅឆ្នាំ២០០៨ ។

ពិធីចុះហត្ថលេខាលើអនុសញ្ញាផ្តល់កម្ចីនេះ ត្រូវបានធ្វើឡើងរវាងលោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលោក Eric Beugnot នាយក AFD និងក្រោមអធិបតីភាពរបស់លោក គាត ឈន់ និងលោក Jean Francous Desmazieres ឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋបារាំងប្រចាំកម្ពុជា ។

ក្រសួងហិរញ្ញវត្ថុបានអោយដឹងថា ប្រទេសបារាំងតាមរយៈ AFD ចាប់តាំងពីឆ្នាំ ១៩៩៩ មកបានផ្តល់ជំនួយឥតសំណងសំរាប់ដំណាំកៅស៊ូគ្រួសារ និងកសិកម្មមានទឹកប្រាក់ចំនួនសរុប ៥.៤លានអឺរ៉ូហើយ ដែលជំនួយនេះបានផ្តល់ដល់អ្នកដាំកៅស៊ូតូចតាចដោយមានការចូលរួមគាំទ្រខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុផងដែរ ។
*រស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ ទី០៥ ខែកក្កដាឆ្នាំ២០០៧ ទំព័រក៣ ។*

## ប្រតិភូក្រុមមិត្តភាពកម្ពុជា-បារាំង ទស្សនកិច្ចនៅកម្ពុជា

គណប្រតិភូព្រឹទ្ធសភាបារាំង ដឹកនាំដោយលោកស្រី Catherine TASCAS សមាជិកព្រឹទ្ធសភា និងជាប្រធានប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជាបានអញ្ជើញមកធ្វើទស្សនកិច្ចផ្លូវការនៅកម្ពុជា ពីថ្ងៃទី៣១ខែមីនាឆ្នាំ២០០៧ ដើម្បីពង្រឹងទំនាក់ទំនងមិត្តភាព សហប្រតិបត្តិការទ្វេរភាគីរវាងស្ថាប័ននីតិបញ្ញត្តិ ក៏ដូចជារវាងប្រទេសទាំងពីរផងដែរ ។

ប្រតិភូនេះ និងចំណាយពេល១សប្តាហ៍នៅកម្ពុជា ហើយក្នុងអំឡុងពេលនេះ ប្រតិភូក៏នឹងចូលបង្គំគាល់ព្រះមហាក្សត្រកម្ពុជា ជួបសម្តែងការគួរសមជាមួយសម្តេច ជា ស៊ីម សម្តេច ហេង សំរិន សម្តេច ហ៊ុន សែន។ ប្រតិភូក៏នឹងជួបពិភាក្សាការងារជាមួយនឹងក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា-បារាំង ។

*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី០១-០២ ខែមេសា ឆ្នាំ២០០៧ ទំព័រក២ ។*

## បារាំងសន្យាផ្តល់ជំនួយក្នុងទឹកប្រាក់ជាង៩០លានដុល្លារសំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា

រដ្ឋាភិបាលបារាំងបានសន្យាផ្តល់ជំនួយក្នុងទឹកប្រាក់ចំនួន ៩០,៦៦៧,៩៤៣ ដុល្លារអាមេរិកសំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជារយៈពេល៣ឆ្នាំ ពីឆ្នាំ២០០៧ដល់ឆ្នាំ២០០៩ ដែលជំនួយនេះក៏ជាផ្នែកមួយដ៏សំខាន់ផងដែរនៅក្នុងការពង្រឹងពង្រីកបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេរភាគីរវាងប្រទេសទាំងពីរ ។

ការសន្យារបស់រដ្ឋាភិបាលបារាំងនេះ ត្រូវបានលើកឡើងដោយលោក JEAN FRANCOIS DESMAZIERE ឯកអគ្គរដ្ឋទូតបារាំងថ្មីប្រចាំនៅកម្ពុជា ខណៈលោកជួបពិភាក្សាការងារជាមួយលោក ហោ ណាំហុង កាលពីថ្ងៃទី០៥ ខែកក្កដា ។ តែការសន្យានេះ ក៏បានត្រូវគូសបញ្ជាក់ផងដែរនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៩-២០ ខែមិថុនាឆ្នាំ២០០៧ ។

គំរោងជំនួយសហប្រតិបត្តិការកម្ពុជា-បារាំង ដែលកំពុងអនុវត្តសព្វថ្ងៃនេះមាន៣១គំរោង : ផ្តល់ថវិកាដោយមូលនិធិសាមគ្គីភាពជាអាទិភាព(FSP)ទាក់ទងនឹងវិស័យដូចជា : នីតិរដ្ឋនិងអភិបាលកិច្ចល្អ ការអប់រំថ្នាក់ឧត្តមនិងការស្រាវជ្រាវ វប្បធម៌និងប្រាង្គ់កូហ្វូនី សង្គមស៊ីវិល សុខាភិបាលនិងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ វិស័យផលិតកម្ម ដែលមានទឹកប្រាក់សរុបចំនួន ២៩.២៥៦.០០០អឺរ៉ូ។ និងមាន១៨គំរោងផ្សេងទៀតផ្តល់ថវិកាដោយភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍(AFD) ទាក់ទងនឹងវិស័យដូចជា វិស័យកសិកម្មនិងសន្តិសុខស្បៀង ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍន៍ក្រុងវិស័យសុខាភិបាលនិងការប្រយុទ្ធនឹងជំងឺអេដស៍ វិស័យផលិតកម្ម ការពារបរិស្ថាននិងជីវចំរុះ ដែលមានទឹកប្រាក់សរុបចំនួន ៤៩.៩៣៤.០០០ អឺរ៉ូ ។

ភាគីទាំងពីរក៏ពិភាក្សាគ្នាផងដែរពីដំណើរទស្សនកិច្ចរបស់លោករដ្ឋមន្ត្រីការបរទេសបារាំង Bernard Kouchner ដែលគ្រោងនឹងមកកាន់កម្ពុជានៅមុនដំណាច់ឆ្នាំ២០០៧ ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី០៧ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៤ ។*

## សម្តេច ជា ស៊ីម ទទួលជួបឯកអគ្គរដ្ឋទូតបារាំង និងអ៊ីតាលី

សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា បានទទួលជួបសន្ទនាដោយឡែក១ពីគ្នាកាលពីថ្ងៃទី២០ខែកក្កដាឆ្នាំ២០០៧ ជាមួយលោក Jean Francous Desmazieres ឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋបារាំង និងលោក Ignasio DI PACE ឯកអគ្គរដ្ឋទូតអ៊ីតាលី ដែលលោកទាំងពីរត្រូវបានតែងតាំងអោយបំពេញបេសកម្មការទូតប្រចាំនៅកម្ពុជា ។

សម្តេច ជា ស៊ីម បានថ្លែងថា បេសកម្មការទូតរបស់ប្រទេសទាំងពីរមានសារៈសំខាន់ណាស់ក្នុងការពង្រឹងទំនាក់ទំនងមិត្តភាពកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក៏ដូចជាស្ថាប័ននីតិបញ្ញត្តិនៃប្រទេសទាំងពីរផងដែរ ។

ក្នុងឱកាសនោះ លោកឯកអគ្គរដ្ឋទូតបារាំងបាននាំយកនូវ Computer ចំនួន១០គ្រឿង និងម៉ាស៊ីន Printer ចំនួន ១០គ្រឿង ដែលជាអំណោយរបស់ព្រឹទ្ធសភាបារាំងជូនចំពោះព្រឹទ្ធសភាកម្ពុជា។

ចំណែកលោកឯកអគ្គរដ្ឋទូតអ៊ីតាលី ក៏បានបញ្ជាក់ជូនសម្តេច ជា ស៊ីម ថា រដ្ឋាភិបាលអ៊ីតាលីនឹងបន្តជួយឧបត្ថម្ភគាំទ្រ ហើយនឹងពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការជាមួយស្ថាប័ននីតិបញ្ញត្តិកម្ពុជា។

ដោយឡែកក្នុងថ្ងៃដដែលនោះដែរ លោកស្រី Zhang Jin Feng ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា ក៏បាននាំយកនូវ Computer និង Printer ដែលជាអំណោយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនទូទាំងប្រទេសចិន មកប្រគល់ជូនដល់ព្រឹទ្ធសភាកម្ពុជាផងដែរ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ទី២១ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ២។*

## សម្តេច ហ៊ុន សែន ទទួលជួបអ្នកការទូតកាណាដា និងបារាំង

កាលពីថ្ងៃទី១៧ខែកក្កដា នៅក្រសួងការបរទេស សម្តេច ហ៊ុន សែន បានទទួលជួបសវនការជាមួលោកលោកស្រីឯកអគ្គរដ្ឋទូតកាណាដាប្រចាំកម្ពុជាដែលត្រូវបញ្ចប់អាណត្តិ DONICA PO POTIE និងលោក JEAN FRANCOIS DESMAZIERE ឯកអគ្គរដ្ឋទូតបារាំងថ្មីប្រចាំនៅកម្ពុជា។

កម្ពុជានិងកាណាដា មានទំនាក់ទំនងជាមួយគ្នាតាំងពីឆ្នាំ ១៩៥៤ ហើយបច្ចុប្បន្នកាណាដាតែងតែជួយកម្ពុជា ដូចជាស្វែងរកសន្តិភាព ការដោះមីន ហើយចុងក្រោយនេះបានចុះហត្ថលេខាជួយដល់ការធ្វើប្លង់ និងបញ្ហាកម្មសិទ្ធិដីធ្លីជូនដល់ប្រជាពលរដ្ឋកម្ពុជាតាមរយៈការផ្តល់ជំនួនដល់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។

ចំនែកបារាំងនិងកម្ពុជា មានប្រវត្តិទំនាក់ទំនងគ្នាច្រើនបំផុតក្នុងបញ្ហាទំនាក់ទំនងទូត ដោយសារបារាំងធ្លាប់ធ្វើជាអាណានិគមលើកម្ពុជាជិតមួយសតវត្ស ហើយបារាំងជាអ្នកកំណត់ព្រំប្រទល់ដែនកម្ពុជានិងប្រទេសជិតខាង។
*រស្មីកម្ពុជា ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ២។*

## ប្រមុខរដ្ឋប្រទេសស្វីសអញ្ជើញមកដល់ប្រទេសកម្ពុជា

លោកជំទាវ មីស្សឺលីន អានមារី កាល់មីរី ប្រមុខរដ្ឋនៃសហព័ន្ធស្វីស និងជារដ្ឋមន្ត្រីការបរទេសស្វីស បានអញ្ជើញមកដល់ប្រទេសកម្ពុជាកាលពីព្រលប់ថ្ងៃទី០៩ខែកុម្ភៈ សំរាប់ដំណើរទស្សនកិច្ចលើកដំបូងរយៈពេល២ថ្ងៃរបស់លោកស្រីនៅកម្ពុជា។ ពុំមានការចុះហត្ថលេខាអ្វីសំខាន់ក្នុងដំណើរទស្សនកិច្ចនេះទេ តែរាជរដ្ឋាភិបាលកម្ពុជាបានដាក់សំណើរចំនួន ៤ ដើម្បីសុំរដ្ឋាភិបាលស្វីសគាំទ្រ។

ក្នុងអំឡុងស្នាក់នៅកម្ពុជា លោកជំទាវប្រមុខរដ្ឋស្វីស ត្រូវបានទទួលស្វាគមន៍ ពីព្រះមហាក្សត្រកម្ពុជា សម្តេចបរមនាថ នរោត្តសីហមុនី។ ជួបសវនកាលជាមួយសម្តេច ហ៊ុន សែន និងជួបលោក ហោ ណាំហុង បន្ទាប់មកលោកជំទាវអញ្ជើញទៅបំពេញទស្សនកិច្ចនៅមន្ទីរពេទ្យគន្ធបុប្ផាទី៤នៅក្រុងភ្នំពេញ និងអង្គការហាហ្កា ដែលកន្លែងទាំងពីរនេះទទួលបានការឧបត្ថម្ភពីប្រទេសស្វីស។

សំណើ ៤ ចំនុច ដែលរដ្ឋាភិបាលកម្ពុជាស្នើដល់លោកជំទាវប្រមុខរដ្ឋស្វីស រួមមាន ទី១- សុំអោយរដ្ឋាភិបាលស្វីសជួយសិក្សាទីផ្សារសូត្រខ្មែរនៅសហគមន៍អឺរ៉ុបនិងប្រទេសស្វីស ដើម្បីនាំផលិតផលសូត្រខ្មែរទៅលក់នៅប្រទេសស្វីស ដោយសារវត្ថុធាតុដើមកម្ពុជានាំចូលពីបរទេស។ ទី២- រដ្ឋាភិបាលកម្ពុជាស្នើសុំអោយរដ្ឋាភិបាលស្វីសជួយលើវិស័យចិញ្ចឹមនាងសរសៃសូត្រដែលជាការផ្តល់ការងារអោយប្រជាពលរដ្ឋកម្ពុជា ពិសេសស្ត្រីកម្ពុជាមានការងារធ្វើរាប់លាននាក់។ ទី៣- សុំអោយស្វីសជួយលើវិស័យបណ្តុះបណ្តាលធនធានមនុស្សផ្នែកទេសចរណ៍ ពីព្រោះប្រទេសនេះមានសាលាពូកែជាងគេនៅលើពិភពលោកក្នុងករណីបណ្តុះបណ្តាលធនធានមនុស្ស។ ទី៤- សុំអោយស្វីសជួយកម្ពុជាលើការនាំចេញផលិតផលកសិកម្មកម្ពុជា។

ជាមួយនេះប្រមុខរដ្ឋស្វីស និងសម្តេច ហ៊ុន សែន បានចុះហត្ថលេខារួមគ្នាមួយលើកិច្ចព្រមព្រៀងស្តីពីសេវាកម្មដឹកជញ្ជូនផ្លូវអាកាសប្រទេសទាំងពីរ។

លោកជំទាវប្រមុខរដ្ឋក៏បានអញ្ជើញទស្សនកិច្ចនៅខេត្តសៀមរាប ដោយផ្តោតជាពិសេសលើប្រាសាទបន្ទាយស្រីដែលរដ្ឋាភិបាលស្វីសបានជួយដល់សកម្មភាពជួសជុល និងអភិរក្ស។ *រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៧។*

## ព្រះមហាក្សត្រយាងជាអធិបតីក្នុងពិធីរំលឹកខួបលើកទី៥០នៃទំនាក់ទំនងការទូតកម្ពុជា-ស្វីស

ទំនាក់ទំនងការទូតរវាងប្រទេសស្វីសនិងប្រទេសកម្ពុជាបានចាប់ផ្តើមពីឆ្នាំ ១៩៥៧។ ប្រទេសដ៏តូច នៅទ្វីបអឺរ៉ុបដែលមានខឿនសេដ្ឋកិច្ចរឹងមាំនេះ បានចូលរួមយ៉ាងសកម្មក្នុងការជួយដល់វិស័យសុខាភិបាល ជាពិសេសជាម្ចាស់ជំនួយដ៏សំខាន់នៃមន្ទីរពេទ្យគន្ធបុប្ផាទាំងនៅរាជធានីភ្នំពេញនិងខេត្តសៀមរាប។

លោក Rodolphe S.Imhoof ឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋសហព័ន្ធស្វីស បានមានប្រសាសន៍ថា មូលហេតុនៃការប្រារព្ធពិធីនេះឡើងគឺលោកស្រីប្រធានាធិបតីស្វីសបានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសកម្ពុជា កាលពីខែកុម្ភៈដើមឆ្នាំនេះ ហើយនៅប៉ុន្មានថ្ងៃខាងមុខព្រះមហាក្សត្រកម្ពុជានឹងយាងបំពេញទស្សនកិច្ចនៅទ្វីបអឺរ៉ុប ជាពិសេសព្រះអង្គនឹងយាងទៅប្រទេសស្វីស។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី២៤ ខែឧសភា ឆ្នាំ២០០៧ ទំព័រ២។*

## ចំណងការទូតរវាងកម្ពុជានិងស្វីសរឹតតែមាំតាមរយៈដំណើរទស្សនកិច្ចរបស់ព្រះមហាក្សត្រ

យោងតាមសេចក្តីរាយការណ៍របស់ប្រព័ន្ធព័ត៌មានស្វីស(NZZ) កាលពីថ្ងៃទី៣០ខែឧសភាបានអោយ ដឹងថា ព្រះមហាក្សត្រកម្ពុជាបានយាងទៅដល់ប្រទេសស្វីសយ៉ាងសុវត្ថិភាព ហើយព្រះអង្គត្រូវបានទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដោយលោកស្រី Micheline Calmy Rey ប្រធានាធិបតីស្វីស។

ប្រភពដដែលបានអោយដឹងដែរថា ព្រះមហាក្សត្រកម្ពុជា និងលោកស្រីប្រធានាធិបតីស្វីស បានជួបពិភាក្សាគ្នា ហើយនៅក្នុងពេលពិភាក្សាគ្នានោះក៏មានការចូលរួមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចស្វីសផងដែរ។

ដំណើរបំពេញទស្សនកិច្ចរបស់ព្រះមហាក្សត្រកម្ពុជាទៅកាន់ប្រទេសស្វីសនេះ គឺធ្វើឡើងក្រោយពេលដែលលោកស្រីប្រធានាធិបតីបានមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជាកាលពីខែកុម្ភៈ ក្នុងខណៈពេលដែលប្រទេសទាំងពីររៀបចំពិធីរំលឹកខួបនៃការភ្ជាប់ទំនាក់ទំនងការទូត៥០ឆ្នាំរបស់ប្រទេសទាំងពីរ។

ប្រទេសស្វីសជាម្ចាស់ជំនួយដ៏សំខាន់របស់ប្រទេសកម្ពុជាផងដែរ ហើយប្រទេសនេះផ្តល់ជំនួយដល់កម្ពុជាតាមរយៈទីភ្នាក់ងារស្វីសដើម្បីអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) ។

ក្រៅពីបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅក្នុងប្រទេសស្វីស ព្រះមហាក្សត្រកម្ពុជាក៏ចំណាយពេលឯកជនរបស់ព្រះអង្គនៅក្នុងប្រទេសនេះផងដែរ ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី៣១ ខែឧសភា ឆ្នាំ២០០៧ ទំព័រក២ ។*

## អ៊ីតាលីស្នើកម្ពុជាបង្កើតអគ្គកុងស៊ុលកិត្តិយសឡើងវិញនៅភ្នំពេញ

លោក Ignazio DI PACE ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអ៊ីតាលី ដែលមាននិវេសនដ្ឋាននៅទីក្រុងបាងកក ប្រទេសថៃ បានជួបពិភាក្សាជាមួយលោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ។

ភាគីទាំងពីរបានផ្តោតលើកិច្ចពិភាក្សាធ្វើយ៉ាងណា អោយចំណងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរមានលក្ខណៈទូលំទូលាយ។ ក្នុងនោះ លោក អ៊ុច បូរិទ្ធ បានលើកឡើងពីចំណុចសំខាន់ពាក់ព័ន្ធទៅនឹងវិស័យទេសចរណ៍វិស័យវិនិយោគទុនធ្វើយ៉ាងណាអោយអ្នកវិនិយោគទុនអ៊ីតាលីមកទស្សនាកម្ពុជា និងស្វែងរកឱកាសដើម្បីដាក់ទុនវិនិយោគ ។

លោកឯកអគ្គរដ្ឋទូតអ៊ីតាលីបានឯកភាពចំពោះការលើកឡើងនេះ ម្យ៉ាងទៀតដើម្បីសំរួលដល់ការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ លោកបានស្នើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាបើកឡើងវិញនូវកុងស៊ុលកិត្តិយសរបស់អ៊ីតាលីដែលធ្លាប់មានក្នុងរយៈពេលដ៏យូរលង់ណាស់មកហើយ ហើយនឹងពិចារណាបើកស្ថានទូតតែម្តងនៅពេលដែលអ៊ីតាលីមានថវិកាគ្រប់គ្រាន់ ។ លោកបានជំរាបភាគីកម្ពុជាពីជំនួយអ៊ីតាលីតាមរយៈអង្គការ UNESCO និងអ្នកបច្ចេកទេសអ៊ីតាលីមកជួយដល់កម្ពុជាក្នុងការថែទាំប្រាសាទអង្គរ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា ។

ដោយឡែកលោកឯកអគ្គរដ្ឋទូតអ៊ីតាលី ក៏បានចូលជួបពិភាក្សាការងារជាមួយលោក ងួន ញ៉ិល ប្រធានរដ្ឋសភាស្តីទី ផងដែរកាលពីថ្ងៃទី១៩ ខែកក្កដានោះ ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី២១ខែកក្កដា ឆ្នាំ២០០៧ ទំព័រក២ ។*

## អ៊ីតាលីត្រៀមពង្រីកកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា

ប្រទេសអ៊ីតាលីមានបំណងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសកម្ពុជា ដែលក្នុងនោះភាគីអ៊ីតាលីក៏បានបញ្ជាក់ថា ទីក្រុង Milan អាចនឹងត្រៀមទទួលផលិតផលកសិកម្មដែលកន្លងមកប្រទេសកម្ពុជាលំបាកនាំចេញទៅបណ្តាប្រទេសនៅអឺរ៉ុប ។

ការអះអាងខាងលើនេះ ត្រូវបានលើកឡើងដោយលោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោយពីលោកបានជួបពិភាក្សាការងារជាមួយលោក Claudio Moreno តំណាងពិសេសរបស់រដ្ឋាភិបាលអ៊ីតាលី កាលពីថ្ងៃទី១២ខែកក្កដាឆ្នាំ២០០៧ ។

កន្លងមកផលិតផលកសិកម្មកម្ពុជាមានការលំបាកក្នុងការនាំចេញទៅកាន់អឺរ៉ុប ដោយសារគេថា ផលិតផលកម្ពុជាមិនឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ។ ប៉ុន្តែពេលនេះ ទីក្រុង Milan របស់អ៊ីតាលីត្រៀមទទួលផលិតផលកសិកម្មរបស់កម្ពុជាទាំងអស់ ដើម្បីរៀបចំកែច្នៃនិងលក់ដូរនៅប្រទេសអ៊ីតាលី ឬនាំចេញទៅប្រទេសអឺរ៉ុបផ្សេងទៀត។

លោក អ៊ុច បូរិទ្ធ ក៏បានបន្ថែមទៀតថា អ៊ីតាលីនឹងរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្មនៅខែកុម្ភៈឆ្នាំ២០០៨ ខាងមុខនេះ ដើម្បីធ្វើការពិភាក្សាគ្នាអំពីផលិតផលកសិកម្ម ក្នុងនោះចំណុចសំខាន់គឺ ការសហការគ្នាដើម្បីលើកកំពស់តំលៃក៏ដូចជាការនាំចេញផលិតផលកសិកម្ម។ ហើយពាក់ព័ន្ធបញ្ហានេះ ក្រសួងការបរទេសក៏បានរៀបចំអោយមានការជួបដោយផ្ទាល់រវាងភាគីអ៊ីតាលីជាមួយក្រសួងទេសចរណ៍ ក្រសួងកសិកម្ម និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

ជាមួយនេះ អ៊ីតាលីក៏កំពុងតែស្វែងរកការគាំទ្រពីកម្ពុជា លើបេក្ខភាពទីក្រុង Milan សំរាប់ជាទីក្រុងតាំងពិព័រណ៍អន្តរជាតិឆ្នាំ២០១៥។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ច័ន្ទ ទី១៥-១៦ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ៤។*

## ប៉ូឡូញបង្វែរបំណុលទៅជាជំនួយសំរាប់ការថែទាំប្រាសាទ

ប្រសាសន៍នេះលើកឡើងដោយលោក Habil Ryszard OLSZEWSKI ឯកអគ្គរដ្ឋទូតប៉ូឡូញប្រចាំកម្ពុជា ក្នុងឱកាសលោកជួបសម្តែងការគួរសម និងជំរាបលាលោក ហោ ណាំហុង កាលពីថ្ងៃទី២៣ខែតុលាឆ្នាំ២០០៧ បន្ទាប់ពីរូបលោកបញ្ចប់បេសកម្មការទូតនៅកម្ពុជា។

ប្រភពនៃជំនួបនោះបានបញ្ជាក់ថា កាលពីឆ្នាំទៅមិញរដ្ឋាភិបាលប៉ូឡូញបានជួយដល់ប្រទេសកម្ពុជាលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ប្រមាណ២៥លានប្រាក់ប៉ូឡូញ ហើយបំណុលដែលកម្ពុជាជំពាក់កន្លងមករដ្ឋាភិបាលប៉ូឡូញនឹងបង្វែរបំណុលទាំងនោះទៅជាជំនួយរបស់ប៉ូឡូញសំរាប់ការថែទាំជួសជុលប្រាសាទបុរាណកម្ពុជាវិញ។

ជាមួយនេះ ភាគីទាំងពីរក៏បានពិភាក្សាគ្នារិះរកវិធីយ៉ាងណា ដើម្បីជំរុញអោយកិច្ចសហប្រតិបត្តិរវាងប្រទេសទាំងពីរកាន់តែរឹងមាំ និងមាននិរន្តរភាព។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ៍ ទី២៥ ខែតុលា ឆ្នាំ២០០៧ ទំព័រក២។*

## ប៉ូឡូញនឹងបង្វែរបំណុលរបស់កម្ពុជាសំរាប់មកជួយថែទាំប្រាសាទ

ជំហរនេះត្រូវបានលើកឡើងដោយលោក WOJCIECH RZAIEKCHI នាយករងនៃក្រសួងហិរញ្ញវត្ថុប៉ូឡូញ ក្នុងឱកាស ដែលលោកបានជួបជាមួយលោក គាត ឈន់ កាលពីថ្ងៃទី១២ខែវិច្ឆកាឆ្នាំ២០០៧។

ប្រភពជំនួបនេះបានអោយដឹងថា មន្ត្រីប៉ូឡូញបានសន្យានឹងបន្តជួយលើការផ្តល់ហិរញ្ញប្បទានមានការប្រាក់ទាបគួបផ្សំនឹងជំនួយ៥០ភាគរយសំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាផងដែរ។

មិនមានការបញ្ជាក់ តើកម្ពុជាជំពាក់ប៉ូឡូញចំនួនប៉ុន្មាននោះទេ? ប៉ុន្តែគេដឹងថា ប្រទេសកម្ពុជាជំពាក់អតីតសហភាពសូវៀតនិងសម្ព័ន្ធមិត្តកុម្មុនីស្តប្រមាណ១ពាន់លានដុល្លារក្រោយសម័យឆ្នាំ១៩៧៩។
*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រក៤។*

## ដាណឺម៉ាកផ្តល់ជំនួយ៥០ម៉ឺនដុល្លារអាមេរិកសំរាប់គាំទ្រការងារសវនកម្មនៅកម្ពុជា

រដ្ឋាភិបាលដាណឺម៉ាកសំរេចផ្តល់ជំនួយជាទឹកប្រាក់សរុប៥០ម៉ឺនដុល្លារអាមេរិក ស្មើ៣លានគួរោនលុយដាណឺម៉ាក ជូនអាជ្ញាធរសវនកម្មជាតិសំរាប់អនុវត្តគំរោងការងារសវនកម្មនៅក្នុងប្រទេសកម្ពុជារយៈពេល២ឆ្នាំ ២០០៧-២០០៨។

អនុស្សរណៈនៃការយោគយល់គ្នាស្តីពីគំរោងគាំទ្រអាជ្ញាធរសវនកម្មជាតិ បានត្រូវចុះហត្ថលេខាកាលពីរសៀលថ្ងៃទី២៩ខែធ្នូឆ្នាំ២០០៦ រវាងលោក អ៊ុត ឈន អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ និងលោក ម៉ូហ្គេន ឡូមែន គ្រីសស្ទែនសេន ទីប្រឹក្សាថ្នាក់រដ្ឋមន្ត្រីនិងជាតំណាងអង្គការ DANIDA ទទួលបន្ទុកផ្នែកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៃស្ថានទូតដាណឺម៉ាកប្រចាំកម្ពុជា។

ក្នុងចំនួនទឹកប្រាក់សរុប៥០ម៉ឺនដុល្លារអាមេរិកនេះ ដាណឺម៉ាកបានសំរេចផ្តល់ជាជំនួយប្រហែលជាង៣០ម៉ឺនដុល្លារអាមេរិកសំរាប់ជួយលើការងារព័ត៌មានវិទ្យា។ *កាសែតរស្មីកម្ពុជា ថ្ងៃទី០២ ខែមករា ឆ្នាំ២០០៧។*

## ហ្វាំងឡង់ជួយថវិកា២លានដុល្លារបន្ថែមសំរាប់ការងារដីធ្លី

ប្រទេសហ្វាំងឡង់បានសំរេចផ្តល់ជំនួយដល់គំរោងដីធ្លី និងរដ្ឋបាលដីធ្លីមានទឹកប្រាក់សរុបប្រមាណ២លានដុល្លារអាមេរិកបន្ថែមទៀតសំរាប់រយៈពេលមួយឆ្នាំកន្លះ រហូតដល់ខែធ្នូឆ្នាំ២០០៨។

ការសំរេចផ្តល់ជាផ្លូវការនេះ ធ្វើឡើងក្នុងឱកាសជំនួបរវាងលោក អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងដែនដី និងលោកជំទាវ មាហ្សាតតា រ៉ាស៊ី អនុរដ្ឋលេខាធិការក្រសួងសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រទេសហ្វាំងឡង់ កាលពីថ្ងៃទី៧ ខែកុម្ភៈឆ្នាំ២០០៧ ខណៈពេលលោកជំទាវបានមកបំពេញទស្សនកិច្ចនៅកម្ពុជា។

ប្រភពនៃជំនួបនោះបានអោយដឹងថា ជំនួយនេះគឺជាជំនួយបច្ចេកទេស ដែលត្រូវយកទៅអនុវត្តពីខែកក្កដាឆ្នាំ២០០៧ ដល់ខែធ្នូឆ្នាំ២០០៨ ដើម្បីពង្រឹងបន្ថែមទៅលើការយល់ដឹងជាសាធារណៈ និងការចូលរួមពីសហគមន៍។ ជាមួយនេះជំនួយនេះនឹងប្រើសំរាប់ការលើកកំពស់គុណភាពក្នុងកម្មវិធីចុះបញ្ជីដីធ្លីតាមលក្ខណៈជាប្រព័ន្ធ និងលក្ខណៈដាច់ដោយដុំ និងជួយលើផ្នែកព័ត៌មានវិទ្យា និងប្រព័ន្ធពិតនៃភូមិសាស្រ្តក្នុងការអភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីទំនើបនិងការរៀបចំការិយាល័យចុះបញ្ជីដីគំរូដើម្បីឈានទៅសំរេចស្វ័យភិបាល ពិសេសជួយទៅលើការចុះបញ្ជីដី និងចេញប័ណ្ណកម្មសិទ្ធិដីជូនប្រជាពលរដ្ឋ។

លោក អ៊ឹម ឈុនលឹម បានថ្លែងអោយដឹងថា តាមពិតជំនួយរបស់ហ្វាំងឡង់ដែលបានធ្វើកិច្ចសហប្រតិបត្តិការល្អជាមួយកម្ពុជា មានតាំងពីឆ្នាំ១៩៩៧មកម្លេះ។ *កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៧។*

## ៤_ទំនាក់ទំនងកម្ពុជា និងប្រទេសចិន

### ធនាគារចិនផ្តល់ប្រាក់កម្ចី២០៧លានដុល្លារសំរាប់ស្ពាន-ផ្លូវ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអោយដឹងថា នៅថ្ងៃទី២២ខែមករាឆ្នាំ២០០៧ ធនាគាររដ្ឋចិនបានសំរេចផ្តល់ប្រាក់កម្ចីសម្បទានចំនួន ២០៧ លានដុល្លារអាមេរិកដល់រដ្ឋាភិបាលកម្ពុជា សំរាប់យកទៅកសាងផ្លូវជាតិលេខ៨ ផ្លូវជាតិលេខ៧៦ សង់ស្ពានព្រែកតាមាក់ សង់ស្ពានព្រែកក្តាម និងស្ថាបនាបណ្តាញព័ត៌មានសំរាប់ទំនាក់ទំនងក្នុងប្រទេសមហាអនុតំបន់មេគង្គ។

យោងតាមសេចក្តីប្រកាសរបស់ក្រសួងហិរញ្ញវត្ថុបានអោយដឹងថា ប្រាក់កម្ចីសម្បទានដែលធនាគារចិនផ្តល់អោយប្រទេសកម្ពុជាខណៈនេះមានចំនួន២០៧លានដុល្លារអាមេរិក ក្នុងនោះមានប្រាក់កម្ចីចំនួន១០៩លានដុល្លារអាមេរិជាឥណទានធម្មតា និងជាង១៧លានដុល្លារទៀតជាឥណទានសម្បទាន។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលយកប្រាក់ឥណទាននេះ ធ្វើឡើងរវាងលោក គាត ឈន់ និងលោកស្រី លី ជុន អនុប្រធានធនាគារអហារ័ណ នីហារ័ណចិន កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧។

*កាសែតរស្មីកម្ពុជា ចេញផ្សាយ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៧។*

### កំណាត់ផ្លូវជាតិលេខ ៧៦ បើកការដ្ឋានស្ថាបនាក្រោមប្រាក់កម្ចីរបស់ចិន

កំណាត់ផ្លូវជាតិលេខ៧៦ ប្រវែង១២៧គីឡូម៉ែត្រ ពីស្រុកស្នួល ខេត្តក្រចេះ ទៅកាន់ទីប្រជុំជនសែនមនោរម្យ ត្រូវបានសម្ពោធបើកការដ្ឋានកាលពីថ្ងៃទី១៤ខែកុម្ភៈ ក្រោមវត្តមានសម្តេច ហ៊ុន សែន និងលោកស្រី ZHANG JINFENG ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា។

លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីសាធារណៈការបានអោយដឹងថា ការសាងសង់កំណាត់ផ្លូវលេខ៧៦នេះត្រូវចំណាយអស់ថវិកាសរុបចំនួន៥១.៩លានដុល្លារអាមេរិក ក្នុងនោះប្រាក់កម្ចីរបស់ចិនជាង៤៩លានដុល្លារ និងថវិការដ្ឋាភិបាលកម្ពុជាចំនួន២លានដុល្លារ ហើយគំរោងសាងសង់នេះគ្រោងបញ្ចប់នៅរវាងខែមីនា ឆ្នាំ២០១០។

លោកស្រី Zhang JINFENG ឯកអគ្គរដ្ឋចិនមានប្រសាសន៍ថា ការបើកការដ្ឋានសាងសង់កំណាត់ផ្លូវជាតិលេខ៧៦នាពេលនេះ គឺជាការចាប់ផ្តើមការអនុវត្តន៏គំរោងកម្ចីរបស់ប្រទេសចិនចំនួន២០០លានដុល្លារអាមេរិក សំរាប់សាងសង់ផ្លូវចំនួន២និងស្ពានសំខាន់ៗចំនួន២នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ *រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី១៥ ខែកុមៈ ឆ្នាំ២០០៧។*

### ក្រសួងការបរទេសចិន ផ្តល់អំណោយដល់ក្រសួងការបរទេសកម្ពុជា

សំភារៈការិយាល័យមួយចំនួន រួមមានម៉ាស៊ី Computer Desktop ១០គ្រឿង Computer Laptop ១គ្រឿង Laser Printer ៣០គ្រឿង Scanner ១គ្រឿង និង Digital Coie ២គ្រឿង ត្រូវបានផ្តល់ជាអំណោយដល់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយក្រសួងការបរទេសចិន តាមរយៈស្ថានទូតចិនប្រចាំកម្ពុជា។

ពិធីប្រគល់នឹងទទួលសំភារៈការិយាល័យទាំងនេះ បានធ្វើឡើងកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ តាមរយៈការចុះហត្ថលេខាលើឯកសាររវាងលោក ឡុង វិសាលោ រដ្ឋលេខាធិការក្រសួងការបរទេសកម្ពុជា និងលោកស្រី Zhang Jim Feng ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១២ ខែមេសា ឆ្នាំ២០០៧ ទំព័រ៥២។*

**សាងសង់ស្ពានព្រែកតាមាក់ក្រោមកម្ចីរបស់ចិនជាង៤៣លានដុល្លារ**

ពិធីបើកការដ្ឋាននេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៦ខែមិថុនាឆ្នាំ២០០៧ ក្រោមអធិបតីភាពសម្តេច ហ៊ុន សែន និងលោកជំទាវឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា។

ស្ពាននេះតភ្ជាប់ផ្លូវជាតិលេខ៦A ទៅនឹងផ្លូវជាតិលេខ៨ ត្រង់ស្រុកខ្សាច់កណ្តាលខេត្តកណ្តាល។

សម្តេច ហ៊ុន សែន បានធ្វើប្រកាសថាគ្រប់ស្ពានផ្លូវដែលកសាងដោយជំនួយនិងកម្ចីពីចិនថា ជាស្ពានមិត្តភាព ឬផ្លូវមិត្តភាពកម្ពុជា-ចិន ហើយក្រោយពីស្ពានព្រែកតាមាក់នេះសាងសង់រួចហើយ ស្ពាននេះនឹងប្រសិទ្ធិនាមថាជាស្ពានមិត្តភាពកម្ពុជា-ចិនព្រែកតាមាក់។

ថ្លែងនៅក្នុងឱកាសនោះ សម្តេចបានលើកឡើងថា ស្ពាននេះនឹងរួមចំណែកយ៉ាងធំក្នុងការបង្កើតកាលានុវត្តភាពនៃការពង្រឹងនិងពង្រីកវិសាលភាពបរិយាកាសវិនិយោគ និងពាណិជ្ជកម្មកំរិតអន្តរជាតិ ដែលអាចជួយលើកកំពស់សេដ្ឋកិច្ចជាតិនិងគ្រួសារកម្ពុជាអោយមានកំរិតឈានឡើងជាបន្តបន្ទាប់។

ស្ពានព្រែកតាមាក់ដែលត្រូវសាងសង់នៅពេលនេះមានប្រវែង១.០៦០ម៉ែត្រ ទទឹង១៣.៥ម៉ែត្រ មានប្រឡោះសសរកណ្តាលស្ពានប្រវែង១៧០ម៉ែត្រ និងកំពស់ធ្មៀបនឹងផ្ទៃទឹកអតិបរមាប្រវែង១៥ម៉ែត្រ។ ស្ពាននេះនឹងត្រូវចំណាយថវិកាសាងសង់សរុបជាង៤៣.៥លានដុល្លារអាមេរិក ក្នុងនោះរដ្ឋាភិបាលចិនផ្តល់ប្រាក់កម្ចីជាង៤១លានដុល្លារ ស្មើនឹង៩៥ភាគរយ និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួនជាង២លានដុល្លារអាមេរិក។

*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី០៧ ខែមិថុនា ឆ្នាំ២០០៧ ទំព័រ៥២។*

**ខេត្តក្វាងស៊ីចុះហត្ថលេខាលើគំរោងវិនិយោគ៤មានទឹកប្រាក់ចំនួន៤៥០លានដុល្លារ**

គំរោងវិនិយោគ៤មានទឹកប្រាក់សរុប៤៥០លានដុល្លារ ត្រូវបានធ្វើពិធីចុះហត្ថលេខាលើអនុស្សរណៈរវាងកម្ពុជា និងតំណាងក្រុមហ៊ុនវិនិយោគខេត្តក្វាងស៊ី របស់សាធារណៈរដ្ឋចិន។

ពិធីចុះហត្ថលេខាលើគំរោងវិនិយោគនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី៣០ខែឧសភាឆ្នាំ២០០៧ ដោយមានលោកអភិបាលរងខេត្តព្រះសីហនុ និងអភិបាលខេត្តក្វាងស៊ី។ គំរោងវិនិយោគទាំង៤នោះ រួមមាន : ទី១- គំរោងអភិវឌ្ឍន៍លំនៅដ្ឋានថ្មី ផ្ទះល្វែង។ ទី២- ការសាងសង់កំពង់ផែប្រេង (គំរោងទី១ និងទី២នេះ អនុវត្តនៅក្រុងព្រះសីហនុ)។ គំរោងទី៣- បង្កើតកសិដ្ឋានដាំដំឡូងមី និងធ្វើរោងចក្រកែច្នៃផលដំឡូងមី និងគំរោងទី៤- សាងផ្លូវហាយវេជាលក្ខណៈ

BOT មានចំងាយផ្លូវ១៦គីឡូម៉ែត្រពីរាជធានីភ្នំពេញទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ គំរោងទាំងអស់នេះនឹងត្រូវអនុវត្តបន្ទាប់ពីការចុះហត្ថលេខានេះតទៅ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី០២ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក៣។*

## ចិនផ្តល់រថយន្តពន្លត់អគ្គិភ័យ៣០គ្រឿងដល់កម្ពុជា

ពិធីប្រគល់នឹងទទួលជំនួយត្រូវបានធ្វើឡើងកាលពីថ្ងៃទី១០ខែឧសភា តាមរយៈការចុះហត្ថលេខាលើឯកសារមួយរវាងលោក ហុក ឡុងឌី និងលោកស្រី Zhang Jinfeng ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា និងក្រោមអធិបតីភាពរបស់លោកឧបនាយករដ្ឋមន្ត្រី ស ខេង។ *រស្មីកម្ពុជា ថ្ងៃសុក្រទី១១ខែឧសភាឆ្នាំ២០០៧ ទំព័រក៤។*

## អតីតរដ្ឋមន្ត្រីការបរទេសចិនមកកម្ពុជា

លោក Xu Dun Xin អតីតរដ្ឋមន្ត្រីការបរទេសចិន បានដឹកនាំគណប្រតិភូមួយក្រុមមកបំពេញទស្សនកិច្ចនៅកម្ពុជា ហើយបានចូលជួបសំដែងការគួរសមដោយឡែកៗពីគ្នាជាមួយសម្តេច ជា ស៊ីម និងសម្តេច ហ៊ុន សែន កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧។

ក្នុងជំនួបនោះសម្តេច ជា ស៊ីម បានថ្លែងអំណរគុណចំពោះប្រទេសចិន ដែលបានជួយដល់កម្ពុជាយ៉ាងច្រើនកន្លងមក ហើយក៏បានថ្លែងអំណរគុណចំពោះប្រទេសចិនដែលបានជួយដល់បណ្ណាល័យរបស់ព្រឹទ្ធសភា។

ដោយឡែកក្នុងជំនួបសម្តេច ហ៊ុន សែន លោក XU បានពាំនាំពាក្យផ្តាំផ្ញើរសួរសុខទុក្ខរបស់លោក វ៉ែន ជាបាវនាយករដ្ឋមន្ត្រីចិនជូនចំពោះសម្តេច ហ៊ុន សែន។ ជាមួយនេះសម្តេចហ៊ុន សែន ក៏បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់របស់មិត្តចិន និងសូមអបអរចំពោះខួប១០ឆ្នាំ នៃការវិលត្រឡប់នៃទីក្រុងហុងកុងមកស្ថិតក្រោមការគ្រប់គ្រងរបស់ចិនវិញ។

ក្នុងជំនួបដោយឡែកមួយទៀត លោក Xu ក៏បានចូលជួបសន្ទនាជាមួយលោក ហោ ណាំហុង ដែលជាមិត្តចាស់របស់លោកផងដែរ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៧ នៅក្រសួងការបរទេស។

*រស្មីកម្ពុជា ថ្ងៃពុធទី០៤ខែកក្កដា ឆ្នាំ២០០៧ ទំព័រក២។*

## រដ្ឋាភិបាលចិនផ្តល់ជំនួយសំភារៈដល់ គ ជ ប

តាមសំណើររបស់រដ្ឋាភិបាលកម្ពុជា និងតាមសេចក្តីរាយការណ៍ការងាររបស់ គ ជ ប រដ្ឋាភិបាលចិនបានសំរេចផ្តល់សំភារៈការិយាល័យចំនួន២៧ប្រភេទដែលមានទឹកប្រាក់សរុបចំនួន១០លានយន់ជូនដល់ គ ជ ប ដែលជំនួយនេះស្ថិតនៅក្នុងគំរោងបំរើអោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២ នៅឆ្នាំ២០០៧។

សំភារៈទាំងនោះមានដូចជា កុំព្យូទ័រ២៦០គ្រឿង ព្រីនធ័រ៦៦គ្រឿង ម៉ាស៊ីនស្តេន័រ១៦គ្រឿង ម៉ាស៊ីថតចំលង ៣៣គ្រឿង ម៉ាស៊ីនសេវា៥គ្រឿង ម៉ាស៊ីនស្វិតឈើ១០គ្រឿង វិទ្យុទាក់ទងលើតុនិងកាន់ដៃសរុបចំនួន១៣១១គ្រឿង និងសំភារៈមួយចំនួនផ្សេងទៀត។

ពិធីប្រគល់និងទទួលធ្វើឡើងរវាងលោកស្រី ហ្សាង ជីនហ្វេង ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា និងលោក អ៊ឹម សួស្តី ប្រធាន គ ជ ប កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៧។

កន្លងរដ្ឋាភិបាលចិនបានផ្តល់សំភារៈដល់ គ ជ ប ច្រើនដងមកហើយ ដូចជា នៅឆ្នាំ១៩៩៨ ចិនបានសំរេចផ្តល់រថយន្តហ្ស៊ីបចំនួន ២៧ គ្រឿងដល់ គ ជ ប ដែលមានតំលៃជាទឹកប្រាក់ ២៥០.០០០ ដុល្លារអាមេរិក ហើយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៣ កាលពីឆ្នាំ២០០៣ ចិនបានផ្តល់សំភារៈការិយាល័យចំនួន១២ប្រភេទ ដែលមានតំលៃជាទឹកប្រាក់សរុប ២០.០០០. ដុល្លាអាមេរិក។ *រស្មីកម្ពុជា ថ្ងៃពុធ ទី១១ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៣។*

**សម្តេច ហ៊ុន សែន : កម្ពុជាគាំទ្រនយោបាយចិនតែមួយ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ**

សម្តេចបានបញ្ជាក់ជាថ្មីម្តងទៀត ជំរាបជូនគណប្រតិភូបក្សកុម្មុនីស្តចិនកាលពីថ្ងៃទី១២ ខែកញ្ញ ឆ្នាំ២០០៨។ សម្តេចអរគុណចិនដែលចាត់ទុករូបសម្តេចជាមិត្តចាស់របស់ចិន ហើយក៏អរគុណចំពោះអតីតព្រះមហាក្សត្រកម្ពុជា សម្តេច នរោត្តម សីហនុ ដែលបានបង្កើតទំនាក់ទំនងមិត្តភាពលជាមួយបណ្តាមេដឹកនាំចិន តាំងពីដើមរៀងមក ហើយទំនាក់ទំនងដ៏ល្អប្រសើរនេះត្រូវបានរក្សាមកដល់ព្រះមហាក្សត្របច្ចុប្បន្ន។

លោក Wang Yang សមាជិកបក្សកុម្មុនីស្តចិន និងជាសមាជិកសភាខេត្តឆុងឈីងប្រទេសចិន បានមានប្រសាសន៍អរគុណចំពោះការគាំទ្រគោលនយោបាយចិនតែមួយថា បានរួមចំនែកការបង្រួបបង្រួមជាតិរបស់ប្រទេសចិន។ លោកបានសុំអោយសម្តេចបង្ហាញអំពីលទ្ធភាពដែលខេត្តឆុងឈីងរបស់ចិនអាចធ្វើការវិនិយោគនៅលើវិស័យណាខ្លះ។

សម្តេចបានជំរាបជូនទៅលោក Wang វិញថា ខេត្តឆុងឈីអាចពិនិត្យមើលការបង្កើតរោងចក្រផលិតឧបករណ៍កសិកម្ម ឬគ្រឿងបរិក្ខារអគ្គសនីជាដើម ដើម្បីបំរើទីផ្សារកម្ពុជា។ ជាមួយនេះ ក៏មានវិស័យជាច្រើនទៀតដូចជាហេដ្ឋារចនាសម្ព័ន្ធ វ៉ារីអគ្គសនី និងការបណ្តុះបណ្តាលធនធានមនុស្ស។ សម្តេចបញ្ជាក់ បន្ថែមទៀតថា កម្ពុជាមានទីផ្សារឥតខ្ចះទេ គ្រាន់ទីផ្សារកម្ពុជានៅចិនគឺអាចធ្វើការនាំចូលទំនិញទៅលក់នៅប្រទេសចិនដោយរួចពន្ធលើមុខទំនិញជាង ៤០០ មុខ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១៣ ខែកញ្ញា ឆ្នាំ២០០៨ ទំព័រក២។*

**ក្រសួងសន្តិសុខសាធារណៈចិនផ្តល់ម៉ូតូ១០៤គ្រឿងដល់ក្រសួងមហាផ្ទៃ**

ក្រសួងសន្តិសុខសាធារណៈនៃប្រទេសចិន បានផ្តល់អំណោយម៉ូតូសំរាប់ប៉ូលីសចរាចរធុន១២៥សេសេ ចំនួន១០៤ គ្រឿងជូនចំពោះក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជា ដើម្បីផ្តល់ជូនអគ្គស្នងការដ្ឋាននគរបាលជាតិចាត់ចែងប្រើប្រាស់បំរើបុព្វហេតុរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅក្នុងប្រទេសកម្ពុជា។

ក្រោមអធិបតីភាពលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកនាយឧត្តម សេនីយ៍ ហុក ឡងឌី អគ្គស្នងការនគរបាលជាតិ និងលោកស្រី ចាង ជីនហ្វឹង ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជាបានចុះហត្ថលេខាលើឯកសារប្រគល់ទទួលម៉ូតូសំរាប់ប៉ូលីសចរាចរ១០៤គ្រឿងនេះ។ *រស្មីកម្ពុជាថ្ងៃពុធ ទី២៦ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៣។*

**សម្តេច ហ៊ុន សែន អញ្ជើញជាអធិបតីសម្ពោធការិយាល័យពាណិជ្ជកម្មកម្ពុជាប្រចាំទីក្រុងណាននីងប្រទេសចិន**

ក្នុងឱកាសអញ្ជើញចូលរួមក្នុងការតាំងពិព័រណ៍ចិន-អាស៊ាន នៅប្រទេសចិន សម្តេច ហ៊ុន សែន និងគណៈប្រតិភូកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធអាគារការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជាប្រចាំក្រុងណានទីង ប្រទេសចិន ដែលក្នុងនោះភាគីចិនតំណាងដោយលោក លូ ប៊ីង អភិបាលខេត្តស្វយ័តក្វាងស៊ី។

អគារការិយាល័យពាណិជ្ជកម្មនោះមានកំពស់៣ជាន់ សង់នៅក្នុងបរិវេណសួនពាណិជ្ជកម្មអន្តរជាតិទីក្រុងណានទីង នៃខេត្តក្វាងស៊ី ហើយត្រូវចំណាយអស់ប្រមាណ ១.៣ លានដុល្លារ។

លោក ចម ប្រសិទ្ធ មានប្រសាសន៍នាឱកាសសម្ពោធកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៧ នោះថា ប្រទេសចិនបានធ្វើវិភាគទានដល់បណ្តាប្រទេសនានាក្នុងសមាគមអាស៊ាន ដើម្បីកសាងអាគារការិយាល័យពាណិជ្ជកម្មនេះឡើង ប្រយោជនដើម្បីសំរួលដល់ការទំនាក់ទំនងពាណិជ្ជកម្មអោយបានកាន់តែប្រសើរ។

លោក លូ ប៊ីង បានលើកឡើងផងដែរថា ការផ្តល់ទីធ្លាសំរាប់ការកសាងនេះ គឺធ្វើឡើងសំរាប់បណ្តាប្រទេសនានាក្នុងតំបន់អាស៊ាន សំរាប់សំរួលដល់ការធ្វើពាណិជ្ជកម្ម ដែលមានទឹកប្រាក់សរុបប្រមាណ ១៦០.៨ ពាន់លានដុល្លារ សំរាប់ក្របខ័ណ្ឌអាស៊ាន-ចិន ហើយគ្រាន់តែរយៈរយៈពេល៨ខែដើមឆ្នាំនេះ មានទឹកប្រាក់ប្រមាណ ២៧.៩៥ ពាន់លានដុល្លារ។

គេរំពឹងថា ទំនាក់ទំនងទ្វេរភាគីរវាងអាស៊ាន-ចិន នឹងកើនឡើងដល់ ១៩០ ពាន់លានដុល្លារនៅក្នុងឆ្នាំ២០០៧។ ក្នុងក្របខ័ណ្ឌទំនាក់ទំនងទ្វេរភាគីរវាងចិន-កម្ពុជា ប្រទេសចិនបានផ្តល់អោយកម្ពុជានូវទឹកប្រាក់កម្ចីនិងជំនួយឥតសំណងសំរាប់ការកសាងស្ពានព្រែកតាមាក់ ស្ពានព្រែកក្តាម និងនៅខេត្តស្ទឹងត្រែង។ ហើយប្រទេសចិនក៏បានផ្តល់ហិរញ្ញប្បទានដល់ប្រទេសកម្ពុជាប្រមាណជាង ៩០ លានដុល្លារក្នុងវេទិកាកិច្ចសហប្រត្តិការអភិវឌ្ឍន៏កម្ពុជា កាលពីខែសីហា ឆ្នាំ២០០៧ សំរាប់ស្តារនិងអភិវឌ្ឍន៏ប្រទេសកម្ពុជាផងដែរ។ *រស្មីកម្ពុជា ថ្ងៃអង្គារទី៣០ ខែតុលា ឆ្នាំ២០០៧ ទំព័រក៤។*

## ចិនផ្តល់ជំនួយឥតសំណង១៣០លានយន់ទៀតដល់កម្ពុជា

ប្រទេសចិនបានសំរេចផ្តល់ជំនួយប្រមាណ១៣០លានយន់ ដល់ប្រទេសកម្ពុជាបន្ថែមទៀតនៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់សម្តេច ហ៊ុន សែននៅខេត្តក្វាងស៊ី ពីថ្ងៃទី២៧ ដល់២៨ ខែតុលា ឆ្នាំ២០០៧។

លោក ស្រី ថាមរុង្គ ទីប្រឹក្សាសម្តេច ហ៊ុន សែន បានអោយដឹងថា ក្នុងដំណើរទស្សនកិច្ចនោះ សម្តេច ហ៊ុន សែន បានទទួលជួបសវនាការជាមួយលោកលេខាបក្សខេត្តក្វាងស៊ី និងបានជួបជាមួយលោកឧបនាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សារដ្ឋចិន ហើយនៅក្នុងឱកាសនោះសម្តេចក៏បានធ្វើជាសាក្សីនៅក្នុងពិធីចុះកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសរវាងកម្ពុជានិងចិន ដែលកិច្ចព្រមព្រៀងនេះស្តីពីការផ្តល់នូវហិរញ្ញប្បទានជំនួយឥតសំណងដែលមានទឹកប្រាក់ចំនួន៨០លានយន់ ជាជំនួយឥតសំណងនិង៥០លានយន់ទៀតជាឥណទានគ្មានការប្រាក់។

*រស្មីកម្ពុជា ថ្ងៃអង្គារ៍ ទី៣០ ខែតុលា ឆ្នាំ២០០៧ ទំព័រក៤។*

## ចិនផ្តល់លុយដល់កម្ពុជានិងប្រទេសនៅមហាអនុតំបន់មេគង្គ

រដ្ឋាភិបាលចិនបានសំរេចផ្តល់ថវិកាចំនួន ៥០០.០០០ ដុល្លារ ដល់ ADB សំរាប់ចាត់ចែងជំនួយបច្ចេកទេសដល់ប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀតនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដើម្បីពង្រឹងគំរោងកាត់បន្ថយភាពក្រីក្រ

នៅក្នុងតំបន់។ ប្រភពពីADBកាលពីថ្ងៃទី១៤ខែវិច្ឆិកាបានអោយដឹងថា ទឹកប្រាក់ទាំងនេះនឹងប្រើប្រាស់លើជំនួយបច្ចេកទេសនៅក្នុងការគ្រប់គ្រងនិងវាយតំលៃលើគំរោងកាត់បន្ថយភាពក្រីក្រទាំងឡាយដែលកំពុងតែដំណើរការនៅក្នុងមហាអនុតំបន់ទន្លេមេគង្គទាំងមូល ជាពិសេសវៀតណាម ឡាវ និងកម្ពុជា។

*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ៨។*

## ៥_ទំនាក់ទំនងកម្ពុជា និងប្រទេសកូរ៉េ

### កូរ៉េខាងត្បូងស្ថិតនៅលើគេក្នុងបញ្ជីគំរោងវិនិយោគនៅកម្ពុជា

ការវិនិយោគនៅកម្ពុជាបានកើនឡើងដល់ជាង៤ពាន់លានដុល្លារនៅឆ្នាំ២០០៦ ហើយប្រទេសកូរ៉េខាងត្បូងបានបណ្តាក់ទុនច្រើនជាងគេខណ:ដែលប្រទេសជប៉ុនចាប់ផ្តើមមានការវិនិយោគនៅក្នុងប្រទេសកម្ពុជាទោះបីជាស្ថិតនៅក្រោមគេលំដាប់ទី១៤ក៏ដោយ។

តាមតួលេខដែលធ្វើឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍វិនិយោគកម្ពុជាបានអោយដឹងថា ការវិនិយោគនៅកម្ពុជាក្នុងឆ្នាំ២០០៦ មានចំនួនទឹកប្រាក់ជាង ៤.៤ ពាន់លានដុល្លារ ដោយក្នុងនោះគំរោងវិនិយោគដោយក្រុមហ៊ុននៅកម្ពុជាចំនួនជាង ២ ពាន់លានដុល្លារ ហើយក្រៅពីនេះគឺជាការវិនិយោគមកពីប្រទេស ១៤ ផ្សេងទៀត។

ក្នុងចំណោមប្រទេសទាំង ១៤ នោះ ប្រទេសកូរ៉េខាងត្បូងមានការវិនិយោគច្រើនជាងគេ គឺមានរហូតដល់ជាងមួយពាន់លានដុល្លារ ហើយប្រទេសចិនស្ថិតនៅលំដាប់ថ្នាក់ទី២ ដោយវិនិយោគជាទឹកប្រាក់ជាង ៧១៧ លានដុល្លារ។

តួលេខរបស់ក្រុមប្រឹក្សាវិនិយោគកម្ពុជា ក៏បង្ហាញផងដែរថា ប្រទេសរុស្ស៊ីជាប្រទេសដែលមានគំរោងវិនិយោគច្រើនជាងគេលំដាប់ថ្នាក់ទី៣ ជាមួយនឹងទឹកប្រាក់ជាង ២៧៧ លានដុល្លារ ហើយប្រទេសថៃស្ថិតនៅលំដាប់ថ្នាក់លេខ ៤ មានទឹកប្រាក់ ជាង ១០០ លានដុល្លារ សហរដ្ឋអាមេរិកស្ថិតនៅលំដាប់ថ្នាក់ទី៥ ជាមួយនឹងទឹកប្រាក់ ៦២.២ លានដុល្លារ។

ចំណែកប្រទេស៩ទៀត ដែលមានគំរោងវិនិយោគក្នុងប្រទេសកម្ពុជា រួមមាន ម៉ាឡេស៊ី វៀតណាម សិង្ហបុរី កាណាដា បែលហ្ស៊ិក អង់គ្លេស កោះតៃវ៉ាន់ ទីក្រុងហុងកុង និងប្រទេសជប៉ុន។

កាលពីឆ្នាំ ២០០៥ គំរោងវិនិយោគដែលបានចុះបញ្ជីមានតំលៃជាទឹកប្រាក់ត្រឹមតែជាងមួយពាន់លានដុល្លារតែប៉ុណ្ណោះ ហើយប្រទេសចិន គឺជាប្រទេសដែលមានគំរោងវិនិយោគច្រើនជាងគេបំផុត ដោយមានទឹកប្រាក់ចំនួនជាង ៤៥៣ លានដុល្លារ។ នៅក្នុងឆ្នាំ ២០០៥ នោះ ប្រទេសកូរ៉េខាងត្បូងមានគំរោងវិនិយោគគិតជាតំលៃទឹកប្រាក់ ៥៦ លានដុល្លារ ដោយស្ថិតនៅលំដាប់ទី៣។ ចំណែកពេលនោះប្រទេសថៃស្ថិតនៅលំដាប់ថ្នាក់ទី២ ដោយមានគំរោងវិនិយោគជាង ៨១ លានដុល្លារ។

បើពិនិត្យទៅតាមវិស័យនោះ ឆ្នាំ២០០៦ ការវិនិយោគភាគច្រើនបំផុត គឺផ្នែកសេវាកម្ម ដែលមានតំលៃជាទឹកប្រាក់២៥៩លានដុល្លារ ដោយក្នុងនោះគំរោងផ្នែកសំណង់មានច្រើនជាងគេ គឺតំលៃជាទឹកប្រាក់ជាង ២.៤៤៤លានដុល្លារ។ វិស័យឧស្សាហកម្មវិញមានគំរោងវិនិយោគចំនួនជាង៩៤៥លានដុល្លារ។ ចំណែកគំរោងវិនិយោគក្នុងវិស័យទេសចរណ៍វិញ

មានតំលៃជាទឹកប្រាក់ជាង៣៥២លានដុល្លារ ហើយគំរោងវិនិយោគកសិកម្មមានតំលៃជាទឹកប្រាក់ជាង៥១៤លានដុល្លារ។
*កាសែតកោះសន្តិភាព ចេញផ្សាយថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧។*

## នាយករដ្ឋមន្ត្រីកម្ពុជាស្នើអោយកូរ៉េរក្សាភាពនាំមុខលើវិស័យ៥នៅកម្ពុជា

នៅក្នុងឱកាសអនុញ្ញាតអោយលោក Kim Guan Yong អភិបាលខេត្តឃ្យុងសាងប៊ូកដូ នៃសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី០៥ខែមីនា សម្តេច ហ៊ុន សែន បានមានប្រសាសន៍ថា ប្រទេសកូរ៉េបាននាំមុខគេលើវិស័យ៥នៅកម្ពុជា ដែលក្នុងនោះ **ទី១**– វិស័យវិនិយោគទុន **ទី២**– វិស័យទេសចរណ៍ **ទី៣**– វិស័យវប្បធម៌ **ទី៤**– វិស័យព័ត៌មានវិទ្យា(IT) **និងទី៥**– វិស័យអភិវឌ្ឍន៍ធនធានមនុស្ស។

លោក Kim បានជំរាបសម្តេចថា បំណងរបស់លោកមកកាន់ប្រទេសកម្ពុជានាពេលនេះ គឺដើម្បីសាងសង់នូវអគារវប្បធម៌ចំនួន២នៅក្នុងប្រទេសកម្ពុជា ដែលមួយកន្លែងកសាងនៅខេត្តសៀមរាប និងមួយកន្លែងទៀតនៅទីក្រុងភ្នំពេញ។ ជាមួយគ្នានេះ លោក Kim ក៏បានគោរពអញ្ជើញសម្តេចនិងលោកជំទាវទៅចូលរួមក្នុងពិធីតាំងពិព័រណ៍ពិភពលោកឃ្យុងយូ នៅខែកញ្ញា ឆ្នាំ២០០៧ ខាងមុខនៅទីក្រុងឃ្យុងយូ។

ជាការឆ្លើយតប សម្តេចបានស្នើកូរ៉េបន្តជួយដល់កម្ពុជាបន្ថែមទៀតដើម្បីអោយកូរ៉េនៅតែបន្តការនាំមុខលើវិស័យទាំង៥ ហើយសម្តេចក៏បានទទួលយកការអញ្ជើញរបស់លោក Kim និងសូមគាំទ្រនៅគោលបំណងរបស់លោក Kim ដែលបានសំរេចចិត្តសាងសង់អគារវប្បធម៌នោះផងដែរ។ *រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៧។*

## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងថវិកាកូរ៉េខាងត្បូង ព្រមព្រៀងធ្វើសហប្រតិបត្តិការជាមួយគ្នា

មន្ត្រីហិរញ្ញវត្ថុបាននិយាយអោយដឹងថា កាលពីថ្ងៃទី២៤ ខែមេសា ក្រសួងសេដ្ឋកិច្ច និងក្រសួងថវិការបស់កូរ៉េខាងត្បូង បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីជំរុញការធ្វើទំនាក់ទំនងរវាងក្រសួងទាំងពីរក្នុងវិស័យសហិរញ្ញវត្ថុសាធារណៈ។

លោក ជូ គឹមសួង អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងលោក Ho In Kang ប្រធានប្រតិភូកូរ៉េខាងត្បូងបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់នេះនៅក្រសួងសេដ្ឋកិច្ចកម្ពុជា។
*រស្មីកម្ពុជា ថ្ងៃពុធទី២៥ ខែមេសា ឆ្នាំ២០០៧ ទំព័រ៤។*

## សម្តេច ហ៊ុន សែន កត់សំគាល់ថា កូរ៉េខាងត្បូងស្ថិតក្នុងលំដាប់ទី១នៃទំហំទឹកប្រាក់បណ្តាក់ទុននៅកម្ពុជា

សម្តេចបានធ្វើការកត់សំគាល់ថា ទោះបីជាទំនាក់ទំនងកម្ពុជា-កូរ៉េ ទើបមានអាយុ១០ឆ្នាំ ក៏ប៉ុន្តែកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរមានការរីកចំរើនគួរអោយកត់សំគាល់ ដូចជាវិស័យទេសចរណ៍ វិស័យព័ត៌មានវិទ្យានិងការបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យវប្បធម៌ សិល្បៈ និងការវិនិយោគ ដែលសព្វថ្ងៃនេះ កូរ៉េស្ថិតនៅក្នុងលំដាប់ថ្នាក់ទី១នៃទំហំទឹកប្រាក់ដែលបានបណ្តាក់ទុននៅកម្ពុជា។

សម្តេចធ្វើលើកឡើងក្នុងពេលអនុញ្ញាតអោយលោក Park Sangkoo ស្ថាបនិកនៃគំរោងស្ថាបនាទីក្រុងរណបថ្មី និងជាប្រធានកិត្តិយសនៃធនាគារ BUSAN-MUTUAL SAVING កូរ៉េ ចូលជួបកាលថ្ងៃទី០១ ខែមិថុនា នៅតាខ្មៅ។

ប្រភពនៃជំនួបនោះក៏បានបញ្ជាក់អោយដឹងផងដែរថា នៅក្នុងជំនួបនោះលោក Park បានសុំការអនុញ្ញាតពីសម្តេច ហ៊ុន សែន ដើម្បីរួមវិភាគទានក្នុងការស្ថាបនាអគារសាលាក្រុងថ្មីនៅទីក្រុងរលាប ដែលមានតំលៃទឹកប្រាក់ប្រមាណ២០លានដុល្លារអាមេរិក ដែលជាអំណោយរបស់ក្រុមហ៊ុនជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា និងផ្តល់អាហារូបករណ៏ដល់សិស្សថ្នាក់មធ្យមសិក្សា ដែលក្នុងនោះជ្រើសរើសយកសិស្សពូកែ៥នាក់ធ្វើការបណ្តុះបណ្តាលរហូតដល់កំរិតខ្ពស់។

*រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី០២ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក២។*

## កូរ៉េខាងត្បូងផ្តល់កម្ចីជាង៣៦លានដុល្លារសំរាប់ស្តារផ្លូវជាតិលេខ៣

ស្ថានទូតកូរ៉េប្រចាំកម្ពុជាបានអោយដឹងនៅថ្ងៃទី៧ខែឧសភាឆ្នាំ២០០៧នេះថា កិច្ចសំរបសំរួលមួយស្តីពីកម្ចីមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចនេះ ត្រូវបានចុះហត្ថលេខាដោយលោក ហោ ណាំហុង និង លោក ស៊ិន យុនស៊ុន ឯកអគ្គរដ្ឋទូតកូរ៉េប្រចាំកម្ពុជា ក្រោមអធិបតីភាពរបស់សម្តេច ហ៊ុន សែន។

ស្ថានទូតកូរ៉េ បានអោយដឹងដែរថា អំឡុងពេលនៃកិច្ចពិភាក្សាជាផ្លូវការរវាងលោក រ៉ូ មូយុន ប្រធានាធិបតីកូរ៉េ និងសម្តេច ហ៊ុន សែន នៅក្នុងឱកាសទស្សនកិច្ចផ្លូវរដ្ឋកាលពីថ្ងៃទី១៩-២២ ខែវិច្ឆកា ឆ្នាំ២០០៦ លោកប្រធានាធិបតី រ៉ូ បានសន្យាផ្តល់នូវកម្ចីសម្បទាន(EDCF)សំរាប់គំរោងស្តារឡើងវិញនូវកំណាត់ផ្លូវជាតិលេខ៣ដំណាក់កាលទី២។ ការចុះហត្ថលេខាទៅកិច្ចសំរបសំរួលដែលបានបញ្ជាក់ជូនខាងលើគឺអនុវត្តន៏ទៅតាមការសន្យានេះ។

គួររំលឹកថា រដ្ឋាភិបាលកូរ៉េបានផ្តល់រួចមកហើយចំពោះរដ្ឋាភិបាលកម្ពុជា ជាមួយនឹងកម្ចី EDCF ដែលមានចំនួនទឹកប្រាក់ ១៧.០៥០.០០០ ដុល្លារ សំរាប់គំរោងស្តារឡើងវិញនូវកំណាត់ផ្លូវជាតិលេខ៣ដំណាក់កាលទី១។

*រស្មីកម្ពុជា ថ្ងៃអង្គារ៍ ទី០៨ ខែឧសភា ឆ្នាំ២០០៧ ទំព័រក១។*

## អនុរដ្ឋមន្ត្រីការបរទេសខាងត្បូងវាយតំលៃទំនាក់ទំនងកម្ពុជា-កូរ៉េក្នុងរយៈពេល១០ឆ្នាំ

នៅក្នុងឆ្នាំ២០០៧នេះ ទំនាក់ទំនងរវាងកម្ពុជានិងសាធារណៈរដ្ឋកូរ៉េបានឈានដល់គំរប់១០ឆ្នាំហើយ អនុរដ្ឋមន្ត្រីការបរទេសកូរ៉េ បានវាយតំលៃខ្ពស់ចំពោះការរីកចំរើននៃទំនាក់ទំនងរវាងប្រទេសទាំង២ ទាំងផ្នែកសេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។

ថ្លែងនៅឯក្រសួងការបរទេសនិងពាណិជ្ជកម្ម ទីក្រុងសេអ៊ូល លោកអនុរដ្ឋមន្ត្រីការបរទេស Shim Yoon Joe បានលើកឡើងថា ទំនាក់ទំនងរវាងប្រទេសទាំងពីរនេះបានឈានដល់កំរិតកំពូល ពិសេសតាមរយៈដំណើរទស្សនកិច្ចរបស់សម្តេច ហ៊ុន សែន មកកូរ៉េកាលពីឆ្នាំ២០០១និងឆ្នាំកន្លងមកក៏បានមកម្តងទៀត។ ជាមួយនេះកាលពីខែវិច្ឆកា ឆ្នាំ២០០៦ កម្ពុជាបានទទួលដំណើរទស្សនកិច្ចប្រវត្តិសាស្ត្ររបស់ប្រធានាធិបតី កូរ៉េខាងត្បូង Roh Moo-hyun ។

នៅក្នុងការចាប់ដៃជាមិត្តភ័ក្តិល្អ ប្រទេសកូរ៉េបានរួមចំណែកគួរអោយកត់សំគាល់នៅក្នុងការជួយអភិវឌ្ឍន៏ប្រទេសកម្ពុជា។ ជំនួយរបស់កូរ៉េចំពោះកម្ពុជាបានកើនឡើងដល់ជាង២៤លានដុល្លារ ហើយសំរាប់ឆ្នាំ២០០៧កូរ៉េខាងត្បូងនឹងផ្តល់ជំនួយចំនួន៦.៧ លានដុល្លារជូនដល់កម្ពុជា ដោយកើនឡើងពីប្រមាណ៦លានដុល្លារនៅឆ្នាំ២០០៦។

លោកអនុរដ្ឋមន្ត្រីបានអោយដឹងថា មានក្រុមហ៊ុនកូរ៉េចំនួនជាង១៦០ កំពុងតែរកស៊ីនៅក្នុងប្រទេសកម្ពុជា ដោយមានការកើនឡើងខ្លាំងរហូតដល់ទៅចំនួនពីរដងបើប្រៀបធៀបទៅឆ្នាំ២០០៥។ ក្នុងចំណោមក្រុមហ៊ុនទាំងនោះភាគច្រើនរកស៊ីខាងផ្នែកសេវាកម្ម បន្ទាប់មកផ្នែកវាយនភណ្ឌនិងផលិតកម្មរោងចក្រ។ កូរ៉េមានឆន្ទៈដើម្បីចែករំលែកជំនាញនៅក្នុងការអភិវឌ្ឍន៍ដើម្បីចូលរួមចំនែកនៅក្នុងការកាត់បន្ថយគម្លាតក្នុងសមាគមន៍អាស៊ាន។ ដូច្នេះហើយកម្ពុជាបានក្លាយជាប្រទេសដ៏សំខាន់ក្នុងការទទួលជំនួយពីកូរ៉េចាប់ តាំងពីឆ្នាំ២០០៣មក។ ក្រៅពីជំនួយរៀបរាប់ដូចខាងលើ កូរ៉េនៅបានជួយកម្ពុជាលើវិស័យជាច្រើនទៀត។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី៣ ខែឧសភា ឆ្នាំ២០០៧ ទំព័រក៣។*

## កិច្ចព្រមព្រៀងពាណិជ្ជកម្មអនុវត្តគំរោងប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា ដែលមានទឹកប្រាក់ជិត៣០លានដុល្លារត្រូវបានចុះហត្ថលេខា

កិច្ចព្រមព្រៀងពាណិជ្ជកម្មសំរាប់អនុវត្តគំរោងប្រព័ន្ធព័ត៌មានវិទ្យារវាងរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន Kisan Telecome Co. Ltd របស់កូរ៉េ ដែលមានទឹកប្រាក់ប្រមាណជិត៣០លានដុល្លារអាមេរិក ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី១៩ខែកក្កដាឆ្នាំ២០០៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

កិច្ចព្រមព្រៀងនេះចុះហត្ថលេខាដោយលោក សុខ អាន និងលោក Park Byung Ki ជាប្រធាន CEO របស់ក្រុមហ៊ុន Kisan ។

លោក សុខ អាន មានប្រសាសន៍ថា គំរោងប្រព័ន្ធរដ្ឋបាលលើកទី២នេះ គឺជាគំរោងបន្តពីគំរោងលើកទី១ ដែលបានអនុវត្តប្រកបដោយជោគជ័យ។ គំរោងទី២ ដែលមានទឹកប្រាក់ប្រមាណជិត៣០លានដុល្លារអាមេរិកនេះ នឹងឈានទៅរៀបចំប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យាតាមបណ្តាខេត្តប្រមាណ១០ក្នុងប្រទេសកម្ពុជា។ លោកបានបញ្ជាក់ទៀតថា អាជ្ញាធរជាតិ NIDA នឹងក្លាយជាអ្នកផ្គត់ផ្គង់ធនធានមនុស្សទៅកាន់ខេត្ត-ក្រុងទាំង១០ ដើម្បីប្រតិបត្តិការគំរោងទី២នេះអោយបានជោគជ័យ និងជួយបណ្តុះបណ្តាលមន្ត្រីនៅតាមបណ្តោយខេត្ត-ក្រុងទាំង១០។

គួរបញ្ជាក់ថា គំរោងប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យាលើកទី១ ក៏បានចំណាយថវិកាកម្ចីរបស់រដ្ឋាភិបាលកូរ៉េប្រមាណជាង២០លានដុល្លារអាមេរិកផងដែរ ប៉ុន្តែជាកម្ចីដែលមានការប្រាក់ទាបបំផុត។

*រស្មីកម្ពុជា ថ្ងៃសុក្រទី២០ ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៤។*

## សម្តេច ហ៊ុន សែន កត់សំគាល់ពីការនាំមុខរបស់កូរ៉េនៅក្នុងប្រទេសកម្ពុជា

សម្តេច ហ៊ុន សែន បានធ្វើការកត់សំគាល់ថា ក្នុងរយៈពេលនៃការភ្ជាប់ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរដែលមានរយៈពេលត្រឹម១០ឆ្នាំ ក៏ប៉ុន្តែប្រទេសកូរ៉េបានធ្វើអោយមានការនាំមុខយ៉ាងច្រើន ដូចជាវិស័យទេសចរណ៍ វិស័យវិនិយោគ វិស័យបណ្តុះបណ្តាលធនធានមនុស្ស វិស័យព័ត៌មានវិទ្យា ការទទួលយកពលករកម្ពុជាទៅធ្វើការនៅប្រទេសកូរ៉េ និងវិស័យវប្បធម៌។

សម្តេចបានធ្វើការកត់សំគាល់បែបនេះ នៅក្នុងជំនួបជាមួយលោក Park Sung Vam ប្រធានសមាគមមិត្តភាពសភាកូរ៉េ-កម្ពុជា កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ នៅក្រសួងការបរទេស។ ជាមួយនេះសម្តេចក៏បានសំដែងការរីករាយចំពោះការវិវត្តន៍ដ៏ឆាប់រហ័សនៃទំនាក់ទំនងការទូតនិងកិច្ចសហប្រតិបត្តិការដែលកំពុងតែឈានឡើងជាលំដាប់។

សម្តេច ហ៊ុន សែន ត្រូវបានចាត់ទុកថា ជាអ្នកស្ថាបនិកនៃទំនាក់ទំនងកម្ពុជា-កូរ៉េខាងត្បូង ហើយរូបសម្តេចត្រូវបានប្រជាជនកូរ៉េគោរពនឹងស្រលាញ់យ៉ាងជ្រាលជ្រៅ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី០៧ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ២។*

## កូរ៉េខាងត្បូងជាប់ចំណាត់ថ្នាក់លេខ១ខាងវិនិយោគនិងទេសចរណ៍នៅកម្ពុជា

ប្រទេសកូរ៉េខាងត្បូងបានក្លាយជាប្រទេសឈានមុខគេក្នុងការវិនិយោគនៅប្រទេសកម្ពុជា ហើយគឺជាប្រទេសដែលមានចំនួនភ្ញៀវទេសចរណ៍ច្រើនជាងគេបំផុតមកទស្សនានៅប្រទេសកម្ពុជា។ នៅឆ្នាំ២០០៦កូរ៉េខាងត្បូងវិនិយោគនៅកម្ពុជាគិតជាទឹកប្រាក់១.១ពាន់លានដុល្លារដោយជាប់ចំណាត់ថ្នាក់លេខ១ ហើយជនជាតិកូរ៉េ ២៨៥.០០០នាក់ បានមកលេងនៅកម្ពុជា។

លោកឯកអគ្គរដ្ឋទូតកូរ៉េខាងត្បូងប្រចាំកម្ពុជា Shin Hyun Suk បានធ្វើបទសំភាសន៍ជាមួយកាសែតរស្មីកម្ពុជាថា : កម្ពុជា និងកូរ៉េបានបង្កើតទំនាក់ទំងការទូតជាមួយគ្នាអស់រយៈពេល១០ឆ្នាំហើយ ហើយយើងបានចែករំលែកគ្នានូវបទពិសោធន៍ប្រវត្តិសាស្ត្រជាច្រើន។ ដោយសារកូរ៉េជាប្រទេសមានចំណាត់ថ្នាក់ទី១១ ខាងសេដ្ឋកិច្ចនៅលើពិភពលោក ដូច្នេះកូរ៉េកំពុងតែព្យាយាមយ៉ាងសកម្មដើម្បីចែករំលែកចំណេះដឹងនៅក្នុងការអភិវឌ្ឍន៍ជាតិដល់ប្រទេសកម្ពុជា។

លើវិស័យសហប្រត្តិការរវាងប្រទេសទាំងពីរ លោកទូតបានមានប្រសាសន៍ថា : កម្ពុជា-កូរ៉េមានទំនាក់ទំនងលើគ្រប់វិស័យ។ ហើយទំនាក់ទំនងនេះត្រូវបានពង្រឹងនិងពង្រីកបន្ថែមតាមរយៈដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំកំពូលរបស់រដ្ឋាភិបាលទាំងពីរ គឺសម្តេច ហ៊ុន សែន ធ្វើទស្សនកិច្ចនៅកូរ៉េ និងប្រធានាធិបតីកូរ៉េ រ៉ូមូយុន ធ្វើទស្សនកិច្ចនៅកម្ពុជា។ ដោយទំនាក់ទំនងមានលក្ខណៈប្រសើរខ្លាំង ទើបធ្វើអោយកូរ៉េបន្ថែមការវិនិយោគមកកាន់កម្ពុជា និងធ្វើទេសចរណ៍។

កូរ៉េបានជាប់ចំណាត់ថ្នាក់លេខ១ខាងការវិនិយោគបរទេសដោយផ្ទាល់ និងខាងទេសចរណ៍នៅកម្ពុជា។ កូរ៉េបានដើរតួនាទីនាំមុខគេនៅក្នុងសហប្រតិបត្តិការសេដ្ឋកិច្ចនិងឧស្សាហកម្ម បច្ចេកវិជ្ជាព័ត៌មាន។ កូរ៉េបានជាប់ចំណាត់ថ្នាក់លេខ ១ បីឆ្នាំជាប់គ្នាដោយមានចំនួនអ្នកទេសចរណ៍មកកាន់កម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះក្រុមហ៊ុនអាកាសចរណ៍កូរ៉េ ក៏មានជើងហោះហើរដោយផ្ទាល់មកកម្ពុជា គឺ Korea Air និង Asiana Air ភ្នំពេញ-សេអ៊ូល និងសេអ៊ូល-សៀមរាប។

ចំពោះជំនួយគាំទ្រដល់ការអភិវឌ្ឍន៍ផ្សេងៗ កូរ៉េបានផ្តល់ជំនួយប្រហែល៤០លានដុល្លារជាជំនួយឥតសំណង និងប្រាក់កម្ចីការប្រាក់ទាបជារៀងរាល់ឆ្នាំដល់កម្ពុជា។

កូរ៉េកំពុងតែជួយគាំទ្រដល់កម្ពុជាចំពោះគំរោងបច្ចេកវិទ្យាព័ត៌មានចំនួនពីរ គឺគំរោងប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់រដ្ឋាភិបាល និងគំរោងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងប្រព័ន្ធព័ត៌មានរដ្ឋបាលខេត្ត។ គំរោងទី១បានបញ្ចប់រួចហើយនៅឆ្នាំ២០០៥ ចំណែកគំរោងទី២ទើបតែចាប់ផ្តើម។

វិទ្យាស្ថានពហុបច្ចេកវិជ្ជាជាតិកម្ពុជា ត្រូវបានបង្កើតឡើងនៅខែឧសភាឆ្នាំ២០០៥ ក្រោមប្រាក់ឥណទាន ២៧.៧ លានដុល្លារអាមេរិក របស់កូរ៉េ។ ជាមួយនេះ កូរ៉េក៏នៅមានការផ្លាស់ប្តូរវប្បធមិត្តទៅវិញទៅមក ដូចជាការរៀបចំតាំង

ពិព័រណ៍ពិភពលោកអង្គរ-យ៉ុងយូ ការសំដែងសិល្បៈកូរ៉េនៅកម្ពុជា ការសំដែងសិល្បៈកម្ពុជានៅកូរ៉េ និងមហោស្រព ភាពយន្តកូរ៉េនៅទីក្រុងភ្នំពេញជារៀងរាល់ឆ្នាំ។

កូរ៉េកំពុងតែរួមចំណែកជួយស្តារនិងអភិវឌ្ឍន៍កម្ពុជាតាមរយៈជំនួយអភិវឌ្ឍន៍ផ្លូវការ និងការគាំទ្រវិស័យឯកជន។ ជំនួយឥតសំណងរបស់កូរ៉េតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកូរ៉េសំរាប់កម្ពុជា កំពុងតែកើនឡើងជាប់រហូត។ នៅឆ្នាំ ២០០៦ ជំនួយនេះមានចំនួន ៦.៨៥ លានដុល្លារ ហើយឆ្នាំ២០០៧ ជំនួយឥតសំណងនេះ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៧ លានដុល្លារ។ ក្នុងពេលជាមួយគ្នានេះ ក៏មានអ្នកស្ម័គ្រចិត្តកូរ៉េ នៅទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ចំនួន ៧០ នាក់កំពុងតែធ្វើការបង្រៀននៅក្នុងប្រទេសកម្ពុជា ដូចជាផ្នែកសុខាភិបាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមហ៊ុនកូរ៉េជាច្រើនទៀតបាននិងកំពុងជួយកម្ពុជាលើវិស័យអប់រំ សុខាភិបាល និងអភិវឌ្ឍន៍ជនបទ។

ក្រុមហ៊ុនកូរ៉េដែលកំពុងប្រតិបត្តិការវិនិយោគនៅកម្ពុជាមានលើផ្នែក កាត់ដេរ សំណង់ ធនាគារ ទេសចរណ៍ និងសេវាកម្មដទៃទៀត។ ក្រុមហ៊ុនកូរ៉េសំខាន់ៗរួមមាន ក្រុមហ៊ុនកាត់ដេរចំនួន ៣៥ ក្រុមហ៊ុន ក្រុមហ៊ុនខ្សែកាប្លិ៍ KTC Cable Company, MH-Bio Company, Tongyang investment, Camko Bank, Shinhan Bank, World City, Hanil Construction, Posco Construction, Imperial Garden Villa and Hotel, Korean Air និង Asianna Airline ជាដើម។ នៅឆ្នាំ២០០៦ ការវិនិយោគកូរ៉េនៅកម្ពុជា បានកើនឡើងដល់ ១១០០ លានដុល្លារ។

លោកទូតបញ្ជាក់បន្ថែមថា ពាណិជ្ជកម្មរវាងប្រទេសកម្ពុជា-កូរ៉េនៅមិនទាន់សកម្មនៅឡើយទេ។ កូរ៉េបាននាំទំនិញចូលមកកាន់កម្ពុជាចំនួន ១៥០ លានដុល្លារក្នុងមួយឆ្នាំ។ កម្ពុជានាំចេញទៅកូរ៉េវិញមានចំនួនតែ ៦ លានដុល្លារតែប៉ុណ្ណោះ នេះព្រោះដោយសារផលិតផលកម្ពុជានៅទាន់ខ្សោយ។

ម្យ៉ាងទៀតក៏មានការប្រែប្រួលច្រើនចំពោះភ្ញៀវទេសចរណ៍របស់នៅកម្ពុជា ក្រោយព្រឹត្តការណ៍ធ្លាក់យន្តហោះនៅក្រុងព្រះសីហនុដែលបណ្តាលអោយស្លាប់ជនជាតិកូរ៉េចំនួន២២នាក់។ ប៉ុន្តែយ៉ាងនេះក្តីក៏មកកាន់កម្ពុជាដើម្បីបុព្វហេតុជំនួយនិងអ្នកស្ម័គ្រចិត្តដទៃមានការកើនឡើងបើធៀបជាមួយបណ្តាឆ្នាំមុនៗ។ តែសំខាន់ក៏ត្រូវពង្រឹងសុវត្ថិភាពផ្លូវអាកាសផងដែរជាមួយគ្នានេះ។

លោកក៏បានលើកអនុសាសន៏ផងដែរថា ដើម្បីជំរុញបន្ថែមដល់ឧស្សាហាកម្មកម្ពុជា ជាពិសេសខាងផ្នែកទេសចរណ៍ គឺត្រូវបង្កើតហាងទំនិញធំៗបន្ថែមទៀត និងទីលានវាយកូនហ្គោល ការសំដែងសិល្បៈពេញមួយឆ្នាំ ការពង្រីកព្រលានយន្តហោះនៅសៀមរាប និងក្រុងព្រះសីហនុ និងការកសាងបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

ទាក់ទងនឹងផ្សារហ៊ុន ដែលគាំទ្រដោយក្រុមហ៊ុន Korea Exchange នោះ លោកបញ្ជាក់ថា : លោកប្រធានាធិបតីកូរ៉េ រ៉ូ ម៉ូយុន បានសន្យាជាមួយសម្តេច ហ៊ុន សែន ថានឹងផ្តល់ការគាំទ្រសំរាប់បើកផ្សារហ៊ុនកម្ពុជានៅឆ្នាំ២០០៩ ខណៈដែលលោកបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងឆ្នាំ២០០៦។ ហើយឥឡូវនេះ ក្រសួងសេដ្ឋកិច្ច និងក្រុមហ៊ុន Korea Exchange កំពុងអនុវត្តកម្មវិធីរយៈពេល២ឆ្នាំ ២០០៧-២០០៨ ដើម្បីបណ្តុះបណ្តាលជំនាញការ បង្កើតច្បាប់និងបទដ្ឋានហើយរៀបចំប្រព័ន្ធកំព្យូទ័រក្នុងទិសដៅបង្កើតផ្សារភាគហ៊ុននៅឆ្នាំ២០០៩។

ដោយឡែកលោកទូតក៏ថ្លែងការកោតសរសើរដល់កម្មករកម្ពុជា ដែលចេញទៅធ្វើការនៅប្រទេសកូរ៉េ ថា ពួកគេជាមនុស្សស្មោះត្រង់ ហើយប្រឹងប្រែងធ្វើការ។ ចាប់ពីឆ្នាំ២០០៣មកមានកម្មករកម្ពុជាចំនួន ៤.០០០ នាក់ធ្វើការនៅកូរ៉េ ហើយភាគច្រើនពួកគេធ្វើការនៅផ្នែកផលិត។

ជាចុងក្រោយលោកបញ្ជាក់ថា សហប្រតិបត្តិការផ្នែកវប្បធម៌ជាមូលដ្ឋានសំខាន់ណាស់ក្នុងការបង្កើតទំនាក់ទំនងយូរអង្វែង ហើយពេលនេះកូរ៉េបានបង្កើតអោយមានមហាវិទ្យាល័យអក្សរសាស្រ្តកូរ៉េនៅគ្រឹះស្ថានឧមត្តសិក្សារបស់រដ្ឋនៅក្នុងប្រទេសកម្ពុជា ដែលឆ្លុះបញ្ចាំងអោយឃើញនូវចេតនាបង្កើតទំនាក់ទំនងយូរអង្វែងរបស់កូរ៉េ។

*រស្មីកម្ពុជា ថ្ងៃពុធ ទី០៣ ខែតុលា ឆ្នាំ២០០៧ ទំព័រក៦។*

## នាយករដ្ឋមន្ត្រីកូរ៉េខាងជើងបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជារយៈពេល៤ថ្ងៃ

លោក Kim Yong Il នាយករដ្ឋមន្ត្រីនៃសាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ បានអញ្ជើញមកដល់រាជធានីភ្នំពេញកាលពីព្រឹកថ្ងៃទី០១ ខែវិច្ឆកា ឆ្នាំ២០០៧ សំរាប់ដំណើរទស្សនកិច្ចពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-កូរ៉េខាងជើង អោយបានខ្លាំងក្លាថែមទៀត។

ដំណើរមកដល់របស់នាយករដ្ឋមន្ត្រី ត្រូវបានអញ្ជើញទៅទទួលស្វាគមន៍ដោយសម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់លំដាប់ថ្នាក់ជាច្រើនរូប។

ក្នុងរយៈពេលស្នាក់នៅកម្ពុជា លោក Kim និងជួបពិភាក្សាការងារជាមួយសម្តេច ហ៊ុន សែន ចូលបង្គំគាល់ព្រះព្រះមហាក្សត្រ សម្តេច នរោត្តម សីហមុនី ចូលជួបសំដែងការគួរសមជាមួយសម្តេច ជា ស៊ីម និងសម្តេច ហេង សំរិន។

នៅក្នុងកិច្ចពិភាក្សាជាមួយសម្តេច ហ៊ុន សែន លោក គីម បានលើកឡើងនូវចំណុច ៣ ក្នុងគោលបំណងពង្រឹងនូវទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងកូរ៉េខាងជើងអោយកាន់តែរឹងមាំថែមទៀត : ការផ្លាស់ប្តូរគណៈប្រតិភូគ្រប់ជាន់ថ្នាក់ ការបង្កើតទំនាក់ទំនងលើវិស័យពាណិជ្ជកម្មដែលរួមមានបង្កើនការជំរុញនិងការពារវិនិយោគនិងដឹកជញ្ជូនផ្លូវសមុទ្រ។ លោកក៏បានសំណូមពរអោយមានការគាំទ្រគ្នាលើផ្នែកនយោបាយនិងការផ្លាស់ប្តូរមតិគ្នានៅក្នុងបញ្ហាអន្តរជាតិសំខាន់ៗ ដែលប្រទេសកម្ពុជានិងកូរ៉េបានយកចិត្តទុកដាក់ ដូចជាគាំទ្រគ្នាក្នុងអង្គការសហប្រជាជាតិក្នុងចលនាមិនចូលបក្សសម្ព័ន្ធ និងក្នុងប្រទេសអាស៊ាន ដើម្បីបញ្ចៀសការគាបសង្កត់ពីប្រទេសមហាអំណាចមួយចំនួនមកលើប្រទេសកំពុងអភិវឌ្ឍន៍។ ជាមួយនេះ លោក Kim ក៏បានអញ្ជើញសម្តេច ហ៊ុន សែន ទៅទស្សនកិច្ចនៅប្រទេសកូរ៉េខាងជើងវិញដែរ

ជាការឆ្លើយតប សម្តេច ហ៊ុន សែន បានទទួលយកការអញ្ជើញ ហើយសន្យានឹងរកពេលវេលាសមស្របណាមួយទៅទស្សនកិច្ចនៅកូរ៉េខាងជើង។ ហើយសម្តេចក៏បានអបអរចំពោះជំនួបកំពូលរវាងកូរ៉េទាំងពីរកាលពីថ្ងៃទី០២-០៤ ខែតុលាកន្លងមក និងការឈានទៅជំនួបចរចារ៦ភាគី។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី០២ខែវិច្ឆកា ឆ្នាំ២០០៧ ទំព័រក២។*

## ទូតកូរ៉េខាងជើងបង្ហាញពីការចង់ជួយវិស័យកសិកម្មកម្ពុជា

កាលពីថ្ងៃទី១៨ខែកក្កដា លោក ច័ន្ទ សារុន រដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលជួបសវនការជាមួយលោក Ri In Sok ឯកអគ្គរដ្ឋទូតកូរ៉េខាងជើងប្រចាំកម្ពុជា ។

លោកទូតកូរ៉េជំរាបលោករដ្ឋមន្រ្តីកសិកម្មកម្ពុជាថា កូរ៉េខាងជើងបច្ចុប្បន្ន ពុំមានលទ្ធភាពផ្តល់ជំនួយដល់កម្ពុជាជាជំនួយឥតសំណងជាជំនួយឥណទានដូចជាប្រទេសមួយចំនួនបានធ្វើនោះទេ ប៉ុន្តែកូរ៉េមានទឹកចិត្តចង់ជួយដល់កម្ពុជាណាស់ ទោះបីស្ថានភាពនៅកូរ៉េជួបបញ្ហាខ្លះៗក៏ដោយ ។ ប៉ុន្តែជំនួយបច្ចេកទេស និងជំនាញការអត់មានបញ្ហាទេ ហើយលោកនឹងខិតខំធ្វើទំនាក់ទំនងទៅក្រសួងកសិកម្មកូរ៉េ ហើយរំពឹងថាលទ្ធផលនិងប្រសើរ ។

លោករដ្ឋមន្រ្តីកសិកម្មបានថ្លែងអំណរគុណចំពោះទឹកចិត្តរបស់លោកទូត ហើយបានលើកឡើងនូវសមិទ្ធិផលដែលកូរ៉េធ្លាប់ជួយដល់កម្ពុជាកាលពី៤0ឆ្នាំមុន ។ សមិទ្ធិផលមួយចំនួនដែលជាជំនួយរបស់កូរ៉េដែលនៅសល់នឹងបានបន្តប្រើប្រាស់រហូតដល់បច្ចុប្បន្ននេះ ដូចជារោងជាងគ្រឿងយន្តកសិកម្មនៅខេត្តព្រៃវែង មានស្ថានីយ៍បូមទឹកមួយកន្លែង ទោះម៉ាស៊ីនចាស់តែនៅអាចជួសជុលប្រើប្រាស់ ។ លោកក៏កោតសរសើរអំពីសមត្ថភាពបច្ចេកទេសរបស់កូរ៉េនៅក្នុងវិស័យកសិកម្ម វិស័យវេចខ្ចប់ ដែលវិស័យទាំងនេះសុទ្ធសឹងតែកម្ពុជាចង់បាន ។

*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១៩ខែកក្កដាឆ្នាំ២00៩ ទំព័រក២ ។*

## ៦-ទំនាក់ទំនងកម្ពុជា និងប្រទេសជប៉ុន

### ជប៉ុនផ្តល់ថវិកាជាង ១០ លានដុល្លារដល់រដ្ឋាភិបាលកម្ពុជាអនុវត្តគំរោង២

ឆ្លើយតបទៅនឹងសំណើររបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយឈរនៅលើទស្សនៈដើម្បីជួយជំរុញដល់កិច្ចប្រឹងប្រែងដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ច និងការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលជប៉ុនបានសំរេចផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់ទាំងអស់ ១.២៤៩ លានយ៉េន ប្រហាក់ប្រហែលស្មើនឹង ១០.៥ លានដុល្លារអាមេរិកជូនដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តគំរោងចំនួនពីរ ។

សារលិខិតប្តូរនៃគំរោងជំនួយទាំងពីរនេះ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ក្រោមអធិតបីភាពរបស់សម្តេច ហ៊ុន សែន និងធ្វើឡើងរវាងលោក ហោ ណាំហុង និងលោក តាកាហាស៊ិ ហ្វ៊ុមីអាគី ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា ។

ជំនួយឥតសំណងនេះ ត្រូវបានប្រើប្រាស់ដើម្បីទិញផលិតផលនាំចូលដែលជាសេចក្តីត្រូវការចាំបាច់ជាបន្ទាន់សំរាប់ការអនុវត្តន៍កម្មវិធីកែតំរូវរចនាសម្ព័ន្ធ។ ចាប់តាំងពីឆ្នាំ១៩៩៣មក រដ្ឋាភិបាលជប៉ុនបានផ្តល់ដល់ប្រទេសកម្ពុជានូវជំនួយឥតសំណងក្រៅគំរោងសរុបទាំងអស់មានចំនួន ១៧.៣០០ លានយ៉េន។ នេះគឺជាជំនួយឥតសំណងក្រៅគំរោងលើកទី១០ដែលផ្តល់ចំពោះប្រទេសកម្ពុជាដើម្បីជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើអោយប្រសើរឡើងនូវកំណែទំរង់រចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន។

បន្ទាប់ពីបញ្ចប់ដោយជោគជ័យដំណាក់កាលទី១ នៃគំរោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយលូក្នុងទីក្រុងភ្នំពេញដែលអនុវត្តដោយគ្រោងការជំនួយរបស់រដ្ឋាភិបាលជប៉ុនពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៤ (២.០៥៦លានយ៉េន) រាជរដ្ឋាភិបាលកម្ពុជាបានដាក់សំណើរសំរាប់ដំណាក់កាលទី២នៅខែមិថុនា ឆ្នាំ២០០៤ ដើម្បីអនុវត្តនៅតំបន់អាទិភាពមួយចំនួនដែលនៅតែធ្វើអោយប្រជាជនទទួលរងនូវការលំបាកពីទឹកជំនន់នៅរៀងរាល់រដូវវស្សា។

*កាសែតរស្មីកម្ពុជា ចេញ ផ្សាយថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៧ ។*

### ជប៉ុនផ្តល់ប្រាក់កម្ចី២០លានដុល្លារសំរាប់អគ្គិសនីកំពត-ក្រុងព្រះសីហនុ

ធនាគារជប៉ុនសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ JBIC បានផ្តល់ប្រាក់កម្ចីការប្រាក់ក៏រិតទាបបំផុតដល់ប្រទេសកម្ពុជាចំនួនជាង២០លានដុល្លារអាមេរិកសំរាប់គំរោងអភិវឌ្ឍន៏បណ្តាញថាមពលអគ្គសនីពីកំពតទៅក្រុងព្រះសីហនុ។

លោក គាត ឈន់ និងលោក SATO IKURO តំណាងធនាគារ JBIC បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ឥណទានសម្បទានចំនួន២.៦៣២លានយ៉េន ឬប្រមាណជាង ២២ លានដុល្លារ កាលពីថ្ងៃទី២៦ខែមីនាឆ្នាំ២០០៧។

គួររំលឹកថា កាលពីឆ្នាំ២០០៤ ធនាគារជប៉ុនបានផ្តល់ឥណទានការប្រាក់ទាបបែបនេះចំនួន ៤0 លានដុល្លារដល់ប្រទេសកម្ពុជាសំរាប់គំរោងការពង្រីកកំពង់ផែក្រុងព្រះសីហនុ។

លោក គាត ឈន់ មានប្រសាសន៏ថា ឥណទាននេះមានអត្រាការប្រាក់0.០១ភាគរយទេក្នុងមួយឆ្នាំ ហើយកម្ពុជាមានរយៈពេលសងរហូតដល់៤0ឆ្នាំ ដែលក្នុងនោះមានរយៈពេលអនុគ្រោះ១0ឆ្នាំ។ លោកមានប្រសាសន៏ផងដែរថាការពិតគំរោងអភិវឌ្ឍន៏បណ្តាញអគ្គសនីពីកំពតទៅក្រុងព្រះសីហនុ មានទឹកប្រាក់សរុបចំនួន៥៣លានដុល្លារ ក្នុងនោះយើងទទួលបានហិរញ្ញប្បទានពីធនាគារ ADB ចំនួន២0លានដុល្លារ រដ្ឋាភិបាលកម្ពុជាចូលរួមប្រមាណ២0លានដុល្លារអាមេរិក។

ដោយបូករួមបញ្ចូលទាំងគំរោងនេះផង ជំនួយកម្ចីសម្បទានរបស់ជប៉ុនដែលបានសន្យាផ្តល់ជូនប្រទេសកម្ពុជាបានកើនឡើងដល់ ១៥.៩៥១ លានយ៉េន ប្រហែល ជាង ១៣២.៥១៩.000 ដុល្លារអាមេរិក។

*កាសែតរស្មីកម្ពុជា ចេញផ្សាយ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧។*

## អង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុនផ្តល់ជំនួយជួយជនពិការកម្ពុជា

អង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន(JCIA) បានសំរេចផ្តល់ជំនួយឥតសំណងចំនួន១៩៨.៧៤៥ដុល្លារតាមរយៈកិច្ចសហប្រតិបត្តិការជាមួយក្រសួងសង្គមកិច្ចដើម្បីបន្តជួយដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈភ្នំពេញថ្មី ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ ជនក្រីក្រ និងចិញ្ចឹមកុមាររយៈពេល៣ឆ្នាំបន្តទៀត បន្ទាប់ពីបានផ្តល់ជំនួយរយៈពេល១0ឆ្នាំកន្លងមកហើយ។

គំរោងរយៈពេល៣ឆ្នាំ ដែលមានទឹកប្រាក់ជិត២សែនដុល្លារ នឹងត្រូវអនុវត្តចាប់ពីឆ្នាំ២០០៧ដល់ឆ្នាំ២០១០នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈភ្នំពេញថ្មី ដែលមានជនពិការចំនួន១0៥នាក់ ទទួលបានការស្តារលទ្ធភាពពលកម្មវិជ្ជាជីវៈ ជនក្រីក្រចំនួន៩0នាក់ទទួលបានការបណ្តុះបណ្តាលមុខរបរនិងអាចរកប្រាក់ចំណូលសំរាប់ចិញ្ចឹមជីវិត និងកុមារកំព្រាចំនួន៤៥នាក់ ទទួលបានការអប់រំនៅតាមសាលាចំណេះទូទៅ។

គំរោងខាងលើត្រូវបានចុះហត្ថលេខាកាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៧ នៅទីស្តីការក្រសួងដោយលោកអ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចជាមួយលោក ហ្វូមីយ៉ូ យ៉ាម៉ាដា ប្រធានអង្គការ JICA។

*កាសែតរស្មីកម្ពុជា ចេញផ្សាយ ថ្ងៃទី៣0 ខែមីនា ឆ្នាំ២០០៧។*

## លោកអគ្គរាជទូតជប៉ុន កោតសរសើរការសំរេចបានកំណើនសេដ្ឋកិច្ចកម្ពុជា

លោក Katsuhiro Shinohara ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា បានថ្លែងក្នុងវេទិកា ដែលរៀបចំដោយក្លឹបអ្នកកាសែតកម្ពុជាកាលពីថ្ងៃទី២២ខែមិថុនាថា វាដល់ពេលដែលអ្នកវិនិយោគជប៉ុនសម្លឹងមើលទីផ្សារវិនិយោគនៅក្នុងប្រទេសកម្ពុជាហើយ ព្រោះអ្វីៗនៅក្នុងប្រទេសកម្ពុជាកំពុងមានការផ្លាស់ប្តូរ។

ប្រភពនៃស្ថានទូតជប៉ុននៅកម្ពុជាបានអោយដឹងថា ជប៉ុនជាម្ចាស់ជំនួយដ៏ធំរបស់ប្រទេសកម្ពុជា ដែលក្នុងនោះស្ថិតិបានបង្ហាញថា ពីឆ្នាំ១៩៩២ដល់ឆ្នាំ២០០៦ ប្រទេសជប៉ុនផ្តល់ជំនួយដល់កម្ពុជាប្រមាណជា១.១៧៧លានដុល្លារ ហើយថ្មីៗនេះប្រមុខរដ្ឋាភិបាលជប៉ុនបានសន្យានឹងរក្សាការផ្តល់ជំនួយដល់ប្រទេសកម្ពុជាក្នុងរយៈពេល៣ឆ្នាំដដែល ដោយមួយឆ្នាំទទួលបានទឹកប្រាក់ប្រមាណជា ១២២ លានដុល្លារ។

លោក Shinohara បានលើកឡើងថា ជំនួយជារឿងរបស់រដ្ឋាភិបាល រីឯវិនិយោគជារឿងរបស់ឯកជន ប៉ុន្តែពេលនេះក្រុមហ៊ុនជប៉ុនកំពុងសិក្សាលើបញ្ហាសន្តិសុខ នយោបាយសង្គម និងគ្រាប់មីនជាដើម។ ប៉ុន្តែលោកបញ្ជាក់ថា ពេលនេះអ្វីដែលជាកង្វល់ធ្លាប់មាននៅកម្ពុជាបានប្រែប្រួលច្រើន ហើយឈានទៅរកភាពប្រសើរ។ ជាមួយនេះលោកក៏បានលើកឡើងពីសក្តានុពលជាច្រើនសំរាប់អភិវឌ្ឍន៍និងទាក់ទាញវិនិយោគ ដូចជាប្រេងកាត រ៉ែបុកស៊ីត និងកសិកម្មជាដើម។

តាមប្រភពពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអោយដឹងថា ចាប់តាំងពីឆ្នាំ ១៩៩៤ រហូតដល់ឆ្នាំ២០០៦ ប្រទេសកូរ៉េខាងត្បូង គឺជាប្រទេសដែលមកបណ្តាក់ទុនធំជាងគេនៅក្នុងរង្វង់ទឹកប្រាក់ប្រមាណជា ២.៣៦ ពាន់លានដុល្លារ ប្រទេសចិននៅក្នុងរង្វង់ទឹកប្រាក់ ១.៥៨ ពាន់លានដុល្លារ ចំនែកប្រទេសជប៉ុនវិញគឺមានត្រឹម២២លានដុល្លារប៉ុណ្ណោះ។ តួរលេខនេះទាប ជាងសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបទៅទៀត បើទោះបីជាប្រទេសជប៉ុន គឺជាប្រទេសដែលឈរមុខគេនៅក្នុងទីផ្សារវិនិយោគនៅក្នុងតំបន់អាស៊ានក្តី។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី២៣ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក២។*

## នាយករដ្ឋមន្រ្តីកម្ពុជាទាក់ទាញវិនិយោគជប៉ុនដោយសន្យាកំចាត់អំពើពុករលួយ

សម្តេច ហ៊ុន សែន និងសមភាគីជប៉ុន លោក Sinzo Abe បានចុះហត្ថលេខានៅលើកិច្ចព្រមព្រៀងជំរុញ និងការពារវិនិយោគកាលពីថ្ងៃទី១៤ខែមិថុនា។ ទន្ទឹមនឹងនោះ សម្តេចក៏បានជួបជាមួយពាណិជ្ជករធំៗរបស់ជប៉ុន ហើយបានសន្យាថានឹងកំចាត់អំពើពុករលួយ ដើម្បីទាក់ទាញពួកគេអោយមកបណ្តាក់ទុននៅកម្ពុជា។

យោងតាមទីភ្នាក់ងារព័ត៌មានបារាំងកាលពីថ្ងៃទី១៤ ខែមិថុនា បានអោយដឹងថា នៅក្នុងដំណើរទស្សនកិច្ចផ្លូវការលើកទី១ដែលមានរយៈពេល៤ថ្ងៃនោះ ប្រមុខរដ្ឋាភិបាលកម្ពុជាបានដឹកនាំគណៈប្រតិភូជួបជាមួយពាណិជ្ជករធំៗជប៉ុន។ ហើយក្នុងពិធីជប់លៀងថ្ងៃត្រង់ជាមួយពាណិជ្ជករទាំងនោះ សម្តេច ហ៊ុន សែន បានសន្យាថា នឹងលុបបំបាត់អំពើពុករលួយ ហើយនឹងកាត់បន្ថយតំលៃផ្សេងៗសំរាប់អ្នកវិនិយោគទុនទាំងឡាយ។

សម្តេចបានបន្តថា ការវិនិយោគរបស់ជប៉ុន គឺសំខាន់ណាស់សំរាប់ការអភិវឌ្ឍន៍ទៅអនាគតរបស់កម្ពុជា។ ហើយកម្ពុជាកំពុងធ្វើអោយមានស្ថិរភាពនយោបាយ សេដ្ឋកិច្ច និងបរិស្ថានសន្តិសុខ ដូច្នេះរាល់ការធ្វើវិនិយោគអាចត្រូវដំណើរការឡើងដោយទុកចិត្ត។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី១៥ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក២។*

## សម្តេច ហ៊ុន សែន វិលត្រឡប់ពីទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសជប៉ុន

សម្តេច ហ៊ុន សែន បាននិវត្តន៍មកដល់មាតុភូមិវិញនៅថ្ងៃទី១៦ ខែមិថុនា បន្ទាប់ពីបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសជប៉ុនរយៈពេល៤ថ្ងៃ( ពីថ្ងៃទី១៣-១៦ ខែមិថុនា ឆ្នាំ២០០៧) ។

លោក ឡុង វិសាលោ រដ្ឋលេខាធិការក្រសួងការបរទេស បានប្រាប់អ្នកកាសែតនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញថា : ដំណើរទស្សនកិច្ចលើកទី១របស់សម្តេចទៅកាន់ប្រទេសជប៉ុននាពេលនេះ ពិតជាមានសារៈសំខាន់ជាប្រវត្តិសាស្ត្រសំរាប់កម្ពុជា ក្នុងរយៈពេល៥០ឆ្នាំចុងក្រោយនេះ។ លោកបានបញ្ជាក់ថា សម្តេចបានជួបសវនការជាមួយព្រះចៅអធិរាជជប៉ុន អាគី ហ៊្សិតូ និងបានស្នើយាងព្រះអង្គមកបំពេញព្រះរាជទស្សនកិច្ចនៅកម្ពុជា។ ហើយសំណើរនេះ ព្រះអង្គបានចាត់អោយរដ្ឋាភិបាលទាំងពីររៀបចំដំណើរទស្សនកិច្ចនេះអោយបានឆាប់ផងដែរ ។

ចំពោះជំនួបចរចាទ្វេភាគីរវាងសម្តេច និងលោក ស៊ីនហ្សេ អាបេ នោះគឺថា សម្តេចបានអរគុណប្រទេសជប៉ុនដែលបានជួយដល់ប្រទេសកម្ពុជាក្នុងការស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ចឡើងវិញ។ ជាមួយនេះសម្តេចក៏បានស្នើសុំគំរោង៣ទៅដល់រដ្ឋាភិបាលជប៉ុន ក្នុងនោះមាន : ទី១- សុំអោយជប៉ុនជួយស្តារប្រព័ន្ធធារាសាស្ត្រទន្លេវៃកូខេត្តស្វាយរៀង ដែលទន្លេនេះជាប្រភពទឹកសំខាន់មួយសំរាប់ខេត្តស្វាយរៀង និងកំពង់ចាម។ ទី២- ស្នើសុំអោយប្រទេសជប៉ុនផ្តល់សំភារៈបរិក្ខារនិងគ្រឿងចក្រដល់ប្រទេសកម្ពុជាសំរាប់ស្ថាបនាផ្លូវ និងទី៣- សុំអោយជប៉ុនជួយស្ថាបនាផ្លូវជាតិលេខ២ដែលមានប្រវែង ៦០ គីឡូម៉ែត្រពីព្រែកហូរដល់តាកែវ និងបានស្នើអោយជប៉ុនបើកការដ្ឋានស្ថាបនាស្ពានអ្នកលឿងអោយបានឆាប់។

ក្នុងជំនួបនោះដែរសម្តេចក៏បានស្នើអោយភាគីជប៉ុនជួយជំរុញវិនិយោគិនមកកាន់កម្ពុជាអោយបានច្រើន ពិសេសនៅតំបន់ព្រះសីហនុដែលជប៉ុនកំពុងជួយស្ថាបនា។ សម្តេចក៏ស្នើអោយជប៉ុនជំរុញសហប្រតិបត្តិការលើវិស័យទេសចរណ៍តាមរយៈការបង្កើតអោយមានជើងហោះហើរត្រង់ពីជប៉ុនមកកម្ពុជា។

ជាការឆ្លើយតបលោកនាយករដ្ឋមន្ត្រីជប៉ុន អាបេ បានទទួលយកសំណើរ នឹងអះអាងថាប្រទេសជប៉ុននៅតែបន្តជួយដល់កម្ពុជា ហើយគំរោងស្នើសុំរបស់សម្តេចទាំងអស់ភាគីជប៉ុននិងបញ្ជូនអ្នកជំនាញការមកសិក្សា។ ជាមួយនេះ ជប៉ុនក៏អរគុណកម្ពុជា ដែលកន្លងមកតែងតែគាំទ្រជប៉ុនក្នុងតួនាទីជីសកម្មនៅក្នុងអង្គការសហប្រជាជាតិ។

សម្តេច ហ៊ុន សែន ក៏ស្នើអញ្ជើញលោកនាយករដ្ឋមន្ត្រីមកបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងឆ្នាំ២០០៧ផងដែរ។ ហើយសំណើរនេះលោក អាបេ ក៏បានទទួលយកនិងរកពេលវេលាដ៏សមរម្យណាមួយ។

ក្នុងឱកាសស្នាក់នៅប្រទេសជប៉ុន សម្តេចក៏បានទទួលជួបជាមួយប្រធានធនាគារជប៉ុន JBIC ហើយជំនួបនោះ គឺពិភាក្សាលើកម្ចីសំរាប់ពង្រីកកំពង់ផែក្រុងព្រះសីហនុ គំរោងតបណ្តាញអគ្គសនីខេត្តកំពត-ក្រុងព្រះសីហនុ អគ្គសនីភ្នំពេញកំពង់ចាម ក្រចេះផងដែរ។

ដំណើរទស្សនកិច្ចនេះក៏មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការធ្វើសេរីភាវូបនីយកម្ម ការជំរុញនិងការការពារវិនិយោគទុន និងសេចក្តីថ្លែងការណ៍រួមរវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ ហើយក៏បានចុះហត្ថលេខាលើលិខិតប្តូរសារស្តីពីជំនួយឥតសំណងរបស់ប្រទេសជប៉ុនដល់កម្ពុជា ដែលមានទឹកប្រាក់ ២.៩៥៩ លានយ៉េនសំរាប់គំរោង២( គំរោងទី១- គំរោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធលូទឹកក្នុងក្រុងភ្នំពេញដំណាក់កាលទី២ គំរោងទី២- កម្មវិធីអាហារូបករណ៍

អភិវឌ្ឍន៍ធនធានមនុស្ស ដែលចុះហត្ថលេខាដោយលោក តារ៉ូ អាសូ រដ្ឋមន្ត្រីការបរទេសជប៉ុននិងលោក ឡុង វិសាលោ។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ច័ន្ទ ទី១៧-១៨ ខែមិថុនា ឆ្នាំ២០០៧ ទំព័រ៧។*

## ជប៉ុនសំរេចជួយសិក្សាប្លង់មេអំពើរ៉ែនិងឧស្ម័នក្រោមដីរបស់កម្ពុជា

លោក KASSURO SHINOHARA ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំកម្ពុជា បានជំរាបជូព័ត៌មាននេះដល់លោក សុខ អាន កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

លោក Kassuro បានលើកឡើងថា គំរោងសិក្សាប្លង់មេអំពីរ៉ែនិងឧស្ម័នក្រោមដីរបស់ប្រទេសកម្ពុជា គឺជាការឆ្លើយតបទៅនឹងសំណូមពររបស់រដ្ឋាភិបាលកម្ពុជា។ លោកទូតជំរាបលោក សុខ អាន ថា នៅថ្ងៃទី១៦ខែកក្កដា ខាងមុខនេះ ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មជប៉ុននិងដឹកនាំបណ្តាក្រុមហ៊ុនធំៗរបស់ជប៉ុនចំនួន១៣ក្រុមហ៊ុនមកទស្សនកិច្ចស្វែងរកការវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ប្រតិភូនោះនិងពិនិត្យមើលលើវិស័យកសិកម្ម ពាណិជ្ជកម្ម វប្បធម៌ ទេសចរណ៍ និងវិស័យផ្សេងៗទៀត ដែលប្រទេសកម្ពុជានៅមានសក្តានុពលជាច្រើននៅឡើយមិនទាន់បានអភិវឌ្ឍន៍។ លោកទូតបានស្នើអោយរដ្ឋាភិបាលជួយជំរុញក្រុមហ៊ុនក្នុងស្រុក បង្កកិច្ចសហការជាមួយក្រុមហ៊ុនធំៗរបស់ជប៉ុនដែលមានបំណងមកបណ្តាក់ទុននៅកម្ពុជា។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ៍ ទី១២ខែកក្កដា ឆ្នាំ២០០៧ ទំព័រ៣។*

## វិនិយោគិនជប៉ុនធំៗបានមកដល់កម្ពុជា

គណៈប្រតិភូរដ្ឋ និងក្រុមហ៊ុនឯកជនជប៉ុនធំៗបានមកបំពេញទស្សនកិច្ចនៅកម្ពុជាជាលើកដំបូង កាលពីថ្ងៃទី១៧ និងទី១៨ខែកក្កដា ដឹកនាំដោយលោក កូហ្ស យ៉ាម៉ាម៉ូតូ អនុរដ្ឋមន្ត្រីសេដ្ឋកិច្ចពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន ហើយត្រូវបានអនុញ្ញាតអោយចូលជួបសម្តេច ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់កម្ពុជានៅក្រសួងសំខាន់ៗដែលពាក់ព័ន្ធមួយចំនួន។

នៅក្នុងជំនួបជាមួយសម្តេច ហ៊ុន សែន កាលពីថ្ងៃទី១៧ខែកក្កដានៅក្រសួងការបរទេស លោក កូហ៊្ស យ៉ាម៉ាម៉ូតូ បានជំរាបសម្តេចថា ក្រុមហ៊ុនជប៉ុនដែលបានមកកាន់កម្ពុជានាពេលនេះ គឺមានការចាប់អារម្មណ៍ខ្លាំងទៅលើការរុករករ៉ែប៊ុកស៊ីត រ៉ែប្រេងនិងថាមពលគីមី។ លោកបន្តថា ជប៉ុននៅតែមានបំណងជួយដល់កម្ពុជាលើការស្តារហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្តល់ជំនួយសំរាប់សាងសង់ផ្លូវថ្នល់ ស្ពាន ផ្លូវដែក កំពង់ផែ វារីអគ្គិសនី និងរោងចក្រធំៗជាដើម។

ជាការឆ្លើយតប សម្តេចបានស្វាគមន៍ចំពោះដំណើរទស្សនកិច្ចនេះ និងសូមអោយជប៉ុនបន្តជួយផ្តល់ជំនួយឥតសំណងនិងកម្ចីដែលមានការប្រាក់ទាបដល់កម្ពុជា ដើម្បីយកទៅស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងបន្តជួយដល់ការបណ្តុះបណ្តាលធនធានមនុស្សថែមទៀត។ ជាមួយនេះ សម្តេចក៏បានស្នើអោយក្រុមហ៊ុនជប៉ុនពិនិត្យលទ្ធភាពក្នុងការបោះទុនវិនិយោគជួយអភិវឌ្ឍន៍កម្ពុជា និងបានស្នើអោយក្រុមហ៊ុនជប៉ុនចាប់អារម្មណ៍លើវារីអគ្គិសនី។

ដោយឡែកនៅថ្ងៃទី១៨ខែកក្កដា សម្តេច ហ៊ុន សែន ក៏បានអនុញ្ញាតអោយលោក HANCHANGWOO ប្រធានក្រុមហ៊ុន MARUHAN Corperation ចូលជួបនៅភូមិគ្រឹះក្រុងតាខ្មៅ។

លោក WOO បានជំរាប់សម្តេច ហ៊ុន សែន ថា ក្រុមរបស់លោកមានបំណងបោះទុនវិនិយោគជាមួយក្រុមហ៊ុនក្នុងស្រុក ក្នុងការបើកនូវធនាគារមេក្រូហិរញ្ញវត្ថុ ដើម្បីផ្តល់ឥណទានដល់កសិករនិងប្រជាជនក្រីក្រកម្ពុជាអោយមានទុនសំរាប់

ពង្រីកមុខរបរបន្ថែម។ លោកបានបញ្ជាក់ជូនសម្តេចទៀតថា ក្រុមហ៊ុនរបស់លោកនឹងជួយដល់ក្រុមកីឡាបាល់ទាត់កម្ពុជាដើម្បីក្លាយជាកីឡាករបាល់ទាត់ដ៏ល្បីនៅអាស៊ី។

សម្តេច ហ៊ុន សែន បានគាំទ្រចំពោះគំរោងវិនិយោគទាំងអស់របស់លោក WOO ហើយបានណែនាំអោយលោក WOO ធ្វើការជាមួយធនាគារជាតិដើម្បីទទួលបានច្បាប់អនុញ្ញាត។

តាមសេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអោយដឹងថា លោក Kozo Yamamoto អនុរដ្ឋមន្ត្រីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម បានដឹកនាំគណៈប្រតិភូវិនិយោគិនជប៉ុនមួយក្រុមមានចំនួន៣៥នាក់ ដែលរួមមានមន្ត្រីជាន់ខ្ពស់ពីបណ្តាក្រសួងពាក់ព័ន្ធរបស់ជប៉ុន និងធុរជនតំណាងអោយផ្នែកឯកជន ដែលសុទ្ធសឹងតែជាក្រុមហ៊ុនធំៗរបស់ជប៉ុនរួមមាន ក្រុមហ៊ុនតូយ៉ូតា ម៉ារុយបេនី អ៊ីតូឈូ មីតស៊ុយប៊ីស៊ី ស៊ុយមីតូស៊ូ . . . មកបំពេញទស្សនកិច្ចនៅកម្ពុជា ដែលប្រតិភូនេះមកដល់កម្ពុជានៅថ្ងៃទី១៦ និងបញ្ចប់ទៅវិញនៅថ្ងៃទី២០ខែកក្កដា។

ប្រតិភូនេះ ក៏បានចូលជួបពិភាក្សាការងារជាមួយលោកទេសរដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលោករដ្ឋមន្ត្រី ស៊ុយ សែម របស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពលផងដែរ។

ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៦ ប្រទេសជប៉ុនបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការប្រមាណ ១.៤០០ លានដុល្លារអាមេរិក។ ចំនែកវិនិយោគជប៉ុនដាក់ទុនវិនិយោគនៅកម្ពុជាចន្លោះពីឆ្នាំ១៩៩៤ដល់ឆ្នាំ២០០៦មានទឹកប្រាក់ប្រមាណ ២២លានដុល្លារអាមេរិក បើគិតទៅមានប្រមាណតែ០,២ភាគរយប៉ុណ្ណោះបើធៀបនិងទុនវិនិយោគដោយផ្ទាល់ពីបរទេស។

ជំនួយហិរញ្ញប្បទានរបស់ជប៉ុនកន្លងមកនេះ បានជំរុញអោយសេដ្ឋកិច្ចកម្ពុជាមានកំណើនរហូតដល់ពីរក្នុងរយៈពេល៣ឆ្នាំជាប់ៗគ្នា។

ក្នុងឱកាសបំពេញទស្សនកិច្ចរបស់ប្រតិភូជប៉ុននេះផងដែរ ភាគីកម្ពុជាបានបង្ហាញពីសក្តានុពលសេដ្ឋកិច្ចដែលកម្ពុជាមាន ក្នុងនោះមានដូចជា ថ្មកំបោរ ខ្សាច់សមុទ្រ រ៉ែទង់ដែង និងរ៉ែម៉ូលីដែន ។

*រស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ ទី១៩ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៣ ។*

## ជប៉ុនពង្រីកទំនាក់ទំនងទ្វេរភាគីជាមួយកម្ពុជាលើវិស័យការពារជាតិ

នៅក្នុងជំនួបជាមួយសម្តេច ហ៊ុន សែន កាលពីថ្ងៃទី០៦ខែសីហាឆ្នាំ២០០៧ លោក TAKAHIDE KIMURA អនុរដ្ឋមន្ត្រីក្រសួងការពាជាតិជប៉ុន បានថ្លែងថា ទស្សនកិច្ចរបស់លោកមកកាន់កម្ពុជាលើកនេះ គឺដើម្បីពង្រីកនូវកិច្ចសហប្រតិបត្តិការទ្វេរភាគីរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុនលើវិស័យការពារជាតិ។

កន្លងមកប្រទេសជប៉ុនបានជួយសហការជួយដល់កម្ពុជាតែតាមរយៈកិច្ចសហប្រតិបត្តិការពហុភាគីតែប៉ុណ្ណោះ លើផ្នែកការពារជាតិនេះ។

ជាមួយនេះ សម្តេចក៏បានស្នើរអោយភាគីទាំងពីរសហការលើផ្នែកវិស្វកម្ម ព្រោះកម្ពុជានៅខ្វះច្រើនណាស់នូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នេះ។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ ទី០៧ ខែសីហា ឆ្នាំ២០០៧ ទំព័រក២ ។*

## រដ្ឋាភិបាលជប៉ុនផ្តល់ទឹកប្រាក់ចំនួន ៩៨៩ លានយ៉េនអោយអង្គការស៊ីម៉ាក់

ថវិកានេះរដ្ឋាភិបាលជប៉ុនផ្តល់តាមរយៈប្រព័ន្ធសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICS) ដែលពិធីចុះហត្ថលេខាទទួលថវិកាធ្វើឡើងនៅថ្ងៃទី១២ខែកញ្ញា រវាងលោក ហេង រតនា អគ្គនាយករង CMAC និងលោក MAYUMI Takefumi អ្នកដឹកនាំនិងគ្រប់គ្រងកម្មវិធីនៃប្រព័ន្ធសហប្រតិបត្តិការអន្តរជាតិ។

លោក ហេង រតនា បញ្ជាក់ថាជំនួយនេះនឹងយកទៅប្រើលើកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍន៍សំភារៈ និងបច្ចេកទេសបោសសំអាតមីនដំណាក់កាលទី២របស់រាជរដ្ឋាភិបាលជប៉ុនជូនដល់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ប៉ុន្តែជាលើកដំបូងគេនឹងប្រើប្រាស់ទឹកប្រាក់នេះដើម្បីទិញគ្រឿងចក្រយកមកធ្វើការបោសសំអាតមីននៅកម្ពុជា។ ជាមួយនេះដែរ ទឹកប្រាក់នេះនឹងប្រើប្រាស់សំរាប់អនុវត្តន៍គំរោងរយៈពេលមួយឆ្នាំ សំរាប់ទិញគ្រឿងចក្រម៉ាស៊ីនកំទេចមីនធុនធ្ងន់ អេស្កាវ៉ាទ័រ និងសំរាប់ការប្រតិបត្តិដែលចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០០៧ ហើយបញ្ចប់នៅខែតុលា ឆ្នាំ២០០៨។

*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ៍ ទី១៣ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រ៤។*

## កម្ពុជា-ជប៉ុន បង្កើនកិច្ចសហប្រតិបត្តិការទ្វេរភាគី

លោក ហោ ណាំហុង បានទទួលជួបពិភាក្សាជាមួយលោក Alsumi Chhiro អគ្គនាយកកិច្ចការអាស៊ីអាគ្នេយ៍នៃក្រសួងការបរទេសជប៉ុន ដើម្បីពិភាក្សាលើការងារសហប្រតិបត្តិការទ្វេរភាគី ពិសេសលើការងារអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ជំនួបនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៧។

*រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី១៥ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រ២។*

## ជប៉ុនផ្តល់ជំនួយទឹកប្រាក់ ៤៨៤ លានយ៉េន សំរាប់ប្រយុទ្ធប្រឆាំងមីននៅកម្ពុជា

រាជរដ្ឋាភិបាលជប៉ុន បានសំរេចផ្តល់ជំនួឥតសំណងដែលមានទឹកប្រាក់ចំនួន៤៨៤លានយ៉េន (ស្មើរនឹងប្រមាណ ៤.១៧២.០០០លានដុល្លារអាមេរិក)ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តនូវគំរោងស្រាវជ្រាវ និងអភិវឌ្ឍន៍ឧបករណ៍បោសសំអាតមីនដំណាក់កាលទី២។

លិខិតប្តូរសារ នៃគំរោងជំនួយនេះត្រូវបានចុះហត្ថលេខាដោយលោក ហោ ណាំហុង និងលោក Shinohara Katsuhiro ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា កាលពីថ្ងៃទី០៦ខែកញ្ញានេះ។

គំរោងនេះនឹងបន្តពីដំណាក់កាលទី១ (ចុះហត្ថលេខានៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ មានទឹកប្រាក់ចំនួន ៤១៦ លានយ៉េន) គឺដើម្បីផ្តល់មូលនិធិអោយ CMAC ធ្វើការពិសោធន៍លើឧបករណ៍បោសសំអាតមីន និងឧបករណ៍រាវរកមីនថ្មីទៀត។

តាមតួរលេខ នៃការរួមវិភាគទានដែលរដ្ឋាភិបាលជប៉ុនបានផ្តល់ចំពោះ CMAC ចាប់ពីឆ្នាំ១៩៩៤មកនោះ គឺមានប្រហែល៨.៩៦២លានដុល្លារ ពីគំរោងជំនួយឥតសំណងសំរាប់គំរោងខ្នាតតូចសន្តិសុខមនុស្សជាតិ **គូសាណូណេ** និង ១១.៥ លានដុល្លារពីមូលនិធិទំនុកចិត្ត UNDP (UNDP Trust Fund) និង៣៧៦.៩១០ លានដុល្លារ ពីមូលនិធិសមាហរណកម្ម

ជប៉ុន-អាស៊ាន(JAIF)និង២៩.៣៣៣លានដុល្លារពីជំនួយឧបត្ថម្ភឥតសំណងទូទៅ និង៧.៧៨៩លានដុល្លារពីគំរោងស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិជ្ជាថ្មី។

ក្រៅពីជំនួយដែលរាជរដ្ឋាភិបាលជប៉ុនផ្តល់ដល់ CMAC នោះចាប់ពីឆ្នាំ ១៩៩៤ មកមានទឹកប្រាក់ប្រហែល ១១.១៨៦ លានដុល្លារ ត្រូវផ្តល់ដល់អង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការក្នុងសកម្មភាពបោសសំអាតមីនតាមរយៈជំនួយឧបត្ថម្ភ គូសាណូណេ សំរាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងនោះមាន JAHDS, HALO Trust, Mine Asvisory Group, និង JMAS ។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី០៧ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៣ ។*

## ជប៉ុនផ្តល់ប្រាក់កម្ចីសម្បទានចំនួន ១.០០០ លានយ៉េនដល់កម្ពុជា

រដ្ឋាភិបាលជប៉ុនបានសំរេចផ្តល់ដល់រាជរដ្ឋាភិបាលកម្ពុជានូវកម្ចីសម្បទានដែលមានទឹកប្រាក់ទាំងអស់ ១.000 លានយ៉េន ប្រហែល ៨.៦៩៥.000 ដុល្លារអាមេរិក។

ប្រាក់កម្ចីនេះនឹងត្រូវផ្តល់ជូនដោយធនាគារជប៉ុនសំរាប់សហប្រតិបត្តិការអន្តរជាតិ(JBIC) ដែលជាទីភ្នាក់ងារអនុវត្តជំនួយកម្ចីសម្បទានរបស់រដ្ឋាភិបាលជប៉ុនដើម្បីគាំទ្រដល់កម្មវិធីប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច។ ពិធីសារនេះត្រូវបានចុះហត្ថលេខាដោយលោក ហោ ណាំហុង និងលោក Katsuhiro Shinohara ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា។

កម្មវិធីប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រនិងកំណើនសេដ្ឋកិច្ច(PRGO) ២០០៧-២០០៩ ដែលជាកម្មវិធីមួយដែលឧបត្ថម្ភដោយម្ចាស់ជំនួយពហុភាគី ដើម្បីផ្តល់នូវការគាំទ្រដល់ការអនុវត្តន៍កម្មវិធីកំណែទំរង់អភិបាលកិច្ចល្អ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ២០០៦-២០១០។

ដោយបូករួមបញ្ចូលទាំងគំរោងនេះផង ជំនួយកម្ចីសម្បទានរបស់ជប៉ុនដែលផ្តល់ជូនកម្ពុជាសរុបកើនឡើងដល់ ១៦.៩៥១ លានយ៉េនប្រហែលជាង ១៤៦ លានដុល្លាររអាមេរិក។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី១៦ខែតុលា ឆ្នាំ២០០៧ ទំព័រក២ ។*

## សម្តេច ហេង សំរិន ជួបពិភាក្សាជាមួយនឹងលោកនាយករដ្ឋមន្ត្រីជប៉ុន

បន្ទាប់ពីចាកចេញពីប្រទេសកម្ពុជាកាលពីថ្ងៃទី១៤ ខែតុលា ទៅកាន់ប្រទេសជប៉ុន នៅក្នុងដំណើរបំពេញទស្សនកិច្ចរយៈពេល៦ថ្ងៃ សម្តេច ហេង សំរិន បានជួបពិភាក្សាជាមួយលោកនាយករដ្ឋមន្ត្រីជប៉ុន Yasuo Fukuda នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧។

ក្នុងដំណើរបំពេញទស្សនកិច្ចរយៈពេល៦ថ្ងៃនោះ ក្រៅពីជួបពិភាក្សាជាមួយលោក Yasuo សម្តេចគ្រោងចូលបង្គំគាល់ព្រះចៅអធិរាជជប៉ុន ជួបពិភាក្សាជាមួយប្រមុខស្ថាប័ននីតិបញ្ញត្តិ និងបំពេញទស្សនកិច្ចនៅកន្លែងសំខាន់ជាច្រើន។ *រស្មីកម្ពុជា ថ្ងៃពុធ ទី១៧ ខែតុលា ឆ្នាំ២០០៧ ទំព័រក២ ។*

## កិច្ចសហប្រតិបត្តិការ កម្ពុជា-ជប៉ុន ក្នុងរយៈពេល១៥ឆ្នាំ ១៩៩២-២០០៧

- ទឹកប្រាក់សរុបនៃកិច្ចសហប្រតិបត្តិការ ប្រហែល ១.៦០០ លានដុល្លារ

- ជំនួយឧបត្ថម្ភប្រចាំឆ្នាំ ក្នុងរយៈកាល ៥ ឆ្នាំចុងក្រោយនេះ ១០០ លានដុល្លារក្នុងមួយឆ្នាំៗ ( ប្រហែល ១/៧ នៃថវិកាជាតិប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងប្រហែល ២០ ភាគរយនៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ដែលផ្តល់ជូនកម្ពុជា)

**ប្រាក់ជំនួយរបស់ជប៉ុនទាំងនេះ បានជួយប្រទេសកម្ពុជាលើវិស័យជាច្រើន ដូចជា :**

- កំណែទំរង់រដ្ឋបាល និងហិរញ្ញវត្ថុ
- រៀបចំរដ្ឋបាលមូលដ្ឋាន
- កំណែទំរង់ច្បាប់ ( រៀបនីតិវិធី និងក្រមរដ្ឋប្បវេណី ជួយរាជបណ្ឌិតសភាជីវៈតុលាការ)
- ការកសាងប្រព័ន្ធធារាសាស្ត្រ
- ជំនួយឧបត្ថម្ភបច្ចេកទេស ដើម្បីពង្រឹងផលិតកម្មកសិកម្ម
- បង្កើតទីផ្សារពូជស្រូវបើកចំហរ
- សាងសង់មន្ទីរពេទ្យ ( មជ្ឈមណ្ឌលគាំពារមាតា និងទារក)
- គំរោងអភិវឌ្ឍន៍ធនធានមនុស្សសំរាប់សហ-គ្រូពេទ្យ
- កម្មវិធីចាក់ថ្នាំបង្ការជំងឺឆ្លងនានា
- សាងសង់អគារសិក្សា
- ឧបត្ថម្ភដល់ជនងាយរងគ្រោះ( មានទឹកប្រាក់ ៧៧០.៣៩២ ដុល្លារ)
- ជំនួយខ្នាតតូចរបស់ជប៉ុន( គូសាណូណេ មានទឹកប្រាក់សរុប ៣២ លានដុល្លារ)
- សាងសង់ផ្លូវថ្នល់ សាងសង់ស្ពាន ឋាបនីយភ័ណ្ឌកំពង់ផែ
- សាងសង់រោងចក្រអគ្គសនី
- សាងសង់រោងចក្រផលិតទឹកសាត សាងសង់អណ្តូងទឹក
- សាងសង់ច្រាំងទន្លេ
- ឋាបនីយភ័ណ្ឌផ្សព្វផ្សាយ និងទូរគមនាគមន៍ ។

*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី២៣-២៤ ខែធ្នូ ឆ្នាំ២០០៧ ទំព័រក៨។*

## ក្រុមហ៊ុនជប៉ុនបោះទុន១៥លានដុល្លារវិនិយោគលើវិស័យកសិ -ឧស្សាហកម្មនៅកំពង់ចាម

ក្រុមហ៊ុនជប៉ុនបានសំរេចបោះទុនវិនិយោគលើវិស័យកសិ-ឧស្សាហកម្មនៅកម្ពុជា ដោយបានបោះទុនជំហានទី១ មានទឹកប្រាក់ប្រមាណពី១៥ទៅ២០លានដុល្លារ សំរាប់ដាំដំណាំកសិកម្មនៅក្នុងស្រុកមេមត់ ខេត្តកំពង់ចាម នៅលើផ្ទៃដី ប្រមាណ ១៣០០ ហិកតា។

នៅក្នុងជំនួបជាមួយលោក សុខ អាន ប្រតិភូនៃក្រុមហ៊ុនជប៉ុន ឈ្មោះ KODE BUSSAN ដែលផ្តល់ប្រឹក្សា ដោយក្រុមហ៊ុន LOCOMO Co .Ltd ដែលដឹកនាំដោយលោក Sagawa Kanji ប្រធានក្រុមហ៊ុន KOBE បានលើក

ឡើងថា ក្រុមហ៊ុននឹងធ្វើការដាំដំណាំ ដូចជា ត្រសក់ ផ្លែថាវ ខ្ទឹ ជំឡូងបារាំង ដើម្បីនាំចេញទៅលក់ដោយផ្ទាល់នៅប្រទេសជប៉ុន ចិន និងអេហ្ស៊ីប និងសំរាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក។ *រស្មីកម្ពុជា ថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំ២០០៧ ទំព័រក៤។*

**រដ្ឋាភិបាលជប៉ុនផ្តល់ជំនួយ៦០លានយ៉េនសំរាប់អនុវត្តគំរោងកែលំអមន្ទីរពេទ្យខេត្តកំពង់ចាម**

រដ្ឋាភិបាលជប៉ុនបានសំរេចផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់សរុប៦០លានយ៉េន ស្មើនឹង ៥២១ ពាន់ដុល្លារអាមេរិកជូនដល់រាជរដ្ឋាភិបាលកម្ពុជា សំរាប់ការសិក្សាលើប្លង់សំរាប់ការអនុវត្តន៏គំរោងសាងសង់ កែលំអមន្ទីរពេទ្យកំពង់ចាមក្នុងខេត្តកំពង់ចាម។

លិខិតប្តូរសារគំរោងជំនួយនេះត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី៣ខែធ្នូ ដោយលោក ហោ ណាំហុង និងលោក SHINOHARA Katsuhiro ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី០៤ខែធ្នូឆ្នាំ២០០៧ ទំព័រក១។*

**ជប៉ុនផ្តល់ជំនួយជិត២លានដុល្លារដល់គំរោងចំនួន៨ក្នុងប្រទេសកម្ពុជា**

រាជរដ្ឋាភិបាលជប៉ុនតាមរយៈកម្មវិធីជំនួយឥតសំណងមួយដែលមានឈ្មោះថា គូសាណូណិ នឹងផ្តល់ជំនួយចំនួន ១,៩៩៧,៨០០ ដុល្លារអាមេរិក ដល់ការអភិវឌ្ឍន៏គំរោងចំនួន៨នៅកម្ពុជា។

ការចុះហត្ថលេខានេះ បានធ្វើឡើងនៅថ្ងៃទី៣០ ខែវិច្ឆកា នៅស្ថានទូតជប៉ុនប្រចាំកម្ពុជា ដោយ លោក កាត់ស៊ុហ៊ីរ៉ូ ស៊ីណូហារ៉ា ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា និងតំណាងគំរោងទាំង៨ផងដែរ។

ថវិកាគំរោងជំនួយនេះផ្តល់ជូនដល់អាជ្ញាធរក្នុងស្រុក និងអង្គការក្រៅរដ្ឋាភិបាលផងដែរ **ទី១-** ជួយដល់គំរោងបោសសំអាតមីនមនុស្សធម៌ក្នុងខេត្តកំពង់ធំ ឧត្តរមានជ័យ និងព្រះវិហារ មានចំនួនទឹកប្រាក់៨៦១.៨៣៣ដុល្លារអាមេរិក អ្នកអនុវត្តគំរោងគឺCMAC។ **ទី២-** គាំទ្រការបោសសំអាតមីន មនុស្សធម៌ក្នុងស្រុកដែលមានព្រំដែននៅភាគពាយ័ព្យប្រទេសមានចំនួនទឹកប្រាក់ ៧៨១.០៨៩ ដុល្លារ អ្នកអនុវត្តគំរោងអង្គការ HALO Trust។ **ទី៣-** គំរោងបោះពុម្ពសៀវភៅណែនាំសំរាប់អ្នកបោះឆ្នោតរដ្ឋសភាឆ្នាំ២០០៨ មានចំនួនទឹកប្រាក់៨៥.៧០៥ដុល្លារ អ្នកអនុវត្តគំរោងមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម។ **ទី៤-** គំរោងស្តាប្រព័ន្ធស្រោចស្រពបុស្សលាវ ខេត្តក្រចេះ មានទឹកប្រាក់ចំនួន៨៥.៥៣៥ដុល្លារអាមេរិក អ្នកអនុវត្តន៏គំរោងមន្ទីរធនធានទឹកខេត្តក្រចេះ។ **ទី៥-** គំរោងគាំទ្រសំភារៈអប់រំអ្នកបោះឆ្នោតសំរាប់ការបោះឆ្នោតរដ្ឋសភា ឆ្នាំ២០០៨ មានចំនួនទឹកប្រាក់ ៦៣.០៥០ ដុល្លារអាមេរិក អ្នកអនុវត្តគំរោង COMFREL។ **ទី៦-** គំរោងគាំទ្រការជីកអណ្តូងទឹកក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មានចំនួនទឹកប្រាក់ ៥១.១៥៣ ដុល្លារ អ្នកអនុវត្តគំរោងអង្គការ RCEDO។ **ទី៧-** គំរោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យកោះរះក្នុងស្រុកល្វាឯម ខេត្តកណ្តាល មានចំនួនទឹក ប្រាក់៣៦.៣១២ដុល្លារ អ្នកអនុវត្តន៏គំរោងការិយាល័យអប់រំយុវជននិងកីឡា ស្រុកល្វាឯម ខេត្តកណ្តាល។ **គំរោងទី៨-** គំរោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យស្លែងក្នុងស្រុកគីរីវង់ មានចំនួនទឹក ប្រាក់ ៣៣.១២៣ ដុល្លារ អ្នកអនុវត្តន៏គំរោងអនុវិទ្យាស្លែង។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី០១ ខែធ្នូឆ្នាំ២០០៧ ទំព័រក៣។*

**ជប៉ុនបង្កើនជំនួយក្រៅគំរោង និងប្រាក់កម្ចីសំរាប់ឆ្នាំ២០០៨**

សំរាប់ឆ្នាំ២០០៨ខាងមុខនេះ ប្រទេសជប៉ុននឹងផ្តល់ជំនួយឥតសំណងក្រៅគំរោងចំនួន១៤លានដុល្លារ និងសន្យាបង្កើនការផ្តល់ប្រាក់កម្ចីឡើងដល់១០០លានដុល្លារ។

ការសន្យានេះ ត្រូវបាននាំមកដោយលោក កាស៊ូហ៊ីរ៉ូ ស៊ីណូហារា ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា ជំរាបលោក គាត ឈន់ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៧។

មន្ត្រីហិរញ្ញវត្ថុបាននិយាយថា សំរាប់ឆ្នាំ២០០៨ខាងមុខនេះ រដ្ឋាភិបាលជប៉ុននឹងផ្តល់ហិរញ្ញប្បទាន ឥតសំណងក្រៅគំរោងមានទឹកប្រាក់ចំនួន ១.៤០០ លានយ៉េន ឬប្រមាណ១៤លានដុល្លារ ដែលចំនួននេះមានការកើនឡើងប្រមាណ ២០០លានយ៉េនបើធៀបឆ្នាំ២០០៧។

ទន្ទឹមនឹងជំនួយឥតសំណងក្រៅគំរោងរដ្ឋាភិបាល ជប៉ុនបានសំរេចដែរថា នៅឆ្នាំ២០០៨ ជប៉ុននឹងបង្កើនប្រាក់កម្ចីដល់ប្រទេសកម្ពុជារហូតដល់១០០លានដុល្លារក្នុង១ឆ្នាំ សំរាប់កម្ពុជាយកទៅវិនិយោគសាធារណៈ។

*រស្មីកម្ពុជា ថ្ងៃសៅរ៍ទី០១ខែធ្នូឆ្នាំ២០០៧ ទំព័រក៤។*

## ៧-ទំនាក់ទំនងកម្ពុជា និងសហរដ្ឋអាមេរិក

### *សភាអាមេរិកនឹងអនុម័តលុបចោលបំរាមផ្តល់ជំនួយដោយផ្ទាល់ដល់កម្ពុជា*

លោក ចូសេហ្វ ម៉ូសូមេលី ឯកអគ្គរដ្ឋអាមេរិកប្រចាំនៅកម្ពុជាបានមានប្រសាសន៍ថា សភាអាមេរិកត្រូវតែអនុម័តច្បាប់ទាំងអស់លុបចោលបំរាមមិនអោយផ្តល់ជំនួយដោយផ្ទាល់មកដល់រាជរដ្ឋាភិបាលកម្ពុជាជាមុនសិន ដែលនេះជាសញ្ញានៃការពង្រីកទំនាក់ទំនងរវាងរដ្ឋាភិបាលអាមេរិក ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

លោក ចូសេហ្វ បានមានថ្លែងថា ការរង់ចាំអនុម័តច្បាប់របស់រដ្ឋសភាអាមេរិកនឹងមិនពាក់ព័ន្ធជាមួយការអភិវឌ្ឍនៃប្រទេសយើងទាំងពីរនោះទេ ហើយវាជាការប្រសើរណាស់ប្រសិនបើរដ្ឋសភាអាមេរិកលុបចោលនូវបំរាមទាំងអស់ស្តីពីការផ្តល់ជំនួយឡើងវិញដោយផ្ទាល់ទៅដល់រដ្ឋាភិបាលកម្ពុជា ពេលនោះវាកាន់តែប្រសើរថែមទៀត ចំពោះទំនាក់ទំនងរវាងរដ្ឋាភិបាលនិងរដ្ឋាភិបាលហើយយើងនឹងធ្វើអោយរដ្ឋាភិបាលទទួលខុសត្រូវកាន់តែច្រើនចំពោះការងាររបស់គេ។

លោកឯកអគ្គរដ្ឋទូតអាមេរិកថ្លែងដូចនេះនៅក្នុងសន្និសីទសារព័តិមានឯកំពង់ផែអន្តរជាតិនាក្រុងព្រះសីហនុ កាលពីថ្ងៃទី១០ខែកុម្ភៈក្រោយពីការចូលចតនៅកំពង់ផែដោយនាវាចំបាំងអាមេរិក USS CARY រយៈពេល៥ថ្ងៃនៅកម្ពុជា។

លោក ចូសេហ្វ បានបន្តទៀតថា សហរដ្ឋអាមេរិក និងប្រទេសកម្ពុជា ធ្លាប់មានទំនាក់ទំនងផ្នែកយោធា និងមនុស្សធម៌ជាយូរមកហើយ ប៉ុន្តែទំនាក់ទំនងនេះមានពេលខ្លះល្អ និងពេលខ្លះមិនសូវល្អ បន្ទាប់មកបានកាត់ផ្តាច់មួយរយៈពេលប្រមាណ៣២ឆ្នាំកន្លងទៅ ហើយទើបតែពេលនេះរដ្ឋាភិបាលនៃប្រទេសទាំងពីរបើកកិច្ចសហប្រតិបត្តិការឡើងវិញ។ *កាសែតកោះសន្តិភាព ចេញផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧។*

## អាមេរិកចង់ជួយកម្ពុជាដើម្បីលុបបំបាត់គំលាតនៅក្នុងអាស៊ាន

ខណៈជួបពិភាក្សាការងារជាមួយលោក ហោ ណាំហុង កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៧ លោក Eric John ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិក បានបង្ហាញពីគោលបំណងរបស់រដ្ឋាភិបាលអាមេរិកក្នុងការជួយដល់ប្រទេសកម្ពុជាដើម្បីលុបបំបាត់គំលាតរវាងសមាជិកចាស់និងសមាជិកថ្មីនៃអាស៊ាន ។

ប្រភពនៃជំនួបនោះបានអោយដឹងថា ការពិភាក្សានោះភាគីទាំងពីរផ្តោតលើការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-អាមេរិក ក៏ដូចនៅក្នុងតំបន់ផងដែរ ។ លោក Eric John បានចាត់ទុកកម្ពុជាជាដៃគូរមួយសំខាន់នៅក្នុងតំបន់អាស៊ាន ក៏ដូចនៅក្នុងវេទិកាផ្សេងៗទៀត ។

ក្នុងឱកាសនោះ លោក Eric ក៏បានសរសើរដល់ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២ ដែលធ្វើឡើងកាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ កន្លងមកថ្មីនេះ ។

ការពិភាក្សានេះដែរ ភាគីទាំងពីរក៏បានលើកឡើងអំពីទំនាក់ទំនងរវាងអាស៊ាន និងសហរដ្ឋអាមេរិក ដែលក្នុងនេះបានផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចប្រជុំកំពូលអាមេរិក-អាស៊ាន ដែលនឹងប្រព្រឹត្តទៅនៅក្នុងពេលខាងមុខ ប៉ុន្តែមិនទាន់កំនត់ទីកន្លែង ។ តែទីកន្លែងធ្វើកិច្ចប្រជុំនេះអាមេរិកចង់ធ្វើនៅសិង្ហបុរី ព្រោះថានៅក្នុងតំបន់អាស៊ានមានតែសិង្ហបុរីទេ ដែលមានបណ្តាញព័ត៌មានយល់ដឹងពីអាមេរិកច្រើន ។

ចំពោះបញ្ហាគំលាតនៅក្នុងអាស៊ាន ប្រសិនបើកម្ពុជាចង់អោយអាមេរិកជួយ អាមេរិកនឹងជួយដោយផ្ទាល់តាមរយៈស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ដើម្បីលុបបំបាត់នូវគំលាតដែលកំពុងតែមានរវាងសមាជិកចាស់ និងសមាជិកថ្មី ។
*រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី០៧ ខែមេសា ឆ្នាំ២០០៧ ទំព័រ២ ។*

## យោធាអាមេរិក និងកម្ពុជាកាន់តែទិតជិតចូលគ្នា

បុគ្គលិកយោធាអាមេរិកចំនួន៨នាក់ និងកងយោធពលខេមរភូមិន្ទចំនួន៩៥នាក់ កំពុងចូលរួមប្រតិបត្តិការគាំទ្រសន្តិភាពនៅកម្ពុជាឆ្នាំ២០០៧ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៤ ដល់ទី១៧ ខែមិថុនា ឆ្នាំ២០០៧ នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនបោសសំអាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល(TMCC)នៅឧត្តុង្គ ។

តាមសេចក្តីប្រកាសព័ត៌មានកាលពីថ្ងៃទី១៣ ខែមិថុនា ស្ថានទូតអាមេរិកនិយាយថា ប្រតិបត្តិការគាំទ្រសន្តិភាពនៅកម្ពុជាឆ្នាំ២០០៧នេះឧបត្ថម្ភដោយកងយោធពលខេមរភូមិន្ទ និងបញ្ជាការដ្ឋានកងទ័ពអាមេរិកប្រចាំតំបន់មហាសមុទ្រប៉ាស៊ីហ្វិក ដោយមានការគាំទ្ររបស់ក្រសួងការបរទេសអាមេរិក ។

ប្រភពនេះបញ្ជាក់ផងដែរថា ប្រតិបត្តិការនេះនឹងជួយកងយោធពលខេមរភូមិន្ទ ដូចជា :

- កែលំអប្រតិបត្តិការគាំទ្រសន្តិភាពរបស់ខ្លួន(កងយោធពលខេមរភូមិន្ទ)
- ធ្វើអោយគ្រូបង្រៀននិងអ្នកចូលរួមទាំងអស់ទទួលបាននូវការទទួលស្គាល់ដោយសហប្រជាជាតិ ដើម្បីបំពេញបេសកម្មថែរក្សាសន្តិភាពនៅលើពិភពលោក ។

- លើកកំពស់សមត្ថភាពអន្តរប្រតិបត្តិការ និងទំនាក់ទំនងក្នុងជំនាញវិជ្ជាជីវៈរវាងកងទ័ពអាមេរិក និងកងយោធានៅតំបន់អាស៊ីប៉ាស៊ីហ្វិក។

ការហ្វឹកហ្វឺននេះ គឺផ្អែកលើបែបបទ និងគោលការណ៍ណែនាំរបស់សហប្រជាជាតិ ហើយបញ្ចូលអ្វីៗដែលអ្នកថែរក្សាសន្តិភាពគ្រប់រូបត្រូវដឹង ទាក់ទងនឹងបច្ចេកទេសក្នុងការថែរក្សាសន្តិភាពរបស់សហប្រជាជាតិ( អង្គការសហប្រជាជាតិមានភារកិច្ចជាង២១៥ក្នុងការថែរក្សាសន្តិភាព ប៉ុន្តែក្នុងនោះ មានភារកិច្ចប្រមាណ៣៣ ដែលតែងប្រទះ និងអនុវត្តញឹកញាប់ជាងគេ) ។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី១៥ ខែមិថុនា ឆ្នាំ២០០៧ ទំព័រ២ ។*

## ស្ថានទូតអាមេរិកផ្តល់ឧបករណ៍ការពារគ្រុនផ្តាសាយបក្សីដល់ក្រសួងកសិកម្ម

ស្ថានទូតអាមេរិកប្រចាំកម្ពុជា បានប្រគល់ឧបករណ៍ការពារខ្លួនចំនួន ៤៥០០ កញ្ចប់ និងឧបករណ៍សំលាប់មេរោគចំនួន៥០កេស ដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សរុបទឹកប្រាក់ប្រមាណជា៦៥. ០០០ដុល្លារអាមេរិក ដើម្បីប្រយុទ្ធប្រឆាំងជំងឺគ្រុនផ្តាសាយបក្សី និងការពារជំងឺរាតត្បាតផ្សេងៗ។

ពិធីប្រគល់និងទទួលនេះធ្វើឡើងរវាងលោកឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា Joseph A. Mussomeli និងលោករដ្ឋមន្ត្រីកសិកម្ម ច័ន្ទ សារុន កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៧។

ឧបករណ៍ដែលមានទឹកប្រាក់ប្រមាណ៦៥.០០០ដុល្លារអាមេរិកនេះ រួមមានសំលៀកបំពាក់សំរាប់ការពារប្រដាប់ដកដង្ហើម វ៉ែនតាការពារ និងស្រោមដៃ។

ចាប់តាំងពីឆ្នាំ២០០៤មក ប្រទេសកម្ពុជាមានមនុស្សផ្ទុះជំងឺផ្តាសាយបក្សីចំនួន២២កន្លែង ហើយបានសំលាប់មនុស្សអស់ចំនួន៧នាក់។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី១៨ ខែឧសភា ឆ្នាំ២០០៧ ទំព័រ៥ ។*

## កម្ពុជានិងប្រទេស៣ទៀតចូលរួមជាមួយអាមេរិកនិងរុស្ស៊ីដើម្បីប្រឆាំងភេរវកម្មនុយក្លេអ៊ែរ

យោងតាមសេចក្តីរាយការណ៍របស់ទីភ្នាក់ងារព័ត៌មានឡូដូកាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៧ បានអោយដឹងថាក្រសួងការបរទេសអាមេរិកបានអះអាងពីវត្តមានរបស់កម្ពុជា អាមេនី ម៉ាសេដូនៀ និងរូម៉ានី នៅក្នុងគំនិតផ្តួចផ្តើមរបស់ប្រទេសអាមេរិកនិងរុស្ស៊ីនៅក្នុងការប្រយុទ្ធប្រឆាំងភេរវកម្មអាវុធដ៏មហាប្រល័យ។

មកដល់ពេលនេះមានប្រទេស២៤ដែលបានចូលជាសមាជិកនៃគំនិតផ្តួចផ្តើមនេះហើយ ប្រទេសកាហ្សាក់ស្ថានជាប្រទេសង្កេតការណ៍ ហើយអាមេរិកបានស្វាគមន៍ចំពោះកម្ពុជានិងប្រទេស៣ទៀត។

គំនិតផ្តួចផ្តើមដែលដឹកនាំដោយអាមេរិកនិងរុស្ស៊ីនេះ គឺជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការដើម្បីពង្រឹងការត្រួតពិនិត្យនូវសារធាតុដែលផលិតអាវុធនុយក្លេអ៊ែរ ហើយការពារនិងចាត់វិធានការប្រឆាំងនិងសកម្មភាពរត់ពន្ធសំភារៈទាំងអស់នេះ។ *រស្មីកម្ពុជា សៅរ៍ទី០៥ ខែឧសភា ឆ្នាំ២០០៧ ទំព័រ២ ។*

## ក្រុមហ៊ុនអាមេរិកគ្រោងបោះទុន១០០លានដុល្លារវិនិយោគលើវិស័យ IT នៅកម្ពុជា

ក្រុមហ៊ុនទិន្នន័យអន្តរជាតិរបស់អាមេរិក IDG គ្រោងបោះទុនប្រមាណ១០០លានដុល្លារអាមេរិកដើម្បីវិនិយោគជាមួយក្រុមហ៊ុនដែលមានសក្តានុពលនៅក្នុងប្រទេសកម្ពុជាចូលរួមអភិវឌ្ឍន៍វិស័យព័ត៌មានវិទ្យា។

លោក PATRICKMC. GOVERN ប្រធានអគ្គនាយកនៃក្រុមហ៊ុន IDG បានជំរាបបញ្ហានេះទៅកាន់ លោក សុខ អាន នៅក្នុងជំនួបកាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៧។

លោក PATRICK បានលើកឡើងថា IDG មានអតិថិជនប្រមាណ ២០០ លាននាក់លើពិភពលោក ដែលកំពុងតាមដានសកម្មភាពរបស់ IDG ។

លោក PATRICK ក៏បានអញ្ជើញលោក សុខ អាន ទៅបំពេញទស្សនកិច្ចនៅបូស្តុន សហរដ្ឋអាមេរិក និងមន្ទីរស្រាវជ្រាវផ្នែកជំងឺខួរក្បាលនៅសកលវិទ្យាល័យមួយ ដែលលោកបានផ្តល់ថវិកា១៥០លានដុល្លារអាមេរិក ដើម្បីសាងសង់មន្ទីរពេទ្យស្រាវជ្រាវនេះ។ *រស្មីកម្ពុជា ថ្ងៃពុធទី១១ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៤។*

## អាមេរិកផ្តល់ថវិកាបន្ថែមដល់កម្ពុជាសំរាប់សំអាតទីតាំងផលិតគ្រឿងញៀន

សហរដ្ឋអាមេរិកបានផ្តល់ថវិកាបន្ថែមចំនួន៨ម៉ឺនដុល្លារបន្ថែមទៀតដល់កម្ពុជា សំរាប់ប្រើប្រាស់ក្នុងការបោសសំអាតសារធាតុគីមីនៅទីតាំងផលិតគ្រឿងញៀនដែលរកឃើញនៅខេត្តកំពង់ស្ពឺ។ ការបន្ថែមនេះបានធ្វើអោយទឹកប្រាក់សំរាប់ការសំអាតនេះកើនដល់ ១៤ ម៉ឺនដុល្លារ។

ការផ្តល់ជំនួយបន្ថែមនេះ គឺសហរដ្ឋអាមេរិកមានការពេញចិត្តចំពោះមន្ត្រីអាជ្ញាធរកម្ពុជា ដែលមានស្នាដៃក្នុងការរកឃើញកន្លែងផលិតគ្រឿងដែលប្រកបដោយគ្រោះថ្នាក់នេះ។ ហើយអាមេរិកមានមោទនភាពដែលបានចូលរួមជាមួយប្រទេសកម្ពុជា អូស្ត្រាលី កាណាដា និង UNODC ក្នុងការសំអាតទីតាំងនេះ ដើម្បីដោះស្រាយបញ្ហាគំរាមកំហែងដល់ប្រជាពលរដ្ឋមូលដ្ឋាន និងសំអាតបរិស្ថាន។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី២៣ ខែសីហា ឆ្នាំ២០០៨ ទំព័រក២។*

## សហរដ្ឋអាមេរិកផ្តល់ជំនួយគាំទ្រគំរោងកម្មវិធីសុខាភិបាល និងអប់រំ ជាង៣០លានដុល្លារអាមេរិក

ពិធីចុះហត្ថលេខាលើវិសោធនកម្មកិច្ចព្រមព្រៀងទ្វេរភាគីចំនួនពីរ ដែលមានទឹកប្រាក់សរុបចំនួន ២៦.៧៦លានដុល្លា បានប្រព្រឹត្តទៅរវាងលោក ហោ ណាំហុង និងលោកស្រី Erin Soto នាយកទីភ្នាក់ងារ USAID កាលពីព្រឹកថ្ងៃទី១២ ខែកញ្ញាឆ្នាំ២០០៧។

បន្ថែមលើជំនួយផ្តល់អោយក្រោមកិច្ចព្រមព្រៀងទ្វេភាគីចំនួនពីរនេះ USAID នឹងផ្តល់ជំនួយបន្ថែមចំនួន ៣.៣២ លានដុល្លារតាមរយៈយន្តការផ្សេងៗទៀត ដែលនាំអោយជំនួយរបស់ USAID ដល់ប្រទេសកម្ពុជាសំរាប់សកម្មភាពផ្នែកអប់រំនិងសុខាភិបាលមានចំនួនសរុបជាង ៣០ លានដុល្លារ។

សហរដ្ឋអាមេរិកបានសន្យាលៃប្រាក់ជាង ៦៥ លានដុល្លារសំរាប់ជាជំនួយដល់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៧ ដែលផ្តល់តាមរយៈទីភ្នាក់ងារ USAID ក្រសួងការបរទេសសហរដ្ឋអាមេរិក មជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺឆ្លងរបស់ក្រសួងសុខាភិបាល និងសុខុមាលភាពរបស់អាមេរិក ហើយនឹងក្រសួងការពារជាតិរបស់អាមេរិក។ រយៈពេល១៥ឆ្នាំកន្លងទៅនេះ USAID បានផ្តល់នូវមូលនិធិសរុបជាង៦០០លានដុល្លារ គាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកម្ពុជា។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១៣ ខែកញ្ញា ឆ្នាំ២០០៨ ទំព័រក៣។*

## អដ្ឋធាតុទាហានអាមេរិកត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវិញ

លោក ចូសេហ្វ អេមូសូមេលី ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បានថ្លែងនៅក្នុងពិធីមាតុភូមិនិវត្តន៍នៃអដ្ឋិធាតុអាមេរិកកាំងកាលពីព្រឹកថ្ងៃទី១៧ខែកញ្ញាឆ្នាំ២០០៧នេះថា យើងប្តេជ្ញាចិត្តខ្ពស់ក្នុងការសំរេចអោយខាងតែបាននូវការស្វែងរកអដ្ឋិធាតុដែលមិនទាន់មានអត្តសញ្ញាណ។

លោកឧត្តមសេនីយ៍ ប៉ុល សារឿន ប្រធានគណៈកម្មការស្វែងរកទាហានអាមេរិកបាត់ខ្លួន បានអោយដឹងថាបេសកម្មនេះទទួលបានជោគជ័យ។ ជានិច្ចការយើងបានណែនាំដល់ក្រុមការងារកម្ពុជា-អាមេរិក អោយសហការគ្នាបំពេញបេសកម្មការងារមនុស្សធម៌នេះអោយទទួលបានជោគជ័យដូចសព្វថ្ងៃនេះ។

សូមបបញ្ជាក់ថា ប្រតិបត្តិការនេះចាប់ផ្តើមពីថ្ងៃទី១៥ខែសីហាឆ្នាំ២០០៧ និងអនុវត្តដោយក្រុមការងារដែលមានសមាជិក១៨រូប តំណាងអោយរដ្ឋាភិបាលកម្ពុជា-អាមេរិក។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី១៨ខែកញ្ញាឆ្នាំ២០០៧ ទំព័រក២។*

## យោធាអាមេរិកផ្តល់ថវិកាចំនួន ៩៧៥.០០០ ដុល្លារជួសជុលវិទ្យាល័យព្រះរាជសម្ភារនៅខេត្តកំពត

ថវិកានេះផ្តល់តាមរយៈគំរោងជំនួយមនុស្សធម៌ ដើម្បីជួសជុលអគារវិទ្យាល័យព្រះរាជសម្ភារ ក្នុងខេត្តកំពតដែលសាងសង់ឡើងដោយរដ្ឋាភិបាលសហរដអាមេរិកនៅចុងទសវត្សរ៏១៩៥០ ក្រោយអាគារនេះចាស់ទ្រុឌទ្រោមស្ទើរតែមិនអាចសិក្សាបាននោះ។

លោកឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា រួមជាមួយមន្ត្រីស្ថានទូតបានចុះទៅពិនិត្យដោយផ្ទាល់កាល ពីថ្ងៃទី២០ខែកញ្ញា មុននឹងចាប់ផ្តើមធ្វើការជួសជុលឡើងវិញនៅខែវិច្ឆកា ឆ្នាំ២០០៧។

លោក ចូសេហ្វ មូសូមេលី បានលើកឡើងថា ចាប់ពីឆ្នាំ ១៩៧៥ មកទំនាក់ទំនងកម្ពុជានិងអាមេរិកមិនសូវល្អនោះទេ ប៉ុន្តែទំនាក់ទំនងយើងលបន្តិចឡើងវិញហើយ។ ខាងយោធាសួរមកខ្ញុំថា តើធ្វើយ៉ាងណា ដើម្បីអោយទំនាក់ទំនងកម្ពុជានិងអាមេរិកកាន់តែប្រសើរឡើង? ខ្ញុំឆ្លើយប្រាប់គេថា យើងគួរជួយកម្ពុជាលើផ្នែកអប់រំ និងសុខាភិបាល។

លោក មូលី បញ្ជាក់បន្ថែមថា ដូចអស់លោកដឹងហើយថា សហរដ្ឋអាមេរិកបានធ្វើការសហការជាមួយកម្ពុជាលើផ្នែកសុខាភិបាលនិងអប់រំដែលយើងយកចិត្តទុកដាក់។ លោកបានបន្តថាវិទ្យាល័យព្រះរាជសម្ភារ នេះជាសាលាដែលសហរដ្ឋអាមេរិកបានធ្វើជាប្រវត្តិសាស្ត្រសំរាប់ប្រទេសកម្ពុជា បង្ហាញពីទំនាក់ទំនងល្អរវាងគ្នា ដូច្នេះការដែលយើងជួសជុលឡើងវិញនូវអគារនេះវាហាក់បីដូចជាយើងធ្វើការជួសជុលឡើងវិញ នូវទំនាក់ទំនងសហរដ្ឋអាមេរិកនិងកម្ពុជាអីចឹងដែរ។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី២៣-២៤ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក១។*

## ទាហានម៉ារីនអាមេរិកចុះជួយព្យាបាលជំងឺជូនពលរដ្ឋកម្ពុជា

កងកំលាំងទាហានម៉ារីនអាមេរិកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក បានធ្វើការរួមគ្នាជាមួយកងយោធពល ខេរមភូមិន្ទក្នុងកម្មវិធីសកម្មភាពផ្នែកពេទ្យ ដើម្បីព្យាបាលជូនប្រជាពលរដ្ឋនៅខេត្តកំពត ចាប់ពីថ្ងៃទី១២ដល់ថ្ងៃទី២២ខែកញ្ញា។

លោក អនុសេនីយ៍ Brllkes Engleebert មន្ត្រីទទួលបន្ទុកបេសកម្មគិលានុបដ្ឋាកក្នុងកងទ័ពជើងទឹកអាមេរិកនិងជាបញ្ជាការក្រុមបានមានប្រសាសន៍ថា បុគ្គលិកផ្នែកពេទ្យក្នុងកងទាហានម៉ារីន និងកងទ័ពជើងទឹកសហរដ្ឋអាមេរិក

ដែលមកធ្វើសកម្មភាពជួយព្យាបាលជំងឺជូនប្រជាពលរដ្ឋកម្ពុជាសរុបទាំងអស់ចំនួន២០នាក់ អាមេរិក១០និងកងទ័ពកម្ពុជាចំនួន១០នាក់។

លោកស្រីបន្តថា ការព្យាបាលជូនប្រជាពលរដ្ឋរួមមានព្យាបាលជំងឺទូទៅនិងព្យាបាលជំងឺធ្មេញ។ ក្នុងមួយថ្ងៃយើងទទួលព្យាបាលអ្នកជំងឺប្រមាណ៣០០នាក់ ហើយចាប់តាំងពីធ្វើការព្យាបាលរហូតមកទល់នឹងពេលនេះយើងបានដឹកអ្នកជំងឺដែលមានសភាពធ្ងន់ធ្ងរចំនួន៧នាក់មកធ្វើការវះកាត់ នៅមជ្ឈមណ្ឌលវះកាត់សំរាប់កុមារនៅភ្នំពេញ ដើម្បីព្យាបាលបន្ត។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទទី២៣-២៤ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៣។*

## យោធាអាមេរិកផ្តល់ថវិកាចំនួន ២.៣៨លានដុល្លារដល់កម្ពុជា

តាមរយៈបញ្ជាការដ្ឋានសហរដ្ឋអាមេរិកប្រចាំតំបន់មហាសមុទ្រប៉ាស៊ីហ្វិក ក្រសួងការពារប្រទេសសហរដ្ឋអាមេរិកបានសន្យាផ្តល់ប្រាក់ចំនួន២.៣៨០០.០០ដុល្លារក្នុងឆ្នាំសារពើពន្ធ២០០៧សំរាប់គំរោងជំនួយមនុស្សធម៌នៅកម្ពុជា។

តាមសេចក្តីប្រកាសព័ត៌មានស្ថានទូតសហរដ្ឋអាមេរិកចេញផ្សាយថ្ងៃទី២៧ ខែកញ្ញា បានអោយដឹងថា ថវិកានេះជាផ្នែកមួយនៃជំនួយមនុស្សធម៌ក្រៅប្រទេសរបស់ក្រសួងការពារជាតិអាមេរិក ហើយកម្មវិធីនេះស្ថិតនៅក្រោមការចាត់ចែងរបស់ការិយាល័យកិច្ចសហប្រតិបត្តិការយោធារបស់ស្ថានទូតអាមេរិក និងកងវិស្វកម្មអាមេរិកចំណែកការងារអនុវត្តន៏នៃគំរោងសាងសង់ធ្វើដោយក្រុមហ៊ុនម៉ៅការក្នុងស្រុក។

ប្រភពដដែលបានបន្ថែមថា គំរោងទាំងនេះកំពុងតែស្ថិតក្នុងដំណាក់កាលរៀបផែនការនៅឡើយ ដែលសកម្មភាពសាងសង់ពិតប្រាកដនឹងចាប់ផ្តើមប្រហែលជាក្នុងខែធ្នូឆ្នាំ២០០៧។ ជាមួយនេះដែរ សេចក្តីប្រកាសក៏បានបញ្ជាក់អោយដឹងលំអិតថវិកានៃគំរោងនិមួយៗ ដែលរួមមាន :

- ថវិកាចំនួន ២៧៥.០០០ ដុល្លារ សំរាប់មណ្ឌលសុខភាពស្រុកអូរាំងឪ ខេត្តកំពង់ចាម-សង់បន្ថែម
- ថវិកាចំនួន ២៥០.០០០ ដុល្លារ សំរាប់សាលាបឋមសិក្សារកាពប្រាំ ខេត្តកំពង់ចាម-សង់បន្ថែម
- ថវិកាចំនួន ៤៧៥.០០០ ដុល្លារ សំរាប់វិទ្យាល័យព្រះរាជសម្ភារ នៅខេត្តកំពត-ជួសជុល
- ថវិកាចំនួន ៤០០.០០០ ដុល្លារ សំរាប់មណ្ឌលសុខភាពប៉ោយប៉ែត-សង់អាគារបន្ថែម
- ថវិកាចំនួន ៤០០.០០០ ដុល្លារ សំរាប់វិទ្យាល័យពោធិសាត់ -ជួសជុល
- ថវិកាចំនួន ២០០.០០០ ដុល្លារ សំរាប់សាលាបឋមសិក្សាសូភី ខេត្តពោធិសាត់-សង់បន្ថែម
- ថវិកាចំនួន ២៥០.០០០ ដុល្លារ សំរាប់អនុវិទ្យាល័យកែវ សុវណ្ណ ស្រុកកណ្តៀង ខេត្តពោធិសាត់
- ថវិកាចំនួន ១៣០.០០០ ដុល្លារ សំរាប់ទិញមុង

ថវិកាដែលទទួលបានសំរាប់គំរោងនិមួយៗនេះ នឹងត្រូវយកទៅកសាងអគារបន្ថែមសំរាប់កន្លែងដែល ខ្វះខាតនិងជួសជុលឡើងវិញចំពោះអគារចាស់ទ្រុឌទ្រោម។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី២៨ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៤។*

## អាមេរិកចាប់ផ្តើមលើកកំពស់ពាណិជ្ជកម្មនិងវិនិយោគជាមួយកម្ពុជា

យោងតាមសេចក្តីប្រកាសរបស់ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជាបានអោយដឹងថា កាលពីថ្ងៃទី២២ ខែវិច្ឆិកានេះ លោកស្រី SusanC .Schwab តំណាងពាណិជ្ជកម្មអាមេរិកបានមកជួបពិភាក្សាការងារជាមួយលោក ចម ប្រសិទ្ធិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា។

គោលបំណងសំខាន់នៃទស្សនកិច្ចរបស់លោកស្រី Susanc នៅកម្ពុជាដើម្បីពិនិត្យមើលការកែទំរង់លើលក្ខខ័ណ្ឌច្បាប់ និងបែបបទផ្សេងរបស់កម្ពុជាដែលបានសន្យានៅពេលចូល WTO ។ ជាមួយនេះលោកស្រីនឹងពិភាក្សាជាមួយលោក ចម ប្រសិទ្ធិ លើកិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគ និងពាណិជ្ជកម្ម (TIFA) រវាងកម្ពុជានិងសហរដ្ឋអាមេរិក។

រហូតមកដល់ពេលនេះ អាមេរិកជាដៃគូរពាណិជ្ជកម្មដ៏សំខាន់របស់កម្ពុជា ថ្វីត្បិតតែប្រទេសនេះនៅមិនទាន់មានអ្នកវិនិយោគធំៗមកកាន់កម្ពុជាក៏ដោយ។ តាមតួលេខនៅក្នុងសេចក្តីប្រកាសនេះ បានអោយដឹងថា ពាណិជ្ជកម្មរវាងកម្ពុជានិងសហរដ្ឋអាមេរិកចាប់ពីដើមឆ្នាំ២០០៧មកដល់ខែកញ្ញ មានតំលៃជាទឹកប្រាក់ចំនួន ១.៩៥ ពាន់ លានដុល្លារអាមេរិក។ ដែលក្នុងនោះ ការវិនិយោគផ្ទាល់របស់អាមេរិកនៅកម្ពុជា មានតំលៃជាទឹកប្រាក់ត្រឹមតែប្រហែល ១ លានដុល្លារ ដែលការវិនិយោគនេះផ្តោលលើយានយន្ត និងគ្រឿងម៉ាស៊ីន។ ចំណែកការនាំចេញរបស់កម្ពុជា គិតជាទឹកប្រាក់មានចំនួន ១.៨៥ ពាន់លានដុល្លារអាមេរិក ហើយផលិតផលចំបង គឺសំលៀកបំពាក់។

*រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី២៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ៨។*

## កម្ពុជា-អាមេរិកពិភាក្សាអំពីការសូមកូនចិញ្ចឹមជាលក្ខណៈអន្តរប្រទេស

លោក ឡុង វិសាលោ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលោកស្រី Maura A.Harty ឧបការីរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក បានជួបពិភាក្សាគ្នាកាលពីថ្ងៃទី២៨ខែវិច្ឆិកាឆ្នាំ២០០៧ ដោយផ្តោតជាសំខាន់លើបញ្ហាទាក់ទងទៅនឹងការអនុវត្តន៍សន្ធិសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ នឹងសហប្រតិបត្តិការទាក់ទងនឹងការសូមកូនអន្តរប្រទេស។

លោក ឡុង វិសាលោ បានលើកឡើងថា កម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញានេះ កាលពីថ្ងៃទី២២ខែមករាឆ្នាំ២០០៧ ហើយយើងបានចូលជាសមាជិក អនុសញ្ញានេះពីថ្ងៃទី១ខែសីហាឆ្នាំ២០០៧ ក្នុងចំណោមប្រទេស៩ដែលបានចូលជាសមាជិកនិងប្រទេសចំនួន៤១ដែលបានផ្តល់សច្ចាប័នរួចហើយ។

លោកស្រី Harty បានអះអាងថា ភាគីសហរដ្ឋអាមេរិកចង់ធ្វើការផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមកជាមួយកម្ពុជា និងចង់ផ្តល់អ្នកបច្ចេកទេសនឹងចង់ជួយបណ្តុះបណ្តាលដល់អ្នកបច្ចេកទេសកម្ពុជា ដើម្បីរួមគ្នាអនុវត្តន៍តាមសន្ធិសញ្ញាស្តីពីការសូមកូនជាអន្តរប្រទេសនេះ។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ៨។*

## សម្តេច ហ៊ុន សែន ស្វាគមន៏នាវាចំបាំងអាមេរិកចូលចតនៅកម្ពុជា

សម្តេចបានមានប្រសាសន៍ស្វាគមន៏នេះកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ក្នុងសិក្ខាសាលាស្តីពីសន្តិសុខដែនសមុទ្រកម្ពុជា ដោយសម្តេចបានបញ្ជាក់ថា កម្ពុជាកំពុងបើកទូលាយកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរជាមួយប្រទេសទាំងអស់ដែល

ចង់ធ្វើទំនាក់ទំនងជាមួយកម្ពុជា។ សម្តេចក៏ផ្តាំផ្ញើរសួរសុខទុក្ខនាយទាហាន ពលទាហាន តាមរយៈលោកស្រីឯកអគ្គរដ្ឋទូត ដែលមានវត្តមាននៅក្នុងសិក្ខាសាលានោះផងដែរ។

នាយទាហាន និងពលទាហាននៃកងនាវាចំបាំងរបស់អាមេរិកដែលចូលចតនៅក្រុងព្រះសីហនុ កំពុងធ្វើការងារមនុស្សធម៌នៅតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដូចជា : នៅថ្ងៃទី២៧-២៨ ខែវិច្ឆកា កងទ័ពអាមេរិកចំនួន ៤៨ នាក់ ដោយសហការជាមួយជាមួយពេទ្យទាហានកម្ពុជាចំនួន៦នាក់ បានផ្តល់ការព្យាបាលមាត់ធ្មេញនឹងសុខភាពទូទៅដល់ប្រជាពលរដ្ឋនៅឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ដោយឡែក កងទ័ពអាមេរិកចំនួន ៨០ នាក់ផ្សេងទៀត បានធ្វើសកម្មភាពមនុស្សធម៌មួយចំនួននៅសាលាបឋមសិក្សាហ៊ុនសែនក្រុង នៅក្រុងព្រះសីហនុ កាលពីថ្ងៃទី២៧ខែវិច្ឆកា ដោយចែករំលែកនូវចំណេះវិជ្ជាភាសាអង់គ្លេសមូលដ្ឋានដល់លោកគ្រូអ្នកគ្រូនិងសិស្សានុសិស្សផងដែរ។ ក្រៅពីនោះមានដូចជាលាបថ្នាំអាគារ សំអាតបរិវេណជុំវិញសាលារៀន . . .។ល។ ក្នុងថ្ងៃនោះដែរមានកងទ័ពអាមេរិកមួយក្រុមទៀតបានធ្វើការបណ្តុះបណ្តាលដល់កងទ័ពកម្ពុជាចំនួន៤៥នាក់នៃបញ្ជាការដ្ឋានកងពលតូចលេខ៧០ដែលមានរយៈពេល ៣ ថ្ងៃ។

គួររំលឹកថា នាវាចំបាំងអាមេរិក ឈ្មោះ The USS Essex ដែលផ្ទុកកងម៉ារីនអាមេរិកក្នុងអង្គភាពទ័ពលេខ ៣១ ដែលមានចំនួនប្រមាណ ៣០០០នាក់បានចូលចតនៅក្នុងកំពង់ផែក្រុងព្រះសីហនុចាប់ពីថ្ងៃទី២៦ខែវិច្ឆកា ដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៧។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ៍ ទី២៩ ខែវិច្ឆកា ឆ្នាំ២០០៧ ទំព័រ១-២។*

## អាមេរិកផ្តល់ថវិកា១៣ដល់អង្គការ៣នៅកម្ពុជាដើម្បីប្រយុទ្ធនិងជំងឺអេដស៍

រដ្ឋាភិបាលអាមេរិក តាមរយៈUSAID បានប្រកាសផ្តល់ប្រាក់ចំនួន១៣លានដុល្លារដល់អង្គការចំនួន៣សំរាប់ប្រយុទ្ធជាមួយការរីករាលដាលមេរោគអេដស៍នៅកម្ពុជា។

អង្គការដែលទទួលបានជំនួយទាំងនោះនឹងលើកកម្មវិធីថ្មីមួយដែលមានឈ្មោះថា **ប្រសិទ្ធិ** ដែលនឹងប្រើប្រាស់ថវិកាទាំងនេះរយៈពេល៣ឆ្នាំ ចាប់ពីខែសីហាឆ្នាំ២០០៧ដល់ខែវិច្ឆកាឆ្នាំ២០១០។

អង្គការដែលទទួលបានជំនួយថវិកាខាងលើនេះ រួមមាន : អង្គការសុខភាពគ្រួសារអន្តរជាតិ អង្គការស្ត្រីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ និងអង្គការវេជ្ជសាស្ត្រនិងក្តីសង្ឃឹម។

លោក Joseph A Mussomeli ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ដែលបានអញ្ជើញចូលរួមក្នុងពិធីប្រកាសផ្តល់ជំនួយកាលពីថ្ងៃទី០១ខែវិច្ឆកា បានអោងដឹងថា ការផ្តល់ជំនួយ១៣លានដុល្លារនេះ គឺមានបំណងជួយកម្ពុជាអោយបន្តនូវជោគជ័យគួរអោយកត់សំគាល់របស់ខ្លួនក្នុងការកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ និងផ្តល់សេវាប្រកបដោយគុណភាពដល់អ្នករស់នៅជាមួយមេរោគអេដស៍ជំងឺអេដស៍។

លោកបន្តដោយគូសបញ្ជាក់ថា តាមរយៈកម្មវិធីប្រសិទ្ធិជំនួយរបស់យើងនឹងនៅតែបន្តផ្តោតលើការបង្ការជាមួយអ្នកប្រឈមមុខខ្ពស់ ជាពិសេសស្ត្រីធ្វើការនៅតាមសេវាកំសាន្តសប្បាយនិងអតិថិជនរបស់ពួកគាត់ ក្រុមបុរសស្រលាញ់បុរស និងអ្នកប្រើថ្នាំញៀន។ ជាមួយនេះប្រសិទ្ធិនឹងជួយពង្រឹងគុណភាពបណ្តាញសេវាថែទាំបន្ត និងលើកកំពស់ការផ្សារភ្ជាប់ជាមួយនឹងសេវាសុខភាពនានា ដូចជាសេវាសុខភាពបន្តពូជ និងពន្យារកំណើត ការអង្កេតថ្នាក់ជាតិ ការត្រួតពិនិត្យ

និងវាយតំលៃ និងការប្រើប្រាស់ព័ត៌មាន ដើម្បីធានាថា យើងនៅតែមានសមត្ថភាពឆ្លើយតបចំពោះការប្រែប្រួលការឆ្លងមេរោគអេដស៍។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ទី០៣ខែវិច្ឆកា ឆ្នាំ២០០៧ ទំព័រក៤។*

## អាមេរិកត្រៀមជួយកម្ពុជាក្នុងការពង្រឹងសមត្ថភាពជួយសង្គ្រោះគ្រោះមហន្តរាយ

បំណងនេះត្រូវបានលើកឡើងដោយលោក Charles A .Ray ឧបការីក្រសួងការពារជាតិសហរដ្ឋអាមេរិកទទួលបន្ទុក MIA និង POW (ស្វែងរកអដ្ឋិធាតុទាហានអាមេរិកបាត់ខ្លួននិងការរៀបចំបណ្ដាញនៅទូទាំងពិភពលោកដើម្បីជួយសង្គ្រោះប្រទេសដែលជួបគ្រោះមហន្តរាយ) ជំរាបសម្ដេច ហ៊ុន សែន កាលពីថ្ងៃទី០៥ ខែវិច្ឆកា ឆ្នាំ២០០៧។

លោក Charles ក៏ជាអតីតឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជាផងដែរ។ លោកបានថ្លែងការចាប់អារម្មណ៍ថាប្រទេសកម្ពុជាមានការរីកចំរើនច្រើនបន្ទាប់ពីលោកចាកចេញទៅ ហើយលោកសូមអបអរចំពោះការរីកចំរើននេះ។ លោកបន្តថា សហរដ្ឋអាមេរិកត្រៀមខ្លួនដើម្បីជួយដល់ប្រទេសកម្ពុជា ពិសេសកងទ័ពកម្ពុជាអោយមានលទ្ធភាពដើម្បីត្រៀមខ្លួនជួយដល់ប្រទេសដែលជួបគ្រោះមហន្តរាយដោយធម្មជាតិនៅក្នុងពិភពលោក។
*រស្មីកម្ពុជា ថ្ងៃពុធទី០៧ខែវិច្ឆកាឆ្នាំ២០០៧ ទំព័រក២។*

## អាមេរិកផ្តល់ថវិកា ៧៤.០០០ដុល្លារសំរាប់គំរោងអភិរក្សវប្បធម៌

រដ្ឋាភិបាលអាមេរិកបានសំរេចផ្ដល់ថវិកាចំនួន៧៤.000ដុល្លារដល់រាជរដ្ឋាភិបាលកម្ពុជា សំរាប់គំរោងអភិរក្សវប្បធម៌ចំនួន២ ដែលត្រូវអនុវត្តន៍ដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ដល់ថវិកា ធ្វើនៅថ្ងៃទី១៥ខែវិច្ឆកាឆ្នាំ២០០៧ រវាងលោក Joseph A. Mussomeli ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា និងលោក វ៉េង សេរីវុឌ្ឍ រដ្ឋមន្ត្រីវប្បធម៌។

ថវិកាទាំងនេះសំរាប់អនុវត្តន៍គំរោង២ : ទី១- មូលនិធិឯកអគ្គរដ្ឋទូតសំរាប់ការអភិរក្សវប្បធម៌និងផ្ដល់ថវិកាជាង៤៤.000ដុល្លារ សំរាប់បង្ហើយការងារជួសជុលឡើងវិញនៅប្រាសាទ ហាន់ ជ័យ ខេត្តកំពង់ចាម។ ទី២- មជ្ឈមណ្ឌលបេតិកភណ្ឌវប្បធម៌របស់ក្រសួងការបរទេសអាមេរិក នឹងផ្ដល់ថវិកាចំនួន ៣0.000 ដុល្លារ ដើម្បីជួយក្រសួងក្នុងការប្រមូលវត្ថុបុរាណដែលមិនទាន់បញ្ចូលក្នុងការសារពើពន្ធដោយដាក់វត្ថុបុរាណទាំងនោះចូលទៅក្នុងមូលដ្ឋានទិន្នន័យសារពើពន្ធជាតិដែលទើបតែត្រូវបានបង្កើតឡើង។

ក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅ រដ្ឋាភិបាលអាមេរិកបានផ្ដល់ថវិកាជាង ៨៦៦.000 ដុល្លារសំរាប់គំរោងអភិរក្សវប្បធម៌នៅកម្ពុជា។ ក្រៅពីនេះអាមេរិកនៅមានកិច្ចព្រមព្រៀងជាច្រើនជាមួយកម្ពុជាពាក់ព័ន្ធនឹងបញ្ហាវប្បធម៌នេះ។
*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១៥ ខែវិច្ឆកាឆ្នាំ២០០៧ ទំព័រក២។*

## ក្រុមហ៊ុនអាមេរិកបើករោងចក្រនៅកម្ពុជា

រោងចក្ររបស់ក្រុមហ៊ុន CROWN BEVERAGE CANS (CAMBODIA) LTD. ដែលជាក្រុមហ៊ុនវិនិយោគទុនមកពីសហរដ្ឋអាមេរិកបានបើសម្ពោធកាលពីថ្ងៃទី៤ខែធ្នូនៅខ័ណ្ឌដង្កោរាជធានីភ្នំពេញ។

លោក សុខ អាន ដែលបានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធនេះ បានថ្លែងថា ការវិនិយោគនៅកម្ពុជានឹងមានការកើនឡើងសំរាប់ពេលបច្ចុប្បន្ន ក៏ដូចជាអនាគត។

រោងចក្រនេះនឹងផលិតសំបកវេចខ្ចប់ផ្សេងៗ ជាពិសេសភេសជ្ជៈ កំប៉ុងស្រាបៀ កំប៉ុងទឹកគ្រូច។

*រស្មីកម្ពុជា ថ្ងៃពុធទី០៥ខែធ្នូឆ្នាំ២០០៧ ទំព័រ៣។*

## ជំនួបរវាងកម្ពុជា-អាមេរិកផ្ដោតលើបញ្ហាជាច្រើន

លោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងលោក Cobh Mixter ប្រធានគណៈប្រតិភូសភាអាមេរិកបានជួបពិភាក្សាគ្នានៅថ្ងៃទី៣០ខែវិច្ឆកា ដើម្បីពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា-អាមេរិក ហើយក៏បានផ្ដោតជាពិសេសលើបញ្ហាភូមា និងបញ្ហាជាសកលមួយចំនួនផងដែរ។

លោក អ៊ុច បូរិទ្ធ បានមានប្រសាសន៍ក្រោយជំនួបថា ជំនួបនេះមានការពិភាក្សាផ្ដោតទៅលើបញ្ហា :

- លោក Cobb បានលើកពីបញ្ហាទាក់ទងទៅនឹងការជួញដូរមនុស្ស។ លោករដ្ឋលេខាធិការបាន ថ្លែងបញ្ជាក់ពីការខិតខំរបស់កម្ពុជាក្នុងការអនុវត្តន៍តាមដាន ហើយតែងតែធ្វើការចាប់ពិរុទ្ធជន។ លោក Cobb បានបញ្ជាក់វិញថា អាមេរិកបានត្រៀមខ្លួនដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជា មួយនឹងភាគីកម្ពុជាលើបញ្ហានេះ។
- ទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-អាមេរិក។ លោក អ៊ុច បូរិទ្ធ បានលើកឡើងពីការរីកចំរើនរបស់កម្ពុជាក្នុងរយៈការប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសតាមរយៈការសំរេចបានកំណើនសេដ្ឋកិច្ចជាងពីរខ្ទង់។ លោកបញ្ជាក់ផងដែរអំពីការនាំចេញសំលៀកបំពាក់ទៅអាមេរិក មានចំនួនជាង៣កោដិដុល្លារអាមេរិក។ លោកក៏បានបញ្ជាក់ពីមូលហេតុដែលនាំអោយមានការសំរេចបានយ៉ាងដូច្នេះ ក៏ដោយសារតែមកពីការកែទំរង់របស់រដ្ឋាភិបាល។ ទន្ទឹមនេះកម្ពុជាកំពុងរៀបចំច្បាប់ប្រឆាំងនឹងអំពើពុករលួយ ហើយថ្មីៗនេះកម្ពុជាបានចុះហត្ថលេខាកាលពីខែតុលាឆ្នាំ២០០៧ លើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីការប្រឆាំងអំពើពុករលួយ។ លោក Cobb បានអបអរចំពោះការរីកចំរើននេះ ជាចំពោះមាគ៌ារដ្ឋាភិបាលលើមូលដ្ឋានប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស។
- ចំពោះកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងភេរវកម្មនុយក្លេអ៊ែរ ដែលជាគំនិតផ្ដួចផ្ដើមលើកឡើងដោយលោកប្រធានាធិបតី ប៊ូស របស់អាមេរិក និងលោកប្រធានាធិបតីរុស្ស វ្លាឌីមៀរ ពូទីន ។ លោក អ៊ុច បូរិទ្ធ បានលើកឡើងថា កម្ពុជាមានកិច្ចសហប្រតិបត្តិការលណាស់ជាមួយអាមេរិកលើបញ្ហានេះ ហើយកម្ពុជាបានគាំទ្រនូវសេចក្ដីប្រកាសជាគោលការណ៍នេះ។ ហើយជាមួយនេះ លោកបានលើកឡើងថា មិនមែនមានត្រឹមតែវិស័យខាងលើនោះទេដែលកម្ពុជា-អាមេរិកមានកិច្ចសហប្រតិបត្តិការជាមួយគ្នា នៅមានវិស័យជាច្រើនទៀត ជាពិសេសវិស័យសិក្សាធិការនិងសុខាភិបាល។ លោក Cobb បានលើកឡើងពីការយោគយល់គ្នារវាងប្រជាជន នៃប្រទេសទាំងពីរ ជាពិសេសតាមរយៈការមកដល់របស់ Peace Corp កន្លងមកនៅកម្ពុជា។

- ពាក់ព័ន្ធនិងបញ្ហាមីយ៉ាន់ម៉ា លោក Cobb បានស្នើកម្ពុជាអោយជួយ ធ្វើយ៉ាងណាអោយសភាពការណ៍នៅមីយ៉ាន់ម៉ាមានការរីកចំរើន។ បញ្ហានេះ លោក អ៊ុច បូរិទ្ធលើកឡើងថា ការដោះស្រាយបញ្ហាមីយ៉ាន់ម៉ាទាមទារនូវការអត់ធ្មត់ ហើយធ្វើយ៉ាងណាលើកទឹកចិត្តអោយរដ្ឋាភិបាលមីយ៉ាន់ម៉ាក៏ដូចជាគ្រប់ភាគីទាំងអស់មានទំនោរក្នុងការប្រាស័យរួមគ្នាដោះស្រាយវិបត្តិ។ ហើយជាមួយនេះ កម្ពុជាក៏ដូចជាប្រទេសអាស៊ានផ្សេងទៀតគាំទ្រចំពោះតួនាទីដ៏សំខាន់របស់លោកអគ្គលេខាធិការរងអង្គការសហប្រជាជាតិ ដើម្បីរិះរកដំណោះស្រាយវិបត្តិនៅប្រទេសមីយ៉ាន់ម៉ា។ ប៉ុន្តែយើងត្រូវគោរពសិទ្ធិ សេរីភាព ក៏ដូចជាអធិបតេយ្យរបស់មីយ៉ាន់ម៉ាផងដែរ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ទី០១ ខែធ្នូឆ្នាំ២០០៧ ទំព័រក៣។*

## **មន្ត្រីអាមេរិកសរសើរការវិវត្តន៍នៅកម្ពុជា**

លោក Clint Williamson ឯកអគ្គរដ្ឋទូតគោចរទទួលបន្ទុកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាមអាមេរិកបានលើកឡើងជំរាបលោក សុខ អាន កាលពីថ្ងៃទី៧ខែធ្នូថា កម្ពុជាកំពុងតែដើរចំទិសដៅ ជាពិសេសសញ្ញាវិជ្ជមាននៃសាលាក្តីខ្មែរក្រហម។

លោកទូតគោរចរ ដែលអមដំណើរដោយលោកឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា Joseph A. Mussomeli បានអះអាងថា នេះជាជោគជ័យយ៉ាងពិតប្រាកដរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាមោទនភាពរបស់កម្ពុជា ដែលនៅលើផ្ទាំងកាសែត New York Time នៃទំព័រដំបូងរបស់គេដែលបានសរសេរអត្ថបទ យ៉ាងល្អស្អីពីតុលាការខ្មែរក្រហមនេះ។

លោក សុខ អាន បានលើកឡើងថា អ្វីដែលកម្ពុជាទទួលបាន និងការគោរពចំពោះដំណើរការសាលាក្តីខ្មែរក្រហមនោះគឺ ផ្តោតលើ៥ចំនុច : **ទី១-** ការវិនិច្ឆ័យក្តីតាមរយៈតុលាការ ដែលគំរោងចំណាយមានតិចបំផុត(៥៦លានដុល្លាររយៈពេល៣ឆ្នាំ) **ទី២-** ការធ្វើវិនិច្ឆ័យអស់ចិរវេលាខ្លី គឺរយៈពេល៣ឆ្នាំ **ទី៣-** បង្ហាញគោលការណ៍សហការរវាងប្រទេសសាម៉ី(ប្រទេសកើតហេតុនិងអន្តរជាតិ) **ទី៤-** ផលប្រយោជន៍សកលជាគំរូតំណាងដោយសហចៅក្រមសកលជាគំរូតំណាងដោយចៅក្រមជាតិនិងអន្តរជាតិ ទី៥- តម្លាភាព និងការ ចូលរួមរបស់ប្រជាពលរដ្ឋក្នុងការវិនិច្ឆ័យ។

*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី០៩-១០ខែធ្នូឆ្នាំ ២០០៧ ទំព័រក២។*

## ៨_ទំនាក់ទំនងកម្ពុជា និងប្រទេសអូស្ត្រាលី_ណូវែលហ្សេឡង់

### អូស្ត្រាលីជួយ៣០លានដុល្លារពង្រឹងប្រព័ន្ធព្រហ្មទណ្ឌនិងយុត្តិធម៌

រដ្ឋាភិបាលអូស្ត្រាលី បានសំរេចផ្តល់ជំនួយជាទឹកប្រាក់ចំនួន ៣០ លានដុល្លារអូស្ត្រាលី ដើម្បីរួមវិភាគទានជាមួយទឹកប្រាក់របស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៤លាន ២សែនដុល្លារអូស្ត្រាលីទៀត សំរាប់ជួយក្នុងគំរោងព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាក្នុងដំណាក់កាលទី៣។

ពិធីចុះហត្ថលេខាលើអនុស្សរណៈនេះ បានរៀបចំឡើងកាលពីថ្ងៃទី១២ខែមីនា នៅក្រសួងមហាផ្ទៃ រវាងលោក ស ខេង និងលោកស្រី Lisa Filipetto ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា។

លោក ស ខេង បានអោយដឹងថា គំរោងនេះមានរយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១២ គឺជាជំនួយរួមគ្នារវាងរដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា រួមមានការិយាល័យទំនាក់ទំនងប៉ូលីសសហព័ន្ធអូស្ត្រាលី គំរោងសំរបសំរួលជំនាញបច្ចេកទេសកម្ពុជា-អូស្ត្រាលី កម្មវិធីអប់រំសិទ្ធិមនុស្សនៅកម្ពុជាតាមរយៈកិច្ចព្រមព្រៀងសហប្រតិបត្តិការរបស់អង្គការក្រៅរដ្ឋាភិបាល។

គំរោងនេះនឹងបន្តជួយពង្រឹងសមត្ថភាពក្នុងវិស័យព្រហ្មទណ្ឌនិងយុត្តិធម៌បន្ថែមទៀត ជាពិសេសផ្តោតចំបងលើកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ការទប់ស្កាត់បទល្មើសនិងសុវត្ថិភាពសហគមន៍ នគរបាលជាតិ ក្រសួងយុត្តិធម៌ តុលាការនិងនាយកដ្ឋានពន្ធនាគារ តាមរយៈការផ្តល់ថវិកាដើម្បីជួយគាំទ្រដល់សកម្មភាពផ្តួចផ្តើមនានាដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង។ *កាសែតកម្ពុជា ថ្មីចេញផ្សាយថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៧*។

### អូស្ត្រាលីប្រកាសផ្តល់ប្រាក់១២លានដុល្លារដល់ស៊ីម៉ាក់

រដ្ឋាភិបាលប្រទេសអូស្ត្រាលីបានសំរេចថា ខ្លួននឹងផ្តល់ទឹកប្រាក់ចំនួន១២លានដុល្លារ ដើម្បីគាំទ្រសកម្មភាពបោសសំអាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅកម្ពុជា។

តាមសេចក្តីប្រកាសព័ត៌មានរួមគ្នាមួយរបស់អង្គការ AusAid និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ កាលពីថ្ងៃទី៤ខែមេសា កន្លងទៅនេះបានអោយដឹងថា ជំនួយនេះបានត្រូវគេប្រកាសអោយដឹងនៅក្នុងទិវាកំចាត់មីនអន្តរជាតិ។

ជំនួយរបស់អូស្ត្រាលីរួមជាមួយបណ្តាប្រទេសដទៃទៀត បានជួយកាត់បន្ថយអត្រាគ្រោះថ្នាក់បណ្តាលមកពីគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ពី ៣០០០ មកត្រឹម ៤៥០ ករណីក្នុងមួយឆ្នាំៗ។

ចាប់តាំងពីឆ្នាំ១៩៩៦មក អូស្ត្រាលីបានផ្តល់ជំនួយគិតជាទឹកប្រាក់អស់ចំនួនប្រហែល៥០លានដុល្លារដល់សកម្មភាពដែលទាក់ទងនឹងការសំអាតមីននៅកម្ពុជារួមទាំងទឹកប្រាក់ចំនួន២លានដុល្លារសំរាប់គំរោងសំអាតមីនកាលពីឆ្នាំមុន។

ប្រភពពីសេចក្តីប្រកាសនេះបានអោយដឹងបន្ថែមថា អូស្ត្រាលីបានសន្យានឹងផ្តល់ជាទឹកប្រាក់ចំនួន៧៥លានដុល្លារក្នុងរយៈពេល៥ឆ្នាំរហូតដល់ឆ្នាំ២០១០ សំរាប់សកម្មភាពកំចាត់មីនជាសកល។

*រស្មីកម្ពុជា ថ្ងៃសុក្រ ទី០៦ ខែមេសា ឆ្នាំ២០០៧ ទំព័រក៤។*

## កម្ពុជា-អូស្ត្រាលី ពិភាក្សាពីជំនួយកសិកម្ម

ជំនួបពិភាក្សារវាងលោក ចន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម និងលោកស្រី Margaret Adamson ឯកអគ្គរដ្ឋទូតអូស្ត្រាលីថ្មីប្រចាំកម្ពុជា កាលពីថ្ងៃទី១១ ខែមិថុនា បានផ្តោតសំខាន់លើជំនួយរបស់អូស្ត្រាលីដល់កម្ពុជាក្នុងវិស័យកសិកម្ម។

ប្រភពមន្ត្រីកសិកម្មបានអោយដឹងថា អូស្ត្រាលីបានជួយកម្ពុជាលើផ្នែកកសិកម្មនេះតាំងពីទសវត្សរ៍ឆ្នាំ៨០មកម្លេះពិសេសចាប់ពីឆ្នាំ១៩៨៧ អូស្ត្រាលីបានជួយកម្ពុជាតាមរយៈគំរោងមួយចំនួនដូចជា : គំរោងកម្ពុជា-អ៊ីរី (IRI) គំរោងផ្សព្វផ្សាយកសិកម្ម គំរោងបង្កើនគុណភាពកសិកម្ម គំរោងស្រាវជ្រាវកសិកម្មជាដើម ហើយដែលគំរោងទាំងនេះមានទឹកប្រាក់ប្រហែល៧៧លានដុល្លារអាមេរិក។

ប្រភពដដែលបានបញ្ជាក់ផងដែរថា ភាគីទាំងពីរបានពិភាក្សាលើបញ្ហាពីរទៀត រួមមាន :

ទី១- អូស្ត្រាលីកំពុងសហការជាមួយក្រសួងកសិកម្មកម្ពុជា ក្នុងការរៀបចំគំរោងមួយមានឈ្មោះថា ខ្សែសង្វាក់ផលិតកម្ម បន្ថែមលើផលិតផលកសិកម្មកម្ពុជា ដែលគ្រោងទឹកប្រាក់ប្រមាណចំនួន៤៥លានដុល្លារអូស្ត្រាលី សំរាប់អនុវត្តពីឆ្នាំ២០០៧-២០១០។

ទី២- ភាគីទាំងពីរពិភាក្សាជំរុញការរៀបចំកម្មវិធីអភិវឌ្ឍន៍យុទ្ធសាស្ត្រនិងទឹក ដែលក្រសួងកសិកម្មនិងក្រសួងធនធានទឹករបស់កម្ពុជា ជាដៃគូជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតដែលដឹកនាំដោយប្រទេសអូស្ត្រាលី ហើយដែលបានដាក់អោយអនុវត្តកាលពីពេលថ្មីៗកន្លងទៅនេះ។ *រស្មីកម្ពុជា ថ្ងៃពុធ ទី១៣ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក៤។*

## អូស្ត្រាលីផ្តល់ជំនួយ ៧.៥ លានដុល្លារ សំរាប់ផលប៉ះពាល់នៃបំរែបំរួលអាកាសធាតុក្នុងប្រទេសក្រីក្រ

រដ្ឋាភិបាលអូស្ត្រាលី នឹងផ្តល់មូលនិធិចំនួន៧.៥លានដុល្លារសំរាប់ជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដល់បណ្តាប្រទេសក្រីក្របំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ ដែលក្នុងនោះមានប្រទេសកម្ពុជាផងដែរ ។

គំរោងផ្តល់ជំនួយនេះត្រូវបានប្រកាសឡើងដោយលោក Alexander Downer រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី ដែលប្រាប់ទីភ្នាក់ងារព័ត៌មានរបស់ខ្លួន AAP កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៧ ។

ប្រភពព័ត៌មានខាងលើបានបញ្ជាក់ថា មូលនិធិនេះនឹងត្រូវបានគេផ្តល់ទៅអោយមូលនិធិនៃបណ្តាលប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចរបស់គំរោងអនុសញ្ញាស្តីអំពីការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ ដើម្បីគាំទ្រសកម្មភាពទាំងឡាយដែលជួយកាត់បន្ថយផលប៉ះពាល់ពីបញ្ហានេះទៅបណ្តាប្រទេសក្រីក្រទាំងឡាយ ។

ទឹកប្រាក់ទាំងអស់នេះនឹងត្រូវប្រើប្រាស់ដើម្បីជួយទៅដល់បណ្តាកោះនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលនៅជិត១នឹងប្រទេសអូស្ត្រាលីនិងបណ្តាប្រទេសដែលក្រីក្រនៅអាស៊ីទាំងឡាយ ដូចជាកម្ពុជាជាដើម អោយចេះធ្វើការប៉ាន់ប្រមាណនិងចេះប្រែប្រួលទៅតាមផលប៉ះពាល់ទាំងឡាយស្តីអំពីការប្រែប្រួលអាកាសធាតុនៅតាមប្រទេសរបស់ពួកគេ ។

*រស្មីកម្ពុជា ថ្ងៃពុធ ទី០៦ ខែមិថុនា ឆ្នាំ២០០៧ ទំព័រក៣ ។*

## កម្ពុជា-អូស្ត្រាលី ឈានដល់ទំនាក់ទំនងខ្ពស់

អូស្ត្រាលីបានឈានដល់ការកសាងស្ថានទូតថ្មីលើកដំបូងនៅកម្ពុជា ដែលមានទីតាំងនៅក្បែរវិមានរដ្ឋសភា និងក្រសួងការបរទេសនៃព្រះរាជាណាចក្រកម្ពុជា ។

លោកស្រី ម៉ាហ្គារ៉េត អាដាមសុន ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា បានប្រសាសន៍កាលពីថ្ងៃទី១៤ខែវិច្ឆកា ឆ្នាំ២០០៧ ក្នុងបញ្ចុះបឋមសិលា កសាងស្ថានទូតថា យើងចង់បង្កើនការយល់ដឹងអំពីប្រទេសអូស្ត្រាលីនៅក្នុងប្រទេសកម្ពុជា និងចង់បង្ហាញពីការប្តេជ្ញាចិត្តដ៏រឹងមាំរបស់អូស្ត្រាលីចំពោះកិច្ចសហប្រតិបត្តិការដើម្បីសន្តិភាព សន្តិសុខ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមប្រកបដោយចីរភាពរបស់កម្ពុជា ។

លោក អ៊ុច បូរិទ្ធ តំណាងលោក ហោ ណាំហុង ដែលបានអញ្ជើជាអធិបតីក្នុងពិធីនោះដែរ បានវាយតំលៃខ្ពស់ចំពោះទំនាក់ទំនងការទូតរវាងកម្ពុជា-អូស្ត្រាលី ដែលមានតាំងពីឆ្នាំ១៩៥២ ហើយដែលត្រូវបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ជាពិសេសសក្តិភាពនាពេលនេះ ។

អូស្ត្រាលីបានចូលរួមចំនែកយ៉ាងសកម្មក្នុងការស្តារនិងកសាងកម្ពុជាក្នុងផ្នែកយុត្តិធម៌ ហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍ធនធានមនុស្ស កសិកម្ម ។

អាគារស្ថានទូតដែលត្រូវសង់នៅពេលនេះ គ្រោងនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០០៨ ចំនែកតំលៃមិនត្រូវគេបញ្ជាក់អោយដឹងនោះទេ ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ ទី១៥ខែវិច្ឆកាឆ្នាំ២០០៧ ទំព័រក២ ។*

## AUSAID ផ្តល់ថវិកា៦ម៉ឺនដុល្លារសំរាប់បំផ្លាញសារធាតុផ្សំគ្រឿងញៀននៅកំពង់ស្ពឺ

អង្គការ AUSAID បានសំរេចផ្តល់ថវិកា៦ម៉ឺនដុល្លារអាមេរិកតាមរយៈអង្គការ UNODC សំរាប់គាំទ្រសកម្មភាពបំផ្លាញសារធាតុគីមីផ្សំគ្រឿងញៀនដែលអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបានបង្ក្រាប និងរឹបអូសបានកាលពីពេលកន្លងទៅនៅខេត្តកំពង់ស្ពឺ។

កិច្ចព្រមព្រៀងស្តីពីការផ្តល់ថវិកាសំរាប់គាំទ្រសកម្មភាពបំផ្លាញសារធាតុគីមីផ្សំគ្រឿងញៀន នៅខេត្តកំពង់ស្ពឺនេះបានត្រូវចុះហត្ថលេខាកាលពីថ្ងៃទី១៨ខែកក្កដា រវាងលោកស្រី Magaret Adamson ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ជាមួយលោក Jeffry Avina នាយកប្រតិបត្តិនៃអង្គការ UNODC ប្រចាំនៅទីក្រុងវីយែននៃប្រទេសអូទ្រីសដែលលោកកំពុងបំពេញទស្សនកិច្ចការងារនៅកម្ពុជា។

ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពលោកឧត្តមសេនីយ៍ឯក លួ រ៉ាមីន អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ច័ន្ទ ទី១៥-១៦ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ៤។*

## នូវែលហ្សេឡង់គ្រោងចំណាយ១ឆ្នាំ១លានដុល្លារជួយប្រជាជននៅតំបន់ប្រាសាទអង្គរ

បំណងនេះត្រូវបានលើកឡើងដោយលោក John Howse អនុប្រធានក្រុមហ៊ុន FRASEFR THOMAS និងជានាយកនៃគំរោង ជំរាបជូនលោក សុខ អាន កាលពីថ្ងៃទី៣០ខែមេសាឆ្នាំ២០០៧។

លោក John បានលើកឡើងថា រដ្ឋាភិបាលនូវែលហ្សេឡង់មានគំរោងចំណាយក្នុងមួយឆ្នាំប្រមាណ១លានដុល្លារសំរាប់រយៈពេល៥ឆ្នាំដើម្បីជួយប្រជាជនប្រមាណ១៩ម៉ឺននាក់ដែលកំពុងរស់នៅតំបន់ទី១និងតំបន់ទី២នៃប្រាសាទអង្គរ។

គំរោងនេះ មានការដាំបន្លែ ដាំដើមឈើនៅក្នុងប្រាសាទ និងបង្រៀនប្រជាជនអោយចេះថែរក្សា អភិរក្សប្រាសាទនិបង្រៀនអោយចេះប្រកបមុខរបរ ដែលអាចទាញយកផលបានពីវិស័យទេចរណ៍។

*រស្មីកម្ពុជា ថ្ងៃអង្គារ៍ ទី០១ ខែឧសភា ឆ្នាំ២០០៧ ទំព័រក៣។*

## ៩. ទំនាក់ទំនងកម្ពុជា និងបណ្តាប្រទេសផ្សេងៗ

### សម្តេច ហ៊ុន សែន បញ្ចប់ទស្សនកិច្ចនៅឥណ្ឌា

សម្តេច ហ៊ុន សែន បានអញ្ជើញវិលត្រឡប់ពីបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅសាធារណៈរដ្ឋឥណ្ឌានៅថ្ងៃ ទី១០ខែធ្នូ បន្ទាប់ពីបំពេញទស្សនកិច្ចនៅសាធារណៈរដ្ឋឥណ្ឌាអស់រយៈពេល៤ថ្ងៃ(ពីថ្ងៃទី០៧ដល់ ថ្ងៃទី១០ខែធ្នូឆ្នាម២០០៧)។

នៅឯព្រលានយន្តហោះ លោក ហោ ណាំហុង បានថ្លែងថា : នេះជាដំណើរទស្សនកិច្ចលើកទី៧ហើយ របស់សម្តេច ហ៊ុន សែន ទៅកាន់សាធារណៈរដ្ឋឥណ្ឌាចាប់តាំងពីឆ្នាំ១៩៨២មក។ លោកក៏បានលើកឡើងផងពីលទ្ធផលនៃដំណើរទស្សនកិច្ចលើកនេះ មានការចុះហត្ថលេខាលើឯកសារចំនួន៧ ដែលមានដូចជា :

- កិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចីដែលមានទឹកប្រាក់ចំនួន ៣៥,២លានដុល្លារអាមេរិក ដែលក្នុងនោះចំនួន ១៥លានដុល្លារ សំរាប់ការកសាងទំនប់ទឹកស្ទឹងក្រសាល។ ប្រាក់កម្ចី១៥លានដុល្លារសំរាប់ រៀបចំបណ្តាញអគ្គសនីពីខេត្តស្ទឹងត្រែងមកខេត្តក្រចេះនិងទឹកប្រាក់កម្ចីចំនួន៥,២លានដុល្លារ ទៀតសំរាប់ទិញម៉ាស៊ីនបូមទឹក
- កម្ពុជា-ឥណ្ឌា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបញ្ជូននិងផ្ទេរទណ្ឌិតទៅវិញទៅមក
- កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ
- អនុស្សរណៈស្តីពីការការិយាល័យពិគ្រោះយោបល់ក្រសួងការបរទេស
- អនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យធនធានទឹក
- អនុស្សរណៈនៃផែនការការងារកសិកម្មនិងអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការនិងជំនួយ បច្ចេកទេសរវាងអាជ្ញាធរប្រេងកាត និងឧស្ម័នធម្មជាតិឥណ្ឌា

ក្នុងដំណើរទស្សនកិច្ចនោះ សម្តេច ហ៊ុន សែន បានជួបសម្តែងការគួរសមជាមួយលោកជំទាវ Pratibha Patil ប្រធានាធិបតី នៃសាធារណៈរដ្ឋឥណ្ឌា លោក Mohammad Hamid Ansari អនុប្រធានាធិបតី និងជួបពិភាក្សាជាមួយលោក Mannmohan Singh នាយករដ្ឋមន្ត្រីឥណ្ឌា ។

ក្រៅពីនេះ សម្តេចបានអញ្ជើញទៅទស្សនាកន្លែងមួយចំនួនទៀតនៅក្នុងប្រទេសឥណ្ឌា ជាពិសេសកន្លែងអភិវឌ្ឍបច្ចេកវិទ្យា ។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី១១ខែធ្នូឆ្នាំ២០០៧ ទំព័រក២ ។*

## ឥណ្ឌាគ្រោងផ្តល់ប្រាកកម្ចី៣៥លានដុល្លារ

មន្ត្រីក្រសួងសេដ្ឋកិច្ច បានអោយដឹងកាលពីថ្ងៃទី១៤ខែវិច្ឆកាឆ្នាំ២០០៧ ថា លោក Aloke Sen ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា បានជួបពិភាក្សាជាមួយលោក គាត ឈន់ ដើម្បីពិភាក្សាលើការរៀបចំផ្តល់ហិរញ្ញប្បទានជាឥណទានចំនួន៣៥លានដុល្លារ ។

មន្ត្រីដដែលប្រាប់ថា ទឹកប្រាក់ជំនួយឥណទាននេះនឹងត្រូវយកទៅប្រើប្រាស់គំរោងការចំនួន៣ : គឺគំរោងអភិវឌ្ឍន៍ស្ទឹងតាសាល គំរោងការផ្តល់ម៉ាស៊ីនបូមទឹក និងគំរោងការសាងសង់បណ្តាញថាមពលអគ្គសនីដែលមានតង់ស្យុងខ្ពស់ពីក្រចេះទៅស្ទឹងត្រែង ។

កន្លងមកឥណ្ឌាធ្លាប់បានជួយប្រទេសកម្ពុជាពីរគំរោងអភិវឌ្ឍន៍ផ្សេងៗ ដូចជា គំរោងការស្តារទឹកបារាយណ៏នៅសៀមរាប និងគំរោងការផ្តល់ម៉ាស៊ីនបូមទឹក ដែលមានទឹកប្រាក់ចំនួន១០លានដុល្លារ ។ ហើយគំរោងបន្ទាប់នេះ ជាគំរោងឥណទានមានការប្រាក់ទាប ។ *រស្មីកម្ពុជា ថ្ងៃសុក្រទី១៦ខែវិច្ឆកាឆ្នាំ២០០៧ ទំព័រក៦ ។*

## កម្ពុជា -ប៉ាគីស្ថាន ពិភាក្សាស្វែងការរកពង្រឹងទំនាក់ទំនង

ជំនួបពិភាក្សានេះបានធ្វើឡើងកាលពីថ្ងៃទី២២ខែមិថុនាឆ្នាំ២០០៧ រវាងលោក ហោ ណាំហុង និងលោក Mohammad Younis Khan ដែលទើបត្រូវបានរដ្ឋាភិបាលប៉ាគីស្ថានតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេសកម្ពុជា ។

តាមប្រភពនៃជំនួបនេះបានបញ្ជាក់ថា ភាគីទាំងពីរបានពិភាក្សាធ្វើយ៉ាងណារឹតចំណងទាក់ទងទ្វេរភាគីអោយកាន់តែរឹងមាំ ។ ភាគីទាំងពីរក៏បានផ្តោតការពិភាក្សាលើបញ្ហាតំបន់កាស្មៀរដែលជាប់ព្រំដែនប៉ាគីស្ថាននិងឥណ្ឌា ។ ជាមួយនេះ ប៉ាគីស្ថានក៏បង្ហាញឆន្ទៈក្នុងស្នើសុំចូលជាដៃគូរពេញសិទ្ធក្នុងការពិភាក្សាជាមួយអាស៊ាន ។

ភាគីទាំងពីរ ក៏បានពិភាក្សាលើការសន្យារបស់លោក Mir Zafarullah Khan Jamali នាយករដ្ឋមន្ត្រីប៉ាគីស្ថានដែលបានប្រកាសផ្តល់ឥណទានសម្បទានដល់កម្ពុជាចំនួន១០លានដុល្លារអាមេរិក ក្នុងការប្រាក់១ភាគរយ សំរាប់គំរោងអភិវឌ្ឍន៍អាងស្តុកទឹកស្ទឹងតាសាល ស្ថិតនៅតំបន់ឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលបញ្ហានេះ លោក ហោ ណាំហុង បានស្នើអោយភាគីប៉ាគីស្ថានជួយជំរុញអោយបានឆាប់ ។

ប្រទេសប៉ាគីស្ថានបានភ្ជាប់ទំនាក់ទំនងការទូតជាមួយកម្ពុជាចាប់ពីថ្ងៃទី២៨ខែឧសភាឆ្នាំ១៩៥២ រហូតដល់ឆ្នាំ១៩៧៥ ទើបទំនាក់ទំនងនេះបានកាត់ផ្តាច់មួយរយៈក្នុងរបបខ្មែរក្រហម ។ ប៉ុន្តែទំនាក់ទំនងនេះបានភ្ជាប់ឡើងវិញនៅខែ

កក្កដា ឆ្នាំ១៩៩២ ប៉ុន្តែពេលនោះនិវេសនដ្ឋានស្ថិតនៅទីក្រុងបាងកក រហូតដល់ថ្ងៃទី១៤ខែសីហាឆ្នាំ២០០៥ ទើបស្ថានទូតប៉ាគីស្ថានបើកជាផ្លូវការប្រចាំនៅកម្ពុជា ប៉ុន្តែទំនាក់ទំនងនេះត្រឹមកំរិតភារៈធារីស្តីទីប៉ុណ្ណោះ ។

ក្នុងទំនាក់ទំនងទ្វេរភាគី ប៉ាគីស្ថានបានផ្តល់អាហារូបករណ៍ដល់មន្ត្រីកម្ពុជាចំនួន៦រូបក្នុងឆ្នាំ២០០៤-២០០៥ ចំនែកកម្ពុជាបានផ្តល់ជំនួយមនុស្សធម៌វិញនូវទឹកប្រាក់ ៣.៦១០.០០០ រៀល និង ២០.៣០៦ ដុល្លារអាមេរិក សំរាប់ជួយដល់ជនរងគ្រោះដោយការរញ្ជួយដីនៅក្នុងប្រទេសប៉ាគីស្ថាន ។ ចំពោះទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ គឺមានតិចតួចបំផុត ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ទី២៣ ខែមិថុនា ឆ្នាំ២០០៧ ទំព័រ១ ។*

## ម៉ារ៉ុករកការគាំទ្រពីកម្ពុជា ដើម្បីក្លាយជាដៃគូពិភាក្សារបស់អាស៊ាន

ការស្វែករកការគាំទ្រនេះត្រូវបានលើកឡើងដោយលោក El Hassane Zahid ឯកអគ្គរដ្ឋទូតម៉ារ៉ុកប្រចាំកម្ពុជា ខណៈពេលដែលលោកត្រូវបានជួបទទួលជួបសន្ទនាជាមួយលោក ហោ ណាំហុង កាលពីថ្ងៃទី២៥ ខែកក្កដា ។

ក្រៅពីស្នើសុំកម្ពុជា ដើម្បីគាំទ្រម៉ារ៉ុកចំពោះបេក្ខភាពជាសមាជិកនៃកិច្ចពិភាក្សាស្តីពីសហប្រតិបត្តិការអាស៊ាន (A.C.D) ភាគីទាំងពីរបានពិភាក្សាលើបញ្ហាមួយចំនួនទៀតដូចជា :

បញ្ហាសាហារ៉ាខាងលិច ដែលមានការជឿនលឿនក្នុងការដោះស្រាយបញ្ហាជាមួយនឹងរណសិរ្សអារ៉ាប់សាហារ៉ាវី ។ នឹងពិភាក្សាគ្នាអំពីដំណើរទស្សនកិច្ចរបស់លោក ហោ ណាំហុង ទៅប្រទេសម៉ារ៉ុកតាមការស្នើសុំ យ៉ាងទទូចរបស់លោក Mohamed BENAISSA រដ្ឋមន្ត្រីការបរទេសម៉ារ៉ុក នៅខែកញ្ញា ឆ្នាំ២០០៧ ខាងមុខនេះ ។

ព្រះរាជាណាចក្រម៉ារ៉ុក បានភ្ជាប់ទំនាក់ទំនងការទូតជាថ្មីឡើងវិញ ជាមួយព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩៦ ។

នៅថ្ងៃទី៦ខែមិថុនា ឆ្នាំ២០០២ នៅរាជធានីភ្នំពេញ លោក Rechad Bouhlal អគ្គលេខាធិការក្រសួងការបរទេសម៉ារ៉ុក និងលោក អ៊ុជ គឹមអន រដ្ឋលេខាធិការក្រសួងការបរទេសកម្ពុជាបានចុះហត្ថលេខាសង្ខេប(Paraphe) លើកិច្ចព្រមព្រៀងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស និងវប្បធម៌រវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រម៉ារ៉ុក ។

ពីថ្ងៃទី២៧-២៩ខែមករាឆ្នាំ២០០៣ លោក Abdelouahed RADI ប្រធានរដ្ឋសភាម៉ារ៉ុកបានអញ្ជើញមកធ្វើទស្សនកិច្ចផ្លូវការនៅកម្ពុជា ។

ពីថ្ងៃទី២០-២២ខែកក្កដាឆ្នាំ២០០៥ និងពីថ្ងៃទី៩-១១ ខែសីហា ឆ្នាំ២០០៦ លោក Taeib FASSI FIHEI រដ្ឋមន្ត្រីប្រតិភូការបរទេសនិងសហប្រតិបត្តិការ ម៉ារ៉ុក បានអញ្ជើញមកទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ។

យោងតាមសំណើររបស់ម៉ារ៉ុក កម្ពុជាបានឯកភាពអោយមានពិធីសារស្តីពី ការបង្កើតយន្តការពិគ្រោះយោបល់ផ្នែកនយោបាយរវាងក្រសួងការបរទេសទាំងពីរនិងបានឆ្នោតអនុបវាទនៅលើគំរោងសេចក្តីសំរេចចិត្តស្តីពីសហារ៉ាខាងលិច កាលពីខែធ្នូឆ្នាំ២០០៦ ។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី២៧ ខែកក្កដា ឆ្នាំ២០០៧ ។*

## កាណាដាផ្តល់ជំនួយឥតសំណងជាង៧លានដុល្លារដល់ក្រសួងដែនដី

រដ្ឋាភិបាលកាណាដា បានសំរេចផ្តល់ជំនួយឥតសំណងចំនួនជាង ៧លានដុល្លារអាមេរិក បន្ថែមទៀតដល់រដ្ឋាភិបាលកម្ពុជាសំរាប់យកមកអនុវត្តន៍លើការងារគំរោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លីនៅកម្ពុជា។

ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាផ្លូវការទទួលជំនួយនេះ ត្រូវបានធ្វើឡើងដោយលោកទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម និងលោកស្រី DONICA PO POTIE ឯកអគ្គរដ្ឋទូតកាណាដាប្រចាំកម្ពុជា កាលពីថ្ងៃទី៩ខែកក្កដា។

ជំនួយនេះផ្តោតការគាំទ្រទៅលើ : ទី១- ការចុះបញ្ជីដីធ្លី ទី២- ការចុះបញ្ជីដីធ្លីរដ្ឋ ទី៣-ការអភិវឌ្ឍន៍ប្រព័ន្ធវាយតំលៃដីធ្លី និងទី៤- ការដោះស្រាយទំនាស់ដីធ្លី។ ជំនួយនេះប្រើសំរាបរយៈពេល៥ឆ្នាំ គឺចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១២។ *រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី១០ខែកក្កដា ឆ្នាំ២០០៧ ទំព័រក៤។*

## សភាកាណាដាជួយស្ថាប័ននីតិបញ្ញាតិកម្ពុជា

លោក Bob Miller ប្រធានមជ្ឈមណ្ឌលសភាកាណាដា និងជាប្រធានភ្នាក់ងារប្រតិបត្តិនៃគំរោងគាំទ្រនីតិបញ្ញាតិកម្ពុជា-កាណាដា បានបញ្ជាក់ជូនសម្តេច ហេង សំរិន និងបញ្ជាក់ក្នុងជំនួបដោយឡែកមួយទៀតជាមួយសម្តេច ជា ស៊ីម កាលពីថ្ងៃ១៦ខែវិច្ឆកាឆ្នាំ២០០៧ ថា កាណាដាមានគំរោងនឹងជួយដល់កម្ពុជារយៈពេល៥ឆ្នាំទៀត។

ប្រភពនៃជំនួបបានថ្លែងថា សភាកាណាដាបានជួយគាំទ្រដល់ស្ថាប័ននីតិបញ្ញាតិកម្ពុជាក្នុងរយៈពេល៥ឆ្នាំហើយ (ចាប់ពីឆ្នាំ២០០១មក) ដែលបានចំណាយអស់ទឹកប្រាក់ចំនួន៥លានដុល្លារកាណាដា ស្មើនឹង៤.៥លានដុល្លារអាមេរិក។

ប្រភពនោះបានបញ្ជាក់ថា ជំនួយដែលបានអនុវត្តកន្លងមកនោះ គឺផ្តោតលើការពង្រឹងលទ្ធិប្រជាធិបតេយ្យ ពង្រឹងសមត្ថភាពអ្នកតំណាងរាស្ត្រ និងមន្ត្រីអគ្គលេខាធិការដ្ឋាន។ ប៉ុន្តែគំរោងជំនួយជំហានទី២នេះមិនទាន់ដឹងថា ចំណាយថវិកាប៉ុន្មាននៅឡើយទេ។ *រស្មីកម្ពុជា ថ្ងៃសៅរ៍ទី១៧ខែវិច្ឆកាឆ្នាំ២០០៧ ទំព័រក២។*

## អ៊ីរ៉ង់ចង់បង្កើតគណៈកម្មការចំរុះចួយជាមួយកម្ពុជា

លោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជួបសន្ទនាជាមួយលោក Seyaed Javad Ghavem Shahidi ដែលលោកត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មីប្រចាំកម្ពុជា កាលពីថ្ងៃទី១៦ ខែវិច្ឆកា ដោយជំនួបនេះផ្តោតជាសំខាន់ទៅលើការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២តាមរយៈការដាក់ស្ថានឯកអគ្គរដ្ឋទូតនិងការបង្កើតគណៈកម្មការចំរុះរវាងប្រទេសទាំងពីរ។

លោកទូតអ៊ីរ៉ង់ បានជំរាប់លោក អ៊ុច បូរិទ្ធ ថា លោកបានថ្វាយលិខិតតែងដល់ព្រះមហាក្សត្រកម្ពុជារួចហើយ ហើយការសន្ទនាថ្ងៃនេះ គឺក្នុងស្មារតីរីតចំណងទាក់ទង កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ហើយលោកសំណូមពរអោយរាជរដ្ឋាភិបាលកម្ពុជាមានស្ថានទូត និងនិវេសនដ្ឋានរបស់ឯកអគ្គរដ្ឋរាជទូតកម្ពុជាប្រចាំនៅប្រទេសកម្ពុជាផ្ទាល់តែម្តង។ *រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី១៨-១៩ ខែវិច្ឆកាឆ្នាំ២០០៧ ទំព័រក២។*

## លោក ហោ ណាំហុង ជួបគណៈប្រតិភូអ៊ីរ៉ង់និងម៉ារ៉ុក

ថ្ងៃទី០៦ខែវិច្ឆកាឆ្នាំ២០០៧ លោក ហោ ណាំហុង បានទទួលជួបគណៈប្រតិភូ២ក្រុមផ្សេងដោយឡែកពីគ្នា។ មួយក្រុមមកពីប្រទេសអ៊ីរ៉ង់ដឹកនាំដោយលោក Nematollah Izadi អគ្គនាយកទទួលបន្ទុកអាស៊ីខាងកើតនិងតំបន់អូសេ

អានីនៃក្រសួងការបរទេសអ៊ីរ៉ង់ ដោយនាំយកសាររបស់លោករដ្ឋមន្ត្រីការបរទេសអ៊ីរ៉ង់ ដើម្បីអញ្ជើញលោក ហោ ណាំហុង ទៅបំពេញទស្សនកិច្ចនៅប្រទេសអ៊ីរ៉ង់ ដើម្បីពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរអោយមានការរីកចំរើនលើវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងវិស័យផ្សេងៗទៀត។

ក្នុងជំនួបដោយឡែកមួយទៀតជាម៉ារ៉ុក ដែលដឹកនាំដោយលោក បេដរោហ៊ាក ឡាហ៊រាក ទីប្រឹក្សានាយករដ្ឋមន្ត្រី និងជាបេសកជនរបស់ព្រះមហាក្សត្រ Mahmmed VI នៃប្រទេសម៉ារ៉ុក ភាគីម៉ារ៉ុកបានស្នើអោយមានការជំរុញកិច្ចសហប្រតិបតិការលជាមួយប្រទេសកម្ពុជាលើគ្រប់វិស័យ ហើយភាគីម៉ារ៉ុកស្នើកម្ពុជាជួយគាំទ្រដល់ការតាំងពិព័រណ៍ស្តីពីវប្បធមិនិងផលិតផលផ្សេងៗនៅក្រុងតុងហ៊ើរ នៃប្រទេសម៉ារ៉ុកនៅឆ្នាំ២០១២ខាងមុខ។ ទន្ទឹមនេះ រដ្ឋាភិបាលម៉ារ៉ុកស្នើកម្ពុជាចូលរួមតាំងពិព័រណ៍នេះដែរ ហើយម៉ារ៉ុកនឹងផ្តល់ស្តង់តាំងពិព័រណ៍ដល់កម្ពុជាដោយឥតគិតថ្លៃ ព្រមទាំងជួយចំណាយទូទៅលើការធ្វើដំណើរស្នាក់នៅសំរាប់គណៈប្រតិភូកម្ពុជា។ *រស្មីកម្ពុជា ថ្ងៃពុធទី០៧ខែវិច្ឆកាឆ្នាំ២០០៧ ទំព័រ២។*

## ១០-កម្ពុជា និងអង្គការអន្តរជាតិ

### ធនាគារពិភពលោកផ្តល់ប្រាក់១៨លានដុល្លារតបណ្តាញអគ្គិសនីពីឡាវនិងវៀតណាម

ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងខេត្តកំពង់ចាម នឹងបានទទួលជំនួយពីធនាគារពិភពលោកប្រមាណ១៨លានដុល្លារ ដើម្បីធ្វើការតបណ្តាញខ្សែភ្លើងយកពីឡាវ និងវៀតណាម។

ជំនួយនេះជាជំនួយឥតសំណងរបស់ធនាគារពិភពលោក យកមករៀបចំតបណ្តាញខ្សែ និងបង្គោលភ្លើង ដែលមានចម្រឹងជើង៤ តមកពីប្រទេសឡាវ ប្រវែង៥៦គីឡូម៉ែត្រ ចេញពីប្រទេសឡាវមកទីរួមខេត្តស្ទឹងត្រែង។

តាមការសិក្សារបស់អង្គការ ូ ណេឌុភ បានបង្ហាញថា មានប្រជាជនកម្ពុជាប្រមាណ១៧ភាគរយប៉ុណ្ណោះ ដែលបានទទួលការផ្តល់សេវាកម្មអគ្គិសនី។ *កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧។*

### ធនាគារពិភពលោកអោយលុយថ្មី១៤លានដុល្លារសំរាប់គំរោងគ្រប់គ្រងហិរញ្ញវត្ថុ

យោងតាមសេចក្តីថ្លែងការណ៍មួយរបស់ការិយាល័យធនាគាពិភពលោកនៅកម្ពុជា បានអោយដឹងថា ធនាគារពិភពលោកនៅថ្ងៃអង្គារ៍នេះបានសំរេចផ្តល់ជំនួយឥតសំណងចំនួន១៤លានដុល្លារអាមេរិកដល់ប្រទេសកម្ពុជា ដើម្បីគាំទ្រដល់ការកែលំអគ្រប់គ្រងហិរញ្ញវត្ថុនិងកែលំអគណនេយ្យហិរញ្ញវត្ថុ។

លោក គាត ឈន់ និងលោក ចេម អាដាម អនុប្រធានធនាគារពិភពលោក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់ជំនួយឥតសំណងចំនួន១៤លានដុល្លារនេះ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧។

ជំនួយនេះជាផ្នែកដ៏សំខាន់មួយរបស់ធនាគារពិភពលោកក្នុងការកែលំអអភិបាលកិច្ច និងប្រឆាំងអំពើពុករលួយ។ ធនាគារនេះបានប្រកាសអោយដឹងថា លុយជំនួយខាងលើនេះបានមកពីជំនួយរបស់ប្រទេសអូស្ត្រាលីចំនួន៣លានដុល្លារអូស្ត្រាលី ប្រទេសអង់គ្លេសចំនួន ៤.៥ លានផោន និងគណៈកម្មការអឺរ៉ុប ៣ លានអឺរ៉ូ។

គួររំលឹកថា កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលដែលបានដាក់ចេញដោយ សម្តេច ហ៊ុន សែន កាលពីចុងឆ្នាំ២០០៤នោះ ត្រូវបានគាំទ្រដោយម្ចាស់ជំនួយចំនួន១១ មាន ADB ប្រទេសអូស្ត្រាលី សហគមន៍អឺរ៉ុប បារាំង អាល្លឺម៉ង់ អង់គ្លេស ស៊ុយអ៊ែត ជប៉ុន IMF UNDP និង WB ។

*កាសែតរស្មីកម្ពុជា ចេញផ្សាយ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ ។*

## ជំនួយកាត់បន្ថយភាពក្រីក្រកម្ពុជាដំណាក់កាលដំបូងអាចពី១៥ដល់៤០លានដុល្លារ

សំរាប់ដំណាក់កាលដំបូងនៃកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ដែលពីមុននេះធនាគារពិភពលោកថា មានប្រហែលពី១៥ទៅ២០លានដុល្លារអាមេរិក លោក រ៉ូប៊ើត តាលីយ៉េស្ស អ្នកសេដ្ឋកិច្ចជាតិខ្ពស់នៃធនាគារពិភពលោក ប្រចាំកម្ពុជាបានបញ្ជាក់ថា ជំនួយនេះអាចឡើងពី១៥ដល់៤០លានដុល្លារអាមេរិក ។

នេះបើតាមការដកស្រង់សម្តីដោយលោក អ៊ុត ឈន អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ កាលពីព្រឹកថ្ងៃទី១៦ ខែកុម្ភៈ បន្ទាប់ពីលោកបានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមបេសកម្មពីធនាគារពិភពលោក សហភាព អឺរ៉ុប និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា ។

លោក អ៊ុត ឈន បានមានប្រសាសន៍អោយដឹងថា គណៈប្រតិភូមួយក្រុមនេះ មានបេសកម្មដើម្បីពិនិត្យ និងវាយ តំលៃអំពីជំនួយរបស់គេ ដែលបានផ្តល់មកអោយប្រទេសកម្ពុជាសំរាប់អនុវត្តគំរោងស្តីពី ការកាត់បន្ថយភាពក្រីក្រក្នុង ដំណាក់កាលទី១ ។ *កាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៧ ។*

## ធនាគារពិភពលោក និងអង្គការជំនួយអូស្ត្រាលីផ្តល់ជំនួយឥតសំណង៣៦លានដុល្លារសំរាប់ថែទាំផ្លូវ

ធនាគារពិភពលោក និងអង្គការជំនួយ នៃប្រទេសអូស្ត្រាលី សំរេចផ្តល់ជំនួយឥតសំណងប្រមាណ៣៦លានដុល្លារ សំរាប់ធ្វើការថែទាំ និងជួសជុលផ្លូវថ្នល់ជាប្រចាំនៅប្រទេសកម្ពុជា ។

នេះជាប្រសាសន៍ដែលលើកឡើងដោយលោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន ដែល បានលើកឡើងកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៧ ។ លោកបញ្ជាក់ថា ក្នុងចំនួនទឹកប្រាក់៣៦លានដុល្លារនេះ គឺ៣០លាន ដុល្លារជាជំនួយរបស់ធនាគារពិភពលោក និង៦លានដុល្លារទៀត ជាជំនួយរបស់អង្គការអូស្ត្រាលី ។ ក្នុងនោះអូស្ត្រាលីនឹង ជួយទៅលើការនាំអ្នកជំនាញការសំខាន់ៗមកធ្វើការថែទាំថ្នល់ទៅលើគំរោងរបស់យើង ។ ចំណែកធនាគារពិភពលោកនឹង ផ្តល់៦លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ សំរាប់បំរើអោយការថែទាំផ្លូវថ្នល់អោយកាន់តែប្រសើរឡើង ។

*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ច័ន្ទ ទី២២-២៣ ខែមេសា ឆ្នាំ២០០៧ ទំព័រ៤ ។*

## ធនាគារ WB ផ្តល់ថវិកាចំនួន៣៦,២៥លានដុល្លារដល់កម្ពុជា

ធនគារ WB បានសំរេចផ្តល់ជំនួយចំនួន ៣៦,២៥ លានដុល្លារសំរាប់គាំទ្រដល់ដំណើរការអភិវឌ្ឍន៍ឃុំនិងសង្កាត់ ហើយនិងកែលំអអភិបាលកិច្ចនៅតាមមូលដ្ឋាន ។

តាមសេចក្តីប្រកាសព័ត៌មានរបស់ WB កាលពីថ្ងៃទី២៧ខែកក្កដា កន្លងទៅនេះបានអោយដឹងថា ដើម្បីជំរុញ ដំណើរការវិមជ្ឈការនៅតាមឃុំនិងសង្កាត់ ព្រមទាំងកំណែទំរង់អភិបាលកិច្ចនៅតាមមូលដ្ឋានធនាគារនេះបានសំរេចផ្តល់

ជំនួយចំនួន ៣៦.២៥ លានដុល្លារដល់គំរោងអភិបាលកិច្ចមូលដ្ឋាន និងវិនិយោគទុននៅជនបទ ដែលពីមុនធ្លាប់បានផ្តល់ចំនួន២២លានដុល្លាររួចមកហើយនៅអំឡុងពីឆ្នាំ២០០៣ដល់ឆ្នាំ២០០៧។

*រស្មីកម្ពុជា ថ្ងៃសៅរ៍ទី២៨ខែកក្កដា ឆ្នាំ២០០៧ ទំព័រក២។*

## ធនាគារពិភពលោកផ្តល់ជំនួយឥតសំណង៧០លានដុល្លារ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសអោយដឹងថា ធនាគារពិភពលោកបានប្រកាសផ្តល់ជំនួយឥតសំណងមានទឹកប្រាក់ប្រមាណជិត៧០លានដុល្លារសំរាប់គំរោងការអភិវឌ្ឍន៍ធំៗចំនួន៣។

នៅក្នុងសេចក្តីប្រកាសនេះបានអោយដឹងថា ប្រាក់ជំនួយឥតសំណងចំនួន ៦៩.៧៥លានដុល្លារអាមេរិននេះនឹងត្រូវយកទៅប្រើប្រាស់លើគំរោងការអភិវឌ្ឍន៍ចំនួន៣។ គំរោងទាំង៣នេះគឺ : គំរោងពាណិជ្ជកម្មថាមពលមហាអនុតំបន់ទន្លេមេគង្គ មានទឹកប្រាក់ ១៨.៥ លានដុល្លារ។ គំរោងកាត់បន្ថយភាពក្រីក្រនិងប្រតិបត្តិការកំណើន មានទឹកប្រាក់ ១៥ លានដុល្លារ និងគំរោងផ្តល់ហិរញ្ញប្បទានបន្ថែមសំរាប់គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានមានទឹកប្រាក់ ៣៦.២៥ លាន ដុល្លារ។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់សរុប ៦៩.៧៥ លានដុល្លារនេះ កាលពីព្រឹកថ្ងៃអង្គារ៍ ទី១៤ ខែសីហា ឆ្នាំ២០០៧ រវាងលោក គាត ឈន់ និងលោក Ian Poter នាយកធនាគារពិភពលោកប្រចាំតំបន់។ *រស្មីកម្ពុជា ថ្ងៃពុធ ទី១៥ ខែសីហា ឆ្នាំ២០០៧ ទំព័រក២។*

## កម្ពុជាទទួលបានជំនួយ និងប្រាក់កម្ចីពីធនាគារពិភពលោក

ធនាគារពិភពលោក W B បានប្រកាសសន្យាផ្តល់ប្រាក់កម្ចីជំនួយឥតសំណងនិងឥណទាន ដែលមានតំលៃ ៤.៣ ពាន់លានដុល្លារអាមេរិក សំរាប់គំរោងអភិវឌ្ឍន៍និងសហប្រតិបត្តិការនានានៅក្នុងប្រទេសចំនួន១០នៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៅក្នុងឆ្នាំសារពើពន្ធ២០០៧ ដែលក្នុងនោះកម្ពុជាទទួលបាន១៩លានដុល្លារ។

សេចក្តីប្រកាសព័តិមានកាលពីថ្ងៃទី០៩ខែកញ្ញាបានអោយដឹងថា ទោះបីជាធនាគារពិភពលោកបានអនុម័តគំរោងតែមួយសំរាប់ប្រទេសកម្ពុជានៅក្នុងឆ្នាំសារពើពន្ធ២០០៧(ពោលគឺរយៈពេល១២ខែ ដែលបញ្ចប់នៅថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០០៧)ក្តី ក៏ក្រោយរយៈពេលនេះតែបន្តិចប៉ុណ្ណោះ ធនាគារពិភពលោកបានអនុម័តគំរោងចំនួនពីរបន្ថែមទៀត ដែលមានទឹកប្រាក់ចំនួន៥១.២៥លានដុល្លារនៅក្នុងខែកក្កដា ឆ្នាំ២០០៧។ ហើយនៅថ្ងៃទី១៤ ខែសីហា រដ្ឋាភិបាលកម្ពុជា និងធនាគារពិពភលោក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយឥតសំណងសំរាប់គំរោងចំនួន៣ ដែលមានទឹកប្រាក់សរុបចំនួន៧០លានដុល្លារ សំរាប់ប្រទេសកម្ពុជា។ គំរោងទាំង៣នេះ គឺគំរោងពាណិជ្ជកម្មថាមពលមហាអនុតំបន់ទន្លេមេគង្គ មានទឹកប្រាក់១៨.៥លានដុល្លារ។ គំរោងកាត់បន្ថយភាពក្រីក្រនិងប្រតិបត្តិការកំណើនមានទឹកប្រាក់១៥លានដុល្លារ និងគំរោងផ្តល់ហិរញ្ញប្បទានបន្ថែមសំរាប់គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានមានទឹកប្រាក់ ៣៦.២៥ លានដុល្លារ។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី០៧ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៣។*

## ធនាគារ ADB ជួយគំរោងធនធានទឹកនិងគ្រោះមហន្តរាយ ប្រមាណ១៣០លានដុល្លារ

មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិយាយអោយដឹងថា ADBគ្រោងនឹងផ្តល់ជំនួយហិរញ្ញវត្ថុដល់រដ្ឋាភិបាលកម្ពុជានូវទឹកប្រាក់ចំនួន១៣០លានដុល្លារសំរាប់គាំទ្រដល់គំរោងធនធានទឹកនិងគ្រោះមហន្តរាយ ។

មន្ត្រីដដែលនិយាយថា លោក Arjun Thapan អគ្គនាយកដ្ឋានអាស៊ីអាគ្នេយ៍នៃធនាគារ ADB កំពុងស្ថិតនៅក្នុងប្រទេសកម្ពុជា និងបានជួបពិភាក្សាជាមួយលោក អួន ព័ន្ធមុនីរ័ត្ន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនៅថ្ងៃទី០៣ខែធ្នូ ។

បន្ទាប់ពីជំនួបនោះ លោក Arjun បានបង្ហើបអោយដឹងថាតាមលទ្ធភាពនៃកិច្ចប្រជុំជាមួយបណ្តាប្រទេសអ្នកផ្តល់ជំនួយហិរញ្ញប្បទានដល់ធនាគារ ADB សំរាប់ឆ្នាំ២០០៩-២០១២ កាលពីថ្មីៗនេះ ADBនឹងមានថវិកាគ្រប់គ្រាន់សំរាប់ជួយដល់ប្រទេសអាស៊ាន ជាពិសេសកម្ពុជាដែលក្នុងឆ្នាំខាងមុខនេះADBនឹងជួយលើវិស័យធនធានទឹកនិងគ្រោះមហន្តរាយក្នុងទឹកប្រាក់ប្រមាណ១៣០លានដុល្លារ ។

យោងតាមប្រភពព័ត៌មានពីក្រសួងហិរញ្ញវត្ថុបានអោយដឹងថា នៅឆ្នាំ២០០៧-២០០៩នេះ ADBបានជួយដល់វិស័យកសិកម្ម អប់រំ ហេដ្ឋារចនាសម្ព័ន្ធ មានសរុបចំនួន១៤គំរោង មានទឹកប្រាក់ចំនួនប្រមាណ២០៤លានដុល្លារ និងផ្តល់ជំនួយបច្ចេកទេស២២គំរោងមានទឹកប្រាក់១៤០លានដុល្លារ ។ *រស្មីកម្ពុជា ថ្ងៃពុធ ទី០៥ ខែធ្នូឆ្នាំ២០០៧ ទំព័រ៨ ។*

## ADB ផ្តល់ជំនួយ ២០ លានដុល្លារ ជួយតំបន់ជុំវិញបឹងទន្លេសាប

យោងតាមសេចក្តីប្រកាសរបស់ ADB កាលពីថ្ងៃទី០៦ខែធ្នូកន្លងទៅនេះបានអោយដឹងថា ទឹកប្រាក់ ចំនួន ១០,១ លានដុល្លារ នឹងត្រូវផ្តល់ជាប្រាក់កម្ចី ហើយនិងទឹកប្រាក់ចំនួន ៩.៩ លានដុល្លារជាជំនួយឥតសំណងនឹងត្រូវផ្តល់ដល់គំរោងអភិវឌ្ឍន៍ជនបទនៃតំបន់វាលទំនាបបឹងទន្លេសាប ។

ប្រភពនេះក៏បានអោយដឹងផងដែរថា រដ្ឋាភិបាលកម្ពុជាក៏នឹងចូលរួមផ្តល់ថវិកាចំនួន៣លានដុល្លារ បន្ថែមទៀតដែរ ចំណែកឯអ្នកដែលបានផលប្រយោជន៍ពីគំរោងនេះ ក៏នឹងត្រូវចូលរួមផ្តល់វិភាគទានចំនួន១លានដុល្លារដែរ ។

*រស្មីកម្ពុជា ថ្ងៃអង្គារ៍ទី១១ខែធ្នូឆ្នាំ២០០៧ ទំព័រ៨ ។*

## ADB យល់ព្រមផ្តល់ប្រាក់កម្ចី៤២លានដុល្លារស្តារប្រព័ន្ធផ្លូវដែកកម្ពុជា

លោក គាត ឈន់ និងលោក ឡូរ៉ង់ ហ្វ្រិនវូត អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយមួយកាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ នៅក្រសួងសេដ្ឋកិច្ច ។

លោក គាត ឈន់ បានអោយដឹងថា ការស្តារប្រព័ន្ធផ្លូវដែកកម្ពុជា តាមគំរោងត្រូវចំណាយទឹកប្រាក់ប្រមាណ ៧៣ លានដុល្លារ ។ ប្រាក់ចំណាយនេះ បានមកពីហិរញ្ញប្បទានពី ADB ៤២លានដុល្លារ មូលនិធិ Opec ចំនួន ១៣ លានដុល្លា ជំនួយឥតសំណងពីរដ្ឋាភិបាលម៉ាឡេស៊ី ២.៨ លានដុល្លារ ហើយរាជរដ្ឋាភិបាលកម្ពុជានឹងចូលរួមចំនួន១៥.២ លានដុល្លារ ។

គំរោងអភិវឌ្ឍន៍ផ្លូវដែកកម្ពុជានេះនឹងផ្តោតទៅលើការស្តារផ្លូវដែកភាគខាងត្បូង មានប្រវែង ២៥៤ គីឡូម៉ែត្រ តភ្ជាប់ពីភ្នំពេញទៅស្វាយស៊ីសូផុន និងការស្តារផ្លូវដែកប្រវែង ៤៨ គីឡូម៉ែត្រតភ្ជាប់ពីស្វាយស៊ីសូផុនទៅប៉ោយប៉ែត ។

*រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៧ ។*

## លោក គាត ឈន់ ជួបពិភាក្សាជាមួយលោក Phil Bowen នាយក ADB ថ្មី

លោក Phil Bowen ដែលទើបត្រូវបានតែងតាំងជានាយកថ្មីប្រតិបត្តិរបស់ ADB ប្រចាំមណ្ឌលរបស់ប្រទេសចំនួន១២ ដោយរួមមានទាំងកម្ពុជាផងដែរ បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយបានជួបពិភាក្សាការងារជាមួយលោក គាត ឈន់ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៧។

គួររំលឹកថា នៅក្នុងឆ្នាំ២០០៧ នេះ ធនាគារ ADB បានផ្តល់ហិរញ្ញប្បទានចំពោះប្រទេសកម្ពុជាមានទឹកប្រាក់សរុប៨៣លានដុល្លារ ក្នុងនោះហិរញ្ញប្បទានឥតសំណងមានចំនួន៤៧លានដុល្លារ និងឥណទាន ប្រាក់កម្ចីមានទឹកប្រាក់ជិត៣៦លានដុល្លារ។ ហើយពីឆ្នាំ២០០៧-២០០៩ ធនាគារ ADB បានប្រកាសរួចហើយ នឹងផ្តល់ហិរញ្ញប្បទានប្រាក់កម្ចីនិងហិរញ្ញប្បទានឥតសំណងចំនួន១១គំរោងមានទឹកប្រាក់សរុបប្រមាណ១៨២.៥លានដុល្លារ និងជំនួយបច្ចេកទេសមានទឹកប្រាក់ប្រមាណ១១.៦លានដុល្លារផ្សេងទៀត។ *រស្មីកម្ពុជា ថ្ងៃសុក្រ ទី១១ ខែឧសភា ឆ្នាំ២០០៧ ទំព័រ៤។*

## ADB ផ្តល់ប្រាក់កម្ចី៨លានដុល្លារសំរាប់ភ្ជាប់ខ្សែបណ្តាញនាំភ្លើងពីថៃ

ADB បានសំរេចផ្តល់ប្រាក់កម្ចីដែលមានទឹកប្រាក់៨លានដុល្លារដល់កម្ពុជា សំរាប់កសាងបណ្តាញភ្ជាប់នាំចូលថាមពលអគ្គិសនីពីប្រទេសថៃមកផ្គត់ផ្គង់នៅតំបន់ពាយ័ព្យជាពិសេសខេត្តសៀមរាបរបស់ប្រទេសកម្ពុជា។

ទឹកប្រាក់កម្ចីនេះត្រូវបានទទួលដោយក្រុមហ៊ុនឯកជនរបស់កម្ពុជា ឈ្មោះ Power Transmission Lines Co. Ltd ដើម្បីធ្វើនាំថាមពលមកផ្គត់ផ្គង់អោយទីផ្សារ។

ជាមួយនឹងប្រាក់៨លានដុល្លារនេះ បណ្តាញអគ្គិសនីចំនួន២២១គីឡូម៉ែត្រនឹងត្រូវគេសាងសង់តាមបណ្តោយផ្លូវជាតិលេខ៥ និងលេខ៦ ពីទល់ដែនមកកាន់ខេត្តសៀមរាបនិងបាត់ដំបង។

*រស្មីកម្ពុជា ថ្ងៃពុធទី០៤ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ១។*

## អគ្គលេខាធិការរង UN : កម្ពុជាគួរទទួលបានការយកចិត្តទុកដាក់

លោក គីម ហាក់ស៊ូ អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាលេខាធិការប្រតិបត្តិនៃស្នងការសហប្រជាជាតិទទួលបន្ទុកកិច្ចការសង្គមនិងសេដ្ឋកិច្ចតំបន់អាស៊ីប៉ាស៊ីហ្វិក បានធ្វើបទសម្ភាសន៍ជាមួយកាសែតរស្មីកម្ពុជានៅខាងក្រៅសន្និសីទស្តីពីគោលដៅអភិវឌ្ឍន៍សហវត្សរ៍នៃប្រទេសអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ដែលបានរៀបចំធ្វើនៅទីក្រុងហាណូយប្រទេសវៀតណាម កាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ ថា : ប្រទេសកម្ពុជាគួរតែទទួលបានការយកចិត្តទុកដាក់ជាពិសេស ពីប្រទេសផ្តល់ជំនួយដោយសារតែប្រវត្តិនៃការឈឺចាប់ដែលប្រទេសនេះបានជួបប្រទះនឹងសង្គ្រាម។

លោកបញ្ជាក់ថា ប្រទេសកម្ពុជាចាំបាច់ត្រូវតែចេញមុខពន្យល់អំពីស្ថានភាពរបស់ខ្លួននៅតាមវេទិកាអន្តរជាតិនានាដូចជាសន្និសីទនាពេលនេះជាដើម។ លោកបន្ថែមទៀតថា មុនពេលខ្ញុំមកទីនេះ ខ្ញុំបានពិនិត្យឃើញថា ប្រទេសផ្សេងមានអត្រានៃជនពិការតែ៩ភាគរយទេ ប៉ុន្តែកម្ពុជាមានរហូតដល់១០ភាគរយ។

លោក គឹម បានឡើងផងដែរថា អ្នកផ្តល់ជំនួយបស្ចឹមប្រទេសមួយចំនួនគិតថា កម្ពុជាទទួលបានជំនួយគ្រប់គ្រាន់ ហើយពីប្រទេសជប៉ុន កូរ៉េខាងត្បូង ចិន សហភាពអឺរ៉ុបជាដើម។ ប៉ុន្តែសំរាប់រូបលោក លោកគិតថា កម្ពុជាមានតំរូវការពិសេស ដូច្នេះបញ្ហាមួយចំនួនគេមិនដឹងកម្ពុជាត្រូវតែនិយាយចេញ។

ប្រទេសកម្ពុជាទទួលបានជំនួយអភិវឌ្ឍន៍ប្រមាណ ៥០០ លានដុល្លារក្នុងមួយឆ្នាំៗ ។ បើតាមលោក គឹម បានអះអាងថា ប្រជាជននៅតំបន់អាស៊ីទទួលបានជំនួយអភិវឌ្ឍន៍ផ្លូវការក្នុងម្នាក់តែ ១៥ ដុល្លារប៉ុណ្ណោះ ខណៈដែលនៅអាហ្វ្រិកគេទទួលបានដល់ទៅ ៣២ ដុល្លារអាមេរិកក្នុងមួយម្នាក់។ *រស្មីកម្ពុជា ចេញផ្សាយថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៧។*

## មេដឹកនាំពិភពលោក៩០ប្រទេសចូលរួមកិច្ចប្រជុំ UN ស្តីពីការប្រែប្រួលអាកាសធាតុ

លោក Rechard Kinley នាយកប្រតិបត្តិរងនៃគំរោងអនុសញ្ញាស្តីពីបំរែបំរួលអាកាសធាតុរបស់ UN បាននិយាយកាលពីពេលថ្មីៗនេះថា បន្ទាប់ពីលោកអគ្គលេខាធិការបានធ្វើលិខិតអញ្ជើញបណ្តាប្រទេស ចំនួនជាង១០០ប្រទេស ពួកគេអះអាងថានឹងចូលរួម ដែលក្នុងនោះជាងពាក់កណ្តាលគឺជាប្រមុខរដ្ឋ ឬប្រមុខ រដ្ឋាភិបាលតែម្តង។

លោក Richard បានអោយដឹងថា ក្នុងកិច្ចប្រជុំរយៈពេលមួយថ្ងៃនេះ បណ្តារដ្ឋាភិបាលប្រមុខ រដ្ឋាភិបាល និងប្រមុខរដ្ឋទាំងអស់ដែលបានចូលរួម ពួកគេនឹងពិភាក្សាគ្នាដោយផ្តោតសំខាន់ទៅលើការបន្តកិច្ចប្រឹងប្រែងដើម្បីសំរាលហើយនឹងសំរួលនូវផលប៉ះពាល់អំពីបំរែបំរួលបរិស្ថាន និងពិភាក្សាអំពីការកំណត់តំលៃនិងហិរញ្ញវត្ថុ ព្រមទាំងវិធីសាស្ត្រដើម្បីប្រើប្រាស់បច្ចេកវិជ្ជាប្រយុទ្ធប្រឆាំងនឹងបញ្ហាបំរែបំរួលបរិស្ថាន។

ពាក់ព័ន្ធនឹងបញ្ហាបំរែបំរួលអាកាសធាតុនេះ អង្គការសហប្រជាជាតិបានប្រកាសកាលពីដើមឆ្នាំថា នៅមុនចុងបញ្ចប់នៃសតវត្សទី២១នេះ កំណើនកំដៅពិភពលោកនឹងប្រហែលជាបណ្តាលអោយពិភពលោក ជួបប្រទះនូវកង្វះខាតទឹក ភាពរាំងស្ងួត ទឹកជំនន់ ព្យុះ ការកកើតជំងឺ និងបញ្ហាជាច្រើនទៀត។

ដោយឡែករដ្ឋាភិបាលកម្ពុជា ក៏ចាត់បញ្ជូនលោក ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថានអោយទៅចូលរួមក្នុងកិច្ចប្រជុំនេះ។ *រស្មីកម្ពុជា ព្រហស្បត្តិ ទី១៣ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៣។*

## កម្ពុជាជំរុញអង្គការសហប្រជាជាតិកែទំរង់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម

លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា បាននិយាយតំណាងអោយសំលេងកម្ពុជាក្នុងអង្គការសហប្រជាជាតិថា ដើម្បីជំរុញអោយប្រទេសក្រីក្រឈានទៅសំរេចគោលដៅនៃការអភិវឌ្ឍន៍សហស្សវត្សរ៍អង្គការសហប្រជាជាតិគួរតែសំរួលក្រុមប្រឹក្សាសន្តិសុខនិងសង្គម។

លោកបានថ្លែងនៅក្នុងមហាសន្និបាទអង្គការសហប្រជាជាតិកាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧ ថា កម្ពុជាសូមគាំទ្រកំណែទំរង់អង្គការសហប្រជាជាតិ ប៉ុន្តែមិនមែនគ្រាន់តែក្រុមប្រឹក្សាសន្តិសុខប៉ុណ្ណោះទេ គឺក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម ក៏គួរតែកែទំរង់ដែរ។ លោកបញ្ជាក់ថា ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ គួរតែបង្ហាញនូវចំណុចចាប់ផ្តើមដ៏ល្អមួយ នៅក្នុងការជួយប្រទេសដែលកំពុងតែរងគ្រោះអោយឈានទៅសំរេចគោលដៅនៃការអភិវឌ្ឍន៍សហស្សវត្សរ៍។

អង្គការសហប្រជាជាតិ គឺជាអង្គការអន្តរជាតិមួយដែលមានសមាជិកជាប្រទេសឯករាជ្យទាំងអស់ចំនួន ១៩២។ អង្គការនេះត្រូវបានបង្កើតឡើងដើម្បីធានានឹងដោះស្រាយបញ្ហាជាសកលទាំងឡាយ។ ស្ថាប័នកំពូលរបស់អង្គការនេះមាន មហាសន្និបាតក្រុមប្រឹក្សាសន្តិសុខ ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម ក្រុមប្រឹក្សាគ្រប់គ្រង លេខាធិការដ្ឋាន និងតុលាការអន្តរជាតិ។ ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ននេះ បញ្ហាកំពុងតែចោទឡើងនៅក្នុងស្ថាប័នទាំងអស់នេះ ហើយទាមទារអោយធ្វើកំណែទំរង់ដើម្បីដោះស្រាយបញ្ហាពិភពលោកទាំងឡាយ ដោយរួមទាំងបញ្ហានៃការអភិវឌ្ឍន៍សហស្សវត្សរ៍ដែលមាន ៨ ចំណុចសំខាន់ៗទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ អប់រំ សមភាពយ៉េនឌ័រ កាត់បន្ថយមរណភាពកុមារ កែលំអសុខភាពមាតានិងទារក ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺឆ្លងជាដើម អោយមានប្រសិទ្ធិភាព។

*រស្មីកម្ពុជា ថ្ងៃព្រហស្បត្តិ៍ ទី០៤ខែតុលា ឆ្នាំ២០០៧ ទំព័រ១។*

## IMF : ប្រេងកម្ពុជាមានតំលៃប្រមាណ១៥ពាន់លានដុល្លារ

របាយការណ៍ IMF បានធ្វើការប៉ាន់ស្មានជាមូលដ្ឋានថា ប្រាក់ចំណូលរដ្ឋាភិបាលបានមកពីប្រេងនឹងកើនឡើងជាបណ្តើរៗពីចំនួនប្រហែល១៧៤លានដុល្លារនៅក្នុង២០១១ រហូតដល់កំរិតអប្បបរមា១.៧០០លានដុល្លារនៅក្នុងឆ្នាំ២០២១ បន្ទាប់មកប្រាក់ចំណូលនេះនឹងធ្លាក់ចុះ។

តាមការប៉ាន់ស្មាននៅក្នុងសេណារីយ៉ូ ដែលបង្ហាញអំពីផលដែលកើតមានមកពីវិស័យប្រេងក្នុងកំរិតបរិមាណជាមធ្យម IMF បាននិយាយថា ប្រេងអាចនឹងរកបានចំនួន៥០០លានបារ៉ែល (មួយបារ៉ែលស្មើនឹង ១១៧.៣៤លីត្រ) ហើយតាមតំលៃប្រេងពិភពលោកចេះតែបន្តកើនឡើង ប្រេងទាំងនោះមានតំលៃជាទឹកប្រាក់១៥ពាន់លានដុល្លារ។ IMF បាននិយាយថា សេណារីយ៉ូនេះត្រូវបានបង្កើតឡើងដើម្បីបង្ហាញអំពីបញ្ហាប្រឈមខាងនយោបាយទាក់ទងទៅនិងវិស័យប្រេង ហើយវាមិនមានបំណងប៉ាន់ស្មានទៅលើវិស័យប្រេងកម្ពុជាឡើយ។

*រស្មីកម្ពុជា ថ្ងៃអាទិត្យ-ចន្ទ ទី១៦-១៧ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រ២។*

## ព័ត៌មានជំនួយស្មារតីស្តីពីជំនួយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ IMF

IMF ជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយដែលមានសមាជិកចំនួន ១៨៥ ប្រទេស និងមានទីស្នាក់ការនៅទីក្រុងវ៉ាស៊ីតោន សហរដ្ឋអាមេរិក។ IMF ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកំពស់កិច្ចសហប្រតិបត្តិការផ្នែករូបិយវត្ថុ ធានាស្ថិរភាពអត្រាប្តូរប្រាក់ និងធានាសណ្តាប់ធ្នាប់រូបិយវត្ថុ ដើម្បីជំរុញនូវកំណើនសេដ្ឋកិច្ច បង្កើតការងារ បញ្ចៀសវិបត្តិសេដ្ឋកិច្ច ព្រមទាំងផ្តល់ហិរញ្ញវត្ថុដល់ប្រទេសណាដែលត្រូវការកែតំរូវតុល្យភាពជញ្ជីងទូទាត់។

តាមប្រភពព័ត៌មានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជាក់ថា កម្ពុជាបានចូលជាសមាជិកអង្គការ IMF នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៦៩ និងបានសូមចូលជាសមាជិកជាថ្មីឡើងវិញនៅឆ្នាំ១៩៩១។ លោក ជា ចាន់តូ ទេសាភិបាល

ធនាគារជាតិនៃកម្ពុជា ជាទេសាភិបាលរបស់កម្ពុជានៅក្នុង IMF ។ ចំណែកលោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាដៃគូរការងារផ្លូវការក្នុងឋានៈជាប្រធានគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ។

***សកម្មភាពសំខាន់របស់ IMF នៅកម្ពុជា*** : សកម្មភាព IMF នៅកម្ពុជារួមមាន ការតាមដាននិងផ្តល់យោបល់លើគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការផ្តល់ប្រាក់កម្ចី និងហិរញ្ញប្បទានបច្ចេកទេសនិងការបណ្តុះបណ្តាល ។

១- ***ការតាមដាន និងការផ្តល់យោបល់លើគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** : រៀងរាល់ឆ្នាំ អង្គការ IMF តែងបានចាត់បញ្ជូនមន្ត្រីមកពីទីស្នាក់ការធំ សហការជាមួយការិយាល័យតំណាងនៅក្រុងភ្នំពេញ ដើម្បីធ្វើការ ត្រួតពិនិត្យនិងតាមដានការអនុវត្តន៍សេដ្ឋកិច្ចរបស់កម្ពុជា។ ការពិគ្រោះយោបល់ទៅលើការតាមដាន ដូចមានចែងក្នុង មាត្រា ៤ នៃលក្ខន្តិកៈរបស់ IMF ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ។

២- ***ការផ្តល់ប្រាក់កម្ចី*** : IMF មិនមែនជាស្ថាប័នដើម្បីផ្តល់ប្រាក់កម្ចីសំរាប់កសាងហេដ្ឋារចនាសម្ព័ន្ធ ឬយកមកប្រើប្រាស់ដើម្បីគោលដៅអភិវឌ្ឍន៍ឡើយ ។ ប្រាក់កម្ចី IMF គឺផ្តល់ដើម្បីយកទៅគាំទ្រជញ្ជីងទូទាត់ ដើម្បីអោយមានតុល្យភាពរវាងការនាំចេញនិងនាំចូល និងសេវាដើម្បីអោយមានស្ថិរភាពអត្រាប្តូរប្រាក់ និងប្រើប្រាស់សំរាប់ជាធនបំរុង។ IMF បានផ្តល់ប្រាក់កម្ចីដល់កម្ពុជា ក្នុងគោលដៅគាំទ្រនយោបាយហិរញ្ញវត្ថុទប់ស្កាត់អស្ថិរភាពអត្រាប្តូរប្រាក់ និងកាត់បន្ថយឱនភាពជញ្ជីងពាណិជ្ជកម្មក្រៅប្រទេស ដើម្បីលើកកំពស់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ប្រភពក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអោយដឹងថា ចាប់ពីឆ្នាំ១៩៩៣មក IMF បានផ្តល់ឥណទានក្នុងរូបភាពផ្សេងៗពីគ្នាចំនួន៣លើក។ លើកទី១- នៅឆ្នាំ១៩៩៣ គឺកម្មវិធីឥណទានសំរាប់ការផ្លាស់ប្រព័ន្ធ។ លើកទី២- នៅឆ្នាំ១៩៩៤ គឺកម្មវិធីឥណទានសំរាប់ការកែតំរូវរចនាសម្ព័ន្ធ និងលើកទី៣- នៅឆ្នាំ១៩៩ គឺកម្មវិធីឥណទានសំរាប់ការកែតំរូវរចនាសម្ព័ន្ធលើកទី២ ឬហៅថា ឥណទានសំរាប់កំណើននិងកាត់បន្ថយភាពក្រីក្រ។ សរុបមក IMF បានផ្តល់ប្រាក់កម្ចីគិតមកដល់ឆ្នាំ ២០០៥ មានចំនួន ៨២ លានដុល្លារ។ ប៉ុន្តែនៅឆ្នាំ ២០០៥ IMF បានសំរេចលុបបំណុលកម្ពុជា ៨២ លានដុល្លារដោយឈរលើមូលដ្ឋានវិនិច្ឆ័យការរីកចំរើនក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ដែលរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងអនុវត្តកន្លងមក។

៣- ហិរញ្ញប្បទានបច្ចេកទេស និងការបណ្តុះបណ្តាល : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអោយដឹងថា IMF បានផ្តល់ហិរញ្ញប្បទានលើគំរោង៣ ដែលមានទឹកប្រាក់ ៥.៤ លានដុល្លារអាមេរិក ដើម្បីពង្រឹងគុណភាពក្នុងការអនុវត្តន៍លើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ គោលនយោបាយរូបិយវត្ថុ និងផ្នែកស្ថិតិជាតិនៅក្រសួងហិរញ្ញវត្ថុ ក្រសួងផែនការនិងធនាគារជាតិ។

៤- កិច្ចសហប្រតិបត្តិការរវាង IMF និងកម្ពុជា : IMF បន្តការគាំទ្រដល់ប្រទេសកម្ពុជា ដែលមានចំណូលទាបដូចប្រទេសកម្ពុជា ដែលនេះជាគោលដៅសំខាន់នៃយុទ្ធសាស្ត្រកែទំរង់របស់ IMF។ តាមប្រភពព័ត៌មាន

ពីក្រសួងហិរញ្ញវត្ថុបានអោយដឹងថា IMF បច្ចុប្បន្នមិនទាន់ផ្តល់ប្រាក់កម្ចីដល់កម្ពុជាទេ ប៉ុន្តែក្រុមប្រឹក្សាប្រតិបត្តិរបស់ IMF បានធានាថានៅឯកិច្ចប្រជុំថ្ងៃទី២៥ខែកក្កដា ឆ្នាំ២០០៧ លើមាត្រា៤ថា IMF ត្រៀមរួចជាស្រេចហើយក្នុងការផ្តល់ការគាំទ្រខាងផ្នែកហិរញ្ញវត្ថុដល់កម្ពុជា នៅពេលបំណុលជាមួយអាមេរិក និងរុស្ស៊ីបានត្រូវដោះស្រាយរួច។ ប៉ុន្តែនៅក្នុងអន្តរកាល IMF និងបន្តកម្មវិធីមានត្រា ៤ បួកជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីជួយពង្រឹងលើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក្នុងគោលដៅធានាកំណើនសេដ្ឋកិច្ចខ្ពស់ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ។ ហិរញ្ញប្បទានបច្ចេកទេសរបស់ IMF នៅតែបន្ត ដែលជាសំខាន់ផ្តោតទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលពន្ធ វិស័យហិរញ្ញវត្ថុ និងផ្នែកស្ថិតិជាតិ។ *រស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ ទី០២ ខែសីហា ឆ្នាំ២០០៧ ទំព័រក៤។*

## មន្ត្រី WTO សន្យាជួយពង្រីកទីផ្សារសំរាប់ទំនិញកម្ពុជា

លោក សុក ស៊ីផាន់ណា អតីតរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដែលបានសុំលាលែងពីតំណែងកាលពីឆ្នាំ២០០៤ បានជួបពិភាក្សាការងារក្នុងនាមមន្ត្រី WTO ជាមួយលោក គាត ឈន់ កាលពីថ្ងៃទី១២ខែកក្កដាឆ្នាំ២០០៧។

លោក សុក ស៊ីផាន់ណា បច្ចុប្បន្នជាប្រធានមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិរបស់អង្គការ WTO បានពិភាក្សាជាមួយលោក គាត ឈន់ អំពីស្តង់ដារទំនិញរបស់ប្រទេសកម្ពុជាដើម្បីបង្កើនការនាំចេញ ជាពិសេសវាយនភណ្ឌនិងកសិកម្ម។

លោក សុក ស៊ីផាន់ណា សន្យាជួយរកច្រកព័ត៌មានទាំងឡាយដែលរដ្ឋាភិបាលកម្ពុជាត្រូវការដើម្បីពង្រីកទីផ្សារ។

លោក គាត ឈន់ ក៏បានលើកឡើងផងដែរថា រដ្ឋាភិបាលកំពុងតែអនុវត្តកាតព្វកិច្ចដែលបានសន្យាជាមួយ WTO ក៏ដូចជាការកសាងនិងពង្រឹងច្បាប់ផ្សេងៗ។

ទន្ទឹមនេះដែររដ្ឋាភិបាលបានខិតខំបង្កើតនយោបាយលើកទឹកចិត្តដល់វិស័យ ឯកជនដើម្បីអោយសហគ្រាសធុនតូច និងមធ្យមមានភាពរឹងមាំជាពិសេសលើកទឹកចិត្តសហគ្រាសកសិកម្ម។

*រស្មីកម្ពុជា ថ្ងៃសៅរ៍ ទី១៤ ខែកក្កដា ឆ្នាំ២០០៧ ទំព័រក២។*

## អង្គការសុខភាពពិភពលោក WHO ផ្តល់ថវិកា ៥០ ម៉ឺនដុល្លារសំរាប់ប្រយុទ្ធប្រឆាំងជំងឺគ្រុនឈាម

ការិយាល័យសំរបសំរួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា បានប្រកាសអោយដឹងនៅល្ងាចថ្ងៃព្រហស្បតិ៍ ទី២៣ ខែសីហា ឆ្នាំ២០០៧ នេះថា ខ្លួននឹងផ្តល់ថវិកាប្រមាណ៥០ម៉ឺនដុល្លារដល់ប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ការរីករាលដាលជំងឺគ្រុនឈាមនៅទូទាំងប្រទេសកម្ពុជា។

ប្រភពខាងលើបានអោយដឹងថា ជំនួយជាទឹកប្រាក់ខាងលើ បានមកពីការបរិច្ចាគរបស់រដ្ឋាភិបាលអ៊ីតាលីតាមរយៈការិយាល័យសំរបសំរួលកិច្ចការមនុស្សធម៌ (OCHA) ទៅអោយអង្គការសុខភាពពិភពលោកប្រចាំនៅប្រទេសកម្ពុជា។ ថវិកាទាំងនោះនឹងត្រូវប្រើប្រាស់ដើម្បីទិញឧបករណ៍បញ្ចូលឈាម និងសំភារៈពេទ្យសំខាន់ៗមួយចំនួនទៀត។

*រស្មីកម្ពុជា ថ្ងៃសុក្រ ទី២៤ ខែសីហា ឆ្នាំ២០០៧ ទំព័រក៤។*

## មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍វិស័យកសិកម្មជួយជិត១០លានដុល្លារសំរាប់អ្នកក្រីក្រក្នុងខេត្ត៣

ក្រសួងសេដ្ឋកិច្ចបានអោយដឹងថា មូលនិធិនេះអន្តរជាតិនេះមានទីតាំងនៅទីក្រុងរ៉ូមប្រទេសអ៊ីតាលី សំរេចផ្តល់ប្រាក់ជំនួយឥតសំណងចំនួន៩.៥២លានដុល្លារអាមេរិក ដល់ប្រទេសកម្ពុជា សំរាប់គំរោងជួយលើកស្ទួយជីវភាពអ្នកស្រុកជនបទក្នុងខេត្ត៣ ក្រចេះ ព្រះវិហារ រតនគីរី។ នេះជាគំរោងហិរញ្ញប្បទានលើកទី៥ ហើយរបស់មូលនិធិនេះសំរាប់ប្រទេសកម្ពុជា ប៉ុន្តែនេះគឺជាលើកទី១ ដែលមូលនិធិនេះផ្តល់អោយកម្ពុជាដោយឥតសំណង។

កិច្ចព្រមព្រៀងទទួលប្រាក់ជំនួយត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២៨ខែឧសភា ដោយ លោក គាត ឈន់ និង លោក Lennat Bage ប្រធានមូលនិធិនេះ។

មូលនិធិនេះធ្លាប់បានផ្តល់ជំនួយមកដល់ប្រទេសកម្ពុជាមានទឹកប្រាក់សរុបចំនួន៣៨.៨៤លានដុល្លារ សំរាប់គំរោង ៤ រួមមានគំរោងបង្កើនផលិតកសិកម្ម គំរោងកសិកម្ម គំរោងគាំទ្រកម្មវិធីសិលា គំរោងអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាននៅកំពង់ធំ និងគំរោងកាត់បន្ថយភាពក្រីក្រនៅព្រៃវែង និងស្វាយរៀង។

ចំនែកទឹកប្រាក់សំរាប់គំរោងលើកនេះ ត្រូវយកត្រូវជួយប្រជាជននៅខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តរតនៈគីរី ហើយទឹកសរុបសំរាប់គំរោងនេះមានរហូតដល់១១.៥២លានដុល្លារ។ តែឥឡូវបានពីមូលនិធិនេះ៩.២៩លានដុល្លារ និងបានពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិចំនួន១.២៩លានដុល្លារ ហើយរដ្ឋាភិបាលកម្ពុជាគ្រោងចូលរួមបដិភាគចំនួន ០.៧០ លានដុល្លារដែរ។ *រស្មីកម្ពុជា ថ្ងៃពុធទី៣០ ខែឧសភាឆ្នាំ២០០៧ ទំព័រក៤។*

## OFID ផ្តល់ជំនួយ១៣លានដុល្លារសំរាប់ផ្លូវដែក

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិយាយថា មូលនិធិសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ OFID បានផ្តល់ឥណទានសម្បទានមានទឹកប្រាក់ចំនួន ១៣ លានដុល្លារអាមេរិកដល់រដ្ឋាភិបាលកម្ពុជាសំរាប់គំរោងការស្តារប្រព័ន្ធផ្លូវដែកនៅប្រទេសកម្ពុជា។

លោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក NasserLootah ប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិ OPEC សំរាប់ការអភិវឌ្ឍន៍អន្តរជាតិបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើឥណទានកាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ នៅទីក្រុងវីយែន ប្រទេសអូទ្រីស អំឡុងពេលទស្សនកិច្ចរបស់លោកទៅកាន់ទីនោះ។

គំរោងស្តារផ្លូវដែក ត្រូវចំណាយថវិកាសរុប ៧៣ លានដុល្លារអាមេរិកឯណោះ ដែលក្នុងនោះកន្លងមក ADB បានផ្តល់ឥណទានសម្បទានចំនួន៤២លានដុល្លាររួចហើយ រដ្ឋាភិបាលម៉ាឡេស៊ីសន្យាផ្តល់ជំនួយជាដែករ៉ែតំលៃ២.៨លាន

ដុល្លារអាមេរិក រដ្ឋាភិបាលកម្ពុជាបានគ្រោងប្រាក់ចំនួន១៥.២លានដុល្លារ និងឥឡូវមូលនិធិសំរាប់ការអភិវឌ្ឍន៍ (OFID) របស់អង្គការ OPEC បានផ្តល់ឥណទានចំនួន១៣លានដុល្លារទៀត។

*រស្មីកម្ពុជា ថ្ងៃពុធ ទី១២ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រក៨។*